# ✍ ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ✍

## “ ដែលជាឯតទគ្គៈផ្នែកខាងឱ្យឱវាទដល់ពួកភិក្ខុនី ”

*ព្រះនន្ទកត្ថេរ លោកជាមហាសាវកមួយរូប ដែលមានតំណែងជាឯតទគ្គៈ ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ថែមទាំងមានការសម្តែងធម៌ធ្វើចិត្តបរិស័ទទាំង ៤ ជំពូកឲ្យកើតសេចក្តីជ្រះថ្លា និងមានភាពអង់អាចដ៏ខ្ពង់ខ្ពស់ក្នុងព្រះសាសនានេះ ព្រោះលោកជាព្រះអរហន្ត ដែលមានជំនាញក្នុងការរឭកជាតិបានផងដែរ ។*

*ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ មានសម្តែងនៅក្នុងអដ្ឋកថា គម្ពីរមនោរថបូរណី ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី ក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាត មានសេចក្តីថា ៖*

*ព្រះនន្ទកៈកើតនៅក្នុងត្រកូលព្រាហ្មណ៍ ដែលស្ថិតនៅក្នុងក្រុងសាវត្ថី ពេលចម្រើនវ័យធំឡើង លោកបានទៅស្តាប់ធម៌ទេសនាក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏កើតមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទា ។*

*កាលបានបព្វជ្ជាឧបសម្បទាជាភិក្ខុ ក្នុងសាសនព្រហ្មចរិយធម៌នេះហើយ តាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចនូវព្រះអរហត្តផល ( ផលគឺភាពជាអ្នកឆ្ងាយចាកសត្រូវគឺកិលេស ឬជា*

អ្នកមិនមានកិលេស ) ថែមទាំងបានជាព្រះអសេក្ខបុគ្គល ( គឺបុគ្គលមិនមានការសិក្សាជាបន្តទៅទៀត ) ។

ព្រះនន្ទកៈ លោកមានភាពជំនាញក្នុងបុព្វេនិវាសានុស្សតិញ្ញាណ គឺអាចរឭកដឹងដល់ការកើតក្នុងអតីតជាតិរបស់លោក និងសត្វដទៃទៀតបាន លោកជាអ្នកឈ្លាសវៃក្នុងការសម្តែងធម៌ ធ្វើឲ្យចិត្តបរិស័ទទាំង ៤ ជំពូក ឲ្យកើតមានសេចក្តីជ្រះថ្លាក្នុងព្រះសាសនានេះ គឺសម្តែងធម៌ពន្យល់នូវហេតុផលឲ្យជាទីពេញចិត្ត និងយល់បានងាយ ទើបលោកបានទទួលនាមថា ព្រះនន្ទកៈ បានដល់ ភាពជាអ្នកមានការសម្តែងធម៌ ធ្វើឲ្យជាទីសប្បាយពេញចិត្តដល់អ្នកស្តាប់ ។

ការសម្តែងធម៌របស់ព្រះនន្ទកត្ថេរ ដែលរាប់ថាគួរឲ្យអស្ចារ្យនោះបានដល់ ការសម្តែងធម៌ដល់ពួកភិក្ខុនីចំនួន ៥០០ រូប ឲ្យបានសម្រេចជាព្រះអរហន្តទាំងអស់អង្គ ។

ដូចមានរឿងប្រាកដដូច្នេះថា ពួកសក្យកុមារ ៥០០ នាក់ បានចូលមកបួសក្នុងព្រះសាសនាហើយ កើតការមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ឡើយ ។

ព្រះភគវាជាម្ចាស់ ទើបទ្រង់នាំភិក្ខុទាំងនោះទៅកាន់ស្រះកុណាលដែលជាស្រះធំ តាំងនៅក្នុងព្រៃហិមពាន្ត ហើយទ្រង់សម្តែងកុណាល-ជាតក គឺជាតកដែលសម្តែងដល់សត្វតាវៅ និងទ្រង់ជ្រាបថា ភិក្ខុទាំង

៥០០ រូប កើតមានការរន្ធត់ចិត្ត ទើបទ្រង់សម្តែងចតុរារិយសច្ច គឺការពិតដ៏ប្រសើរ ៤ ប្រការ អនុគ្រោះឲ្យភិក្ខុទាំង ៥០០ រូបនោះ បានតាំងនៅក្នុងសោតាបត្តិផល លុះកាលជាខាងក្រោយមក ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងមហាសមយសូត្រអនុគ្រោះភិក្ខុទាំងនោះ ឲ្យបានសម្រេចជាព្រះអរហន្តដែលជាទីបំផុត នៃការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងព្រះសាសនានេះ ។

ចំណែកកិរិយាចាស់របស់ភិក្ខុទាំងនោះ លុះបានជ្រាបថា ស្វាមីរបស់ខ្លួនបួសហើយ ទើបប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងរស់នៅក្នុងភាពជាយរាវាស បានប្រយោជន៍អ្វី ហើយព្រមព្រៀងគ្នាទៅរកព្រះនាងមហាបជាបតិគោតមីថេរី ដើម្បីសូមបព្វជ្ជាឧបសម្បទាជាភិក្ខុនី ព្រះនាងមហាបជាបតិគោតមីក៏ព្រមឲ្យឧបសម្បទា ដោយមានសង្ឃទាំងពីរចំណែក គឺភិក្ខុសង្ឃមួយចំណែក ភិក្ខុនីមួយចំណែក ជាអ្នកឲ្យឧបសម្បទា ។

ដូចមានរឿងសម្តែងទាក់ទងនឹងពួកភិក្ខុនីទាំង ៥០០ រូបនោះថា ក្នុងអតីតកាល ពួកនាងទាំងនោះធ្លាប់បានធ្វើជាអ្នកបម្រើរបស់ព្រះថេរៈ កាលដែលលោកកើតជាព្រះរាជា ដែលមានរឿងប្រាកដនៅក្នុងអដ្ឋកថាបបញ្ច-សូទនី ដែលអធិប្បាយសេចក្តីព្រះបាលីនៃគម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ក្នុងនន្ទកោវាទសូត្រ ដូចមានសេចក្តីថា ៖

ក្នុងអតីតជាតិ លោកកើតនៅក្រុងពារាណសី មានពួកទាសានិងទាសីមួយចំណែកៗ ៥០០ នាក់ដូចគ្នា បានរួមការងារស្នាក់អាស្រ័យ

នៅជាមួយគ្នា ។ ចំណែកព្រះនទ្ទកត្ថេរនោះ បានជាអ្នកគ្រប់គ្រងផ្នែកខាងទាសា ក្នុងកាលនោះ ព្រះនាងមហាបជាបតិគោតមីថេរី បានជាអ្នកគ្រប់គ្រងផ្នែកខាងទាសី ព្រោះនាងជាភរិយារបស់ទាសាដែលជាធំ ប៉ុន្តែអ្នកទាំងពីរនាក់នោះ ជាអ្នកមានបញ្ញាឈ្លាសវៃក្នុងការគ្រប់គ្រងពួកទាសាទាសីទាំង ១០០០ នាក់នោះ ដូចមានការធ្វើបុណ្យរួមគ្នា ប្រាថ្នាឲ្យកើតជាតិណាជួបគ្នា ដូច្នេះ ជាដើម ។

នៅក្នុងថ្ងៃមួយ ដែលជារដូវចូលព្រះវស្សា មានព្រះបច្ចេកពុទ្ធ ៥០០ អង្គ បាននិមន្តមកអំពីភ្នំនន្ទមូលៈ មកគង់នៅក្នុងព្រៃឥសិបតនមិគ-ទាយវ័ន នៅក្នុងក្រុងពារាណសី ហើយបានពោលនឹងគ្នាថា ពួកយើងទាំងឡាយនឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង ហើយនឹងសូមការជួយពីអ្នកស្រុក ដើម្បីឲ្យធ្វើទីអាស្រ័យ សម្រាប់ចាំវស្សាត្រង់ព្រៃឥសិបតនមិគ-ទាយវ័ននេះ ។

ដល់ពេលល្ងាច ព្រះបច្ចេកពុទ្ធជាម្ចាស់បាននាំគ្នា និមន្តចូលទៅកាន់ក្រុងពារាណសី បានចូលទៅឈរនៅទៀបមាត់ទ្វារផ្ទះរបស់សេដ្ឋីម្នាក់ ។ ក្នុងពេលនោះ ជាពេលដែលទាសីជាធំ បានចុះទៅកាន់កំពង់ទឹកដើម្បីដងទឹក ចៃដន្យល្អណាស់ បានជួបព្រះបច្ចេកពុទ្ធកំពុងនិមន្តចូលទៅកាន់ក្រុងពារាណសី ។

ចំណែកសេដ្ឋីម្ចាស់ស្រុកនោះ បានជ្រាបនូវបំណងព្រះបច្ចេកពុទ្ធ

ទាំងនោះហើយ ទើបប្រាប់ដល់ព្រះបច្ចេកពុទ្ធទាំងនោះថា ខ្ញុំព្រះករុណាមិនមានពេល សូមលោកម្ចាស់ទាំងឡាយនិមន្តត្រឡប់ទៅវិញចុះ ។

ព្រះបច្ចេកពុទ្ធជាម្ចាស់ កាលបើបានស្តាប់ពាក្យបដិសេធ របស់សេដ្ឋីហើយ បាននាំគ្នានិមន្តត្រឡប់ទៅវិញ ក្នុងពេលដែលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តត្រឡប់ចេញអំពីក្រុងពារាណសី ក៏ជាពេលដែលទាសីជាធំកំពុងត្រឡប់មកអំពីដងទឹកវិញដែរ គេបានឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ទើបដាក់ក្អមទឹកចុះ លើកដៃឡើងថ្វាយបង្គំ រួចហើយសួរថា បពិត្រលោកម្ចាស់ទាំងឡាយ លោកនិមន្តចូលទៅកាន់ក្រុងអម្បាញ់មិញនេះ ហេតុអ្វីទើបប្រញាប់និមន្តត្រឡប់ចេញមកវិញម៉្លេះ ។

ព្រះបច្ចេកពុទ្ធជាម្ចាស់ប្រាប់នូវបំណង ឲ្យនាងទាសីជាធំដឹងថា នែ៎នាងដ៏ចម្រើន ពួកអាត្មាបាននិមន្តចូលទៅកាន់ក្រុងនោះ ក៏ដើម្បីនឹងសូមឲ្យមនុស្សទាំងឡាយធ្វើទីអាស្រ័យក្នុងការចាំវស្សាឲ្យ ។ ទាសីជាធំសួរថា លោកម្ចាស់ទាំងឡាយបានទទួលការជួយឬទេ ព្រះបច្ចេកពុទ្ធជាម្ចាស់ឆ្លើយថា ពួកអាត្មាមិនទាន់មានអ្នកជួយទេ ។

បពិត្រលោកម្ចាស់ តើទីអាស្រ័យនោះ អាចធ្វើបានតែចំពោះអ្នកមានស្តុកស្តម្ភទេឬ ឬអ្នកទីទ័លក្រក៏នឹងអាចធ្វើបានដែរលោកម្ចាស់ ព្រះបច្ចេកពុទ្ធឆ្លើយថា នាងដ៏ចម្រើន អ្នកណាៗ ក៏នឹងអាចធ្វើបានដែរ ទាសីជាធំក៏ឆ្លើយថា ប្រសិនបើដូច្នោះ ល្អហើយលោកម្ចាស់ ពួកនាងខ្ញុំទាំង

អស់គ្នា នឹងនាំគ្នាទៅធ្វើក្នុងថ្ងៃស្អែកនេះ សូមលោកម្ចាស់និមន្តមកទទួលកិច្ចាក្នុងផ្ទះរបស់នាងខ្ញុំម្ចាស់ ក្នុងថ្ងៃស្អែកនេះផងណា កាលទាសីជាធំពោលដូច្នេះហើយ បានប្រញាប់រូតរះត្រឡប់ទៅផ្ទះ ហើយបានប្រញាប់ត្រឡប់ចេញមកវិញ ដើម្បីប្រាប់ដល់ពួកទាសីដែលមកដងទឹកទាំងនោះថា នាងទាំងអស់គ្នា ចូរឈប់នៅទីនេះសិន ហើយពោលសួរថា ពួកនាងសុខចិត្តព្រមធ្វើជាទាសីរបស់អ្នកដទៃជានិច្ចយ៉ាងនេះរហូតទៅឬ ឬថាចង់រួចផុតពីភាពជាទាសីរបស់អ្នកដទៃដែរឬទេ ? ទាសីទាំងនោះឆ្លើយថា ពួកខ្ញុំម្ចាស់ចង់រួចផុតចាកភាពជាទាសីរបស់អ្នកដទៃ ក្នុងថ្ងៃនេះតែម្តងឯង ។

ពេលនោះ ទាសីជាធំពោលថា ល្អហើយ យើងក៏បាននិមន្តព្រះបច្ចេកពុទ្ធឲ្យមកទទួលចង្ហាន់បិណ្ឌបាត នៅផ្ទះរបស់ពួកយើងក្នុងថ្ងៃស្អែកនេះដែរ ប៉ុន្តែអ្នកទាំងអស់គ្នា ចូរប្រាប់ឲ្យស្វាមីរបស់ពួកនាងទៅជួយធ្វើទីស្នាក់អាស្រ័យ សម្រាប់ចាំព្រះវស្សាប្រគេនចំពោះលោកម្ចាស់ក្នុងថ្ងៃស្អែកផងណា ។

កាលបើទាសីជាធំ បានបបួលទាសីទាំងនោះយ៉ាងនេះហើយ ក៏ទទួលថា ល្អហើយ ទើបប្រាប់ដល់ស្វាមីរបស់ខ្លួនរៀងៗខ្លួន ក្នុងពេលដែលស្វាមីរបស់ខ្លួនត្រឡប់មកអំពីព្រៃវិញ ។ ក្នុងពេលប្រជុំព្រមព្រៀងគ្នានោះ ទាសីជាធំទើបប្រាប់ថា ព្រឹកស្អែកនេះ អ្នកទាំងឡាយចូរជួយគ្នាទៅធ្វើទីស្នាក់អាស្រ័យថ្វាយព្រះបច្ចេកពុទ្ធ ហើយបបួលណែនាំបុគ្គល

ដែលមិនប្រាថ្នាជួយធ្វើ ឲ្យកើតសេចក្តីត្រេកអរដោយហេតុផល ដែលមានសារៈខ្លឹមសារគួរជឿបាន ។ លុះព្រឹកស្អែកឡើងបានរៀបចំការថ្វាយភិក្ខាដល់ព្រះបច្ចេកពុទ្ធ ហើយថែមទាំងពោលជាមួយនឹងបុត្រទាសាទាំងពួង ឲ្យចេញទៅជួយធ្វើការកិច្ចការនោះដែរ ។

ពួកបុត្ររបស់ទាសាប្រមាណ ៥០០ នាក់បានព្រមព្រៀងគ្នាចេញទៅព្រៃរកឈើមកធ្វើកុដិ និងទីចង្ក្រមជាដើម ឲ្យរួចស្រេចរៀបរយល្អ ហើយ ចាត់ចែងរកគ្រឿងប្រើប្រាស់ មានគ្រែ តាំង ក្អមដាក់ទឹក និងគ្រឿងប្រើសព្វគ្រប់ហើយ ។ បន្ទាប់មក ទើបនិមន្តព្រះបច្ចេកពុទ្ធឲ្យគង់ចាំព្រះវស្សាត្រង់ព្រៃឥសិបតនមិគទាយវ័ននោះ ហើយប្តូរវេនដាក់បាត្រ កាលបើវេនមកដល់នរណា អ្នកនោះក៏ត្រូវចាត់ចែងភិក្ខាដាក់បាត្រ ចំណែកទាសីជាធំនោះបាននាំយកភិក្ខាពីផ្ទះរបស់ខ្លួនទៅថ្វាយផងដែរ ។

លុះមកដល់ពេលចេញវស្សាហើយ ទាសីជាធំនោះបានឲ្យទាសីម្នាក់ៗ ថ្វាយសំពត់ដល់ព្រះបច្ចេកពុទ្ធមួយអង្គៗ មួយផ្ទាំង រួមជាសំពត់ ៥០០ ផ្ទាំង ។ ព្រះបច្ចេកពុទ្ធជាម្ចាស់បានទទួលសំពត់អំពីទាសីទាំងនោះហើយ ពោលសុំលាចេញចាកព្រៃឥសិបតនមិគទាយវ័ន ។ លុះទាសានិងទាសីទាំងអស់ស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតក្នុងស្ថានសួគ៌ ពេលចុតិចាកស្ថានសួគ៌មកវិញ បានជាស្វាមីភរិយានឹងគ្នាទៀត ។

ចំណែកទាសាជាធំបានមកកើតនៅក្នុងរាជត្រកូល ចំពោះនាងទេព

ធីតាទាំង ៥០០ នោះ បានមកកើតនៅក្នុងត្រកូលអ្នកមានស្តុកស្តម្ភ ហើយបានជាករិយានៃបុត្ររបស់ទាសាជាធំៗ លោកបានជាក្សត្រក្នុងជាតិនោះ ។ កាលបើនាងទាំង ៥០០ នាក់នោះស្លាប់កើតៗ ក្នុងមនុស្សទេវតាដូច្នេះ ហើយ លុះមកដល់សាសនាព្រះពុទ្ធជាម្ចាស់នៃយើង ពួកនាងក៏បានមកកើតក្នុងត្រកូលក្សត្រសក្យរាជ ក្នុងកោលិយនគរ និងទេវទហនគរ ។

ចំណែកទាសាជាធំនោះ ដែលធ្លាប់បានកើតជាក្សត្រមកពីមុន ក៏បានមកជាព្រះនន្ទកត្ថេរ ។ ចំណែកទាសីជាធំ បានមកជាព្រះនាងមហាបជាបតិគោតមី ជាអគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ ហើយក្នុងកាលជាទីបំផុតក៏ចូលមកបួសជាភិក្ខុនី ។ ចំណែកទាសាដែលជាស្វាមីពីជាតិមុន បានមកកើតជាព្រះរាជកុមារទាំង ៥០០ អង្គ ហើយថែមទាំងបានចេញបួសក្នុងព្រះសាសនា រួចក៏បានសម្រេចជាព្រះអរហន្តគ្រប់ៗព្រះអង្គ ។ ទាសីដែលជាករិយាទាំងនោះ បានមកកើតជាខត្តិយកញ្ញា ក៏បានចេញបព្វជ្ជាជាភិក្ខុនីតាមស្វាមីផងដែរ នៅក្នុងសម្នាក់របស់ព្រះនាងមហាបជាបតិគោតមីថេរី ។ នេះជារឿងអតីតជាតិរបស់ព្រះនន្ទកត្ថេរ និងភិក្ខុនីទាំង ៥០០ រូបនោះ ។

ចំណែកជីវប្រវត្តិបច្ចុប្បន្នជាតិរបស់លោក ដែលមានប្រាកដនៅក្នុងព្រះបាលីនន្ទកោវាទសូត្រ គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ដូចមានសេចក្តីថា ៖

សម័យថ្ងៃមួយ ព្រះសក្យមុនីជាម្ចាស់ទ្រង់សម្រេលព្រះឥរិយាបថ នៅក្នុងវត្តជេតពនមហាវិហារ ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី សាងថ្វាយ តាំងនៅក្បែរក្រុងសាវត្ថី គ្រានោះ ព្រះនាងមហាបជាបតិ-គោតមីថេរី ព្រមទាំងភិក្ខុនីប្រមាណ ៥០០ រូប ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរដល់ខ្លួន ទើបព្រះនាងមហាបជាបតិគោតមីថេរីទូលថា បពិត្រព្រះភគវាជាម្ចាស់ សូមព្រះអង្គទ្រង់មេត្តាសម្តែងធម៌ឲ្យដល់ភិក្ខុនីទាំងឡាយផង គ្រានោះ ព្រះមុនីបានត្រាស់ប្រាប់ភិក្ខុទាំងឡាយ ឲ្យទៅឲ្យឱវាទដល់ភិក្ខុនីទាំងឡាយ ដោយប្តូរវេនគ្នាទៅ ។ កាលតមក ព្រះថេរៈទាំងឡាយបានសម្តែងធម៌ឲ្យភិក្ខុនីបានស្តាប់ដោយអនេកបរិយាយ គឺប្តូរគ្នាទៅតាមលំដាប់ថេរៈ ។ កាលបើមកដល់វារៈព្រះនន្ទកត្ថេរ លោករឭកមើលក្នុងអតីតជាតិក៏ជ្រាបថា ភិក្ខុនីទាំងនោះធ្លាប់ធ្វើជាអ្នកបម្រើរបស់ខ្លួនរៀងមក ទើបលោកគិតថា ប្រសិនបើព្រះថេរៈអង្គដទៃៗ ដែលលោកបានបុព្វេនិវាសានុស្សតិញ្ញាណ មើលឃើញយើងអង្គុយសម្តែងធម៌នៅក្នុងចំណោមពួកភិក្ខុនី ប្រាកដជាយល់ថា ព្រះនន្ទកត្ថេរនេះ នៅមិនទាន់លះបង់នាងស្រីស្នំរបស់ខ្លួនសោះ រហូតដល់ថ្ងៃនេះ ក៏នៅតែហែហមទៅដោយនាងស្រីស្នំចាស់ៗ ទាំងនោះនៅឡើយ ។

ព្រោះដូច្នោះ កាលដល់វារៈព្រះនន្ទកត្ថេរទៅឲ្យឱវាទដល់ភិក្ខុនី ទើបលោកឲ្យភិក្ខុអង្គដទៃទៅជំនួសវិញ ប៉ុន្តែភិក្ខុនីទាំង ៥០០ រូបនោះ មាន

សេចក្តីត្រូវការទទួលស្តាប់ឱវាទរបស់លោក ប៉ុន្តែក៏ត្រូវខុសក្តីសង្ឃឹម ។ ដោយហេតុនោះ ព្រះភគវាទើបត្រាស់សួរព្រះអានន្ទកត្ថេរថា ម្នាលអានន្ទ វារៈនេះជានាទីរបស់នរណាក្នុងការឲ្យឱវាទភិក្ខុនី ព្រះអានន្ទត្ថេរក្រាបបង្គំទូលតាមសេចក្តីពិតថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងពួងបានដាក់វេនទៅឲ្យឱវាទដល់ពួកភិក្ខុនីមកជាវៀងរហូតហើយ ប៉ុន្តែថ្ងៃនេះជាវេនរបស់ព្រះនន្ទកត្ថេរ តែព្រះនន្ទកៈមិនប្រាថ្នានឹងទៅឲ្យឱវាទភិក្ខុនីទាំងនោះទេ ព្រះអង្គ ព្រះបរមសាស្តាត្រាស់ប្រាប់ព្រះនន្ទកត្ថេរថា ម្នាលនន្ទកៈ អ្នកកុំឲ្យភិក្ខុដទៃទៅជំនួសឡើយ ចូរអ្នកទៅឲ្យឱវាទភិក្ខុនីដោយខ្លួនឯងចុះ ។

ព្រះនន្ទកត្ថេរក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ លុះដល់ពេលដែលត្រូវថ្ងៃលោកឲ្យឱវាទភិក្ខុនី ពេលព្រឹកឡើងលោកនិមន្តទៅបិណ្ឌ-បាតក្រុងសាវត្ថី កាលត្រឡប់ពីបិណ្ឌបាត ពេលក្រោយភត្តកិច្ចស្រេចហើយ ទើបចៀងចូលទៅកាន់ទីវត្តរាជការាម ។ វត្តរាជការាម ជាវត្តដែលព្រះបាទបសេនទិកោសលទ្រង់កសាង ដែលតាំងនៅទិសខាងត្បូងក្រុងវេសាលី ។ ភិក្ខុនីទាំងឡាយ ក្រឡេកឃើញព្រះនន្ទកត្ថេរអំពីចម្ងាយ ក៏ត្រៀមរៀបចំតាំងអាសនៈ និងចាត់ចែងទឹកសម្រាប់លាងជើង លុះព្រះនន្ទ-កត្ថេរមកដល់ ទើបនិមន្តឲ្យគង់លើអាសនៈដែលគេក្រាលថ្វាយ ។

ចំណែកភិក្ខុនីទាំងនោះ នាំគ្នាថ្វាយបង្គំព្រះថេរៈហើយ អង្គុយក្នុងទីដ៏សមគួរ ទើបព្រះនន្ទកត្ថេរពោលជាមួយនឹងភិក្ខុនីទាំងនោះថា ម្នាល

ប្អូនស្រីទាំងឡាយ ប្រសិនបើយើងសួរអ្នកហើយ ដឹងចូរឆ្លើយថាដឹង មិនដឹងចូរឆ្លើយថាមិនដឹង ឬមានសេចក្តីសង្ស័យ ស្ទាក់ស្ទើរ ចូរសួរមកចុះ ភិក្ខុនីទាំងនោះត្រេកអរពេញចិត្តចំពោះព្រះនន្ទកត្ថេរថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អនុញ្ញាតទុកដូច្នេះហើយ ធ្វើឲ្យខ្ញុំព្រះករុណាទាំងឡាយ មានសេចក្តីត្រេកអរពេញចិត្តណាស់ ។

ព្រះនន្ទកត្ថេរចាប់ផ្តើមសួរថា នាងទាំងឡាយយល់ថា ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ ចិត្ត ទៀងឬមិនទៀង ? មិនទៀងទេ លោកម្ចាស់ វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខ លោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នាងទាំងឡាយគួរយល់ឃើញ ថាវត្ថុនោះជារបស់យើង ជាយើង ជាខ្លួនរបស់យើងឬ ? មិនគួរទេលោកម្ចាស់ នុ៎ះព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះកាលពីមុនខ្ញុំម្ចាស់ទាំងឡាយ មិនបានឃើញដោយបញ្ញាតាមសេចក្តីពិតថា សូម្បីដោយហេតុដូចនេះ អាយតនៈខាងក្នុង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ជារបស់មិនទៀង ( ពាក្យថា អាយតនៈ បានដល់គ្រឿងដឹង និងវត្ថុដែលគួរដឹង ឬគ្រឿងជាប់បន្តគ្នាជាមួយនឹងអាយតនៈខាងក្រៅ ) ។

ព្រះថេរៈឆ្លើយថា ត្រូវហើយៗប្អូនស្រីទាំងឡាយ ការយល់យ៉ាងនេះ រមែងមានដល់ព្រះអរិយសាវក អ្នកឃើញដោយបញ្ញាដ៏ប្រពៃតាម

សេចក្ដីពិត គឺយល់យ៉ាងច្បាស់ដោយវិបស្សនាបញ្ញា ( បានដល់ បញ្ញាដែលឃើញច្បាស់លាស់ គឺឃើញថា វត្ថុទាំងពួងដែលមានបច្ច័យប្រជុំតាក់តែងមិនទៀង ជាទុក្ខ មិនមែនតួខ្លួន ) ដោយប្រការដូចនេះ កាលបើព្រះថេរៈបានពោលរ៉ាប់រងដូច្នេះហើយ ក៏នឹងតាំងបញ្ហាសួរភិក្ខុនីទាំងនោះតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងយល់ថា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយ ទៀងឬមិនទៀង ? មិនទៀងទេលោកម្ចាស់ ! វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខលោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា នាងគួរយល់ឃើញថា វត្ថុនោះជារបស់យើង ជាយើង ជាតួខ្លួនរបស់យើងឬ ? មិនគួរទេលោកម្ចាស់ ព្រោះហេតុអ្វី ? ព្រោះថា កាលមុននោះ នាងខ្ញុំម្ចាស់ទាំងឡាយមិនបានឃើញយ៉ាងនេះ ដោយបញ្ញាដ៏ប្រពៃតាមពិតថា សូម្បីដោយហេតុនេះៗ អាយតនៈខាងក្រៅ ៦ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទាំងឡាយនោះរបស់យើងទើបឈ្មោះថាមិនទៀង លោកម្ចាស់ ល្អហើយៗ ម្នាលប្អូនស្រីទាំងឡាយព្រះអរិយសាវករមែងឃើញយ៉ាងនេះ ដោយបញ្ញាតាមសេចក្ដីពិតដូច្នេះឯង ។ កាលបើលោកពោលដូច្នេះហើយ បានសួរភិក្ខុនីទាំងនោះតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងយល់ឃើញថា ចក្ខុវិញ្ញាណ សោត-វិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ

ទៀងឬមិនទៀង ? មិនទៀងទេលោកម្ចាស់ វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ ឬជាសុខ ? ជាទុក្ខ លោកម្ចាស់ វត្ថុណាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នាងគួរយល់ឃើញថា វត្ថុនោះជារបស់យើង ជាយើង ជាខ្លួនរបស់យើងឬ ? មិនគួរទេ លោកម្ចាស់ ព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំម្ចាស់មិនបានឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា សូម្បីដោយហេតុនេះៗ វិញ្ញាណទាំង ៦ នោះរបស់យើង ទើបឈ្មោះថា មិនទៀងតាមពិតទេ លោកម្ចាស់ ។

ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ព្រះអរិយសាវករមែងឃើញដោយវិបស្សនាបញ្ញា គឺឃើញយ៉ាងជាក់ច្បាស់តាមសេចក្តីពិតយ៉ាងនេះឯង ។ កាលបើព្រះនន្ទកត្ថេរពោលដូច្នេះហើយ ទើបពោលជាមួយនឹងភិក្ខុនីទាំងនោះដោយធ្វើសេចក្តីឧបមា និងតាំងជាពាក្យសួរថា ៖

ម្នាលប្អូនស្រីទាំងឡាយ កាលបុគ្គលដុតប្រទីបប្រេង ដែលមានប្រេងក៏ល្អ ប្រឆេះក៏ល្អ អណ្តាតប្រទីបក៏ល្អ ពន្លឺប្រទីបក៏ល្អ សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា អ្នកណានឹងពោលថា ប្រទីបប្រេងបែបនេះ កាលបើត្រូវឆេះ ប្រេងក្តី ប្រឆេះក្តី អណ្តាតប្រទីបក្តី សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា វៀរតែពន្លឺនៃប្រទីបនោះជារបស់ទៀង មានការស្ថិតស្ថេរនៅដដែល មិនប្រែសភាពទៅជាយ៉ាងដទៃ នឹងហៅបុគ្គលនោះថា ជាអ្នកពោលត្រឹមត្រូវឬ ? បពិត្រ

លោកម្ចាស់ អ្នកនោះពោលមិនត្រឹមត្រូវទេ ម្នាលប្អូនស្រីទាំងឡាយ សេចក្តីនេះព្រោះហេតុអ្វី ? ព្រោះហេតុថា ប្រទីបប្រេងដែលឆេះនោះ ប្រេងក្តី ប្រឆេះក្តី អណ្តាតប្រទីបក្តី សុទ្ធតែមិនទៀង មានការប្រែប្រួលជាធម្មតា មិនចាំបាច់ពោលថ្វីដល់ពន្លឺនៃប្រទីបនោះ ក៏ជារបស់មិនទៀង មានការប្រែប្រួលជាធម្មតាដូចគ្នា លោកម្ចាស់ (ពន្លឺនៃប្រទីបមានការអាស្រ័យប្រឆេះ និងប្រេងនោះ ) ។

សេចក្តីឧបមាក៏ដូច្នោះដែរ ប្អូនស្រីទាំងឡាយ គឺអ្នកណាពោលថា អាយតនៈខាងក្នុង ៦ របស់យើង ជារបស់មិនទៀង តែទុក្ខ ឬសុខ ឬមិនទុក្ខមិនសុខ ដែលយើងបានទទួល ព្រោះអាស្រ័យអាយតនៈខាងក្នុងនោះជារបស់ទៀង គឺមានការស្ថិតស្ថេរនៅដដែលមិនប្រែប្រួល ដូច្នេះនឹងហៅអ្នកនោះថា ជាអ្នកពោលត្រឹមត្រូវឬទេ ? មិនត្រឹមត្រូវទេ សេចក្តីនោះព្រោះហេតុអ្វី ? បពិត្រលោកម្ចាស់ ពីព្រោះវេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះៗ ដែលអាស្រ័យបច្ច័យទើបកើតឡើងពីអាយតនៈខាងក្នុងនោះៗ ហើយ ទើបកើតឡើងបាន កាលកើតឡើងហើយក៏រលត់ទៅវិញជាធម្មតា ។ ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ការឃើញដូច្នេះរមែងមានដល់ព្រះអរិយសាវក ដែលលោកឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត ។ លុះព្រះនន្ទកត្ថេរពោលយ៉ាងនេះហើយ ទើបពោលប្រៀបធៀបតទៅទៀតថា ម្នាលប្អូនស្រីទាំងឡាយ ឫស ដើម មែក

ស្លឹក និងស្រមោលនៃដើមឈើធំ ជាដើមឈើមានខ្លឹម សុទ្ធតែជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា នឹងមាននរណាមកពោលថា ឫស ដើម មែក ស្លឹកនៃដើមឈើធំនោះក្តី ជារបស់មិនទៀង មានការប្រែប្រួលទៅជាធម្មតា តែថាស្រមោលនៃដើមនោះជារបស់ទៀង គឺជារបស់ស្ថិតស្ថេរនៅដដែល មិនប្រែប្រួលដូច្នេះ ឬនឹងហៅអ្នកនោះថា ជាអ្នកពោលត្រូវឬទេ ? អ្នកនោះពោលមិនត្រឹមត្រូវទេ លោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ម្នាលប្អូនស្រី ព្រោះហេតុថា ឫស ដើម មែក ស្លឹក រហូតដល់ស្រមោលនៃដើមឈើធំនោះ សុទ្ធតែជារបស់មិនទៀងទាំងអស់ មានការផ្លាស់ប្តូរប្រែប្រួលជាធម្មតា ( កាលបើដើមឈើនោះ មិនទៀង ស្រមោលនៃដើមឈើនោះ នឹងទៀងមកពីណា ) ។

ព្រះនន្ទកត្ថេរពោលថា សេចក្តីនោះក៏ដូច្នោះដែរ ហើយទើបលើកយកអាយតនៈខាងក្រៅមកសាកសួរទៀតថា នែ៎ ប្អូនស្រីទាំងឡាយ អ្នកណានិយាយថា អាយតនៈខាងក្រៅ ៦ របស់យើងជារបស់មិនទៀង ប៉ុន្តែទុក្ខ និងសុខ ឬមិនមែនទុក្ខមិនមែនសុខ ដែលយើងបានទទួលព្រោះអាស្រ័យអាយតនៈខាងក្រៅ ៦ នោះជារបស់ទៀង ជារបស់ស្ថិតស្ថេរតាំងនៅដដែល មាំមួនមិនប្រែប្រួលដូច្នេះ នឹងថាអ្នកនោះនិយាយត្រូវដែរឬទេ ? មិនត្រូវទេលោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ម្នាលប្អូនស្រី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះវេទនាដែលកើតឡើងពីអាយតនៈខាង

ក្រៅ ៦ នោះ អាស្រ័យបច្ច័យដែលកើតពីអាយតនៈខាងក្រៅទាំង ៦ នោះហើយ ទើបកើតឡើងបាន កាលកើតឡើងហើយ ក៏រលត់ទៅវិញជាធម្មតា ។ ត្រូវល្អហើយ ប្អូនស្រីទាំងឡាយ ការឃើញដូច្នេះ រមែងមានដល់ព្រះអរិយសាវក ដែលលោកឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត ដូចបានពោលរួចមកហើយ ។ កាលបើព្រះថេរៈពោលយ៉ាងនេះហើយ ទើបពោលឧបមាដោយន័យដទៃទៀតថា ម្នាលប្អូនស្រីទាំង-ឡាយអ្នកសម្លាប់គោ ឬកូនឈ្នួល អ្នកដែលសម្លាប់គោដ៏ឈ្លាសវៃពន្លះស្បែកខាងក្រៅទុកមួយចំណែក ពន្លះសាច់ទុកមួយចំណែក សរសៃ គ្រឿងចង្រៃតខាងក្នុងទុកមួយចំណែកៗ បន្ទាប់មក លាតចំណែកស្បែកខាងក្រៅនោះគ្របដណ្តប់សាច់គោនោះទុក ហើយគេពោលថា ខ្លួនគោនេះផ្សំដោយស្បែកផ្ទាំងនេះដូចដើមនោះឯង ម្នាលប្អូនស្រីទាំងឡាយ អ្នកសម្លាប់គោ ឬកូនឈ្នួលសម្លាប់គោដែលពោលនោះ ឈ្មោះថា ត្រឹមត្រូវឬទេ ? មិនត្រូវទេលោកម្ចាស់ សេចក្តីនោះព្រោះហេតុអ្វី ប្អូនស្រីទាំងឡាយ ព្រោះហេតុថា អ្នកសម្លាប់គោ ឬកូនឈ្នួលសម្លាប់គោដ៏ឈ្លាសវៃនោះ កាលសម្លាប់គោស្លាប់ហើយ ក៏យកកាំបិតដ៏មុតមកពន្លះសាច់ខាងក្នុងទុកមួយចំណែកស្បែកទុកមួយចំណែក សរសៃគ្រឿងចង្រៃតខាងក្នុង ចេញមកជាចំណែកៗ ហើយយកស្បែកគ្របដណ្តប់គោទុក សូម្បីអ្នកនោះនឹងពោលថា គោនេះនឹងនៅមានស្បែកគ្របដណ្តប់ដូចដើមក៏ដោយ គោនោះ

ក៏បែកគ្នាចាកស្បែកជាផ្ទាំងគ្របដណ្ដប់នោះហើយ លោកម្ចាស់ ។

ម្នាលប្អូនស្រីទាំងឡាយ យើងបានលើកការឧបមានេះមកសម្ដែង ដើម្បីនឹងឲ្យជ្រាបសេចក្ដីនៃពាក្យពន្យល់ ពាក្យថា ដុំសាច់ ខាងក្នុងនោះ បានដល់ អាយតនៈខាងក្នុង ៦ ពាក្យថា ស្បែកខាងក្រៅនោះ បានដល់ អាយតនៈខាងក្រៅ ៦ សាច់ដែលជាប់នឹងស្បែកខាងក្នុង សរសៃខាងក្នុង គ្រឿងចងរឹតខាងក្នុងនោះ បានដល់ រាគៈ និងការបិតដ៏មុតនោះ បានដល់ បញ្ញារបស់ព្រះអរិយបុគ្គល ប្រើកាត់ផ្ដាច់នូវកិលេសខាងក្នុង កាត់ផ្ដាច់ សំយោជនៈ ( កិលេសដែលចងរឹតចិត្តសត្វទុកក្នុងវដ្ដសង្សារ ) ខាងក្នុង និងកាត់ផ្ដាច់គ្រឿងចងរឹតខាងក្នុង ។ លំដាប់តមក ព្រះនន្ទកត្ថេរ ពោល អំពីពោជ្ឈង្គ គឺអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងដល់ភិក្ខុនីទាំងនោះថា ៖

ម្នាលប្អូនស្រីទាំងឡាយ ពោជ្ឈង្គ ៧ ប្រការ ដែលភិក្ខុបានអប់រំ ឲ្យច្រើនហើយ ក៏បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមាន អាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយការដឹងដ៏ក្រៃលែងដោយ ខ្លួនឯង ។ ពោជ្ឈង្គ ៧ ប្រការនោះបានដល់អ្វីខ្លះ **សតិ** គឺការព្រួកបាន ធម្មវិចយៈ គឺការយកចិត្តទុកដាក់នូវធម៌ **វិរិយៈ** គឺការព្យាយាម **បីតិ** គឺការឆ្អែតចិត្ត **បស្សទ្ធិ** គឺការស្ងប់ក្នុងអារម្មណ៍ **សមាធិ** គឺការតាំង ចិត្តមាំ **ឧបេក្ខា** គឺភាពព្រងើយៗ ដែលត្រូវអាស្រ័យវិវេក គឺភាពស្ងប់ ស្ងាត់ ការរលត់ បង្អោនទៅក្នុងការលះបង់ដូច្នេះ ។

កាលព្រះថេរៈ បានសម្តែងពន្យល់ធម៌ដល់ពួកនាងភិក្ខុនីទាំងនោះ ដោយឱវាទដូចបានសម្តែងរួចមកហើយទាំងអស់ លោកទើបប្រាប់ភិក្ខុនីទាំងនោះថា ពួកនាងចូរត្រឡប់ទៅវិញចុះ ព្រោះដល់កាលដ៏សមគួរហើយ ។ ភិក្ខុនីទាំងនោះ បានសម្តែងអាការកោតសរសើរត្រេកអរចំពោះឱវាទ ដែលព្រះនន្ទកត្ថេរបានសម្តែងរួចហើយ ក៏ថ្វាយបង្គំលា រួចក៏ចូលទៅគាល់ព្រះសម្ពុទ្ធជាម្ចាស់ ថ្វាយបង្គំរួចហើយ ទើបឈរក្នុងទីដ៏សមគួរដោយសេចក្តីគោរពកោតក្រែង កាលបានស្តាប់នូវព្រះតម្រាស់ថា នាងទាំងឡាយចូរទៅចុះ ដល់កាលដ៏សមគួរហើយ ភិក្ខុនីទាំងអស់ក៏ថ្វាយបង្គំលាព្រះភគវាត្រឡប់ទៅវិញ ។ ក្រោយភិក្ខុនីទាំងនោះត្រឡប់ទៅវិញមិនយូរប៉ុន្មាន ព្រះលោកនាថជាម្ចាស់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ការងឿងឆ្ងល់ ឬការសង្ស័យរបស់បុថុជ្ជន រមែងមិនមាននៅក្នុងថ្ងៃឧបោសថទី ១៤ ពាក្យថា ខែរនោច ឬខ្នើត ប៉ុន្តែព្រះច័ន្ទក៏នៅតែរនោចយ៉ាងណា ម្នាលភិក្ខុ ភិក្ខុនីទាំងឡាយ សូម្បីនឹងមានសេចក្តីត្រេកអរចំពោះការសម្តែងធម៌របស់ព្រះនន្ទកៈក៏ពិតមែន ប៉ុន្តែនៅមិនទាន់ពេញចិត្តតាមសេចក្តីប្រាថ្នា គឺនៅមិនទាន់បានសម្រេចអរហត្តផលដូច្នោះ ។ កាលបើព្រះអង្គត្រាស់ដូច្នេះហើយ ទើបត្រាស់ប្រាប់ព្រះនន្ទកត្ថេរថា ម្នាលនន្ទកៈ ព្រឹកស្អែកនេះ អ្នកចូរសម្តែងធម៌ដល់ភិក្ខុនីទាំងនោះ ដោយធម្មោវាទនោះទៀត ។ ព្រះនន្ទកត្ថេរក្រាបទូលទទួលព្រះពុទ្ធដីកាថា ព្រះករុណា ព្រះអង្គ

លុះព្រឹកស្អែកឡើង ទើបលោកទៅសម្តែងធម៌ដល់ភិក្ខុនីទាំងនោះ ដូចសម្តែងរួចមកហើយកាលពីម្សិលមិញ លើកយកមកសម្តែងម្តងទៀតតាមព្រះពុទ្ធបំណង ។ ភិក្ខុនីទាំងនោះ បានស្តាប់ធម្មកថារបស់ព្រះនន្ទកៈដែលសម្តែងម្តងទៀត ក៏បានសម្រេចនូវអរហត្តផល ជាព្រះអរហន្តីខីណាស្រពគ្រប់ៗ អង្គ ហើយបានចូលទៅគាល់ព្រះបរមសាស្តា ។

កាលបើភិក្ខុនីទាំងនោះ ចេញអំពីកន្លែងស្តាប់ធម៌ មិនយូរប៉ុន្មានក៏ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ការជឿងឆ្ងល់ ឬការសង្ស័យរបស់មនុស្សភាគច្រើន រមែងមិនមានក្នុងថ្ងៃ ១៥ រោចថា ព្រះច័ន្ទរះខាងរនោច ឬរះខាងខ្នើតក៏ដោយ ប៉ុន្តែព្រះច័ន្ទរះពេញវង់ យ៉ាងណា ភិក្ខុនីទាំងនោះក៏មានការកោតសរសើរ ត្រេកអរចំពោះភាសិតរបស់ព្រះនន្ទកៈដូច្នោះដែរ ។ ប្រសិនបើសរុបពុទ្ធតម្រាស់ដែលត្រាស់សរសើរព្រះនន្ទកត្ថេរ ក្នុងថ្ងៃដែលព្រះភិក្ខុនីទាំងនោះ បានសម្រេចព្រះអរហត្តផល ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបថា ភិក្ខុនីទាំងនោះបានសម្រេចជាព្រះអរហន្តីហើយ ព្រោះបានស្តាប់ព្រះធម៌ទេសនារបស់ព្រះនន្ទកត្ថេរ ទើបត្រាស់ថា ព្រះធម៌ទេសនារបស់ព្រះនន្ទកៈ កាលពីម្សិលមិញនោះ មានដូចគ្នានឹងព្រះច័ន្ទរះក្នុងថ្ងៃ ១៤ កើត ចំណែកព្រះធម៌ក្នុងថ្ងៃនេះ ដូចជាព្រះច័ន្ទរះក្នុងថ្ងៃ ១៥ កើត ហើយព្រះអង្គអាស្រ័យគុណសម្បត្តិនេះឲ្យជាដើមហេតុ ទើបទ្រង់តែងតាំងព្រះនន្ទកត្ថេរ ទុកក្នុង

តំណែងជាឯតទគ្គៈមួយអង្គដែរ ។

ដូចមានសេចក្តីក្នុងព្រះបាលី គម្ពីរអង្គុត្តរនិកាយ ឯកនិបាត មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ នន្ទកៈ ប្រសើរជាងភិក្ខុទាំងឡាយដែលជាសាវ័ករបស់ព្រះតថាគត ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ។ គុណសម្បត្តិដ៏ខ្ពង់ខ្ពស់ដែលព្រះនន្ទកត្ថេរបានទទួលនោះ កើតអំពីការកសាងនូវសេចក្តីល្អគ្រប់យ៉ាងក្នុងជាតិបច្ចុប្បន្ននេះ ដូចពោលមកហើយ ក៏នៅមានសេចក្តីល្អរបស់លោកទៀត ក្នុងអតីតជាតិមួយផ្នែកទៀតផងដែរ ដូចមានរឿងដំណាលទុកក្នុងគម្ពីរអដ្ឋកថា មនោរថបូរណី ពោលដោយការកសាងបុណ្យកុសល បុព្វចរិយារបស់ព្រះនន្ទកត្ថេរ ដូចមានសេចក្តីថា ៖

ក្នុងពុទ្ធសម័យនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ លោកបានកើតជាកុលបុត្រនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ ( ក្នុងគម្ពីរខ្លះថា កើតក្នុងត្រកូលសេដ្ឋី ) ក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ លោកបានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្ពុទ្ធបទុមុត្តរៈ កុលបុត្រនោះបានឃើញព្រះបទុមុត្តរៈជាម្ចាស់ ទ្រង់ប្រកាសតែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុនី ក៏កើតមានសេចក្តីពេញចិត្តក្នុងតំណែងនោះ ទើបធ្វើអធិការកុសល ( មានគម្ពីរមួយថា បានថ្វាយសំពត់តម្លៃមួយសែន ) ចំពោះព្រះបទុមុត្តរៈ ហើយប្រាថ្នាតំណែងនោះ និងបានបូជាដើមពោធិ៍ដែលព្រះអង្គត្រាស់ដឹងដោយប្រទីបទៀតផង ទាំង

ធ្វើកុសលវត្តហូតអស់ជីវិត ។ ពេលដែលកុលបុត្រនោះអស់ជីវិតទៅហើយ ក៏បានទៅកើតក្នុងស្ថានសួគ៌ កាលបើចុតិចាកស្ថានសួគ៌មកវិញ ក៏បានមកកើតជាមនុស្ស វិលកើតវិលស្លាប់ដូច្នេះ អស់កាលដ៏យូរប្រមាណមួយសែនកប្ប ទើបបានមកកើតជានន្ទកៈ នៅក្នុងត្រកូលអ្នកមានធនធានក្នុងក្រុងសាវត្ថី ដែលជាជាតិចុងក្រោយបំផុតរបស់លោក ។

ចំណែកអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយសេចក្ដីបាលី គម្ពីរខុទ្ទកនិកាយ នន្ទកថេរគាថា បានពោលដល់ការកសាងបុញ្ញកុសលដែលឲ្យកើតជាបារមីរបស់ព្រះនន្ទកត្ថេរថា ៖

ព្រះនន្ទកត្ថេររូបនេះ ធ្លាប់ធ្វើអធិការកុសលទុកក្នុងសម្នាក់នៃព្រះពុទ្ធជាម្ចាស់ទាំងឡាយក្នុងកាលមុនតរៀងមក ។ ជាតិមួយ លោកបានកើតជានាយព្រាន នៅបច្ចន្តប្រទេសដែលស្របគ្នានឹងពុទ្ធកាលរបស់ព្រះសិទ្ធិសម្ពុទ្ធជាម្ចាស់ ។ នៅថ្ងៃមួយ ខណៈដែលគេត្រាច់ទៅក្នុងពនាលី ( ជាយព្រៃ ឬជួរព្រៃ ) បានទៅជួបទីចង្ក្រមនៃព្រះសម្ពុទ្ធសិទ្ធិ ក៏កើតមានសេចក្ដីជ្រះថ្លា ទើបទៅស្វែងរកដីខ្សាច់មករោយរាយពាសពេញក្នុងទីចង្ក្រមនោះ លុះគេស្លាប់ទៅ បានត្រាច់រង្គាត់ទៅក្នុងមនុស្ស និងទេវតាដោយបុញ្ញកម្មនោះ ។ លុះមកដល់កាលនៃព្រះពុទ្ធជាម្ចាស់នៃយើង លោកបានមកកើតក្នុងត្រកូលគហបតី នៅក្នុងក្រុងចម្បា មានឈ្មោះថា នន្ទកៈ មានបងប្រុសម្នាក់ឈ្មោះ ភារតៈ ។ ដើមហេតុដែលបងប្អូនទាំងពីរនោះចេញ

បួស ព្រោះជ្រាបដំណឹងថា ព្រះសោណកោឡិវិសត្ថេរបួសជាភិក្ខុរួចហើយ ទើបប្រឹក្សាគ្នាថា សោណកោឡិវិសៈ ជាអ្នកមានសុខុមាលជាតិនៅតែអាចបួសបាន រឿងអ្វីយើងបួសមិនបាន ប្រឹក្សាគ្នាដូច្នេះហើយ ក៏នាំគ្នាចេញបួស ។ ព្រះភារតៈជាបងប្រុស បានសម្រេចជាព្រះអរហន្តព្រមដោយអភិញ្ញា ៦ មុន ទើបប្រៀនប្រដៅព្រះនន្ទកត្ថេរ ឲ្យបានសម្រេចជាព្រះអរហន្តក្នុងកាលជាខាងក្រោយ ។

កាលបើព្រះនន្ទកត្ថេរ ពោលអះអាងភាពជាព្រះអរហន្តរបស់ខ្លួន ទើបលោកពោលគាថា ២ គាថា តាមដែលមានសេចក្តីប្រាកដនៅក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា មានសេចក្តីថា ៖

សេះអាជានេយ្យដ៏ចម្រើន ភ្លាត់ភ្លាំងហើយ រមែងឈរស៊ប់ឡើងវិញ ទោះបីបាននូវសេចក្តីតក់ស្លុត ក៏ជាសត្វមានចិត្តមិនរួញរា រមែងនាំនូវធុរៈទៅបាន យ៉ាងណាមិញ អ្នកទាំងឡាយសូមជ្រាបនូវខ្ញុំ ថាជាអាជានេយ្យ បរិបូណ៌ដោយទស្សនៈ ជាសាវករបស់ព្រះសម្ពុទ្ធ ជាបុត្រជាឱរសរបស់ព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។

សេចក្តីក្នុងគម្ពីរដែលពោលរួចមកហើយនេះ មានរឿងផ្សេងគ្នាដែលទាក់ទងនឹងត្រកូល និងក្រុងដែលកើតព្រម ទាំងដើមហេតុនៃការចេញបួសផងដែរ ។ ដូចមានរឿងពោលនៅក្នុងគម្ពីរខុទ្ទកនិកាយ អបទានដូច្នេះថា កាលព្រះនន្ទកត្ថេរ ជាព្រះអរហន្តហើយ លោកបានប្រកាស

បុព្វចរិយាបារមីរបស់លោកទុកថា ខ្ញុំព្រះករុណាម្ចាស់ឈ្មោះនន្ទក: ធ្លាប់បានកើតជានាយព្រានក្នុងកាលមុន កាលបើដើរត្រាច់ទៅស្វែងរកម្រឹគនៅក្នុងព្រៃ បានទៅជួបព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ ព្រះអង្គស្តេចចូលទៅប្រថាប់នៅក្នុងព្រៃ ដើម្បីទ្រង់ត្រូវការវិវេក ខ្ញុំម្ចាស់បានរៀបចំការតាំងមូលដ្ឋាន ៤ មូលដ្ឋាន ធ្វើបារាំប្រក់ដោយផ្កាឈូក ថ្វាយដល់ព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ លុះធ្វើបារាំរួចហើយ ក៏បោះបោលធ្នូក្នុងទីនោះ ហើយក៏បព្វជ្ជាជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។ ក្រោយពីបានបព្វជ្ជារួចហើយមិនយូរប៉ុន្មាន ក៏មានរោគាពាធកើតឡើងដល់ខ្ញុំម្ចាស់ ប៉ុន្តែរឭកចាំនូវបុណ្យកុសលដែលខ្លួនបានធ្វើហើយ នោះដរាបដល់ថ្ងៃស្លាប់ ទើបបានទៅកើតនៅក្នុងស្ថានតុសិតទេវលោក និងពេលដែលខ្ញុំម្ចាស់កើតនៅក្នុងស្ថានតុសិតទេវលោកនោះ មានរថទិព្វទឹមដោយសេះមួយពាន់ ជាពាហនៈរបស់ខ្ញុំ ពេលណាដែលខ្ញុំត្រូវការទៅទីណា ក៏ឡើងជិះរថនោះទៅតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ក៏មានមណ្ឌបលាតសន្ធឹង បាំងដល់ខ្ញុំរហូតដល់មួយរយយោជន៍ សូម្បីពេលដេកក៏ដេក នៅលើកន្ទែលដែលសម្រេចដោយផ្កាមានទាំងផ្កាឈូកជំធ្លាក់ចុះមកបូជា ខ្ញុំផងដែរអស់កាលជានិច្ច ។

ចំណែកក្នុងបច្ចុប្បន្នជាតិនេះ ខ្ញុំម្ចាស់មិនធ្លាប់ត្រូវកម្តៅថ្ងៃក្តៅដូចភ្លើងឡើយ មូលហេតុនេះមានដោយអំណាចអានិសង្សដែលខ្ញុំម្ចាស់បានធ្វើបារាំថ្វាយដល់ព្រះអនុរុទ្ធសម្ពុទ្ធជាម្ចាស់ និងមិនមែនមានផលល្អប្រាកដ

ត្រឹមតែប៉ុណ្ណោះទេ ទាំងអាចបិទទ្វារទុគ្គតិអបាយភូមិបានផងដែរ ការក្តៅក្រហាយរមែងមិនមានដល់ខ្ញុំម្ចាស់ ពេលដែលនៅក្នុងទីណាក៏ដោយ ។ ខ្ញុំម្ចាស់អធិដ្ឋានសមុទ្រឲ្យជាផែនដីក៏បាន អធិដ្ឋានផ្ទៃមេឃឲ្យជាផ្លូវដើរទៅមកក៏បាន ខ្ញុំម្ចាស់មានទិព្វចក្ខុ ដឹងនូវបុព្វេនិវាសានុស្សតិ ( ទីនៅជាតិមុន ) បានដោយល្អ ទាំងបានជាពុទ្ធបុត្រអ្នកទទួលធម្មតិក ជាអ្នកទ្រទ្រង់ធម៌ព្រមទាំងបានបដិបត្តិព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គទ្រង់ជាលោកនាយកទៀតផង ។ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងធម៌ដ៏គម្ភីរភាព គឺភាពដ៏ជ្រាលជ្រៅឲ្យខ្ញុំម្ចាស់ស្តាប់រហូតដល់ខ្ញុំបានសម្រេចធម៌ ដែលធ្វើឲ្យអស់អាសវក្កិលេស ខ្ញុំម្ចាស់មិនមានការកើតតទៅទៀត បានទម្លាយជាតិកំណើតចេញអស់ហើយ ដោយការផ្តាច់ផ្តិលគ្រឿងចងឲ្យដាច់អស់ ដូចដំរីដែលរើខ្លួនចាកកក់បានហើយ ។ កាលដែលខ្ញុំម្ចាស់ចូលមកក្នុងព្រះសាសនានេះ ជាវត្ថុដ៏ប្រសើរក្រៃលែង ពីព្រោះខ្ញុំម្ចាស់បានសម្រេចវិជ្ជា ៣ បានធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ហើយ ។

កាលព្រះនន្ទកត្ថេរ លោកទ្រទ្រង់អាយុសង្ខារមកដល់កាលសមគួរហើយ ក៏រំលត់ខន្ធបរិនិព្វានទៅហោង ។

( ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងអ្នករក្សាទ្វារក្នុងឥន្ទ្រីយ៍ទាំងឡាយ "

ព្រះនន្ទត្ថេរ ជាមហាថេរៈ លោកទ្រទ្រង់គុណធម៌ពិសេស ផ្នែកខាងសង្រួមឥន្ទ្រីយ៍ ៦ ជាអ្នកទទួលនូវតំណែងដ៏ខ្ពង់ខ្ពស់ នៅក្នុងចំណោមអសីតិមហាសាវ័កមួយរូបផងដែរ ប៉ុន្តែការចេញបព្វជ្ជាឧបសម្បទារបស់លោក ប្លែកពីព្រះអរហន្តសាវ័កអង្គដទៃ ព្រោះអាស្រ័យការគោរព និងកោតក្រែងចំពោះព្រះពុទ្ធជាម្ចាស់ ទើបបួស ប៉ុន្តែការបួសនេះ មិនមែនពេញចិត្តទេ គឺបួសទាំងការបង្ខំចិត្តតែប៉ុណ្ណោះ ។

ជីវប្រវត្តិរបស់លោក មានសម្តែងប្រាកដនៅក្នុងគម្ពីរ អដ្ឋកថាមនោរថបូរណី មានសេចក្តីថា ៖

ព្រះនន្ទត្ថេរកើតក្នុងត្រកូលសក្យៈ ក្នុងរាជវង្ស គោតមវង្ស ជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ ជាមួយនឹងព្រះនាងមហាបជាបតិគោតមី ទ្រង់គ្រប់គ្រងរាជសម្បត្តិនៅក្នុងនគរកបិលពស្តុ ប្រសិនបើរាប់តាមលំដាប់នៃព្រះញាតិវង្សជាមួយនឹងព្រះភគវា លោកក៏ជាព្រះអនុជរបស់ព្រះសម្ពុទ្ធផងដែរ រួមព្រះបិតាជាមួយគ្នា ប៉ុន្តែព្រះមាតាផ្សេងគ្នា ។ កាលលោកកើតមកមានឈ្មោះថា នន្ទៈ នោះ មានរឿងតំណាលថា ពេលលោកនៅក្នុងព្រះគភ៌របស់ព្រះមាតា ធ្វើឲ្យព្រះញាតិវង្សទាំងឡាយ

មានសេចក្តីត្រេកអររីករាយ ក្រោយពីលោកប្រសូតហើយ ក្នុងថ្ងៃដែលនឹងកំណត់ព្រះនាមឲ្យ ព្រះរាជកុមារនោះ ក៏ធ្វើឲ្យពពួកញាតិវង្ស កើតសេចក្តីត្រេកអររីករាយ បាមោជ្ជៈម្តងទៀត ។

សមណព្រាហ្មណាចារ្យ និងហោរាព្រឹទ្ធាមាត្យទាំងឡាយ ទើបកាន់យកនិមិត្តទាំងនោះ ថ្វាយព្រះនាមឲ្យថា នន្ទរាជកុមារ សំដៅរាជកុមារដែលធ្វើឲ្យពពួកញាតិវង្ស កើតសេចក្តីត្រេកអររីករាយ មូលហេតុដែលនន្ទរាជកុមារចេញបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនានោះ មានរឿងតំណាលក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃយមកវគ្គ ក្នុងរឿងព្រះនន្ទត្ថេរថា ៖

កាលព្រះបរមសាស្តា ទ្រង់ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធហើយ ស្តេចចារិកទៅដើម្បីសម្តែងធម៌ប្រោសពុទ្ធវេនេយ្យសត្វ ( បុគ្គលដែលព្រះពុទ្ធជាម្ចាស់គួរណែនាំប្រៀនប្រដៅបាន ) ទៅដោយលំដាប់ ដរាបដល់ក្រុងរាជគ្រឹះ ព្រះបាទសុទ្ធោទនមហារាជព្រះពុទ្ធបិតា ប្រើកាឡុទាយីអាមាត្យ ដែលជាអាមាត្យចុងក្រោយក្នុងការទៅអារាធនាព្រះមហាមុនី ឲ្យព្រះអង្គស្តេចយាងមកកាន់ក្រុងកបិលពស្តុ ។ ព្រះលោកនាថ ព្រមដោយភិក្ខុសង្ឃ ២០.០០០ រូប ជាយសបរិវារ ស្តេចចេញចាកក្រុងរាជគ្រឹះ ទ្រង់ចារិកមកតាមផ្លូវមួយថ្ងៃៗ ១ យោជន៍ ទ្រង់ប្រើពេលព្រះពុទ្ធដំណើរអស់ ៦០ ថ្ងៃ ទើបស្តេចដល់ក្រុងកបិលពស្តុ ហើយធ្វើឲ្យភ្លៀងបោក្ខរព័ស៌ គឺភ្លៀងដូចទឹកដែលធ្លាក់ចុះក្នុងស្លឹកឈូក និងមានពណ៌ដូចជើងព្រាប ភ្លៀង

បែបនេះនរណាៗ ប្រាថ្នាឲ្យទទឹក ទើបទទឹក ប្រសិនបើមិនប្រាថ្នាឲ្យទទឹក ក៏មិនទទឹកឡើយ ហើយទ្រង់សម្តែងមហាវេស្សន្តរជាតកប្រោសដល់ពពួកញាតិ ។ លុះព្រឹកឡើងព្រះជិនស្រី ស្តេចចូលទៅបិណ្ឌបាតតាមលំដាប់ផ្ទះ គ្រានោះ ព្រះបាទសុទ្ធោទនៈឃើញ ក៏ទៅអារាធនាព្រះសម្ពុទ្ធឲ្យមកទទួលចង្ហាន់នៅក្នុងរាជនិវេសន៍ ព្រមដោយភិក្ខុសង្ឃរួចហើយ ទ្រង់សម្តែងធម៌ប្រោស ព្រះបាទសុទ្ធោទនមហារាជ ឲ្យបានសម្រេចសោតាបត្តិផល ហើយក៏អារាធនាព្រះភគវា ព្រមដោយភិក្ខុសង្ឃទទួលចង្ហាន់នៅក្នុងថ្ងៃទី ២ ទៀត ស្តេចទៅទទួលភត្តាហារនៅក្នុងរាជវាំង ទ្រង់ធ្វើភត្តកិច្ចរួចហើយ ទ្រង់សម្តែងធម៌ទេសនាប្រោស ព្រះនាងមហាបជាបតិគោតមី ឲ្យបានសម្រេចសោតាបត្តិផល និងព្រះពុទ្ធបិតា ឲ្យបានសម្រេចសកទាគាមិផល ។ ដល់ថ្ងៃទី ៣ ព្រះវិជិតមារ ទ្រង់សម្តែងធម្មបាលជាតកប្រោសព្រះពុទ្ធបិតា ឲ្យបានសម្រេចអនាគាមិផល និងទ្រង់សម្តែងកិន្នរីជាតកប្រោសដល់ព្រះនាងពិម្ពាយសោធរា ឲ្យបានសម្រេចសោតាបត្តិផលផងដែរ ។ លុះដល់ព្រឹកថ្ងៃទី ៤ ព្រះបរមសាស្តាស្តេចទៅកាន់ប្រាសាទថ្មី ជាថ្ងៃដែលព្រះនន្ទរាជកុមារអភិសេក ជាមួយនឹងនាងជនបទកល្យាណី តាមអដ្ឋកថាគម្ពីរខុទ្ទកនិកាយ ថេរគាថា ពោលថា គឺនាងរូបនន្ទា កាលព្រះអង្គទ្រង់ទទួលភត្តរួចស្រេចហើយ ទើបប្រទានបាត្រឲ្យដល់នន្ទរាជកុមារ ក៏បានត្រាស់ប្រសិទ្ធិពរ សិរីសួស្តីមង្គលរួចហើយ ស្តេចក្រោកចាកទី

ប្រថាប់ត្រឡប់ទៅកាន់វត្តវិញ ប៉ុន្តែទ្រង់មិនទទួលបាត្រពីនន្ទរាជកុមារឡើយ ។ ចំណែកនន្ទរាជកុមារមិនអាចក្រាបទូលថា សូមព្រះអង្គទ្រង់ទទួលបាត្រអំពីខ្ញុំព្រះអង្គវិញចុះ ព្រោះមានការគោរពចំពោះព្រះសាស្តា បានគិតថា ព្រះអង្គប្រាកដជាទទួលយកបាត្រអំពីយើងត្រង់ក្បាលជណ្តើរមិនខាន ទៅដល់ក្បាលជណ្តើរហើយ ព្រះសម្ពុទ្ធក៏មិនបានទទួល ក៏គិតតទៅទៀតថា ក៏គង់នឹងទ្រង់ទទួលនៅត្រង់មុខព្រះរាជវាំង ប៉ុន្តែក៏ទ្រង់មិនទទួលទៀត ។

នន្ទរាជកុមារគិតនឹងត្រឡប់វិញគ្រប់ៗ ខណៈ ប៉ុន្តែត្រូវបង្ខំចិត្តទៅមិនអាចក្រាបទូល ឲ្យព្រះបរមសាស្តាទ្រង់ទទួលបាត្របាន ព្រោះការគោរព បានត្រឹមតែគិតស្មានថា នឹងទ្រង់ទទួលទីនេះ នឹងទ្រង់ទទួលទីនោះប៉ុណ្ណោះ ក្នុងខណៈនោះ ពួកស្រីជាទៃក្រឡេកឃើញនន្ទរាជកុមារកាន់បាត្រតាមព្រះមហាវីរៈទៅ ទើបប្រាប់ដល់នាងជនបទកល្យាណីថា បពិត្រព្រះម៉ែម្ចាស់ ព្រះមានព្រះភាគទ្រង់នាំនន្ទរាជកុមារទៅហើយ ទ្រង់គង់នឹងព្រាត់ប្រាសចាកព្រះម៉ែម្ចាស់មិនខានឡើយ ។ ចំណែកនាងជនបទកល្យាណី បានស្តាប់ហើយ ប្រញាប់ក្រោកទៅទូលផ្តាំថា បពិត្រព្រះអយ្យបុត្រជាម្ចាស់ សូមព្រះអយ្យបុត្រស្តេចប្រញាប់ត្រឡប់មកវិញណាព្រះអយ្យបុត្រ ។ កាលបើនន្ទរាជកុមារ បានស្តាប់សំឡេងស្រែកផ្តាំរបស់នាងជនបទកល្យាណីហើយ ក៏ងាកមុខឡើងសម្លឹងមើលដោយការ

សម្តែងមនោសញ្ចេតនាស្រឡាញ់ ប៉ុន្តែមិនអាចសម្តែងអាការយ៉ាងណានីមួយចេញមកក្នុងខណៈនោះបាន ព្រោះគោរពដល់ព្រះសាស្តា សូម្បីអត់ទ្រាំអាការតាមផ្លូវកាយបាន តែមិនអាចអត់ទ្រាំតាមផ្លូវចិត្តបាន ចិត្តតែងនឹកដល់សំឡេងដែលស្រែកផ្តាំជារឿយៗ របស់នាងជនបទកល្យាណី រហូតដល់វិហារជាទីប្រថាប់របស់ព្រះអង្គ កាលព្រះសាស្តាស្តេចយាងដល់វិហារហើយ ទើបត្រាស់សួរនន្ទរាជកុមារថា នន្ទ អ្នកបួសឬទេ ? នន្ទរាជកុមារ សូម្បីមានចិត្តមិនស្មោះនឹងបួសបន្តិចបន្តួចសោះ ប៉ុន្តែមិនហ៊ាននឹងទូលជំទាស់បាន ព្រោះមានការគោរពចំពោះព្រះអង្គ ទើបក្រាបទូលដោយអាការមិនពេញចិត្តថា ខ្ញុំព្រះអង្គនឹងបួស ។ ព្រះសក្យមុនីឲ្យនន្ទរាជកុមារបួស មួយរំពេចក្នុងពេលនោះឯង ។

ជីវប្រវត្តិរបស់លោក បានពោលទុកក្នុងអដ្ឋកថា គម្ពីរធម្មបទ ហើយនៅមានរឿងប្រាកដក្នុងព្រះបាលី នន្ទសូត្រ គម្ពីរខុទ្ទកនិកាយ ឧទាន ដូចមានសេចក្តីថា ៖

ចាប់តាំងពីព្រះនន្ទបានបួសហើយ មិនមានការបដិបត្តិសមណធម៌ឡើយ ព្រោះបាននឹកឃើញតែពាក្យស្រែកផ្តាំរបស់នាងជនបទកល្យាណីជារឿយៗ មិនស្រោកស្ញើយទាល់តែសោះ ហាក់បីដូចថា នាងជនបទ-កល្យាណីនោះ មកឈរនៅជិតជានិច្ច ។ ការនឹកដល់នាងជនបទកល្យាណីនោះ ជាដើមហេតុឲ្យកើតការត្រេកត្រអាលក្នុងកាម ចង់សឹក គ្រាំគ្រា

ដួងចិត្ត កើតទុក្ខយ៉ាងក្រៃលែង ចិត្តក៏មិនបង្អោនទៅក្នុងការប្រព្រឹត្តិព្រហ្មចរិយធម៌ឡើយ ។ ប៉ុន្តែពេលដែលព្រះនន្ទនិមន្តធ្វងមកម្តុំព្រៃឈើ ឬជិតដង្កត់ឈើផ្សេងៗ ក្បែរវិហារនោះ មើលទៅហាក់បីដូចជាព្រះសម្ពុទ្ធប្រថាប់ឈរនៅចំពោះមុខ ហើយលោកក៏វិលត្រឡប់ទៅកុដិវិញ ដោយចិត្តថយត្រឡប់ក្រោយ ដូចគ្នានឹងស្លាបមាន់ត្រូវភ្លើងឆេះហើយរួញចូលដូច្នោះ ( ចិត្តរបស់លោកមិនគិតឈានទៅមុខ ដើម្បីប្រកបសមណកិច្ចឡើយ ) ។

ព្រះមហាមុនី ទ្រង់ជ្រាបដល់ចិត្តរបស់ព្រះនន្ទហើយ ទ្រង់ត្រិះរិះថា នន្ទកំពុងមានចិត្តមួម៉ៅណាស់ មិនអាចរម្ងាប់ភាពក្រវល់ក្រវាយក្នុងចិត្តខ្លួនឯងបាន ទើបទ្រង់ត្រិះរិះដូច្នេះហើយ ត្រាស់ថា ម្នាលនន្ទ អ្នកចូរមក យើងនឹងទៅស្ថានសួគ៌ជាមួយគ្នា ។ ព្រះនន្ទក្រាបទូលតបថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនអាចនឹងទៅកាន់ស្ថានសួគ៌បានទេ ព្រោះស្ថានសួគ៌អាចទៅបាននោះ លុះត្រាតែមានឫទ្ធិ ប៉ុន្តែខ្ញុំព្រះអង្គមិនមានឫទ្ធិទៅម្តេចនឹងបាន ។ ព្រះសម្ពុទ្ធត្រាស់បង្ហាញផ្លូវ ដែលនឹងអាចទៅកាន់ស្ថានសួគ៌ថា ម្នាលនន្ទ អ្នកចូរនឹកតែក្នុងចិត្តត្រឹមតែថា នឹងទៅកាន់ស្ថានសួគ៌ប៉ុណ្ណឹងទៅ អ្នកក៏នឹងទៅបានហើយ ត្រាស់ដូច្នេះហើយ ទើបព្រះអង្គនាំព្រះនន្ទឡើងទៅកាន់ស្ថានសួគ៌ជាន់តាវត្តិង្ស ដោយពុទ្ធានុភាព និងទ្រង់នាំព្រះនន្ទទៅមើលនាងទេពអប្សរ ដ៏ស្អាតល្អក្រៃលែងចំនួន ៥០០ នាក់

ដែលជាបរិវាររបស់ព្រះឥន្ទ្រ ។

កាលព្រះលោកនាថទ្រង់យល់ថា ព្រះនន្ទស្រឡាញ់ពេញចិត្ត ចំពោះស្រីទេពអប្សរទាំងនោះហើយ ទើបត្រាស់សួរថា នែ៎ នន្ទ នាងទេពអប្សរទាំងនោះ ជាមួយនឹងនាងជនបទកល្យាណីនោះ អ្នកណាស្អាតជាង ? ព្រះនន្ទក្រាបទូលថា កាលបើនាំយកមកប្រៀបធៀបគ្នាហើយ នាងជនបទកល្យាណី ក៏ដូចគ្នានឹងនាងពានរ ( ស្វា ) ដែលមានស្លឹកត្រចៀកកំបុត ប្រមុះកញ្ចែប ព្រះអង្គ ម្នាលនន្ទ អ្នកតាំងចិត្តបំពេញសមណធម៌ទៅ រមែងបាននាងទេពអប្សរទាំងនោះដោយមិនលំបាក ព្រះភគវាត្រាស់ប្រាប់ដល់ហេតុ ដែលនឹងឲ្យបាននាងទេពអប្សរទាំងនោះហើយ ដោយមានព្រះពុទ្ធបំណង ដើម្បីឲ្យព្រះនន្ទបំភ្លេចសេចក្តីស្រឡាញ់ដល់នាងជនបទកល្យាណីចោល ។

បពិត្រព្រះមានព្រះភាគជាម្ចាស់ ប្រសិនបើថាព្រះអង្គធានារ៉ាប់រងឲ្យខ្ញុំម្ចាស់បាននាងទេពអប្សរទាំងនោះ ខ្ញុំព្រះអង្គនឹងតាំងចិត្ត បំពេញសមណធម៌ ព្រះអង្គក៏ធានាយល់ព្រម ម្នាលនន្ទ អ្នកចូរបំពេញសមណ-ធម៌ចុះ តថាគតនឹងរ៉ាប់រង នឹងជួយឲ្យអ្នកបាននាងទេពអប្សរទាំងនោះ ។ កាលបើព្រះជិនស្រី ត្រាស់រ៉ាប់រងជាមួយនឹងព្រះនន្ទដូច្នេះហើយ ក៏ទ្រង់នាំព្រះនន្ទដើរមើលស្ថានសួគ៌ តាមកាលដ៏សមគួរហើយ ទើបស្តេចនាំត្រឡប់មកកាន់វត្តជេតពនមហាវិហារ នាក្រុងសាវត្ថីវិញ ។ ចាប់ផ្តើមតាំង

តែអំពីដែលព្រះនន្ទបានទៅឃើញនាងទេពអប្សរមក ព្រះនន្ទក៏តាំងចិត្តបំពេញសមណធម៌ទាំងថ្ងៃទាំងយប់ ព្រោះចង់បានស្រីទេពអប្សរទាំងនោះ ។

នេះជាវិធីមួយ ដែលជាគ្រឿងបញ្ឆោតចិត្ត របស់ព្រះនន្ទឲ្យតាំងមាំក្នុងសមណធម៌ ព្រះភគវា ទើបប្រាប់រឿងនេះដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះនន្ទធ្វើសមណធម៌ព្រោះដើម្បីចង់បាន នាងទេព-អប្សរដែលតថាគតជាអ្នកធានារ៉ាប់រង ។ ភិក្ខុទាំងឡាយក៏នាំគ្នាទៅពោលបោះពាក្យសម្តីឡើងក្នុងសម្នាក់របស់ព្រះនន្ទថា ឮដំណឹងថា ព្រះនន្ទជាកូនឈ្នួល ជាអ្នកដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់លោះមក ដោយហេតុថា ព្រះនន្ទប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះចង់បាននាងទេពអប្សរពិតមែនឬ ទាំងឮដំណឹងថា ព្រះសម្ពុទ្ធទ្រង់ជាអ្នកទទួលរ៉ាប់រងថា នឹងឲ្យព្រះនន្ទបាននាងទេពអប្សរទាំង ៥០០ នាក់ ដែលមានជើងសម្បុរក្រហម ប្រហែលគ្នានឹងជើងនៃសត្វព្រាប ។

ព្រះនន្ទ បានស្តាប់ពាក្យសម្តីរបស់ភិក្ខុទាំងនោះ ដែលនាំគ្នាមកពោលទំនងជាចំអកឡកឡឺយដល់ខ្លួន ក៏គិតក្នុងចិត្តថា ភិក្ខុទាំងនេះគង់មិននិយាយពាក្យសម្តីដល់អ្នកដទៃ គឺនិយាយសំដៅមកដល់យើងទេតើ អំពើរបស់យើងមិនសមគួរទេ នឹកគិតដូច្នេះហើយ ក៏កើតការអៀនខ្មាសចំពោះភិក្ខុទាំងឡាយ ទើបគេចចេញទៅនៅតែម្នាក់ឯង កើតការត្រិះរិះឡើងក្នុងចិត្តថា សេចក្តីស្រឡាញ់មិនមានទីបំផុត ក្នុងពេលនោះសេចក្តី

សង្វេគក៏កើតឡើងក្នុងចិត្ត ទើបបន្ទោបង់នូវការស្រឡាញ់ចេញ ជាអ្នកមិនប្រមាទ ខំចម្រើនវិបស្សនាកម្មដ្ឋានរហូតបានសម្រេចអរហត្ត ជាព្រះអរិយបុគ្គលថ្នាក់ខ្ពង់ខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា បានសម្រេចកិច្ចនៃបព្វជ្ជាដែលនឹងត្រូវសិក្សា ដែលហៅថាព្រះអសេក្ខៈ ប្រែថា អ្នកដែលមិនមានការសិក្សាជាបន្តទៀត ។ ព្រះសក្យមុនី ទ្រង់ពិចារណាដោយព្រះចក្ខុញាណ ក៏ទ្រង់ជ្រាបថា ព្រះនន្ទត្ថេរបានសម្រេចចេតោវិមុត្តិ គឺការរួចផុតដោយអំណាចនៃចិត្ត បញ្ញាវិមុត្តិ គឺដោយការរួចផុតដោយអំណាចនៃបញ្ញា ជាអ្នកអស់អាសវក្កិលេសទាំងឡាយហើយ ។ លុះព្រឹកឡើង ព្រះនន្ទត្ថេរចូលទៅគាល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាអ្នកធានារ៉ាប់រង ឲ្យខ្ញុំព្រះអង្គបាននាងទេពអប្សរទាំង ៥០០ ដែលមានជើងក្រហមដូចជាជើងព្រាប ឥឡូវនេះ សូមព្រះអង្គទ្រង់ផុតអំពីភាពជាអ្នករ៉ាប់រងទាំងនោះចុះ ។ ព្រះបរមសាស្តាត្រាស់តបថា ម្នាលនន្ទ សូម្បីតថាគតក៏ដឹងចិត្តរបស់អ្នកដែរ អ្នកបានសម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាការអស់ទៅនៃអាសវក្កិលេសទាំងឡាយ ក្នុងអត្តភាពនេះហើយ ទេវតាក៏បាននាំដំណឹងនេះមកប្រាប់ដល់តថាគតហើយ នៃ នន្ទ ចិត្តរបស់អ្នកផុតស្រឡះហើយ ចាកអាសវក្កិលេសទាំងឡាយ តថាគតក៏រួចផុតអំពីការធានារ៉ាប់រងនោះដែរ ។

គ្រានោះ ព្រះភគវាទ្រង់ជ្រាបរឿងនេះហើយ ទ្រង់បន្លឺព្រះឧទាន

ឡើងក្នុងពេលនោះថា ៖

បុគ្គលណាធ្វងកក់ គឺកាមបានហើយ ញាំញីបទ្វា គឺកាមបានហើយ បុគ្គលនោះសម្រេចការអស់ទៅនៃមោហៈ ( គឺការវង្វេង ល្ងង់ ) រមែង មិនញាប់ញ័រក្នុងសុខ និងទុក្ខ ។

ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ មានរឿងដំណាលទៀត ដែលមាន មកក្នុងអដ្ឋកថា គម្ពីរធម្មបទ នៃយមកវគ្គ មានសេចក្តីថា ៖

ថ្ងៃមួយ ភិក្ខុទាំងឡាយ សួរព្រះនន្ទត្ថេរថា កាលមុនលោកម្ចាស់ ត្អូញត្អែរថាចង់សឹក ឥឡូវនេះលោកម្ចាស់មិនចង់សឹកទេឬ ? ព្រះនន្ទត្ថេរ តបថា លោកម្ចាស់ទាំងឡាយ ខ្ញុំព្រះករុណាអស់ការអាល័យ ដែលនឹង ត្រឡប់ទៅកាន់ភេទជាគ្រហស្ថហើយ ចំណែកភិក្ខុទាំងឡាយ បានស្តាប់ ពាក្យនោះហើយ ក៏ពោលថា ព្រះនន្ទត្ថេរនិយាយរឿងដែលមិនពិត បាន ពោលព្យាករព្រះអរហត្តផលខ្លួនឯង កាលបើមិនជឿការនិយាយរបស់ ព្រះនន្ទត្ថេរ ទើបនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូល សេចក្តីនោះចំពោះព្រះអង្គ ទើបព្រះបរមសាស្តាត្រាស់ ជាមួយនឹងភិក្ខុ ទាំងឡាយនោះថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃដែលកន្លងមកហើយ អត្តភាពរបស់ព្រះនន្ទ រមែងដូចជាផ្ទះដែលប្រក់មិនល្អ ប៉ុន្តែឥឡូវនេះ ដូចជាផ្ទះដែលបានប្រក់ល្អហើយ ព្រោះចាប់ផ្តើមពីព្រះនន្ទបានទៅឃើញ នាងទេពអប្សរមក ជាអ្នកព្យាយាមដើម្បីនឹងឲ្យបានសម្រេចដល់ទីបំផុត

កិច្ចនៃបព្វជ្ជា ហើយក៏បានសម្រេចតាមសេចក្ដីប្រាថ្នាមែន លុះព្រះអង្គត្រាស់ជានាអះអាងព្រះនន្ទត្ថេរដូច្នេះហើយ ទើបត្រាស់ព្រះគាថាទាំងនោះថា **យថា អគារំ ទុច្ឆន្នំ** ជាដើម មានពាក្យប្រែថា ៖

ទឹកភ្លៀង រមែងលិចស្រោចផ្ទះដែលប្រក់មិនបានល្អ យ៉ាងណាមិញ រាគៈរមែងរួបរឹតចិត្ត ដែលមិនបានអប់រំដោយល្អ ក៏ដូច្នោះ ទឹកភ្លៀងរមែងលិចស្រោចផ្ទះដែលប្រក់ល្អហើយមិនបាន យ៉ាងណាមិញ រាគៈក៏រមែងមិនរួបរឹតចិត្ត ដែលបុគ្គលបានអប់រំល្អហើយក៏ដូច្នោះដែរ ។

ថ្ងៃបន្ទាប់មក ភិក្ខុទាំងឡាយបានសន្ទនាគ្នាក្នុងធម្មសភាថា ម្នាលអាវុសោទាំងឡាយ អស្ចារ្យណាស់ ព្រះមានព្រះភាគ ព្រះអង្គជ្រាបដល់ចិត្តរបស់ព្រះនន្ទ ព្រោះសេចក្ដីស្រឡាញ់ ចំពោះនាងជនបទកល្យាណី ប៉ុន្តែព្រះអង្គទ្រង់ណែនាំ ដោយវិធីយកនាងទេពអប្សរមកជាគ្រឿងបោកបញ្ឆោតចិត្តរបស់ព្រះនន្ទទៅវិញ ។ ព្រះសាស្ដា ស្ដេចយាងមកដល់ក៏ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំសន្ទនាគ្នាក្នុងរឿងអ្វី ? លុះទ្រង់ជ្រាបរឿងពីការក្រាបទូលរបស់ភិក្ខុទាំងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងនេះមិនមែនមានតែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងអតីតជាតិ តថាគតក៏ធ្លាប់បានណែនាំនន្ទដែរ ដោយប្រើមាតុគ្រាមមកល្បួងលួងលោមដូចគ្នា ។ ភិក្ខុទាំងនោះ ទូលអារាធនាឲ្យព្រះអង្គសម្ដែងអតីតនិទានឡើង ព្រះសាស្ដា ត្រាស់តំណាលរឿងក្នុង

អតីតជាតិរបស់ព្រះនន្ទត្ថេរថា ៖

ក្នុងកាលកន្លងទៅហើយ ក្នុងសម័យរបស់ព្រះបាទព្រហ្មទត្ត គ្រប់គ្រងសោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី ។ មានឈ្មួញម្នាក់ឈ្មោះ កប្បៈ អាស្រ័យនៅក្នុងក្រុងពារាណសីនោះ កប្បពាណិជមានសត្វលាមួយក្បាល សម្រាប់ប្រើក្នុងការនាំអីវ៉ាន់ផ្សេងៗ សត្វលារបស់គាត់ធ្វើដំណើរមួយថ្ងៃៗ បាន ៧ យោជន៍ ។ ក្នុងថ្ងៃមួយ កប្បពាណិជបានដាក់ទំនិញផ្សេងៗ នាំយកទៅលក់នៅនគរតក្កសិលា លុះទៅដល់ទីសម្រាកហើយ ទើបដោះលាឲ្យដើរទៅស៊ីស្មៅ រហូតដល់លក់ទំនិញអស់ ។ លារបស់គាត់ដើរទៅបានឃើញលាញីមួយទៀត ក៏ចូលទៅរកលាញីនោះៗប្រាស្រ័យសាកសួរលារបស់កប្បពាណិជមុនថា តើអ្នកមកពីទីណា ? លាឈ្មោលឆ្លើយថា ខ្ញុំមកពីក្រុងពារាណសី លាញីសួរថា អ្នកមកធ្វើអ្វី ? លាឈ្មោលឆ្លើយថា ខ្ញុំមកធ្វើជំនួញ លាញីសួរថា អ្នកនាំអ្វីមកខ្លះ ? លាឈ្មោលឆ្លើយថា ខ្ញុំនាំរបស់ជូនមក មានភាជនៈផ្សេងៗ លាញីសួរថា កាលបើអ្នកនាំរបស់ជូនមកដូច្នេះ តើអ្នកដើរបានប៉ុន្មានយោជន៍ក្នុងមួយថ្ងៃ ? លាឈ្មោលឆ្លើយថា ដើរមួយថ្ងៃៗ បាន ៧ យោជន៍ លាញីក៏សួរទៀតថា ក្នុងស្ថានទីដែលអ្នកទៅដល់ហើយនោះ មានអ្នកណាច្របាច់ជើងគក់ខ្នងឲ្យខ្លះទេ ? បានជាលាញីសួរដូច្នេះ ក៏ព្រោះតែសេចក្តីស្រឡាញ់ចំពោះលារបស់កប្បពាណិជ ។

លាឈ្មោលតបថា មិនមានទេ លាញីពោលថា កាលបើដូច្នោះ អ្នកប្រហែលជាលំបាកណាស់ ហើយធ្វើឫកម៉ិកម៉ក់ ។ លារបស់កប្បពាណិជក៏ជាប់ចិត្តដោយពាក្យសម្ដីរបស់លាញី ដែលអាណិតអាសូរចំពោះខ្លួន ។ ចំណែកកប្បពាណិជជញ្ជូនទំនិញអស់ហើយ ក៏ត្រឡប់ទៅរកលារបស់ខ្លួន ហើយប្រាប់ថា កូនអើយយើងត្រឡប់ទៅវិញ លាតបថា សូមនាយទៅមុនចុះ ខ្ញុំមិនទាន់ទៅទេ កប្បពាណិជបានស្ដាប់ពាក្យឆ្លើយរបស់លាហើយ សង្កេតឃើញអាការមិនល្អ ទើបនិយាយអង្វរហើយ អង្វរទៀត ប៉ុន្តែលាមិនព្រមទៅ ទើបគិតថា យើងនឹងគម្រាមលានេះឲ្យខ្លាចទាល់តែបាន ហើយពោលនឹងលាទៀតថា ប្រសិនបើអ្នកមិនទៅទេ យើងនឹងធ្វើជន្ទញដែលមានប្រវែង ១៦ ធ្នាប់ ទុកចាក់កាយរបស់អ្នក អ្នកចូរដឹងចុះ លាបានស្ដាប់ហើយក៏ឆ្លើយតបកប្បពាណិជថា ប្រសិនបើនាយធ្វើដូច្នោះ ខ្ញុំនឹងសងសឹកលោក ពេលលោកចាក់ខ្ញុំដោយជន្ទញ ខ្ញុំនឹងទប់ជើងខាងមុខឲ្យមាំ ហើយលើកជើងខាងក្រោយឡើង ធ្វើឲ្យរបស់របរលោកខ្ចាត់ខ្ចាយទៅ សូមនាយដឹងយ៉ាងនោះចុះ ។

កប្បពាណិជបានស្ដាប់ពាក្យឆ្លើយរបស់លាហើយ សញ្ជឹងគិតថា ហេតុអ្វីហ្ន៎ លានេះទើបនិយាយជាមួយយើងយ៉ាងនេះ មិនដែលធ្លាប់មានឡើយ ទើបក្រឡេកមើលខាងនេះខាងនោះ ក៏ឃើញលាញីនោះ ទើបពិនិត្យមើលថា លារបស់យើង ប្រហែលជាទទួលការញុះញង់ពីលាញី

នេះមិនខាន ប្រសិនបើយ៉ាងនេះ យើងនឹងនិយាយលួងលោមលារបស់យើង ដោយប្រាប់ថា យើងនឹងនាំលាញីក្រមុំ មានមុខដូចសង្ខ ស្អាតសព្វសព៌ាង្គកាយឲ្យមកធ្វើជាភរិយារបស់អ្នក ។ ចំណែកលា លុះបានស្តាប់ពាក្យនោះហើយ ក៏សប្បាយចិត្ត ទើបពោលថា ប្រសិនបើលោកនឹងធ្វើយ៉ាងនោះពិតមែន ខ្ញុំនឹងដើរឲ្យរហ័ស ក្នុងមួយថ្ងៃ ១៤ យោជន៍ ។ កប្បពាណិជជីងថាលា ព្រមធ្វើតាមពាក្យរបស់ខ្លួនហើយ ទើបបបួលឲ្យត្រឡប់ទៅទីលំនៅរបស់ខ្លួនវិញ ។ កាលកន្លងទៅបាន ២-៣ ថ្ងៃ លានោះឃើញនាយរបស់ខ្លួននៅស្ងៀម មិនព្រមធ្វើតាមពាក្យសន្យា ទើបនិយាយជាមួយនឹងកប្បពាណិជថា លោកបានសន្យាជាមួយខ្ញុំថា នឹងនាំញីក្រមុំឲ្យមកធ្វើជាភរិយារបស់ខ្ញុំពិតមែនឬ ? កប្បពាណិជឆ្លើយតបថា ពិតមែនហើយ យើងមិនភ្លេចពាក្យសន្យាទេ យើងនឹងរកលាញីក្រមុំមកឲ្យអ្នកធ្វើជាភរិយា ប៉ុន្តែថា យើងនឹងឲ្យអាហារត្រឹមតែម្នាក់ប៉ុណ្ណោះ ចំណែកភរិយារបស់អ្នកនឹងមានអាហារស៊ីឬអត់ យើងមិនដឹងទេ នេះជាតួនាទីរបស់អ្នក កាលនៅរួមជាមួយគ្នាហើយ ក៏នឹងមានកូន អ្នកនឹងត្រូវរកអាហារឲ្យកូនរបស់អ្នកទៀត ។

កាលបើកប្បពាណិជនិយាយជាមួយនឹងលាយ៉ាងនេះហើយ លាក៏អស់សង្ឃឹម ឈប់គិតចង់បានលាញីតទៅទៀត ។ កាលបើព្រះមានព្រះភាគ ទ្រង់នាំរឿងនោះមកត្រាស់តំណាលរួចហើយ ក៏ទ្រង់ប្រជុំជាតក

ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាញ៊ីបានមកជានាងជនបទ កល្យាណី លាឈ្មោលបានមកជានន្ទ ចំណែកកប្បពាណិជ បានមកជា តថាគត នន្ទ តថាគតជួបប្រញ្ញោតដោយមាតុគ្រាម និងណែនាំហើយ យ៉ាងនេះ ។ ព្រះនន្ទត្ថេរ កាលបានសម្រេចជាព្រះអរហន្តហើយ ជាអ្នក បរិបូណ៌ដោយការសង្រួមឥន្ទ្រីយ៍ទាំង ៦ រហូតដីងទូទៅ ។ ក្នុងគម្ពីរព្រះ- បាលីមហាវិភង្គ ព្រះវិន័យបិដក លោកពោលប្រៀងធៀប កម្ពស់រវាង ព្រះបរមសាស្តាជាមួយនឹងព្រះនន្ទត្ថេរទុកដូច្នេះថា ៖

ព្រះនន្ទត្ថេរ មានរាងកាយទាបជាងព្រះសម្ពុទ្ធ ៤ ធ្នាប់ ( ឬ ៤ អង្គុលី ) មានរាងកាយល្អស្អាត ជាទីគាប់ចិត្តរបស់អ្នកជួប ឬឃើញ លោកមានបុគ្គលិកលក្ខណៈ ស្រដៀងព្រះបរមសាស្តា ទាំងលោកអាច ប្រើចីវរបានស្មើនឹងចីវររបស់ព្រះសុគតសាស្តា ។ គ្រាមួយ ភិក្ខុទាំង ឡាយ ឃើញលោកនិមន្តមកអំពីចម្ងាយ ទើបនាំគ្នាក្រោកចាកអាសនៈ មកទទួល ដោយគិតថា ព្រះបរមសាស្តាយាងមក លុះលោកនិមន្តមក ដល់ជិត ទើបចាំបានថា មិនមែនព្រះមានព្រះភាគទេ គឺព្រះនន្ទទេតើ ។

ចំណែករឿងកិត្តិគុណ និងសេចក្តីល្អរបស់ព្រះនន្ទត្ថេរ មានសម្តែង ទុកថា ក្នុងសម័យតមក កាលព្រះបរមសាស្តាទ្រង់ប្រថាប់នៅវត្តជេត- ពនមហាវិហារ នាក្រុងសាវត្ថីនោះ ទ្រង់ប្រកាសតែងតាំងព្រះនន្ទត្ថេរទុក ក្នុងតំណែងជាឯតទគ្គៈ ដែលមានមកប្រាកដនៅក្នុង គម្ពីរអង្គុត្តរនិកាយ

ឯកនិបាត ថា ៖

***ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោតិ ។***

ប្រែថា ម្នាលភិក្ខុទាំងឡាយ ព្រះនន្ទជាឯតទគ្គៈ គឺជាអ្នកប្រសើរ ជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត ផ្នែកខាងសង្រួមឥន្ទ្រីយ៍ទាំងឡាយ ។

អដ្ឋកថាមនោរថបូរណីអធិប្បាយសេចក្តីនៃព្រះបាលីនោះថា ៖

ព្រះនន្ទត្ថេរនេះ ជាអ្នកបានទទួលការលើកតម្កើងពីព្រះបរមសាស្តា ថា ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងសង្រួមឥន្ទ្រីយ៍នោះ សំដៅដល់ ការរក្សាឥន្ទ្រីយ៍ទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដោយមានសតិ គឺការរឭកបាន សម្បជញ្ញៈ គឺការដឹងខ្លួនជាប់ជានិច្ច ។

ពាក្យថា សតិ គឺការរឭកបាន សំដៅដល់ ឲ្យរឭកមុនធ្វើ មុន និយាយ មុនគិត និងអាចចងចាំនូវវត្ថុដែលធ្វើ ពាក្យដែលនិយាយរួច ហើយ ក៏ចាំបាន ។ ពាក្យថា សម្បជញ្ញៈ គឺការដឹងខ្លួនទាន់ បានដល់ ការដឹងខ្លួនថា វត្ថុណាជាប្រយោជន៍ ១ វត្ថុណាជាទីសប្បាយដល់ខ្លួន ១ កម្មដ្ឋានអ្វីដែលត្រូវចិត្តរបស់ខ្លួន ១ និងការដឹងខ្លួនចំពោះធម្មជាតិ ដើម្បី មិនឲ្យវង្វេងល្ងីល្ងើ ១ ។

មានពាក្យសួរថា សាវកទាំងឡាយរបស់ព្រះពុទ្ធ សុទ្ធតែជាអ្នក

រក្សាឥន្រ្ទីយ៍ទាំងឡាយដូចគ្នា ដូចម្ដេចទើបបានទទួលការលើកតម្កើង ចំពោះតែព្រះនន្ទត្ថេរមួយរូបប៉ុណ្ណោះ ។

មានពាក្យឆ្លើយថា ព្រះនន្ទត្ថេរ កាលបើមានបំណងនឹងក្រឡេក មើលទិសណាៗ ក្នុងទិសទាំង ១០ ក៏ក្រឡេកមើលទិសនោះៗ ដោយ មានសតិ និងសម្បជញ្ញៈ ទើបបានទទួលការលើកតម្កើងឲ្យជាអ្នកប្រសើរ ជាងភិក្ខុទាំងឡាយក្នុងការរក្សាឥន្រ្ទីយ៍ និងមានហេតុមួយទៀត ព្រោះ លោកបានធ្លាប់ធ្វើបុណ្យកុសលហើយ តាំងសេចក្ដីប្រាថ្នាឲ្យបានតំណែង យ៉ាងនោះក្នុងអតីតជាតិ ដូចមានរឿងតំណាលក្នុងគម្ពីរ ខុទ្ទកនិកាយ អបទាន មានសេចក្ដីថា ក្រោយពីព្រះនន្ទត្ថេរ បានជាព្រះអរហន្ត បាន តំណែងដ៏ប្រសើរយ៉ាងនេះហើយ ក៏រឭកដល់បុព្វកម្មរបស់ខ្លួន មានបីតិ សោមនស្សរីករាយ ទើបប្រកាសបុព្វចរិយាបទានឡើងថា ៖

ខ្ញុំបានថ្វាយសំពត់សំបកឈើ ចំពោះព្រះមានព្រះភាគ ព្រះនាម បទុមុត្តរៈ ជាចម្បងក្នុងលោក ទ្រង់ប្រកបដោយតាទិគុណ ជាព្រះ សយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះពុទ្ធជានាយក ព្រះនាមបទុ- មុត្តរៈ ទ្រង់ព្យាកររឿងនោះប្រាប់ខ្ញុំថា ៖

អ្នកនឹងមានពណ៌សម្បុរដូចមាស ដោយការថ្វាយសំពត់នេះ ។ អ្នកនឹងបានទទួលសម្បត្តិទាំងពីរប្រការ ត្រូវកុសលមូលជាស់តឿនហើយ និងបានជាប្អូននៃព្រះមានព្រះភាគ ព្រះនាមគោតម ។ អ្នកនឹងមានសេចក្ដី

ត្រេកអរដោយរាគៈ មានសេចក្ដីសុខជាប្រក្រតី មានសេចក្ដីជាប់ជំពាក់ដោយចំណង់ក្នុងកាមទាំងឡាយ តែលុះព្រះពុទ្ធទ្រង់ជាស់តឿន នឹងប្រែជាបុគ្គលស្ងប់ ហើយចេញបួសក្នុងកាលនោះ ។ អ្នកលុះបួសហើយត្រូវកុសលមូលជាស់តឿន នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វានក្នុងទីនោះ ។ ក្នុងកប្បទីមួយសែន អ្នកនឹងបានជាព្រះរាជា ព្រះនាមចេលៈ ៤ ដង ក្នុងកប្បទី ៦០ ពាន់ នឹងបានកើតជាជន ឈ្មោះឧបចេលៈ ៤ ដង ។ ក្នុងកប្បទី ៥ ពាន់ នឹងបានជាជន ឈ្មោះចេលៈ ៤ ដងទៀត ជាធំក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

សេចក្ដីតាមគម្ពីរខុទ្ទកនិកាយ អបទាន ដូចដែលបានពោលមកនេះ ពោលទុកត្រឹមតែថា ព្រះនន្ទុត្តរ បានធ្វើបុណ្យទុកក្នុងពុទ្ធសម័យនៃព្រះសម្ពុទ្ធបទុមុត្តរៈប៉ុណ្ណោះ ប៉ុន្តែប្រសិនបើរាប់អំពីជាតិដែលថ្វាយសំពត់សំបកឈើនោះមករហូតមួយសែនកប្ប ក៏មានព្រះពុទ្ធស្ដេចឧប្បត្តិឡើងក្នុងលោក ១៥ ព្រះអង្គ គឺ ៖

១ ព្រះបទុមុត្តរៈ ២ ព្រះសុមេធ ៣ ព្រះសុជាត ៤ ព្រះបិយ-ទស្សី ៥ ព្រះអត្ថទស្សី ៦ ព្រះធម្មទស្សី ៧ ព្រះសិទ្ធត្ថៈ ៨ ព្រះតិស្សៈ

៩ ព្រះផុស្សៈ ១០ ព្រះវិបស្សី ១១ ព្រះសិខី ១២ ព្រះវេស្សភូ ១៣ ព្រះកកុសន្ធោ ១៤ ព្រះកោនាគមនោ ១៥ ព្រះកស្សបៈ ហើយទើបមកដល់ព្រះសមណគោតមជាម្ចាស់នៃយើងទាំងឡាយ ។

ព្រះនន្ទុត្តរ កាលលោកត្រាច់រង្គាត់កើតស្លាប់ៗ ជាតិផ្សេងៗ មុនដែលនឹងមកដល់ជាតិបច្ចុប្បន្ននេះ លោកធ្លាប់បានអប់រំកសាងសន្សំគុណគឺសេចក្តីល្អផ្សេងៗ ទុក ដើម្បីឲ្យបានជាបុញ្ញសម្បត្តិ ជាឧបនិស្សយ-បច្ច័យក្នុងកាលជាអនាគត ដូចមានរឿងចារឹកទុកក្នុងអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយសេចក្តីបាលី គម្ពីរខុទ្ទនិកាយ នន្ទថេរគាថា បានពោលដល់ការបំពេញបុណ្យបារមី ក្នុងអតីតជាតិរបស់លោកថា ៖

ព្រះនន្ទុត្តរនេះ បានកើតក្នុងត្រកូលមួយក្នុងក្រុងហង្សវតី ស្រប គ្នានឹងពុទ្ធកាលរបស់ព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់ កាលបើលោកចម្រើនវ័យធំឡើង បានទៅស្តាប់ធម៌ទេសនាក្នុងសម្នាក់ព្រះសម្ពុទ្ធបទុមុត្តរៈ ក៏បានឃើញភិក្ខុមួយរូប ដែលព្រះអង្គទ្រង់ទទួលការលើកតម្កើងថា ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងសង្រួមឥន្ទ្រីយ៍ ៦ ។

កាលបើកុលបុត្រនោះ បានឃើញភិក្ខុរូបនោះបានទទួលតំណែងក្នុងឋានៈជាអ្នកទ្រទ្រង់នូវគុណ ដ៏ប្រសើរបំផុតផ្នែកខាងសង្រួមឥន្ទ្រីយ៍ ក៏កើតមានការពេញចិត្តក្នុងតំណែងនោះ ទើបរៀបចំថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធបទុមុត្តរៈជាប្រធាន ហើយតាំងសេចក្តី

ប្រាថ្នាថា សូមឲ្យខ្ញុំព្រះអង្គបានទូវតំណែងដ៏ប្រសើរ ផ្នែកខាងរក្សាឥន្ទ្រីយ៍ទាំងឡាយ ដូចភិក្ខុរូបនេះក្នុងសាសនាព្រះពុទ្ធអង្គណាទីមួយ នាកាលអនាគតកុំបីខានឡើយ ។

កាលកុលបុត្រនោះអស់ជីវិតទៅហើយ ក៏ត្រាច់រង្គាត់សោយសុខក្នុងមនុស្សទេវតា អស់កាលជាយូរអង្វែង រហូតមកដល់ពុទ្ធកាលនៃព្រះពុទ្ធអត្ថទស្សីជាម្ចាស់ ។ កុលបុត្រនោះ ( នន្ទ ) លោកធ្លាប់ធ្វើបាបកម្មអំពីជាតិណាៗ គ្រាណាក៏មិនអាចដឹងបាន ព្រោះមានរឿងមិនប្រាកដដោយលោកត្រឡប់មកកើតជាអណ្តើកជំនៅនឹងស្ទឹង វិតកតានទី ថ្ងៃមួយអណ្តើកនោះ បានឃើញព្រះអត្ថទស្សីសម្ពុទ្ធ ទ្រង់មានបំណងនឹងយាងឆ្លងស្ទឹងទៅខាងត្រើយម្ខាង ទើបបណ្តែតខ្លួនឡើងអំពីទឹក ឲ្យព្រះអត្ថទស្សីទ្រង់ឈរប្រថាប់លើខ្នងរបស់ខ្លួន ហើយនាំជំណើរទ្រង់ឲ្យឆ្លងដល់ត្រើយដោយសួស្តី ។ ដោយបុញ្ញកម្មដែលអណ្តើកយកខ្លួនជាពាហនៈ លុះអស់ជីវិតទៅ ក៏បានទូវមនុស្សសម្បត្តិ និងទិព្វសម្បត្តិរហូតអស់កាលដ៏យូរច្រើនជួរពុទ្ធកាល រហូតមកដល់ពុទ្ធកាលព្រះសមណគោតមនៃយើងនេះ ក៏បានមកកើតជាព្រះរាជឱរសរបស់ព្រះនាងមហាបជាបតិគោតមី ជាអគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ មានព្រះនាមថា នន្ទរាជកុមារនឹងបានចេញបួស ក្នុងគ្រាដែលព្រះមានព្រះភាគជាម្ចាស់ ស្តេចនឹងនិវត្តន៍ទៅកាន់ក្រុងកបិលពស្តុគ្រាជំបូង នឹងបានសម្រេចទូវធម៌ពិសេសជាព្រះ

អរហន្ត ( បុគ្គលឆ្ងាយចាកសត្រូវ គឺកិលេស ឬបុគ្គល មិនមានទូវកិលេស រាប់ជាព្រះអរិយបុគ្គលជាន់ខ្ពស់បំផុត ក្នុងចំនួនព្រះអរិយបុគ្គល ៤ ជំពូក ) ។

ព្រះនន្ទត្ថេរ កាលបានសម្រេចជាព្រះអរហន្តហើយ លោកបានពោលគាថា ២ គាថា ដោយប្រារព្ធរឿងរបស់លោកផ្ទាល់ ដូចមានសេចក្តីនៅក្នុងព្រះបាលីខុទ្ទកនិកាយ ថេរគាថា មានសេចក្តីថា ៖

ខ្ញុំកាលប្រកបនូវគ្រឿងប្រដាប់ ( កាយ ) ជាបុគ្គលអណ្តែតអណ្តូងឃ្វេងឃ្វាង ត្រូវកាមរាគៈបៀតបៀន ព្រោះមិនមានយោនិសោ-មនសិការៈ ។ ( ឥឡូវនេះ ) ខ្ញុំដកចិត្តក្នុងភពបានហើយ ព្រោះប្រតិបត្តិដោយយោនិសោមនសិការៈ តាមព្រះពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានកុសលោបាយ ( ឧបាយល្អ ) ។

នេះជាឧទាហរណ៍ដ៏ល្អរបស់ព្រះនន្ទត្ថេរ ដែលជាអ្នកសង្រួមរាំងឥន្ទ្រីយ៍ ៦ មិនឲ្យកើតសេចក្តីត្រេកអររីករាយ ឬមិនបណ្តែតបណ្តោយចិត្តឲ្យធ្លាក់ទៅក្នុងអំណាចនៃលោកធម៌ ថែមទាំងជាអ្នកបរិបូណ៌ដោយបដិភាណ ទាំងជាកម្លាំងដ៏សំខាន់ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ។

( ជីវប្រវត្តិរបស់ព្រះនន្ទត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះបិលិន្ទវច្ឆត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ "

ព្រះបិលិន្ទវច្ឆត្ថេរ បានកសាងសេចក្ដីល្អផ្សេងៗ ទុក រហូតដល់មានទេវតាទាំងឡាយឃើញគុណសម្បត្តិរបស់លោកហើយ ក៏នាំគ្នាមកសម្ដែងការគោរពបដិបត្តិចំពោះលោក ដែលស្របគ្នានឹងពាក្យបុរាណាចារ្យ បានពោលឲ្យកម្លាំងចិត្តដល់បុគ្គលអ្នកធ្វើសេចក្ដីល្អថា ការធ្វើសេចក្ដីល្អសូម្បីនឹងមិនមានអ្នកណាឃើញ ក៏គង់អមនុស្សមានទេវតាជាដើមឃើញដែរ ប៉ុន្តែឲ្យតែធ្វើសេចក្ដីល្អ ដើម្បីឲ្យកើតផលល្អ ដោយភាពបរិសុទ្ធនៃចិត្តដែលជាទីតាំង កុំធ្វើសេចក្ដីល្អដើម្បីសង្ឃឹមផលប្រយោជន៍យ៉ាងដទៃជាដើម ។

ប្រសិនបើមានពាក្យសួរថា គុណគឺសេចក្ដីល្អ ដែលព្រះថេរៈបានធ្វើហើយនោះគឺជាអ្វី ទើបជាដើមហេតុធ្វើឲ្យទេវតាទាំងឡាយមកគោរពបូជាចំពោះលោកនោះ ? ឆ្លើយថា គឺត្រូវសិក្សាជីវប្រវត្តិរបស់លោក ទើបដឹងបាន ។

ជីវប្រវត្តិរបស់ព្រះបិលិន្ទវច្ឆត្ថេរ ក្នុងអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយបាលីគម្ពីរខុទ្ទកនិកាយ ថេរគាថា និងអដ្ឋកថាមនោរថបូរណី ដែលអធិប្បាយបាលីក្នុង គម្ពីរអង្គុត្តរនិកាយ ឯកនិបាត ដូចមានរឿង

តំណាលទុកថា ៖

ព្រះបិលិន្ទវច្ឆត្ថេរ កើតនៅក្នុងត្រកូលព្រាហ្មណ៍ វច្ឆគោត្រ នៅក្នុងក្រុងសាវត្ថី លោកមានឈ្មោះថា បិលិន្ទៈ ប៉ុន្តែកាលបើហៅរួមជាមួយនឹងគោត្រ គឺត្រកូល ទើបជាបិលិន្ទវច្ឆៈ ។ កាលបើបិលិន្ទវច្ឆៈចម្រើនវ័យធំហើយ បានចេញបួសជាបរិព្វាជក ព្រោះសេចក្ដីសង្វេគក្នុងវដ្ដសង្សារ លោកបានសម្រេចវិជ្ជាការដែលមានឈ្មោះថា ចូឡគន្ធារៈ វិជ្ជាការនេះគឺជាវិជ្ជាដែលមានឫទ្ធិ ធ្វើឲ្យហោះទៅក្នុងអាកាសបាន និងអាចធ្វើឲ្យដឹងចិត្តរបស់អ្នកដទៃបានទៀតផង ទាំងជួយឲ្យជាអ្នកបរិបូណ៌ប្រសើរដោយលាភ និងយស រហូតមានកិត្តិស័ព្ទល្បីរន្ទឺក្នុងក្រុងរាជគ្រឹះ ។

កាលតមក ព្រះបរមសាស្ដាត្រាស់ដឹងហើយ ព្រះអង្គយាងទៅក្រុងរាជគ្រឹះ គ្រានោះ វិជ្ជាចូឡគន្ធារៈរបស់បិលិន្ទវច្ឆបរិព្វាជក លែងសក្ដិសិទ្ធិដូចកាលមុន ក៏វិនាសព្រាត់ប្រាសទៅដោយអានុភាពនៃព្រះជិនស្រី ។ បិលិន្ទវច្ឆបរិព្វាជក កាលឃើញវិជ្ជារបស់ខ្លួនវិនាសព្រាត់ប្រាសទៅ លែងសក្ដិសិទ្ធិដូច្នេះហើយ ទើបគិតដល់ពាក្យនិយាយរបស់បុព្វាចារ្យថា វិជ្ជាមហាគន្ធារៈមានក្នុងទីណា វិជ្ជាចូឡគន្ធារៈ ក៏មិនសក្ដិសិទ្ធិក្នុងទីនោះដែរ តាំងតែពីព្រះសមណគោតម ស្ដេចយាងមកដល់ក្រុងរាជគ្រឹះ វិជ្ជារបស់យើងក៏លែងសក្ដិសិទ្ធិទៅ នេះបង្ហាញថា ព្រះសមណគោតម ទ្រង់ចេះវិជ្ជាមហាគន្ធារៈពិតប្រាកដ យើងនឹងទៅសូមរៀនវិជ្ជាមហាគន្ធារៈ ក្នុង

សម្នាក់ព្រះសមណគោតម គិតដូច្នេះហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលថា ៖

បពិត្រព្រះមហាសមណៈ ខ្ញុំព្រះអង្គមានបំណងនឹងសូមរៀនវិជ្ជាតែម្យ៉ាងក្នុងសម្នាក់របស់ព្រះអង្គ សូមព្រះអង្គទ្រង់បង្រៀនដល់ខ្ញុំផង ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលបរិព្វាជក ប្រសិនបើអ្នកមានបំណងដូច្នេះហើយ ចូរអ្នកបព្វជ្ជាជាមុនសិន ព្រោះតថាគតនឹងបង្រៀនចំពោះអ្នកដែលមានភេទដូចគ្នានឹងតថាគតតែប៉ុណ្ណោះ ។ បិលិន្ទវច្ឆបរិព្វាជក មានសេចក្តីប្រាថ្នាចង់បានវិជ្ជាមហាគន្ធារៈ ទើបព្រមលះបង់ភេទបរិព្វាជកចេញហើយទើបបព្វជ្ជាក្នុងព្រះពុទ្ធសាសនាមួយរំពេចនោះឯង ទាំងនេះដោយមានការយល់ថា ការបព្វជ្ជាជាបរិកម្មរបស់វិជ្ជាមហាគន្ធារៈ ការបួសរបស់យើងនេះ ព្រោះប្រាថ្នាចង់បានវិជ្ជាតែប៉ុណ្ណោះ ព្រះលោកនាថទ្រង់សម្តែងព្រះធម៌ឲ្យបិលិន្ទវច្ឆៈស្តាប់មុនសិន ទើបទ្រង់ត្រាស់ប្រាប់កម្មដ្ឋាន និងចរិយាវត្ត តម្រូវនឹងអធ្យាស្រ័យរបស់លោក ។ ព្រះបិលិន្ទវច្ឆត្ថេរ កាលបើរៀនគោលការណ៍បដិបត្តិពីព្រះសាស្តាហើយ បានប្រឹងប្រែងបំពេញសេចក្តីព្យាយាម ចម្រើនវិបស្សនាកម្មដ្ឋាន ដោយសេចក្តីមិនប្រមាទ មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្ត ក្នុងព្រះពុទ្ធសាសនាមួយអង្គផងដែរ ។

គ្រាមួយ ព្រះបិលិន្ទវច្ឆត្ថេរអង្គុយក្នុងចំណោមភិក្ខុសង្ឃ ហើយពិចារណាដល់គុណប្រយោជន៍ដ៏ធំមហាសាល ដែលលោកបានទទួលមក

នេះ និងពោលសរសើរផល ដែលបានសម្រេចដោយសេចក្តីព្យាយាមរបស់លោកហើយ ក៏ចូលទៅកាន់សម្នាក់របស់ព្រះបរមសាស្តា ដោយបំណងថា នឹងមករៀនវិជ្ជាមហាគន្ធារៈ ទើបពោលជាគាថា ថា ៖

ដំណើរនៃអាត្មាអញមកល្អហើយ មិនមែនប្រាសចាក ( បញ្ញា ) ទេ សេចក្តីគិតរបស់អាត្មាអញនោះ មិនមែនជាការគិតខុសទេ ព្រោះអាត្មាអញ បានសម្រេចគុណដ៏ប្រសើរនោះ ក្នុងធម៌ទាំងឡាយ ដែលព្រះមានព្រះភាគ ទ្រង់ចែកទុកហើយ ។

ការចារិកបិណ្ឌបាតក្នុងពេលព្រឹក របស់ភិក្ខុសង្ឃក្នុងព្រះពុទ្ធ-សាសនា ចាត់ជានិស្ស័យ គឺបច្ច័យគ្រឿងអាស្រ័យរបស់បព្វជិត ដែលរាប់ថាជាកិច្ចវត្តម្យ៉ាង និងការចារិកបិណ្ឌបាតមានប្រយោជន៍ច្រើនយ៉ាង ដូចដែលបានពោលទុកក្នុងគម្ពីរមិលិន្ទបញ្ហា មាន ១០ ប្រការគឺ ៖

១- ដើម្បីប្រោសវេនេយ្យសត្វ ( អ្នកដែលគួរណែនាំប្រៀនប្រដៅបាន ) ។

២- ដើម្បីដើរតាមស្នាមព្រះយុគលបាទនៃព្រះសម្ពុទ្ធ ។

៣- ដើម្បីបាននូវភត្តាហារមកដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។

៤- ដើម្បីគ្រប់គ្រងរាងកាយបែបអ្នកបួស ( ជាការដើរបញ្ចេញកម្លាំងកាយ ) ។

៥- ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនា ។

៦- ដើម្បីរក្សាធុតង្គវត្ត ។

៧- ដើម្បីការពាររោគបានខ្លះ ។

៨- ដើម្បីឲ្យដឹងពុទ្ធសាសនិកជនល្អ ។

៩- ដើម្បីរក្សាចរិយាវត្ត ( ទំនៀមដែលគួរប្រព្រឹត្ត ) ។

១០- ដើម្បីហ្វឹកហាត់កម្មដ្ឋាន ( ជាទីតាំងនៃការងារ សំដៅយកឧបាយផ្លូវចិត្ត ២ យ៉ាងគឺ សមថ: និងវិបស្សនា ) ។ ការចារិកបិណ្ឌ-បាតជាករណីយកិច្ចរបស់ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា គប្បីធ្វើជាប្រចាំរៀងរាល់ថ្ងៃ ។

ថ្ងៃមួយ ព្រះបិលិន្ទវច្ឆត្ថេរ បានចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បានឃើញបុរសម្នាក់បានដឹកផ្លែដីប៉ីពេញរទេះ ចូលទៅកាន់ក្រុងរាជគ្រឹះ ទើបសួរថា នែមនុស្សថោកទាប របស់អ្វីនៅក្នុងរទេះរបស់អ្នក ? បុរសនោះបានស្តាប់ព្រះថេរវាចាហើយ ក៏មិនពេញចិត្ត នឹកគិតថា សមណ:រូបនេះមានវាចាថោកទាបជាមួយនឹងយើង អំពីព្រឹកតែម្តង យើងនឹងឆ្លើយតប ឲ្យសមរម្យជាមួយនឹងពាក្យនិយាយរបស់សមណ:នេះ គិតដូច្នេះហើយ ទើបឆ្លើយថា បពិត្រលោកម្ចាស់ របស់ដែលមាននៅក្នុងរទេះរបស់ខ្ញុំព្រះករុណានោះ គឺជាអាចម៍កណ្តុរលោកម្ចាស់ ។ ព្រះបិលិ-ន្ទវច្ឆត្ថេរ បានពោលតាមពាក្យរបស់បុរសនោះថា វត្ថុនោះនឹងជាអាចម៍កណ្តុររបស់បុរសថោកទាបនេះចុះ ។

រឿងដែលគិតមិនដល់ ក៏កើតឡើងដល់បុរសនោះ ព្រោះនិយាយមិនពីរោះ ដោយខណៈដែលបុរសនោះទៅផុត អំពីខ្សែភ្នែករបស់ព្រះបិលិន្ទវច្ឆត្ថេរហើយ ផ្លែដីប៉ីទាំងអស់ដែលនៅក្នុងរទេះ ក៏ក្លាយជាអាចម៍កណ្ដុរទាំងអស់មួយរំពេចនោះឯង ។ ទើបបុរសនោះគិតថា ផ្លែដីប៉ីទាំងនេះក្លាយជាអាចម៍កណ្ដុរដោយហេតុអ្វីហ្ន៎ គិតហើយចាប់ឡើងមកញីមើលគ្រាន់តែដឹងថាជាអាចម៍កណ្ដុរ ក៏កើតទោមនស្សយ៉ាងខ្លាំង ទើបគិតថារឿងនេះមិនមែនអ្នកដទៃធ្វើឲ្យយើងទេ ប្រាកដជាភិក្ខុ ដែលយើងឃើញនិងនិយាយពាក្យថោកទាបជាមួយនឹងយើង កាលពីព្រឹកមិញនេះឯង ជាអ្នកធ្វើឲ្យដល់យើងយ៉ាងពិតប្រាកដ យើងនឹងទៅរកភិក្ខុរូបនោះ គិតដូច្នេះហើយ ក៏ប្រញាប់ទៅតាមព្រះបិលិន្ទវច្ឆត្ថេរ ។

គ្រានោះ មានបុរសម្នាក់ទៀត មើលឃើញបុរសម្ចាស់ដីប៉ីកំពុងដើរទៅដោយអាការខឹង ទើបស្រែកសួរថា នែបុរសដ៏ចម្រើន មានហេតុអ្វី ទើបអ្នកសម្ដែងកិរិយាខឹងសម្បាម្ល៉េះ ? បុរសម្ចាស់ផ្លែដីប៉ីប្រាប់ហេតុផលដល់បុរសអ្នកសួរនោះថា ព្រោះសមណៈរូបនោះ មានវាចាថោកទាបធ្វើឲ្យផ្លែដីប៉ីរបស់ខ្ញុំ បានក្លាយជាអាចម៍កណ្ដុរអស់ទៅ បុរសនោះប្រាប់ថាអ្នកដ៏ចម្រើន អ្នកកុំឆាកក្រោយ ប្រញាប់ត្រឡប់ទៅ ព្រោះភិក្ខុនោះមិនមែនលោកម្ចាស់ដទៃណាទេ ពិតជាព្រះបិលិន្ទវច្ឆត្ថេរ ព្រះថេរៈរបស់យើងនោះឯង កាលពន្យល់ឲ្យស្គាល់ព្រះថេរៈ ដែលមានវាចាដូច្នោះជាប្រក្រតីហើយ

ទើបណែនាំដើម្បីជួយឲ្យអាចម៍កណ្ដុរទាំងអស់ ក្លាយមក ជាផ្ទៃដីប៉្ហីវិញ ប្រាប់ថា ចូរអ្នកបររទេះទៅឈប់នៅខាងមុខនៃព្រះថេរៈ កាលបើព្រះថេរៈ សួរថា នុ៎ះអ្វីបុរសថោកទាប ? គប្បីឆ្លើយថា ជាផ្ទៃដីប៉្ហី វានឹងក្លាយជា សភាពដូចដើមវិញ ។

បុរសម្ចាស់ផ្ទៃដីប៉្ហី បានស្ដាប់ពាក្យណែនាំហើយ ក៏ធ្វើតាមការណែនាំនោះគ្រប់យ៉ាង ហើយអាចម៍កណ្ដុរនោះ ក៏ក្លាយជាផ្ទៃដីប៉្ហីជាប្រក្រតីវិញ ។ ព្រះថេរៈដែលជាប់វចីបយោគនិយាយថា បុរសថោកទាបៗ រហូតក្លាយជាទម្លាប់ មានសម្ដែងជាប្រវត្តិ នៃការសន្សំវចីបយោគនោះ ក្នុងអដ្ឋកថាមនោរថបូរណី និងក្នុងអដ្ឋកថាធម្មបទ នៃព្រាហ្មណវគ្គ និងគម្ពីរខុទ្ទកនិកាយឧទាន នន្ទវគ្គ បិលិន្ទវច្ឆសូត្រ មានសេចក្ដីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ តែងហៅរកភិក្ខុទាំងឡាយ ដោយពាក្យអសុរោះ ។ គ្រានោះពួកភិក្ខុច្រើនរូប បានចូលទៅគាល់ព្រះលោកនាថ លុះចូលទៅ ដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ហៅរកពួកភិក្ខុដោយពាក្យអសុរោះ ។ លំដាប់នោះ ព្រះជិនស្រី ទ្រង់ត្រាស់ហៅភិក្ខុមួយរូបមកថា

ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរហៅបិលិន្ទវច្ឆៈភិក្ខុមកតាមពាក្យតថាគតថា នែអាវុសោវច្ឆៈ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះបានទទួលព្រះពុទ្ធដីកានៃព្រះវិជិតមារថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកបិលិន្ទវច្ឆភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយប្រាប់បិលិន្ទវច្ឆៈដ៏មានអាយុដូច្នេះថា នែអាវុសោ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ បិលិន្ទវច្ឆៈដ៏មានអាយុទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមហាវីរៈ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះទសពល រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះបិលិន្ទវច្ឆៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះសយម្ភូទ្រង់ត្រាស់ថា ម្នាលបិលិន្ទវច្ឆៈ បានឮថា អ្នកហៅរកពួកភិក្ខុដោយពាក្យអសុរោះពិតមែនឬ ? បិលិន្ទវច្ឆៈបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនពិតមែន ។ លំដាប់នោះ ព្រះមហាមុនីទ្រង់ធ្វើទុកក្នុងព្រះទ័យនូវបុព្វនិវាសៈរបស់បិលិន្ទវច្ឆៈដ៏មានអាយុ ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំពោលទោសវច្ឆភិក្ខុឡើយ ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុ មិនមែនជាអ្នកមានទោសចិត្ត ហើយហៅរកពួកភិក្ខុដោយពាក្យអសុរោះទេ ម្នាលភិក្ខុទាំងឡាយ វច្ឆភិក្ខុធ្លាប់កើតក្នុងត្រកូលព្រាហ្មណ៍ ប្រឡំបល់គ្នាអស់ ៥០០ ជាតិមកហើយ វច្ឆភិក្ខុនោះធ្លាប់សន្ទនាពាក្យអសុរោះនោះ អស់កាលជាអង្វែងមកហើយ ហេតុនោះទើបវច្ឆភិក្ខុនេះ តែងហៅរកពួកភិក្ខុដោយពាក្យអសុរោះ ។ លុះព្រះភគវា

ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា ៖

មាយា ( ការបិទបាំងទោសខ្លួន ) និងមានះ ( សេចក្តីប្រកាន់ ) មិនប្រព្រឹត្តទៅ ក្នុងបុគ្គលណា ឬក៏បុគ្គលណា អស់សេចក្តីលោភ មិនប្រកាន់ថា របស់អញ មិនមានសេចក្តីប្រាថ្នា បន្ទោបង់សេចក្តីក្រោធ មានចិត្តត្រជាក់ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

តពីនេះនឹងពណ៌នាចំពោះពាក្យនិយាយថា មនុស្សថោកទាប ឲ្យជាក់ច្បាស់ តាមដែលព្រះលោកនាយក ទ្រង់ត្រាស់សម្តែងទុកក្នុងគម្ពីរខុទ្ទកនិកាយ សុត្តនិបាត ឧរគវគ្គ នៃវសលសូត្រ ថាមនុស្សថោកទាបនោះមាន ២០ ប្រការ ដោយសេចក្តីថា ៖

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់នៅក្នុងវត្តជេតពន ក្បែរក្រុងសាវត្ថី ។ គ្រានោះឯង ព្រះទសពលទ្រង់ស្បង់ ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ យាងទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ សម័យនោះឯង អគ្គិកភារទ្វាជព្រាហ្មណ៍ ( ព្រាហ្មណ៍ឈ្មោះភារទ្វាជៈ អ្នកបន្ទាត់ភ្លើង ) កំពុងបន្ទាត់ភ្លើង ផ្គូផ្គងគ្រឿងបូជាក្នុងលំនៅ ។ លំដាប់នោះ ព្រះសក្យមុនីត្រាច់ទៅកាន់លំដាប់ប្រកផ្ទះ ដើម្បីបិណ្ឌបាត ចៀងចូលទៅត្រង់លំនៅ របស់អគ្គិកភារទ្វាជៈ ។ អគ្គិកភារទ្វាជព្រាហ្មណ៍បាន

ឃើញព្រះវិជិតមារ យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទ្រគោះទៅរកព្រះជិនស្រីថា នែស្រមណ៍កំណោរ អ្នកចូរឈប់ក្នុងទីនេះសិន នែសមណៈ អ្នកចូរឈប់ក្នុងទីនេះសិន នែអ្នកថោកទាប អ្នកចូរឈប់ក្នុងទីនេះសិន ។

កាលដែលអគ្គិកភារទ្វាជៈ និយាយយ៉ាងនេះហើយ ព្រះមហាវីរៈត្រាស់តបនឹងអគ្គិកភារទ្វាជៈថា ម្នាលព្រាហ្មណ៍ អ្នកសម្គាល់បុគ្គលថោបទាប ឬធម៌ដែលធ្វើឲ្យថោកទាបដែរឬ ? បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំមិនទាន់ស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបទេ សូមព្រះគោតមដ៏ចម្រើន សម្ដែងធម៌ដែលជាហេតុឲ្យខ្ញុំ ស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបផង ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសម្ដែងប្រាប់ ។ គ្រានោះអគ្គិកភារទ្វាជៈទទួលស្ដាប់ព្រះលោកនាថថា ព្រះករុណាព្រះអង្គ ។ ព្រះសយម្ភូ ទ្រង់សម្ដែងសេចក្ដីនោះថា ៖

១. បុគ្គលណា មានសេចក្ដីក្រោធ ចងសេចក្ដីក្រោធទុក ( គំនុំ ) ជាបុគ្គលបាប លុបគុណគេ ប្រាសចាកសម្មាទិដ្ឋិ មានមាយា អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

២. បុគ្គលណា ក្នុងលោកនេះ បៀតបៀននូវសត្វដែលមានកំណើតម្ដង ( គឺសត្វដែលកើតអំពីញើសក្អែល អំពីទឹកសុកសម្ភៈ និង

ឧបបាតិកៈ ) ឬមានកំណើតពីរដង ( គឺសត្វដែលកើតអំពីពង មានមាន់ទាជាដើម ) ឬបុគ្គលណា មិនមានសេចក្ដីអាណិតចំពោះសត្វ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៣. បុគ្គលណា សម្លាប់ ឬឡោម រឹបជាន់នូវអ្នកស្រុក ឬអ្នកនិគម ដែលអ្នកផង ដឹងច្បាស់ថា ជាអ្នកសង្កត់សង្កិនគេ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៤. បុគ្គលណា កាន់យកទ្រព្យក្នុងស្រុក ឬក្នុងព្រៃ ដែលបុគ្គលប្រកាន់ថាជារបស់អញ ជាទ្រព្យដែលគេមិនបានឲ្យ ដោយអាការលួច អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៥. បុគ្គលណា បុលទ្រព្យគេ យកមកប្រើប្រាស់ ហើយគេចកែថា អញមិនជំពាក់បំណុលអ្នកទេ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៦. បុគ្គលណា សម្លាប់អ្នកផង ដែលដើរក្នុងផ្លូវ ដោយប្រាថ្នាទ្រព្យរបស់អ្នកណាមួយ ដណ្ដើមយកទ្រព្យរបស់អ្នកណាមួយ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៧. បុគ្គលណា គេសួរជាបន្ទាល់និយាយកុហក ព្រោះហេតុនៃខ្លួនក្ដី ព្រោះហេតុនៃបុគ្គលដទៃក្ដី ព្រោះហេតុនៃទ្រព្យក្ដី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៨. បុគ្គលណា ប្រព្រឹត្តខុសចំពោះប្រពន្ធ របស់ពួកញាតិ ឬសម្លាញ់ ដោយការកំហែង ឬដោយការស្រឡាញ់ ស្មគ្រចិត្ត អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

៩. បុគ្គលណា ជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹមមាតា ឬបិតាដែលចាស់ជរា មានវ័យកន្លងហើយ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១០. បុគ្គលណា ប្រហារមាតា ឬបិតា បងប្អូនប្រុស បងប្អូនស្រី ឬម្តាយក្មេក ឬក៏ជេរប្រទេចដោយវាចា អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១១. បុគ្គលណា កាលដែលគេសួរចំពោះហេតុមានប្រយោជន៍ ហើយពន្យល់ប្រាប់ហេតុ ដែលគ្មានប្រយោជន៍ បង្ហាញដោយពាក្យបិទបាំង អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១២. បុគ្គលណា ធ្វើបាបកម្ម ហើយប្រាថ្នាថា អ្នកផងកុំគប្បីដឹងនូវអញ បុគ្គលណា មានការងាបិទបាំង អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៣. បុគ្គលណា ទៅកាន់ត្រកូលញាតិមិត្តដទៃ ទាំងបានបរិភោគភោជនដ៏ស្អាត ហើយមិនបានបូជាគេដែលមកកាន់ផ្ទះរបស់ខ្លួនវិញ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៤. បុគ្គលណា បញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមឯទៀតក្តី ដោយពាក្យកុហក អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៥. បុគ្គលណា ជេរសមណៈ ឬព្រាហ្មណ៍ដោយវាចាក្តី មិនឲ្យភោជនក្នុងវេលាគត្តកាល ដែលគួរទំនុកបម្រុងក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៦. បុគ្គលណា ក្នុងលោកនេះ ត្រូវមោហៈរួបរឹតហើយ កាលស្វែងរកចំពោះទ្រព្យណាមួយ ក៏និយាយបោកប្រាសដោយពាក្យមិនពិត ( នឹងស្ត្រី ) អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៧. បុគ្គលណា លើកតម្កើងខ្លួនឯង ឬបណ្តុះបង្អាប់ពួកជនដទៃ តែខ្លួនជាអ្នកសាបសូន្យ ( ចាកគុណវុឌ្ឍិ ) ព្រោះការតម្កើង និងការបណ្តុះបង្អាប់របស់ខ្លួន អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៨. បុគ្គលណា កោងកាចក្តី ស្វិតរកទ្រឹស្តី មានសេចក្តីប្រាថ្នាអាក្រក់ក្តី កំណាញ់ក្តី អំណួតក្តី មិនអៀនខ្មាសក្តី មិនខ្លាចបាបក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

១៩. បុគ្គលណា ជេរប្រទេចព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ឬបរិព្វាជក ឬក៏គ្រហស្ថ អ្នកចូរដឹង ថាជាបុគ្គលថោកទាប ។

២០. បុគ្គលណា មិនមែនជាអរហន្តទេ តែប្តេជ្ញា ( ខ្លួន ) ថាជាអរហន្ត បុគ្គលនោះ ជាចោរក្នុងលោក ព្រមទាំងព្រហ្មលោក នេះឯងជា

បុគ្គលថោកទាបបំផុត ។

បុគ្គលថោកទាប ទាំងនេះឯង តថាគតបានប្រកាសហើយ បុគ្គលមិនមែនថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ព្រោះជាតិទេ បុគ្គលថោកទាប ព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្ម ។ អ្នកទាំងឡាយ ចូរដឹងនូវសេចក្តីនោះ ដោយពាក្យនេះចុះ ដូចឧទាហរណ៍នេះឯង កូនរបស់មនុស្សចណ្ឌាល មានឈ្មោះប្រាកដថា សោបាកមាតង្គៈ មាតង្គកុមារនោះ បាននូវយសដ៏ប្រសើរ ដែលគេបានដោយក្រក្រៃលែង ពួកក្សត្រព្រាហ្មណ៍ជាច្រើន តែងមកកាន់ទីបម្រើរបស់កុមារនោះ ។ មាតង្គកុមារនោះ ឡើងកាន់យាន គឺសមាបត្តិ ៨ អាចឲ្យទៅកាន់ទេវលោក ប្រាសធូលី គឺកិលេស ជាផ្លូវធំ នឿយណាយនឹងកាមរាគៈ ហើយទៅកើតក្នុងព្រហ្មលោក ។ ជាតិមិនមែនឃាត់មាតង្គៈនោះ ចាកការកើតក្នុងព្រហ្មលោកទេ ។ ពួកព្រាហ្មណ៍ជាផៅពង្សព្រោះមន្ត កើតក្នុងត្រកូលអ្នករៀនមន្ត ពួកព្រាហ្មណ៍ទាំងនោះ រមែងប្រាកដក្នុងបាបកម្មទាំងឡាយរឿយៗ ទុគ្គតិដែលអ្នកផងគួរតិះដៀល ក្នុងបច្ចុប្បន្នក៏មាន ក្នុងបរលោកក៏មាន ( ព្រោះបាបកម្មជាបច្ច័យ ) ។ ជាតិមិនមែនឃាត់ពួកព្រាហ្មណ៍ទាំងនោះចាកទុគ្គតិ ឬចាកការតិះដៀលទេ ។ បុគ្គលមិនមែនថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ ព្រោះជាតិទេ បុគ្គលថោកទាប ព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្មដែរ ។

ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អគ្គិកភារទ្វាជព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះទសពលដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះសម្មាទ្ធដ៏ចម្រើន ភ្លឺច្បាស់ណាស់ ធម៌ដែលព្រះភគវាដ៏ចម្រើន ទ្រង់សម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចគេផ្ងារនូវរបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញ របស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចគេបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះសក្យមុនីដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ សូមព្រះជិនស្រីដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះទៅ ។

ព្រះបិលិន្ទវច្ឆត្ថេរ មិនត្រឹមតែលើកទោសដោយសារវាចាប៉ុណ្ណោះទេ នៅមានរឿងមួយទៀត តាមដែលមានសម្តែងទុកក្នុងគម្ពីរមហាវិភង្គ វិន័យបិដក ថា ៖

គ្រាមួយ ត្រកូលឧបដ្ឋាករបស់លោក ត្រូវពពួកចោរប្លន់ ចាប់យកទារកពីរនាក់ទៅ ។ ព្រះបិលិន្ទវច្ឆត្ថេរ លោកដឹងរឿងនោះហើយ ដោយប្រាថ្នានឹងសម្តែងកតញ្ញូតាធម៌ ចំពោះត្រកូលឧបដ្ឋាករបស់លោក ទើបសម្តែងឫទ្ធិទៅនាំយកទារកទាំងពីរនាក់នោះត្រឡប់មកវិញ ដោយទុកត្រង់ប្រាសាទត្រកូលរបស់ខ្លួន ថែមទាំងមិនមានអន្តរាយអ្វីបន្តិចបន្តួច

ឡើយ ។ កាលបើបុគ្គលទាំងឡាយ បានឃើញទារកទាំងពីរនាក់នោះ ត្រឡប់មកវិញហើយ ដោយអំណាចឫទ្ធិរបស់ព្រះថេរៈដ៏អស្ចារ្យ ដែលអាចនាំយកទារកមកវិញបាន ក៏មានសេចក្តីជ្រះថ្លា ចំពោះព្រះថេរៈយ៉ាងក្រៃលែង ។ រឿងនោះក៏ផ្សព្វផ្សាយទៅដល់ភិក្ខុទាំងឡាយ ភិក្ខុដែលមិនជ្រាបរឿងខាងដើម និងខាងចុង ក៏នាំគ្នាពោលទោសតិះដៀលថា ហេតុអ្វីបានជាព្រះបិលិន្ទវច្ឆៈសម្តែងឫទ្ធិទៅនាំយកទារកទាំងពីរនាក់ ដែលពពួកចោរនាំយកទៅហើយនាំយកត្រឡប់មកវិញ ភិក្ខុទាំងនោះក៏បានក្រាបទូលសេចក្តីនេះចំពោះព្រះមានព្រះភាគ ឲ្យព្រះអង្គទ្រង់វិនិច្ឆ័យ ការធ្វើរបស់ព្រះបិលិន្ទវច្ឆត្ថេរថា តើខុសព្រះវិន័យ ត្រង់សិក្ខាបទណាដែរឬដែរទេ ? ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការត្រូវអាបត្តិ រមែងមិនមានដល់អ្នកមានឫទ្ធិ និងឥទ្ធិវិស័យឡើយ ។ ប្រការដែលថា ព្រះបិលិន្ទវច្ឆត្ថេរ មិនខុសព្រះវិន័យ ក្នុងការនាំយកទារកទាំងពីរនាក់នោះ ដែលចោរចាប់យកទៅហើយនោះ យកត្រឡប់មកវិញបានដោយអំណាចឥទ្ធិឫទ្ធិមិនដូចគ្នា កាលដែលភិក្ខុនាំយកវត្ថុដែលចោរលួចយកទៅហើយ យកត្រឡប់មកវិញ ដោយអាការធម្មតា ប្រសិនបើភិក្ខុនាំយកវត្ថុដែលចោរលួចទៅហើយ យកត្រឡប់មកវិញ ជាការខុសចំពោះព្រះវិន័យ ត្រូវបានទទួលទោសតាមអាបត្តិ (អាបត្តិ ប្រែថា ការត្រូវ សំដៅដល់ទោសដែលកើតអំពីការល្មើសបំពានសិក្ខាបទ) ។

ព្រះបិលិន្ទវច្ឆត្ថេរ ជាភិក្ខុអ្នកចម្រើន និងដឹងបូរណបដិសន្ថរណៈ គឺជួសជុល ធ្វើឲ្យល្អត្រឡប់ឡើងវិញដូចដើម ឬជួសជុលស្ថានទីឲ្យជាប្រយោជន៍រួម ដូចមានរឿងចារឹកទុកក្នុងបាលីភេសជ្ជក្ខន្ធកៈ គម្ពីរមហាវគ្គ ព្រះវិន័យបិដក ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុឲ្យគេជម្រះញកភ្នំក្បែរក្រុងរាជគ្រឹះ ប្រាថ្នានឹងធ្វើទីពួន ឬទីជ្រកកោន ។ គ្រានោះព្រះបាទមាគធសេនិយពិម្ពិសារយាងចូលទៅកាន់លំនៅព្រះបិលិន្ទវច្ឆៈដ៏មានអាយុ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆៈដ៏មានអាយុ រួចគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទមាគធសេនិយពិម្ពិសារគង់ក្នុងទីដ៏សមគួរហើយក៏ទ្រង់មានព្រះរាជឱង្ការនេះនឹងព្រះបិលិន្ទវច្ឆៈដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះថេរៈប្រើឲ្យគេធ្វើអ្វី ? ព្រះបិលិន្ទវច្ឆៈឆ្លើយថា បពិត្រមហារាជ អាត្មាភាពឲ្យគេជម្រះញកភ្នំ ប្រាថ្នានឹងធ្វើទីពួន ឬទីជ្រកកោន ។ ស្តេចសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មានសេចក្តីត្រូវការដោយអារាមិកជនដែរឬ ? ព្រះបិលិន្ទវច្ឆៈឆ្លើយថា បពិត្រមហារាជ ព្រះដ៏មានបុណ្យ មិនទាន់អនុញ្ញាតអារាមិកជននៅឡើយទេ ។ ស្តេចទ្រង់មានព្រះរាជឱង្ការថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ គួរលោកម្ចាស់ក្រាបទូលសួរព្រះមានព្រះភាគហើយមកប្រាប់ខ្ញុំវិញ ។ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុទទួលស្តាប់ព្រះរាជឱង្ការ នៃព្រះបាទពិម្ពិសារ ដោយពាក្យថា

សូមថ្វាយព្រះពរមហារាជ ។ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ក៏បានពន្យល់ព្រះបាទពិម្ពិសារឲ្យទ្រង់ឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ានឲ្យត្រេកអរ ដោយពាក្យដ៏ប្រកបដោយធម៌ ។

លំដាប់នោះ ព្រះបាទពិម្ពិសារ កាលដែលព្រះបិលិន្ទវច្ឆៈដ៏មានអាយុបានពន្យល់ឲ្យទ្រង់ឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យត្រេកអរ ដោយពាក្យប្រកបដោយធម៌ហើយ ក៏ទ្រង់ក្រោកចាកអាសនៈថ្វាយបង្គំព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ធ្វើប្រទក្សិណហើយចៀសចេញទៅ។ ក្រោយពីនោះមក ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ បានប្រើបម្រើឲ្យទៅកាន់សម្នាក់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទពិម្ពិសារទ្រង់មានសេចក្តីប្រាថ្នានឹងប្រគេនអារាមិកជន តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេចទៅ ? ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅពួកភិក្ខុមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលអារាមិកជន ។ ព្រះបាទពិម្ពិសារ ទ្រង់ចូលទៅកាន់លំនៅព្រះបិលិន្ទវច្ឆៈដ៏មានអាយុជាគម្រប់ពីរដង លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆៈ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទពិម្ពិសារ ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ក៏ទ្រង់មានព្រះរាជឱង្ការដូច្នេះនឹងព្រះបិលិន្ទវច្ឆៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះដ៏មានបុណ្យទ្រង់បានអនុញ្ញាតអារាមិកជនហើយឬ ?

ព្រះបិលិន្ទវច្ឆៈឆ្លើយថា ថ្វាយព្រះពរមហារាជ ។ ព្រះបាទពិម្ពិសារទ្រង់មានព្រះរាជឱង្ការថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ ខ្ញុំព្រះករុណានឹងប្រគេនអារាមិកជនដល់លោកម្ចាស់ ។ គ្រានោះឯង ព្រះបាទពិម្ពិសារទទួលថា នឹងប្រគេនអារាមិកជនដល់ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ហើយក៏ទ្រង់ភ្លេចទៅ លុះយូរមកទើបបានទ្រង់រឭកឃើញ ក៏មានព្រះរាជឱង្ការហៅមហាមាត្យម្នាក់ ជាអ្នកសម្រេចរាជការទាំងពួងថា ម្នាលនាយ អារាមិកជនណាដែលអញទទួលថា នឹងប្រគេនដល់លោកម្ចាស់នោះ តើអញបានប្រគេនហើយឬនៅ ?

មហាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គមិនទាន់បានប្រគេនអារាមិកជនដល់លោកម្ចាស់នៅឡើយទេ ។ ព្រះបាទពិម្ពិសារទ្រង់សួរថា ម្នាលនាយ តាំងពីថ្ងៃនោះមកដល់ឥឡូវនេះ តើយូរប៉ុន្មានរាត្រីហើយ ? មហាមាត្យនោះបានរាប់រាត្រីទាំងឡាយ ឃើញហើយក៏ក្រាបបង្គំទូលព្រះបាទពិម្ពិសារក្នុងពេលនោះដូច្នេះថា បពិត្រព្រះសម្មតិទេព បើគិតតាំងពីថ្ងៃនោះមកដល់ថ្ងៃនេះ ចំនួនប្រាំរយរាត្រីហើយ ស្តេចទ្រង់មានព្រះរាជឱង្ការថា ម្នាលនាយ បើដូច្នោះ ចូរអ្នកឯងប្រគេនអារាមិកជនប្រាំរយនាក់ដល់លោកម្ចាស់ចុះ ។ មហាមាត្យនោះ ទទួលស្តាប់ព្រះរាជឱង្ការព្រះបាទពិម្ពិសារដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយក៏ប្រគេនអារាមិកជនប្រាំរយនាក់ ដល់ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ។ ចាប់

តាំងពីថ្ងៃនោះមក ស្រុកនោះក៏តាំងនៅជាស្រុកមួយដោយឡែក ។ ពួកជនក៏ហៅស្រុកនោះថា អារាមិកគ្រាមខ្លះ បិលិន្ទវច្ឆគ្រាមខ្លះ ។

សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុជាជីតុនក្នុងស្រុកនោះ គ្រានោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុស្លៀកស្បង់អំពីព្រឹកហើយប្រដាប់ដោយបាត្រ និងចីវរចូលទៅកាន់បិលិន្ទវច្ឆគ្រាមដើម្បីបិណ្ឌបាត ។ សម័យនោះឯង ក្នុងស្រុកនោះមានល្បែងមហោស្រព ។ ពួកទារកក៏បានប្រដាប់ខ្លួនស្អិតស្អាង ដោយកម្រងផ្កាដើម្បីលែងមហោស្រព ។ ក្នុងពេលនោះ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ បានត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ក្នុងបិលិន្ទវច្ឆគ្រាម ហើយចូលទៅកាន់ផ្ទះអារាមិកជនម្នាក់ លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលគេក្រាលប្រគេន ។ គ្រានោះ ធីតារបស់ប្រពន្ធអារាមិកជននោះ ឃើញពួកទារកដទៃប្រដាប់ខ្លួនស្អិតស្អាងដោយកម្រងផ្កា ក៏យំទារថា អ្នកម៉ែ ចូរឲ្យកម្រងផ្កាដល់ខ្ញុំ អ្នកម៉ែ ចូរឲ្យគ្រឿងប្រដាប់ដល់ខ្ញុំ ។ ក្នុងពេលនោះ ព្រះបិលិន្ទវច្ឆៈបានពោលពាក្យនេះនឹងប្រពន្ធរបស់អារាមិកជននោះថា ព្រោះហេតុអ្វីបានជាទារិកានេះយំ? ប្រពន្ធអារាមិកជននោះឆ្លើយថា បពិត្រលោកម្ចាស់ ទារិកានេះឃើញពួកទារកដទៃប្រដាប់ខ្លួនស្អិតស្អាងដោយកម្រងផ្កា ក៏យំទារថា អ្នកម៉ែ ចូរឲ្យកម្រងផ្កាដល់ខ្ញុំ អ្នកម៉ែ ចូរឲ្យគ្រឿងប្រដាប់ដល់ខ្ញុំដូច្នេះ ឯយើងខ្ញុំទាំង-ឡាយ ជាអ្នកក្រក្សត់នឹងបានកម្រងផ្កានោះមកពីណា ។ នឹងបានគ្រឿង

ប្រដាប់មកពីណា ។ គ្រានោះឯង ព្រះបិលិន្ទវច្ឆៈបានចាប់យករង្វេលស្មៅមួយ ហើយនិយាយនឹងប្រពន្ធអារាមិកជននោះដូច្នេះថា បើដូច្នោះមានតែនាងចូរ បំពាក់រង្វេលស្មៅនេះលើក្បាលទារិកានោះចុះ ។ ទើបប្រពន្ធអារាមិកជននោះ ចាប់យករង្វេលស្មៅនោះ ហើយបំពាក់លើក្បាលទារិកានោះ ។ រង្វេលស្មៅនោះ ក៏ក្លាយទៅជាកម្រងផ្កាមាសល្អល្អះ គួរពិតពិលរមិលមើល ជាទីនាំឲ្យកើតសេចក្ដីជ្រះថ្លា ។ សូម្បីនៅខាងក្នុងព្រះរាជវាំង ក៏រកកម្រងផ្កាមាសបែបនោះគ្មាន ។ ពួកមនុស្សក៏ក្រាបបង្គំទូលព្រះបាទពិម្ពិសារថា បពិត្រព្រះសម្មតិទេព ក្នុងផ្ទះអារាមិកជនឯណោះមានកម្រងផ្កាមាសល្អល្អះ គួរពិតពិលរមិលមើល ជាទីនាំឲ្យកើតសេចក្ដីជ្រះថ្លា សូម្បីខាងក្នុងវាំងរបស់ព្រះករុណា ក៏រកកម្រងផ្កាមាសបែបនោះគ្មានដែរ អារាមិកជននោះជាអ្នកក្រក្សត់ទេ នឹងមានកម្រងផ្កាមាសពីណាប្រាកដជាវាលួចគេមិនខានឡើយ ។ ក្នុងវេលានោះ ព្រះបាទពិម្ពិសារទ្រង់ប្រើមនុស្សឲ្យទៅចាប់ចង ត្រកូលអារាមិកជននោះ ។

លុះព្រឹកព្រហាមឡើង ជាថ្ងៃគម្រប់ពីរ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ហើយក៏ចូលទៅបិណ្ឌបាតឯបិលិន្ទវច្ឆគ្រាម កាលបើត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ក្នុងបិលិន្ទ-វច្ឆគ្រាម ហើយក៏ចូលទៅរកផ្ទះអារាមិកជននោះ លុះចូលទៅដល់ហើយក៏សួរពួកមនុស្សដែលនៅជិតខាងថា តើត្រកូលអារាមិកជននោះទៅណា ។

ពួកមនុស្សដែលនៅជិតខាងឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ត្រកូលអារាមិកជន ស្ដេចឲ្យចាប់ចងអស់ទៅហើយ ព្រោះហេតុតែកម្រងផ្កាមាសដែលលោកម្ចាស់ឲ្យទៅនុ៎ះ ។ ឯព្រះបិលិន្ទវច្ឆៈ ក៏ចូលទៅកាន់ព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលប្រគេន គ្រានោះ ព្រះបាទពិម្ពិសារក៏ចូលមករកព្រះបិលិន្ទវច្ឆៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះបាទពិម្ពិសារគង់ក្នុងទីដ៏សមគួរហើយ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ បានថ្វាយព្រះពរដូច្នេះថា បពិត្រមហារាជ ហេតុអ្វីបានជា ព្រះអង្គឲ្យគេចាប់ចងត្រកូលអារាមិកជនមក ។ ព្រះបាទពិម្ពិសារឆ្លើយថា បពិត្រលោកម្ចាស់ ព្រោះក្នុងផ្ទះអារាមិកជននោះមានកម្រងផ្កាមាសល្អល្អះ គួរពិតពិលរមិលមើលជាទីនាំឲ្យកើតសេចក្ដីជ្រះថ្លា សូម្បីនៅខាងក្នុងរាជវាំងរបស់ខ្ញុំ ក៏រកកម្រងផ្កាបែបនោះគ្មានដែរ អារាមិកជននោះជាមនុស្សក្រីក្រត់ទេ នឹងមានកម្រងផ្កាមាសពីណា ប្រាកដជាវាលួចគេមកមិនខានឡើយ ។ គ្រានោះ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ បានអធិដ្ឋានប្រាសាទរបស់ព្រះបាទពិម្ពិសារ ឲ្យទៅជាមាសមួយរំពេច ។ ប្រាសាទនោះក៏ក្លាយទៅជាមាសសុទ្ធ ។ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុថ្វាយព្រះពរ សួរថា បពិត្រមហារាជ មាសច្រើនម្ល៉េះ តើព្រះអង្គបានមកពីណា ? ព្រះបាទពិម្ពិសារឆ្លើយថា បពិត្រលោក

ម្ចាស់ដ៏ចម្រើន មាសនេះខ្ញុំដឹងហើយ នេះជាឥទ្ធានុភាពរបស់លោកម្ចាស់ទេតើ មានបន្ទូលដូច្នេះហើយ ក៏ឲ្យគេដោះលែង ត្រកូលអារាមិកជននោះទៅ ។ ពួកមនុស្សបានឮដំណឹងថា ព្រះបិលិន្ទវច្ឆៈដ៏មានអាយុសម្តែងឥទ្ធិបាដិហារ្យ ជាឧត្តរិមនុស្សធម្មដល់បរិស័ទ ព្រមទាំងស្តេចហើយ ក៏មានចិត្តត្រេកអរជ្រះថ្លា នាំគ្នាយកភេសជ្ជៈទាំង ៥ គឺ ទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ស្ករអំពៅ ១ មកប្រគេនព្រះបិលិន្ទវច្ឆៈដ៏មានអាយុ ។ ឯព្រះបិលិន្ទវច្ឆៈបានលាភមកហើយ ក៏តែងចាត់ចែងបណ្តាភេសជ្ជៈទាំង ៥ ប្រភេទណាមួយដែលលោកបានមកនោះ ឲ្យដល់បរិស័ទជាធម្មតា ។ ចំណែកបរិស័ទរបស់លោកនោះ ជាមនុស្សល្មោភច្រើន តែងយកភេសជ្ជៈទាំងអម្បាលម៉ានដែលខ្លួនបានមកៗ ទុក ដាក់ពេញថ្លាងខ្លះពេញក្អមខ្លះ ពេញសំពត់តម្រងទឹកខ្លះ ពេញថង់ខ្លះ ហើយព្យួរទុកតាមបង្អួច ។ ភេសជ្ជៈទាំងនោះហៀរហូរកំពប់ខ្ចាត់ខ្ចាយ ។ កុដិក៏ដេរដាសដោយពួកកណ្តុរ ពួកមនុស្សដើរទៅកាន់វិហារបានឃើញហើយ ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រនេះ មានរបស់ទុកដាក់ក្នុងឃ្លាំង ដូចជាព្រះបាទពិម្ពិសារដែរ ។

ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុមិនគួរនឹងមកសន្សំភេសជ្ជៈ ដោយ

សេចក្ដីល្មោភច្រើនបែបដូច្នេះសោះ ។ ទើបភិក្ខុទាំងនោះ ក្រាបបង្គំទូល សេចក្ដីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាល ភិក្ខុទាំងឡាយ ឮថាពួកភិក្ខុសន្សំភេសជ្ជៈដោយសេចក្ដីល្មោភច្រើន បែប ដូច្នេះ ពិតមែនឬ ? ពួកភិក្ខុក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិត មែន ។ ព្រះសម្ពុទ្ធទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុ ទាំងឡាយមកថា ភេសជ្ជៈទាំងឡាយណាដែលពួកភិក្ខុមានជម្ងឺគប្បីលិទ្ធ ភ្លក្សឆាន់បាន គឺទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ស្ករអំពៅ ១ ភិក្ខុទទួលភេសជ្ជៈទាំងនោះហើយ ត្រូវទុកដាក់ឆាន់បាន កំណត់ត្រឹម ៧ ថ្ងៃ យ៉ាងយូរបំផុត បើភិក្ខុទុកភេសជ្ជៈទាំងនោះឲ្យកន្លង ហួសពីកំណត់នោះទៅ ត្រូវវិន័យធរឲ្យភិក្ខុនោះធ្វើតាមធម៌ ។

មនុស្សយើងគ្រប់គ្នា ទាំងគ្រហស្ថ ឬបព្វជិត ដែលថាមិនមានរោគ យ៉ាងណានីមួយកើតឡើងគ្មានទេ ក្នុងពេលណាក៏មិនដឹង មើលតួយ៉ាង នៃព្រះបិលិន្ទវច្ឆត្ថេរលោកមានអាពាធរោគខ្យល់ ដូចមានរឿងចារឹកទុក ក្នុងបាលីភេសជ្ជក្ខន្ធកៈ គម្ពីរមហាវគ្គព្រះវិន័យបិដក មានសេចក្ដីថា ៖

សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ លោកអាពាធកើតអំពី ខ្យល់ ។ ពេទ្យទាំងឡាយនិយាយយ៉ាងនេះថា ភិក្ខុត្រូវស្ងោប្រេង ។ ពួក ភិក្ខុក្រាបទូលសេចក្ដីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុស្ងោប្រេងបាន ។ ភិក្ខុ

ទាំងឡាយក៏លាយទឹកស្រវឹងក្នុងប្រេងដែលស្ងោនោះ ។ ពួកភិក្ខុក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា តថាគតអនុញ្ញាតឲ្យភិក្ខុលាយទឹកស្រវឹងក្នុងប្រេងដែលស្ងោបាន ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុ មានប្រេងដែលស្ងោហើយជាច្រើន ។ តែគ្មានភាជនៈសម្រាប់ដាក់ប្រេង ។ ពួកភិក្ខុក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវតុម្ព គឺកុណ្ឌីទឹកទាំង ៣ យ៉ាង គឺតុម្ពធ្វើដោយទង់ដែង ១ តុម្ពធ្វើដោយឈើ ១ តុម្ពធ្វើដោយផ្លែឈើ ១ ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆៈកើតរោគខ្យល់ក្នុងអវយវៈ ។ ភិក្ខុក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេទកម្ម ការធ្វើឲ្យចេញញើស ។ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុក៏នៅតែអត់ទ្រាំមិនបាន ។ ពួកភិក្ខុក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្មងដោយស្លឹកឈើ និងមែកឈើផ្សេងៗ ។ ព្រះបិលិន្ទវច្ឆៈនៅតែអត់ទ្រាំមិនបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្មងធំ ។ ព្រះបិលិន្ទវច្ឆៈក៏នៅតែអត់ទ្រាំមិនបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកដែលគេស្ងោរលាយនឹងឈើ មែកឈើផ្សេងៗ ។ ព្រះបិលិន្ទវច្ឆៈដ៏មានអាយុក៏នៅតែអត់ទ្រាំ

មិនបាន ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបន្ទប់ទឹក ។ ( ត្រូវដាក់ទឹកក្តៅឲ្យពេញក្នុងភាជនៈហើយ ចូលទៅធ្វើការផ្តួងក្នុងបន្ទប់ទឹកនោះ ) ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆត្ថេរលោកកើតរោគខ្យល់ចុកសៀតក្នុងសន្លាក់ដៃជើងជាដើម ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនោះចំពោះព្រះមុនី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើឈាមឲ្យហូរចេញបាន ។ ព្រះបិលិន្ទវច្ឆៈក៏នៅតែអត់ទ្រាំមិនបាន ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនោះចំពោះព្រះភគវា ។ ព្រះអង្គទ្រង់ត្រាស់ថា តថាគតអនុញ្ញាតឲ្យភិក្ខុជប់យកឈាមដោយបំពង់ស្នែងបាន ។ សម័យនោះឯង ព្រះបិលិន្ទវច្ឆៈដ៏មានអាយុមានបាទាប្រេះ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនោះចំពោះព្រះភគវា ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្នាំសម្រាប់លាបជើង ។ ព្រះបិលិន្ទវច្ឆៈ ក៏នៅតែអត់ទ្រាំមិនបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុតាក់តែងទឹកស្រវឹងសម្រាប់លាបជើងឲ្យស្រួលបាន ។ នេះជាព្រះពុទ្ធានុញ្ញាត ដែលព្រះអង្គទ្រង់ព្រះករុណាដល់ព្រះបិលិន្ទវច្ឆៈ ដែលលោកកើតអាពាធ និងជាតួយ៉ាងសម្រាប់ភិក្ខុអង្គដទៃ កាលបើមានអាពាធកើតឡើងហើយ ក៏មិនចាំបាច់ក្រាបទូលសូមពុទ្ធានុញ្ញាតទៀតឡើយ អាចនឹងធ្វើថ្នាំផ្សេងៗ ប្រើបាន ។

ព្រះបិលិន្ទវច្ឆត្ថេរ បានទទួលការលើកតម្កើងឲ្យជាឯតទគ្គៈ គឺ

ប្រសើរជាងភិក្ខុទាំងឡាយ ដែលទេវតាស្រឡាញ់ ដូចមានប្រាកដនៅក្នុង គម្ពីរអង្គុត្តរនិកាយ ឯកនិបាត មានន័យថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ** ម្នាលភិក្ខុទាំងឡាយ បិលិន្ទវច្ឆៈប្រសើរជាងភិក្ខុ ទាំងឡាយ ជាសាវករបស់តថាគត ផ្នែកខាងជាទីស្រឡាញ់ពេញចិត្ត របស់ទេវតាទាំងឡាយ ដូច្នេះ ។

មូលហេតុដែលព្រះបិលិន្ទវច្ឆត្ថេរ នឹងបានមកបព្វជ្ជាឧបសម្បទា ជាភិក្ខុក្នុងព្រះពុទ្ធសាសនា នឹងបានសម្រេចជាព្រះអរហន្តហើយ ចាត់ ចូលក្នុងចំណោមអសីតិមហាសាវក គឺសាវកធំរបស់ព្រះពុទ្ធជាម្ចាស់ ៨០ រូប ថែមទាំងជាអ្នកបានទទួលការលើកតម្កើង ដ៏ប្រសើរបំផុតមួយរូបក្នុង ព្រះពុទ្ធសាសនានេះ ព្រោះលោកធ្លាប់កសាងសន្សំបុណ្យបារមីរួចមក ហើយ តាំងអំពីអតីតកាល ដូចមានរឿងជីវប្រវត្តិអតីតជាតិរបស់លោក មានសម្តែងប្រាកដនៅក្នុង អដ្ឋកថាមនោរថបូរណីថា ៖

ក្នុងពុទ្ធសម័យរបស់ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ព្រះបិលិន្ទវច្ឆត្ថេរ បានកើតនៅក្នុងត្រកូលដែលមានទ្រព្យសម្បត្តិច្រើន ក្នុងនគរហង្សវតី ។ ថ្ងៃមួយ កុលបុត្រនោះ បានចូលទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្ពុទ្ធ បទុមុត្តរៈ ក៏បានឃើញព្រះអង្គប្រកាសតែងតាំងភិក្ខុមួយរូបទុកក្នុងតំណែង ឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវករបស់ព្រះអង្គ

ផ្នែកខាងជាទីស្រឡាញ់ពេញចិត្តនៃទេវតាទាំងឡាយ ក៏កើតការពេញចិត្ត ក្នុងតំណែងនោះ ទើបបានធ្វើបុណ្យកុសលចំពោះព្រះបទុមុត្តរៈ ហើយ ក៏តាំងសេចក្តីប្រាថ្នាឲ្យបានតំណែងនោះ ចំពោះព្រះភក្ត្រព្រះបទុមុត្តរៈ ក៏ បានទទួលការព្យាករណ៍ថា នឹងបានសម្រេចតាមសេចក្តីប្រាថ្នានោះរួចមក ហើយ កុលបុត្រនោះមិនឈប់ឈរក្នុងការធ្វើសេចក្តីល្អឡើយ ព្យាយាម បំពេញបុណ្យកុសលផ្សេងៗ រហូតអស់ជីវិត ។

កាលបើអស់ជីវិតទៅហើយ ក៏បានត្រាច់រង្គាត់ក្នុងមនុស្ស ទេវតា អស់កាលដ៏យូរអង្វែង ចំណែករឿងអតីតជាតិរបស់ព្រះបិលិន្ទវច្ឆៈមាន សម្តែងនៅក្នុងគម្ពីរខុទ្ទកនិកាយ អបទាន ក្នុងបិលិន្ទវគ្គ ដូចមានន័យថា ៖

ខ្ញុំជាឆ្មាំទ្វារ ក្នុងនគរហង្សវតី ខ្ញុំសន្សំភោគសម្បត្តិជាអក្ខោភិនី រាប់ មិនបានទុកក្នុងផ្ទះ ។ ក្នុងកាលនោះ ខ្ញុំទៅអង្គុយក្នុងទីស្ងាត់ ហើយញុំាង ចិត្តឲ្យរីករាយ គឺអង្គុយក្នុងប្រាសាទដ៏ប្រសើរ ហើយគិតយ៉ាងនេះថា ភោគសម្បត្តិរបស់អញមានច្រើន ទីខាងក្នុងបុរីរបស់អញក៏ធំទូលាយ សូម្បី ព្រះរាជាព្រះនាមអានន្ទ ជាធំលើផែនដី ក៏ទ្រង់ហៅរកអញ ។ ព្រះពុទ្ធ នេះជាមុនី កើតឡើងព្រោះអាស្រ័យហេតុ ក៏កើតឡើងហើយ ទាំងភោគ-សម្បត្តិរបស់អញក៏មាន អញនឹងថ្វាយទានចំពោះព្រះសាស្តា វត្ថុទានដ៏ ប្រសើរ គឺបង្អែកក្នុងបល្ល័ង្កលើដំរី និងវត្ថុមានចំនួនច្រើន ព្រះអង្គម្ចាស់ ព្រះនាមបទុមៈ បានថ្វាយចំពោះព្រះពុទ្ធជិនស្រី ។ ឯអញនឹងថ្វាយទាន

ចំពោះព្រះសង្ឃជាពួកដ៏ប្រសើរខ្ពង់ខ្ពស់ ព្រោះទានដ៏ប្រសើរ អញមិនធ្លាប់ថ្វាយឡើយ អញជាអាទិកម្មិកបុគ្គល ។ សេចក្តីសុខជាផលនៃអំពើណា ក្នុងការបូជា អញនឹងគិតនូវអំពើនោះឲ្យច្រើន អញបានឃើញបរិក្ខារទាន ជាទីញ៉ាំងសេចក្តីត្រិះរិះ របស់អញឲ្យពេញ ។ អញនឹងឲ្យនូវបរិក្ខារចំពោះព្រះសង្ឃ ជាពួកដ៏ប្រសើរខ្ពង់ខ្ពស់ ( ព្រោះថា ) អញមិនដែលឲ្យទានដល់ពួកជនដទៃសោះ អញជាអាទិកម្មិកបុគ្គល ។

ខណៈនោះ ខ្ញុំចូលទៅរកពួកជាងត្បាញផែង ហើយឲ្យធ្វើឆត្ររួចឲ្យគេប្រមូលឆត្រមួយសែនទុកក្នុងទីមួយ ។ ឲ្យគេប្រមូលសំពត់មួយសែនទុកក្នុងទីមួយ ឲ្យគេប្រមូលបាត្រមួយសែនទុកក្នុងទីមួយ ។ ខ្ញុំឲ្យគេធ្វើកាំបិតព្រា កាំបិតកោរ ម្ជុល និងកាំបិតកាត់ក្រចកឲ្យសមគួរដល់វត្ថុនោះ ហើយឲ្យគេទុកក្នុងទីខាងក្រោមឆត្រ ។ ខ្ញុំឲ្យគេធ្វើផ្លិតស្លឹកត្នោតផ្លិតស្លាបក្ងោក ផ្លិតរោមកន្ទុយចាមរី តម្រងទឹក និងវត្ថុសម្រាប់ទ្រប្រេងឲ្យសមគួរដល់ វត្ថុនោះ ខ្ញុំឲ្យគេធ្វើបំពង់ម្ជុល ខ្សែអាយោគ វត្ថុពន្ធចង្កេះ និងជើងបាត្រ ដែលធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។

ខ្ញុំបានញ៉ាំងភេសជ្ជៈទាំងឡាយ ឲ្យពេញក្នុងភេសជ្ជៈសម្រាប់បរិភោគ និងក្នុងផ្តិលលោហៈ ហើយទុកក្នុងទីខាងក្រោមឆត្រ ។ ខ្ញុំបានញ៉ាំងកាដទ៍ទាំងអស់ឲ្យពេញដោយលំពាន់ ស្បូវភ្លាំង ឈើឯម ដីប្ញី និងម្រេច សម៉ ទ្វី ។ ខ្ញុំឲ្យគេធ្វើស្បែកជើងទ្រនាប់ជើង សំពត់សម្រាប់

ជូតទឹក និងឈើប្រត់ដែលគេធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំឲ្យគេធ្វើនូវថ្នាំឱសថ ថ្នាំបន្តក់ភ្នែក ចង្កឹះ ធម្មក្រកដ៏ប្រសើរ កូនសោរ និងប្រអប់កូនសោរ ដែលបុគ្គលដេរដោយចេសមានពណ៌ ៥ ។ ខ្ញុំឲ្យគេធ្វើនូវសំពត់អាយោគ ខ្សៀ ជើងប្រទីប លក្កច័ន និងជបឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានឲ្យគេធ្វើចន្ទាស កាំបិតកាត់ក្រចក កង្វារត្រចៀក និងថង់យាមដាក់កេសជ្ជៈ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំបានឲ្យគេធ្វើគ្រែដ៏វិសេស តាំង និងបល្ល័ង្ក សុទ្ធតែមានជើង ៤ ឲ្យសមគួរដល់វត្ថុនោះហើយឲ្យទុកក្នុងទីខាងឆត្រ ។ ខ្ញុំបានឲ្យគេធ្វើនូវពូកញាត់ដោយរោម ពូកញាត់ដោយសំឡី ពូកដេរភ្ជាប់នឹងតាំង និងខ្នើយដែលគេធ្វើល្អ ឲ្យសមគួរដល់វត្ថុនោះ ។ ខ្ញុំឲ្យគេធ្វើនូវកុរុវិន្ទៈ គឺខ្សែសម្រាប់ដុសក្អែល ក្រមួនឃ្មុំ ជើងក្រានដុតប្រេងសម្រាប់កម្តៅដៃ និងគ្រែសិវេជិផលកៈដ៏ស្អាតព្រមទាំងកម្រាល ។

ខ្ញុំឲ្យគេធ្វើសេនាសនៈ គ្រឿងជូតជើង ទីដេកទីអង្គុយ ឈើប្រត់ឈើស្ទន់ ឈើរងជើង និងគ្រឿងក្រអូប សម្រាប់លាបសីសៈ ។ ខ្ញុំឲ្យគេធ្វើដែកភ្លើង តាំងផែនក្តារ គ្របបាត្រ ថាស ប៉ោយសម្រាប់ដងទឹក លម្អិតសម្រាប់ងូតទឹក និងស្នូកសម្រាប់ជ្រលក់ ។ ខ្ញុំឲ្យគេធ្វើសំពត់ជូតមុខ សំពត់ងូតទឹក សំពត់សម្រាប់ងូតទឹកភ្លៀង និសីទនៈ សំពត់បិទបូស និងស្បង់ ។ ខ្ញុំឲ្យគេធ្វើចីវរ សង្ឃាដី ថ្នាំហិត ប្រាសដុសធ្មេញ

ទឹកជ្រក់ វត្ថុប្រៃ ទឹកឃ្មុំ និងទឹកដោះជូរ ។

វត្ថុណា ឈ្មោះថា ដែលគេគប្បីឲ្យ គឺក្រមួនឃ្មុំ កំណាត់សំពត់ កន្ទ្រេងជូតមុខ និងថេស ឬវត្ថុណា គួរដល់ព្រះសាស្តា ខ្ញុំក៏បានប្រមូលរបស់ទាំងអស់នោះ ហើយនាំចូលទៅគាល់ព្រះរាជាព្រះនាមអានន្ទៈ ព្រះអង្គជាអ្នកចម្រើនពួកជន ជាអ្នកមានយសធំ ។ ខ្ញុំក្រាបបង្គំទូលដោយត្បូងរូបក្រាបបង្គំទូលថា យើងទាំងពីរនាក់ មានជាតិខ្ពង់ខ្ពស់ស្មើគ្នា មានយសបុំប្រើងស្មើគ្នា ។ យើងទាំងពីរនាក់ ជាសាធារណៈ ប្រព្រឹត្តទៅតាមគ្នាក្នុងសុខ និងទុក្ខ បពិត្រព្រះអង្គអ្នកទូន្មានសត្រូវ សេចក្តីទុក្ខប្រ-ព្រឹត្តទៅក្នុងចិត្ត មានព្រះអង្គជាទីតាំង ។

បពិត្រព្រះមហាក្សត្រ បើព្រះអង្គអាច ក៏សូមបន្ទោបង់សេចក្តីទុក្ខនោះចុះ សេចក្តីទុក្ខរបស់ព្រះអង្គ ក៏ដូចជាទុក្ខរបស់ខ្ញុំ ចិត្តរបស់យើងទាំងពីរនាក់ រមែងមានក្នុងទីដូចគ្នា ។ បើព្រះអង្គជ្រាបស្រេចហើយ ព្រះអង្គគប្បីដោះទុក្ខនោះចេញ បពិត្រមហារាជ សូមព្រះអង្គជ្រាបនូវទុក្ខដែលខ្ញុំព្រះអង្គ បន្ទោបង់បានដោយក្រចុះ ។ សូមព្រះអង្គមានព្រះបន្ទូលទៅមើល តើទ្រព្យទាំងប៉ុន្មានក្នុងដែន និងជីវិតទាំងប៉ុន្មានរបស់ខ្ញុំ ទ្រព្យនោះឯង ព្រះអង្គលះបង់បានដោយកម្រឬទេ ។ បើព្រះអង្គមានសេចក្តីត្រូវដោយទ្រព្យ និងជីវិតនោះ ខ្ញុំព្រះអង្គនឹងថ្វាយដោយ ឥតញាប់ញ័រ បពិត្រព្រះសម្មតិទេព ព្រះអង្គធ្លាប់មានបន្ទូលនឹងខ្ញុំមកហើយ តែព្រះ

បន្ទូលនោះច្រើនតែខុស ។ ខ្ញុំនឹងដឹងនូវព្រះអង្គដែលឋិតនៅ ក្នុងធម៌ទាំង ពួងក្នុងថ្ងៃនេះ ព្រះអង្គតែងបៀតបៀនចំពោះខ្ញុំ ដែលជាអ្នកឲ្យទានខ្លាំង ពេក ។ ព្រះអង្គមានប្រយោជន៍អ្វី ដោយការបរបោគ្នា សូមព្រះអង្គប្រាប់ ខ្ញុំនូវហេតុដែលព្រះអង្គប្រាថ្នាចុះ បពិត្រមហារាជ ឯខ្ញុំព្រះអង្គចង់បាន ព្រះពុទ្ធ ជាបុគ្គលប្រសើរខ្ពង់ខ្ពស់ ។ ខ្ញុំនឹងញុំាងព្រះសម្ពុទ្ធឲ្យឆាន់ សូម កុំឲ្យជីវិតរបស់ខ្ញុំមានទោសឡើយ ខ្ញុំថ្វាយពរជ័ទៃដល់ព្រះអង្គថា ព្រះមុនី មិនត្រូវការអ្នកណានិមន្តឡើយ ។ ព្រះពុទ្ធដូចជាកែវមណីជោតិរស មិន ត្រូវឲ្យដល់អ្នកណាមួយទេ បពិត្រព្រះសម្មតិទេព ក្រែងព្រះអង្គធ្លាប់ មានព្រះបន្ទូលហើយថា ជីវិតមានប្រយោជន៍ជាដរាប ។ ព្រះអង្គកាល ឲ្យនូវជីវិត គួរឲ្យព្រះតថាគតដល់ខ្ញុំ ព្រះជិនស្រីជាមហាវីរបុរស ដែលគេ ត្រូវតែតម្កល់ទុក មិនត្រូវឲ្យដល់បុគ្គលណាមួយឡើយ ។

ព្រះពុទ្ធខ្ញុំមិនទាន់ទទួលទេ សូមព្រះអង្គទទួលទ្រព្យ ដែលរាប់ មិនបានចុះ ខ្ញុំព្រះអង្គនឹងដល់នូវការវិនិច្ឆ័យ និងសួរក្នុងទីវិនិច្ឆ័យ ។ ពួក តុលាការនឹងពោលនូវពាក្យដ៏ល្អិតយ៉ាងណា ខ្ញុំនឹងសួរតបពាក្យនោះយ៉ាង នោះ ខ្ញុំចាប់ព្រះហស្តព្រះរាជា ដើរទៅកាន់ទីវិនិច្ឆ័យ ។ ខ្ញុំបានពោលពាក្យ នេះចំពោះមុខតុលាការថា សូមពួកអ្នកតុលាការស្តាប់ពាក្យខ្ញុំ ដ្បិតព្រះ រាជាបានប្រទានពរដល់ខ្ញុំ ។ ខ្ញុំមិនតម្កល់ទុកនូវវត្ថុអ្វីមួយ សូម្បីតែជីវិត ក៏បវារណាដែរ កាលព្រះរាជាបានប្រទានពរដល់ខ្ញុំហើយ ខ្ញុំក៏បានទទួល

យកនូវព្រះពុទ្ធជាបុគ្គលដ៏ប្រសើរ ។ ព្រះរាជាបានប្រទានព្រះពុទ្ធល្អហើយ អ្នកទាំងឡាយចូរកាត់នូវសេចក្ដីសង្ស័យរបស់ខ្ញុំ ខ្ញុំនឹងស្ដាប់នូវព្រះឱង្ការរបស់ព្រះអង្គ ជាស្ដេចរក្សាផែនដី ។ តុលាការពោលថា យើងស្ដាប់ពាក្យរបស់ជនទាំងពីរហើយ នឹងកាត់សេចក្ដីសង្ស័យក្នុងរឿងនោះដូចតទៅនេះ ។ បពិត្រព្រះសម្មតិទេព ពរទាំងពួងដែលព្រះអង្គ ប្រទានហើយដល់ឆ្មាំទ្វារនេះ ជាពរដែលគេត្រូវតែកាន់យកទាំងអស់ ។

ខ្ញុំមិនតម្កល់ទុកនូវវត្ថុអ្វីមួយ សូម្បីតែជីវិតក៏បវារណាដែរ ខ្ញុំស៊ូដល់នូវសេចក្ដីលំបាក ដរាបដល់អស់ជីវិតប្រសើរជាង ។ ខ្ញុំដឹងច្បាស់នូវព្រះអង្គនេះ ដែលដល់នូវទុក្ខដ៏ក្រៃលែង ហើយបានប្រទានពរ ដែលគេត្រូវតែកាន់យកទាំងអស់ បពិត្រព្រះសម្មតិទេព ព្រះអង្គជាអ្នកបរាជ័យហើយ គួរតែព្រះរាជានុញ្ញាតឲ្យព្រះតថាគត ដល់ឆ្មាំទ្វារនោះចុះ ។ ការសង្ស័យរបស់អ្នកទាំងពីរនាក់ ខ្ញុំកាត់រួចហើយ សូមព្រះអង្គឋិតនៅក្នុងរោងដ៏សមគួរចុះ ។ ព្រះរាជាឋិតនៅក្នុងរោងនោះហើយ ក៏ពោលពាក្យនេះចំពោះពួកតុលាការថា អ្នកទាំងឡាយចូរឲ្យដល់ខ្ញុំ ដោយប្រពៃចុះ ខ្ញុំត្រូវបានព្រះពុទ្ធម្ដងដែរ ខ្ញុំញ៉ាំងសេចក្ដីប្រាថ្នារបស់អ្នកឲ្យពេញហើយ ខ្ញុំសូមនិមន្តព្រះតថាគតឲ្យបានផង ។ អ្នកតុលាការពោលនឹងខ្ញុំជាអ្នកឆ្មាំទ្វារថា អ្នកចូរថ្វាយបង្គំមហាក្សត្រ ព្រះនាមអានន្ទៈចំពោះមុខពួកតុលាការ ហើយថ្វាយព្រះពុទ្ធដល់ព្រះរាជា ព្រះនាមអានន្ទៈ មានយសវិញផង ។

ខ្ញុំក៏មានចិត្តត្រេកអររីករាយ ហើយចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅគាល់ព្រះសម្ពុទ្ធព្រះអង្គជាអ្នកឆ្លងនូវឱឃៈ មិនមានអាសវៈហើយ ខ្ញុំក៏បានថ្វាយបង្គំដោយត្បូង ក្រាបបង្គំទូលពាក្យនេះថា បពិត្រព្រះអង្គមានបញ្ញាចក្ខុ សូមព្រះអង្គ ព្រមទាំងភិក្ខុអ្នកសង្រួមឥន្ទ្រិយ៍ ចំនួនមួយសែនរូបទទួលនិមន្តឲ្យទាន ។ សូមព្រះអង្គញ៉ាំងចិត្តរបស់ខ្ញុំឲ្យរីករាយ ហើយស្តេចចូលមកកាន់និវេសន៍របស់ខ្ញុំ ។ ឯព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលនូវការបូជា ទ្រង់មានចក្ខុ ជ្រាបសេចក្តីត្រិះរិះរបស់ខ្ញុំហើយ ក៏ទទួលនិមន្ត ។ ខ្ញុំដឹងនូវការទទួលនិមន្តហើយ ទើបថ្វាយបង្គំលាព្រះសាស្តា ។ ខ្ញុំមានចិត្តត្រេកអររីករាយយ៉ាងក្រៃពេក ទើបចូលទៅកាន់និវេសន៍ ប្រមូលពួកមិត្ត និងអាមាត្យ ហើយពោលពាក្យនេះថា ព្រះសម្ពុទ្ធដូចជាកែវមណីជោតិរស ដែលគេបានដោយក្រក្រៃលែង ឥឡូវនេះ ខ្ញុំបានហើយ ខ្ញុំនឹងបូជាព្រះអង្គដោយវត្ថុដូចម្តេច ព្រោះព្រះជិនស្រី ជាអ្នកប្រាជ្ញ ប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម រកបុគ្គលប្រឹងផងមិនបាន មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបបាន ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើដូចគ្នា ប្រសើរជាងជន ឥតមានបុគ្គលជាគំរប់ពីរ ។ ពិតណាស់ ការកសាងដ៏សមគួរដល់ព្រះពុទ្ធ យើងធ្វើបានដោយក្រ ( ហេតុនោះ ) យើងទាំងឡាយចូរប្រមូលផ្កាផ្សេងៗ ធ្វើមណ្ឌបដោយផ្កា ។

បុប្ផជាតិទុំះ គឺផ្កាឧប្បល ផ្កាឈូក ផ្កាម្ទិះរួត ផ្ការំដួល ជាផ្កាដ៏សមគួរដល់ព្រះពុទ្ធ នឹងបានឈ្មោះថា ជាគ្រឿងបូជាគ្រប់យ៉ាង ។ ខ្ញុំបានឲ្យគេយកផ្កាចម្បា និងផ្កាខ្ទឹងធ្វើមណ្ឌប ហើយក្រាលអាសនៈមួយសែន ក្នុងម្លប់ឆត្រ ។ អាសនៈរបស់ខ្ញុំ ខាងក្រោយបង្អស់ ដល់នូវតម្លៃមួយវេយកហាបណៈ ជាយ៉ាងក្រៃលែង ខ្ញុំក្រាលអាសនៈមួយសែន ក្នុងម្លប់ឆត្រ ។ ខ្ញុំចាត់ចែងបាយ និងទឹករួចហើយ ទៅក្រាបទូលនូវភត្តកាលកាលដែលខ្ញុំក្រាបទូលភត្តកាលហើយ ព្រះមហាមុនីព្រះនាម បទុមុត្តរៈទ្រង់ស្តេចចូលមកកាន់និវេសនដ្ឋានរបស់ខ្ញុំ ដែលបាំងឆត្រអំពីខាងលើក្នុងមណ្ឌបដែលធ្វើអំពីផ្ការីកដ៏ល្អ ( ជាមួយ ) នឹងពួកភិក្ខុមួយសែនអង្គជាអ្នកសង្រួមឥន្រ្ទីយ៍ ។

ព្រះពុទ្ធជាបុរសឧត្តម ព្រមទាំងពួកភិក្ខុមួយសែនអង្គ ជាអ្នកសង្រួមឥន្រ្ទីយ៍ ក៏គង់នៅគ្រប់ចំនួនឆត្រមួយសែន និងអាសនៈមួយសែនបពិត្រព្រះអង្គមានបញ្ញាចក្ខុ សូមព្រះអង្គទទួលកប្បិយវត្ថុ ដែលឥតទោស ។ ឯព្រះបទុមុត្តរសម្ពុទ្ធ ជ្រាបច្បាស់នូវលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា ជាមហាមុនី ព្រះអង្គប្រាថ្នាដើម្បីចម្លងខ្ញុំ ក៏ទ្រង់ទទួលវត្ថុនោះ ខ្ញុំបានប្រគេនបាត្រ ផ្សេងដោយឡែក ដល់ភិក្ខុមួយរូបៗ ។ ពួកភិក្ខុក៏លះបង់បាត្រ ដែលខ្លួនធ្លាប់មាន ហើយទ្រទ្រង់នូវបាត្រជាវិការៈនៃលោហៈ ។ ព្រះពុទ្ធទ្រង់គង់ក្នុងមណ្ឌប ជាវិការៈនៃផ្កាអស់ ៧ យប់ ៧

ថ្ងៃ ទ្រង់ញ៉ាំងពួកសត្វជាច្រើនឲ្យត្រាស់ដឹង ទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ កាលញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ( ក៏ទ្រង់គង់នៅ ) ខាងក្រោមមណ្ឌប ជាវិការៈនៃផ្កា ។

ពួកសត្វ ៨ ម៉ឺន ៤ ពាន់ ក៏បានត្រាស់ដឹងមគ្គផល លុះដល់ថ្ងៃជាគំរប់ ៧ ព្រះមហាមុនីព្រះនាម បទុមុត្តរៈ ព្រះអង្គគង់នៅក្នុងម្លប់ឆត្រ បានសម្តែងនូវគាថាទាំងនេះថា មាណពណា បានឲ្យទានដ៏ប្រសើរ ជាទានមិនខ្វះខាតដល់តថាគត តថាគតនឹងសរសើរមាណពនោះ ហេតុនោះ អ្នកទាំងឡាយចូរស្តាប់នូវពាក្យរបស់តថាគត កាលសម្តែងដូចតទៅនេះចុះ សេនាប្រកបដោយអង្គ ៤ គឺ ដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ នឹងចោមរោមនូវមាណពនេះជានិច្ច នេះជាផលនៃទានទាំងពួង ។ យានដំរី យានសេះ គ្រែស្នែង រថទ្រង់គ្រឿង នឹងបំរើមាណពនេះជានិច្ច នេះជាផលនៃទានទាំងពួង ។ រថ ៦ ម៉ឺនដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ នឹងចោមរោមមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ តូរ្យតន្ត្រី ៦ ម៉ឺន និងស្គរដែលគេតាក់តែងល្អ នឹងប្រគំឲ្យមាណពនោះជានិច្ច នេះជាផលនៃទានទាំងពួង ។ ពួកនាងនារី ៨ ម៉ឺន ៦ ពាន់នាក់ដែលតាក់តែងល្អ មានសំពត់និងគ្រឿងប្រដាប់ដ៏វិចិត្រ ពាក់កណ្ឌលនៃកែវមណី និងកែវមុក្តា មានមុខទូលាយ ស្រស់ស្រាយ មានទ្រគាកល្អមានចង្កេះរៀវ នឹងចោមរោមមាណពនោះជានិច្ច នេះជាផលនៃទានទាំង

ពួង ។ មាណពនោះនឹងរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានជាព្រះឥន្ទ្រសោយរាជ្យក្នុងទេវលោកមួយពាន់ដង នឹងបានជាស្តេចចក្រពត្តិមួយពាន់ដង នឹងបានសោយប្រទេសរាជ្យដ៏ធំទូលាយដែលរាប់បានមួយអសង្ខេយ្យកប្ប កាលមាណពនោះនៅក្នុងទេវលោក ជាអ្នកព្រមព្រៀងដោយបុញ្ញកម្ម ។ ឆត្រស័ត្វនឹងបាំងក្នុងទីបំផុតទេវលោកទៀត មាណពនេះ នឹងប្រាថ្នានូវគ្រឿងបាំង ដែលកើតអំពីសំពត់និងផ្កា ក្នុងកាលណាទេវបុត្រ ដឹងនូវចិត្តរបស់មាណពនេះ នឹងបាំងអស់កាលជានិច្ចក្នុងកាលនោះ ។

មាណពនោះ ច្យុតិចាកទេវលោក ត្រូវកុសលមូលជាស់តឿនជាអ្នកប្រកបដោយបុញ្ញកម្ម នឹងមានផៅសន្តានដ៏ប្រសើរ ។ ក្នុងមួយសែនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ព្រះគោតមសក្យបុង្គវៈ ទ្រង់ជ្រាបហេតុទាំងអស់នោះហើយ ទ្រង់គង់នៅក្នុងពួកភិក្ខុ ហើយតាំងមាណពនេះទុកក្នុងតំណែងជាឯតទគ្គៈ នឹងបានជាសាវ័ករបស់ព្រះសាស្តា ឈ្មោះថាបិលិន្ទវច្ឆៈ ។ បិលិន្ទវច្ឆត្ថេរនោះ មានពួកទេវតា អសុរ គន្ធព្វ ភិក្ខុ ភិក្ខុនី និងគ្រហស្ថ ធ្វើសក្ការៈដូចគ្នា បានជាទីស្រឡាញ់នៃជនទាំងពួង ជាអ្នកមិនមានអាសវៈ ។ បុញ្ញកម្មដែលខ្ញុំបានធ្វើហើយ ក្នុងកប្បទីមួយសែន ឲ្យផលដល់ខ្ញុំក្នុងជាតិនេះ ។ ខ្ញុំរួចស្រឡះហើយ ដូចជាកម្ទាំងកូនសរ ខ្ញុំ

ដុតបំផ្លាញ នូវកិលេសទាំងឡាយហើយ ឱ ! កម្មដែលខ្ញុំធ្វើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ ព្រោះហេតុដែលខ្ញុំធ្វើគ្រឿងសក្ការៈ ចំពោះបុញ្ញក្ខេត្ត ទើបខ្ញុំដល់នូវអចលបទ គឺព្រះនិព្វាន ។

មាណពណា ជាប្រធានខាងដើម បានឲ្យទានដ៏ប្រសើរមិនខ្វះខាត នេះជាផលនៃទាន របស់មាណពនោះ ។ ព្រោះតែខ្ញុំបានថ្វាយឆត្រចំពោះព្រះសុគតនិងព្រះសង្ឃ ជាគណៈសង្ឃដ៏ឧត្តម ទើបបាននូវអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមិនស្គាល់ត្រជាក់ ១ ក្តៅ ១ ផង់ធូលីមិនប្រឡាក់ ១ ខ្ញុំមិនមានឧបទ្រព ១ មិនមានចង្រៃ ១ ខ្ញុំត្រូវគេគោរពកោតក្រែងសព្វៗ កាល ១ ខ្ញុំមានសម្បុរដ៏សុខុម ១ ខ្ញុំមានចិត្តក្លៀវក្លា ១ ។ កាលខ្ញុំអន្ទោលទៅក្នុងភពតូចធំ ឆត្រទាំងមួយសែនប្រកបដោយគ្រឿងអលង្ការគ្រប់មុខ តែងបាំងលើក្បាលរបស់ខ្ញុំ ព្រោះហេតុនៃបុញ្ញកម្មនោះ វៀរលែងតែជាតិនេះចេញ ព្រោះហេតុនោះ បានជាក្នុងជាតិនេះ ខ្ញុំមិនមានឆត្របាំង តែអំពើទាំងអស់ដែលខ្ញុំធ្វើហើយ នាំឲ្យបាននូវឆត្រគឺវិមុត្តិ ។

ព្រោះតែខ្ញុំថ្វាយនូវសំពត់ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈសង្ឃដ៏ខ្ពង់ខ្ពស់ ទើបបានអានិសង្ស ៨ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំមានវណ្ណៈដូចមាស ១ ប្រាសចាកធូលី ១ ប្រកបដោយពន្លឺ ១ មានតេជៈ ១ ខ្លួនរបស់ខ្ញុំជិតស្និទ្ធ ១ កាលខ្ញុំអន្ទោលទៅក្នុងភព

តូចធំ សំពត់ទាំងមួយសែន ពណ៌ស លឿង និងក្រហមរមែងប៉ាំងលើក្បាលខ្ញុំ ១ នេះជាផលនៃទានសំពត់ ខ្ញុំរមែងបាននូវសំពត់ កោសេយ្យ-ពស្ត្រ និងសំពត់កម្ពល ១ បាននូវសំពត់ដែលធ្វើដោយសំបកឈើ និងសំពត់ធ្វើដោយកប្បាស ក្នុងទីទាំងពួង ១ ព្រោះអានិសង្សនៃសំពត់ទាំងឡាយនោះ ។

ព្រោះតែខ្ញុំបានថ្វាយបាត្រ ចំពោះព្រះសុគត និងព្រះសង្ឃ ជាគណៈដ៏ខ្ពង់ខ្ពស់ ទើបបាននូវអានិសង្ស ១០ ប្រការ ដ៏សមគួរដល់អំពើរបស់ខ្ញុំ គឺខ្ញុំរមែងប្រើប្រាស់ ជាសមាស ១ ជាសកែវមណី ១ ជាសប្រាក់ ១ ជាសដែលធ្វើអំពីកែវទទឹម គ្រប់កាលទាំងពួង ១ ខ្ញុំជាអ្នកមិនមានឧបទ្រព ១ មិនមានចង្រៃ ១ ខ្ញុំត្រូវគេគោរពកោតក្រែងគ្រប់កាល ១ ខ្ញុំជាអ្នកបាននូវបាយ ទឹក សំពត់ និងទីដេក ១ ភោគៈទាំងឡាយរបស់ខ្ញុំ មិនដែលវិនាសបាត់ ១ ខ្ញុំមានចិត្តខ្ជាប់ខ្ជួន ១ ។ មិនតែប៉ុណ្ណោះ ខ្ញុំជាអ្នកពេញចិត្ត នឹងធម៌គ្រប់កាល មិនមានកិលេស មិនមានអាសវៈ គុណធម៌ទាំងនេះជាប់តាមហើយ ក្នុងទេវលោក ទាំងក្នុងមនុស្សលោក ។ គុណធម៌ទាំងឡាយ ជាប់ដោយចំណងគឺចិត្ត រមែងមិនលះបង់ខ្ញុំក្នុងទីទាំងពួង ដូចស្រមោលមិនលះបង់រូប ។

ម្យ៉ាងទៀត ក្នុងការថ្វាយនូវវត្ថុបច្ច័យទាំងឡាយយ៉ាងដទៃៗ ក៏មានអានិសង្សច្រើនទៀត តាមដែលលោកពណ៌នាទុក ក្នុងគម្ពីរខុទ្ទក-

និកាយ អបទាននោះ ចំពោះរឿងអតីតជាតិរបស់ព្រះបិលិន្ទវច្ឆត្ថេរ ដែលលោកកសាងបុណ្យបារមីទុក ដូចមានសេចក្ដីថា ៖

កាលព្រះលោកនាថ ព្រះនាមសុមេធ ទ្រង់ជាអគ្គបុគ្គល ទ្រង់បរិនិព្វានហើយ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានធ្វើនូវការបូជាព្រះស្តូប ។ ព្រះខីណាស្រពទាំងឡាយណា ដែលបានអភិញ្ញា ៦ មានឫទ្ធិច្រើន នៅក្នុងទីនោះ ខ្ញុំក៏បានប្រជុំព្រះខីណាស្រពទាំងនោះ ក្នុងទីនោះហើយបានធ្វើសង្ឃភត្ត ។ កាលនោះ ព្រះថេរៈឈ្មោះសុមេធៈ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ព្រះនាមសុមេធៈ ព្រះថេរៈនោះ បានធ្វើអនុមោទនាក្នុងកាលនោះ ។ ដោយចិត្តជ្រះថ្លានោះ ខ្ញុំបានចូលទៅក្នុងវិមាន ដែលមានតែស្រីអប្សរ ៨៦០០០ កើតឡើងសម្រាប់ខ្ញុំ ។ ពួកស្រីប្រព្រឹត្តតម្រូវចិត្តខ្ញុំ ដោយកាមទាំងពួង សព្វៗ កាល ខ្ញុំគ្របសង្កត់នូវពួកទេវតាដទៃ នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្បទី ២៥ កាលនោះ ខ្ញុំបានជាស្ដេចចក្រពត្តិ ឈ្មោះវរុណៈ មានភោជនដ៏បរិសុទ្ធ ។ មនុស្សទាំងឡាយនោះ មិនបាច់សាបព្រោះពូជ មិនបាច់ភ្ជួរដោយនង្គ័ល តែងបរិភោគស្រូវសាលី ដែលដុះក្នុងទីមិនបាច់ភ្ជួរ ។ ខ្ញុំសោយរាជ្យ ក្នុងអត្តភាពជាមនុស្សនោះហើយ ក៏បានទៅកាន់អត្តភាពជាទេវតាម្ដងទៀត ការបរិបូណ៌ដោយភោគៈបែបនេះ ក៏កើតឡើងសម្រាប់ខ្ញុំ ក្នុងកាលនោះ

សត្វទាំងអស់ ទោះបីជាមិត្តក្តី មិនមែនជាមិត្តក្តី មិនដែលបៀតបៀនខ្ញុំ ខ្ញុំរមែងជាទីស្រឡាញ់នៃសត្វទាំងពួង នេះជាផលនៃបុញ្ញកម្ម ។

ក្នុងកប្ប ទី ៣០ ពាន់ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃគ្រឿងក្រអូប និងគ្រឿងលាប ។ ក្នុងកទ្ទកប្បនេះ ខ្ញុំបានជាស្តេចចក្រពត្តិមួយអង្គ ជាធំជាងជនមានអានុភាពច្រើន ជារាជឥសី មានកម្លាំងច្រើន ។ ខ្ញុំនោះតាំងនៅក្នុងសីល ៥ ហើយញុំាងពួកជនច្រើននាក់ ឲ្យដល់នូវសុគតិ ខ្ញុំជាទីស្រឡាញ់នៃទេវតាទាំងឡាយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

មូលហេតុ ដែលព្រះបិលិន្ទវច្ឆត្ថេរ បានទទួលការលើកតម្កើងប្រសើរបំផុត ដែលជាទីស្រឡាញ់ពេញចិត្តរបស់ទេវតាទាំងឡាយនោះ មានសម្តែងក្នុងអដ្ឋកថាមនោរថបូរណី ដូចមានរឿងអធិប្បាយទុកថា ៖

កាលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើងក្នុងលោក ព្រះបិលិន្ទវច្ឆត្ថេរបានកើតជាស្តេចចក្រពត្តិ បានណែនាំមហាជនឲ្យចេះរក្សាសីល ៥ គឺវៀរចាកការសម្លាប់សត្វ ១ ការលួចទ្រព្យគេ ១ ការប្រព្រឹត្តិខុសប្រពន្ធកូនអ្នកដទៃ ១ ការនិយាយកុហក ១ និងការវៀរចាកផឹកនូវទឹកស្រវឹង ១ ។ មួយទៀត ផលល្អដែលមហាជនបានរក្សាសីល ៥ ធ្វើឲ្យមហាជនទាំង

នោះ កាលបើអស់ជីវិតទៅហើយ ក៏បានទៅកើតក្នុងទេវលោក ។

ពួកមហាជនទាំងនោះ កើតនៅក្នុងស្ថានសួគ៌ទាំង ៦ ជាន់ កាលបើក្រឡេកមើល ទិព្វសម្បត្តិរបស់ខ្លួន ក៏គិតថា ពួកយើងបានទិព្វសម្បត្តិនេះព្រោះអាស្រ័យហេតុអ្វី ឬអ្នកណាហ្ន៎ ។ កាលបើគិតពិចារណាមើលរួចហើយ ក៏ឃើញថា ព្រោះអាស្រ័យព្រះបិលិន្ទវច្ឆត្ថេរនោះ ក្នុងសម័យដែលលោកកើតជាស្តេចចក្រពត្តិ ទើបនាំគ្នាចុះមកនមស្ការគោរពចំពោះលោក ទាំងព្រឹក ទាំងល្ងាច ដែលជាការបង្ហាញប្រាប់នូវការដឹងគុណចំពោះព្រះបិលិន្ទវច្ឆត្ថេរ ដែលជាអ្នកទ្រទ្រង់នូវតំណែងឯតទគ្គៈ ឬជាបុគ្គលសំខាន់របស់ ព្រះពុទ្ធសាសនា ដូចបានពោលមកហើយនេះ ។

ព្រះបិលិន្ទវច្ឆត្ថេរ កាលបានសម្រេចជាព្រះអរហន្តហើយ លោកបានជាកម្លាំងដ៏សំខាន់ ក្នុងការប្រកាសព្រះធម៌ព្រះវិន័យរបស់ព្រះជិនស្រីឲ្យបានចម្រុងចម្រើនរហូតដល់លោករំលត់ខន្ធបរិនិព្វាន ។

**( ជីវប្រវត្តិរបស់ព្រះបិលិន្ទវច្ឆត្ថេរ ចប់ )**

# ✍ ជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ ✍

### " ដែលជាឯតទគ្គៈផ្នែកខាងគ្មានអាពាធ "

*ព្រះពក្កុលត្ថេរ ក៏រាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក គឺជាសាវ័កមួយរូប ដែលបានទទួលការលើកតម្កើង ឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងគ្មានអាពាធ អំពីព្រះបរមសាស្ដា ទាំងលោកមានជីវប្រវត្តិប្លែកចម្លែកអស្ចារ្យ មិនដូចជីវប្រវត្តិសាវ័កអង្គដទៃឡើយ ។*

*ដែលមានសម្ដែងក្នុងអដ្ឋកថា បបញ្ចសូទនី ដែលអធិប្បាយសេចក្ដីព្រះបាលី ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ និងគម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ អធិប្បាយសេចក្ដីដែលទាក់ទងនឹងឈ្មោះរបស់ព្រះថេរៈទុកថា ៖*

*ពាក្យថា **ពាកុលៈ** នោះប្រែថា មានត្រកូលពីរ និង **ពាកុលៈ** ស័ព្ទនេះ ចែកចេញជាពីរបទគឺ **ពា** មួយបទ និង **កុល** មួយបទ ។*

***ពា** ប្រែថា ពីរ ព្រោះប្លែងចេញមកពីពាក្យថា **ទ្វិ** ឬ **ទ្វា** ប្រែថា ពីរ ។ **កុលៈ** ប្រែថា ត្រកូល ឬ **សកុលៈ** សម្ដៅដល់ វង្ស ខ្សែស្រឡាយផៅពង្ស និងជាតិដ៏ល្អ ។*

*ចំណែកអដ្ឋកថា មនោរថបូរណីមានសេចក្ដីថា ពាក្យថា **ពាកុលៈ** ព្រោះជាអ្នកចម្រើននៅក្នុងត្រកូលសេដ្ឋីទាំងពីរ ឬជាអ្នកដែលត្រកូល*

សេដ្ឋីទាំងពីរចិញ្ចឹម ។ ឬន័យមួយទៀត **ពាកុលៈ** ដែលប្រែថា មានត្រកូលពីរ សម្ដៅដល់ជាអ្នកនៅក្នុងផ្ទៃមួយជាតិពីរដង បានដល់ នៅក្នុងផ្ទៃមាតាមួយដង និងនៅក្នុងពោះត្រីមួយដងទៀត ក៏រាប់ថាជីវប្រវត្តិរបស់លោកគួរសិក្សាយ៉ាងក្រៃលែង ។

រឿងអតីតជាតិរបស់ព្រះពក្កុលត្ថេរ មានប្រាកដនៅក្នុងអដ្ឋកថាមនោរថបូរណី និងអដ្ឋកថា បរមត្ថទីបនី ដែលអធិប្បាយសេចក្ដីបាលីគម្ពីរខុទ្ទកនិកាយ ថេរគាថា មានសេចក្ដីថា ៖

ក្នុងទីបំផុតមួយអសង្ខេយ្យ និងមួយសែនកប្ប ដោយរាប់ថយក្រោយអំពីភទ្ទកប្បនេះ ព្រះពក្កុលត្ថេរនោះ បានកើតនៅក្នុងត្រកូលព្រាហ្មណ៍ មុនព្រះអនោមទស្សីសម្មាសម្ពុទ្ធ ស្ដេចឧប្បត្តិឡើងក្នុងលោក ប៉ុន្តែមិនប្រាកដថាឈ្មោះអ្វី ។ កាលបើពក្កុលព្រាហ្មណ៍នោះចម្រើនវ័យធំឡើង គេបានទៅសិក្សាវិជ្ជាត្រៃវេទក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ។

ប៉ុន្តែកាលបើលោកពិចារណាវិជ្ជាត្រៃវេទមើលហើយ មិនឃើញយល់វត្ថុដែលជាសារៈ គឺខ្លឹមសារក្នុងវិជ្ជាត្រៃវេទនោះ ទើបលះបង់វិជ្ជាត្រៃវេទនោះចេញ ហើយមកបួសជាតាបសឥសី ដោយមានគំនិតគិតថានឹងស្វែងរកនូវប្រយោជន៍សម្រាប់ខ្លួន ។ ហេតុនោះ កាលលោកកាន់ភេទជាតាបស បានតាំងចិត្តបំពេញផ្នួសតាមបែបប្រពៃណីអាចារ្យមុនៗប្រព្រឹត្តប្រតិបត្តិរហូតបានសម្រេចអភិញ្ញា ៥ សមាបត្តិ ៨ ។

លុះតមក ព្រះអនោមទស្សីសម្មាសម្ពុទ្ធ បានត្រាស់ដឹងនៅក្នុងលោក មានព្រះអរិយសង្ឃជាបរិវារហែហមទៅតាមព្រះអង្គកន្លែងនានា ដើម្បីទ្រង់សម្តែងធម៌ទេសនាប្រោសបរិស័ទឲ្យបានសម្រេចមគ្គផល ទៅតាមឧបនិស្ស័យរៀងៗ ខ្លួន ។ តាបសនោះ បានជ្រាបដំណឹងថា ព្រះពុទ្ធកើតឡើងក្នុងលោកហើយ ក៏បានចូលទៅគាល់ព្រះអនោមទស្សីសម្ពុទ្ធ ក៏បានស្តាប់ព្រះធម្មទេសនា រួចហើយក៏កើតសេចក្តីជ្រះថ្លា មានសទ្ធាប្រកាសខ្លួនជាអ្នកដល់ព្រះរតនត្រៃ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ពក្កុលៈនោះ សូម្បីបានស្តាប់ព្រះធម៌ទេសនា អំពីព្រះសម្ពុទ្ធអនោមទស្សីក៏ដោយ ក៏មិនបានសម្រេចមគ្គផលអ្វីឡើយ ទាំងមិនអាចលះបង់ភេទជាតាបសនោះចេញបានឡើយ ។ ទាំងនេះប្រសិនបើពិចារណាដល់វាសនាបារមីរបស់តាបសនោះ ដែលកសាងសន្សំបុណ្យកុសលទុកក្នុងអតីតជាតិ ក៏គង់នៅមិនទាន់គ្រប់គ្រាន់ នេះប្រការមួយ ។

កាលបើពិចារណាដល់ហេតុបច្ចុប្បន្ន តាបសនេះ បានស្តាប់ព្រះធម៌ទេសនាហើយ អាចកើតវិចិកិច្ឆា គឺសេចក្តីសង្ស័យ និងឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយ គិតដល់ការប្រព្រឹត្តិទៅរវាងធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធអនោមទស្សី ជាមួយនឹងអភិញ្ញាសមាបត្តិដែលខ្លួនបាន ធ្វើឲ្យកើតការសម្រេចចិត្តមិនត្រូវ នេះជាប្រការមួយទៀត ។

សូម្បីតាបសនោះ មិនបានសម្រេចធម៌ជាន់ខ្ពស់ក៏ដោយ ទាំងមិន

ទាន់ព្រមលះបង់ភេទជាតាបសនោះបាន ប៉ុន្តែតែងតែចូលទៅស្តាប់ព្រះធម៌ទេសនាព្រះអនោមទស្សីសម្មាសម្ពុទ្ធជានិច្ចកាល ។ គ្រាមួយ ព្រះ-អនោមទស្សី ទ្រង់អាពាធរោគខ្យល់ក្នុងឧទរ កាលបើតាបសនោះជ្រាបថា ព្រះមានព្រះភាគអនោមទស្សី ទ្រង់មានអាពាធ ទើបចូលទៅក្រាបបង្គំទូលសួរថា ព្រះអង្គមានអាពាធអ្វី ? ព្រះអនោមទស្សីត្រាស់តបថា ម្នាលតាបស តថាគតកើតរោគអាពាធខ្យល់ក្នុងឧទរ ។ កាលបើតាបសនោះបានស្តាប់ពុទ្ធតម្រាស់ដូច្នេះហើយ ទើបគិតថា ពេលនេះ ជាពេលដែលយើងគួរនឹងធ្វើបុណ្យ គិតរួចហើយទើបប្រញាប់ទៅដើងក្នុំបេះថ្នាំផ្សេងៗ មកថ្វាយដល់ព្រះថេរដែលជាឧបដ្ឋាកទទួលនាទីព្យាបាលដោយប្រាប់ថា សូមលោកម្ចាស់នាំយកថ្នាំនេះចូលទៅថ្វាយដល់ព្រះបរមសាស្តាផងចុះ ព្រះថេរៈបាននាំយកថ្នាំនោះទៅថ្វាយដល់ព្រះអនោមទស្សី ដោយតាមពាក្យអង្វររបស់តាបសនោះ ។

កាលបើព្រះសម្មាសម្ពុទ្ធអនោមទស្សី ទ្រង់សោយថ្នាំនេះរួចហើយរោគខ្យល់ក្នុងឧទរក៏ស្ងប់ទៅ នៅពេលដែលព្រះអង្គបាត់អាពាធ តាបសនោះទើបក្រាបទូលតាំងសេចក្តីប្រាថ្នាថា ដោយអានិសង្សដែលខ្ញុំថ្វាយថ្នាំ ដល់ព្រះអង្គនេះ បើខ្ញុំព្រះអង្គកើតក្នុងជាតិណាៗ សូមកុំឲ្យរោគកើតមានដល់ខ្ញុំព្រះអង្គឡើយ ។ កាលដែលថ្វាយថ្នាំនេះដល់ព្រះអនោមទស្សី បានជាកល្យាណកម្មរបស់តាបសយ៉ាងល្អ ពេលដែលតាបសនោះ

ស្លាប់ទៅហើយ បានទៅកើតក្នុងព្រហ្មលោកដោយអំណាចអភិញ្ញាសមាបត្តិ ហើយចុតិចាកព្រហ្មលោកមកវិញក៏កើតក្នុងមនុស្សលោក មានការត្រាច់វង្គាត់វិលស្លាប់វិលកើតក្នុងមនុស្សទេវតា អស់មួយអសង្ខេយ្យ ។

លុះកន្លងមកដល់ពុទ្ធកាល នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ តាបសនោះបានមកកើតនៅក្នុងនគរហង្សវតី ធ្លាប់បានចូលទៅគាល់ព្រះបទុមុត្តរៈជាម្ចាស់ និងបានឃើញព្រះពុទ្ធទ្រង់តែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុសាវកទាំងឡាយអ្នកគ្មានអាពាធ ក៏នឹកពេញចិត្តតំណែងនោះ ដូច្នេះហើយ ទើបធ្វើអធិការកុសលក្នុងសម្នាក់ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ហើយប្រាថ្នាតំណែងនោះចំពោះព្រះភក្ត្រនៃព្រះអង្គនោះ ។

ជីវប្រវត្តិជាអសីតិសាវក របស់ព្រះពក្កុលត្ថេរ មាននៅក្នុងគម្ពីរខុទ្ទកនិកាយ អបទាន មានរឿងតំណាលទុកថា ៖

ខ្ញុំឈ្មោះសោភិតៈ នៅក្នុងព្រៃហិមពាន្ត អាស្រមដ៏ល្អរបស់ខ្ញុំ គឺពួកសិស្សរបស់ខ្ញុំកសាងហើយ ។ មណ្ឌបទាំងឡាយជាច្រើន ដើមឈើភ្លើងមានផ្ការីក ក៏មានក្នុងទីនោះ ដើមខ្វិត ដើមច្បា ដើមខ្ទឹង ដើមរំចេក ក៏មានក្នុងទីនោះ ជាច្រើន ដើមចង្កើរទ្រាយ ដើមពទ្រា ដើមកន្ទួតព្រៃ ដើមម៉ាក់ប្រាង វល្លិឃ្លោក ដើមស្វាយ ដើមស្វាយស មានផ្ការីក ក៏មានក្នុងទីនោះជាច្រើន ដើមរាក់ស ដើមញ្នៅ ដើមចេក ដើមក្រូចថ្លុងក៏មានក្នុងទីនោះ ដើមជន្លាត់ដៃ ដើមអង្ក្រង ដើមប្រិយង្គក៏មានច្រើនក្នុងទីនោះ ។

ដើមស្រួល ដើមស្រល់ ដើមកទម្ព ដើមជ្រៃក្រឹម ដើមក្រសាំង ( ក៏មានក្នុងទីនោះ ) អាស្រមរបស់ខ្ញុំប្រាកដយ៉ាងនេះ ខ្ញុំព្រមទាំងពួកសិស្ស ក៏នៅក្នុងអាស្រមនោះ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាសយម្ភូលោកនាយក ទ្រង់ស្វែងរកទីសម្រាប់ពួនសម្ងំ ស្តេចបានចូលមកកាន់អាស្រមរបស់ខ្ញុំ ។ លុះព្រះអនោមទស្សី ព្រះអង្គមានព្យាយាមច្រើន មានយសធំ កំពុងស្តេចចូលមក អាពាធបណ្តាលអំពីខ្យល់ ក៏បានតាំងឡើង ដល់ព្រះលោកនាថ ក្នុងមួយរំពេច ។ ខ្ញុំកាលត្រាច់ទៅក្នុងព្រៃ បានឃើញព្រះលោកនាយក ក៏ចូលមកជិតព្រះសម្ពុទ្ធ ទ្រង់មានចក្ខុ មានយសច្រើន ។ លុះខ្ញុំបានឃើញឥរិយាបថ ក៏កំណត់ទុកក្នុងកាលនោះថា ព្យាធិទាំងឡាយ ពិតជានឹងកើតដល់ព្រះពុទ្ធ ដោយឥតសង្ស័យ ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយប្រញាប់ប្រញាល់ ខ្ញុំមានបំណងនឹងធ្វើថ្នាំ ក្នុងសម្នាក់ពួកសិស្សរបស់ខ្ញុំ ខ្ញុំបានហៅពួកសិស្សក្នុងកាលនោះ ។ ពួកសិស្សទាំងអស់ ជាអ្នកមានសេចក្តីគោរព បានទទួលស្តាប់ពាក្យរបស់ខ្ញុំ ហើយមកប្រជុំក្នុងទីជាមួយគ្នា ព្រោះពួកសិស្សទាំងនោះ ជាអ្នកមានសេចក្តីគោរពដល់ខ្ញុំជាគ្រូ ។ ខ្ញុំបានឡើងកាន់ភ្នំជាប្រញាប់ ហើយបានធ្វើនូវឱសថទាំងអស់ ខ្ញុំធ្វើផ្សំនឹងទឹកសម្រាប់ផឹក បានថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ កាលព្រះសព្វញ្ញូ លោកនាយកមានយសធំ កាលទ្រង់សោយហើយ រោគខ្យល់នៃព្រះសុគត ទ្រង់ស្វែងរកគុណធំ ក៏បានស្ងប់

រម្ងាប់យ៉ាងឆាប់ ។ ព្រះអនោមទស្សី មានយសច្រើន ទ្រង់ឃើញសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ទ្រង់គង់លើអាសនៈរបស់ព្រះអង្គ រួចទ្រង់ពោលនូវគាថាទាំងនេះថា ៖

បុរសណា បានប្រគេនភេសជ្ជៈ ដល់តថាគតផង បានរម្ងាប់ព្យាធិរបស់តថាគតផង តថាគតនឹងសរសើរបុរសនោះ អ្នកទាំងឡាយចូរស្តាប់ភាសិត ដែលតថាគតនឹងសម្តែងចុះ ។ បុរសនេះនឹងត្រេកអរក្នុងទេវលោក អស់មួយសែនកប្ប នឹងរីករាយក្នុងការប្រគំតន្ត្រីក្នុងទេវលោកនោះ សព្វកាល ។ លុះត្រឡប់មកកាន់មនុស្សលោកវិញ ត្រូវកុសលមូលដាស់តឿន នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង ។ ក្នុងកប្បទី ៥៥ បុរសនេះនឹងបានកើតជាក្សត្រសោយរាជ្យ ព្រះនាមអនោមិ ជាធំក្នុងជម្ពូទ្វីប ជាធំលើផែនដី ឈ្នះសង្គ្រាម មានសមុទ្រទាំង ៤ ជាទីបំផុត ។ នឹងបានជាស្តេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានកម្លាំងច្រើន ញុំាងទេវតាក្នុងឋានតាវត្តិង្សឲ្យរីករាយ ហើយនឹងសោយនូវឥស្សរភាព ។ បុរសនោះ ទោះនឹងកើតជាទេវតាក្តី ជាមនុស្សក្តី នឹងមិនមានអាពាធ នឹងវៀរបង់នូវព្យាធិ ជាគ្រឿងក្តៅក្រហាយ ក្នុងលោក ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ មានព្រះសាស្តាព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ ទ្រង់ត្រាស់ឡើងក្នុងលោក ឯបុរសនេះ នឹងបានជាអ្នកទទួលនូវមត៌ក ក្នុងធម៌របស់ព្រះសាស្តានោះ

ជាឱរសដែលធម៌និម្មិតហើយ ហើយកំណាត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះ នឹងដុតនូវកិលេសទាំងឡាយ ហើយនឹងឆ្លងនូវខ្សែនៃតណ្ហា នឹងបានទីជាសាវ័កនៃព្រះសាស្តា ឈ្មោះពក្កុលៈ ។ ព្រះមានព្រះភាគព្រះនាមគោតម ជាសក្យប្រសើរ ទ្រង់បានជ្រាបនូវដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួកភិក្ខុ នឹងតាំងពក្កុលភិក្ខុក្នុងទីជាឯតទគ្គៈ ។ ព្រះមានព្រះភាគព្រះនាមអនោមទស្សី ជាលោកនាយកជាសយម្ភូ ទ្រង់ប្រមើលមើលសេចក្តីស្ងប់ស្ងាត់ ក៏បានស្តេចចូលមកអាស្រម របស់ខ្ញុំ ។ លុះព្រះសព្វញ្ញូ ជាលោកនាយក ទ្រង់មានព្យាយាម ស្តេចចូលមកដល់ហើយ ខ្ញុំក៏ជ្រះថ្លា បានញុំាងព្រះអង្គឲ្យធាន់ធ្អែតស្កប់ស្កល់ ដោយឱសថទាំងពួង ដោយដៃរបស់ខ្លួន ។ ខ្ញុំនោះបានធ្វើអំពើល្អហើយ ចំពោះបុញ្ញក្ខេត្តដ៏ល្អ ខ្ញុំមិនអាចញុំាងអំពើដែលខ្ញុំធ្វើល្អហើយ ក្នុងកាលនោះ ឲ្យអស់ទៅបាន ព្រោះការដល់ព្រមដោយពូជ ។ ខ្ញុំឈ្មោះថាមានលាភ អត្តភាពជាមនុស្ស ឈ្មោះថាខ្ញុំបានល្អហើយ ដ្បិតខ្ញុំបានឃើញព្រះនាយក ខ្ញុំក៏បានដល់អចលបទ គឺព្រះនិព្វាន ដោយសំណល់នៃកម្មនោះឯង ។ ព្រះគោតមជាសក្យៈដ៏ប្រសើរ ទ្រង់បានជ្រាបដំណើរទាំងអស់នេះ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃភេសជ្ជៈ ។

កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងអស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះសម្ពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ចំណែកសេចក្ដីពិស្ដារ ទាក់ទងនឹងជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ មានក្នុងអដ្ឋកថា មនោរថបូរណី មានសេចក្ដីថា ៖

កុលបុត្រនោះ បានធ្វើអធិការកុសលទុកក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ហើយតាំងសេចក្ដីប្រាថ្នាដើម្បីបាននូវភាពដ៏ប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងគ្មានអាពាធ ហើយក៏បំពេញបុណ្យកុសលរហូតអស់ជីវិត ក៏បានទៅសោយទិព្វសម្បត្តិនៅក្នុងទេវលោក និងមនុស្សលោក មានរយៈកាលជាច្រើន ។

កាលលោកត្រឡប់មកកើតនៅក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងនគរពន្ធុមតី មុនព្រះវិបស្សីទ្រង់ឧប្បត្តិឡើងនៅក្នុងលោក បានបួសជាតាបសសម្រេចអភិញ្ញាសមាបត្តិនៅក្នុំជិតព្រៃហិមពាន្ត ។ កាលតមក ព្រះ-វិបស្សីទ្រង់ត្រាស់ដឹងជាព្រះពុទ្ធ មានភិក្ខុសង្ឃ ៦ លាន ៨ សែនរូប ជាបរិវារ ព្រះអង្គប្រថាប់នៅខេមមិគទាយវ័ន ដើម្បីប្រោសព្រះបាទពន្ធុមតី

មហារាជជាពុទ្ធបិតា ក្នុងនគរពន្ធុមតី ។

កាលបើតាបសនោះជ្រាបដំណឹងថា ព្រះវិបស្សីត្រាស់ដឹងនៅក្នុងលោកហើយ ព្រះអង្គបរិបូណ៌ដោយគុណ ទើបចូលទៅគាល់ព្រះសាស្តាដើម្បីស្តាប់ព្រះធម៌ទេសនា ហើយតាំងនៅក្នុងត្រៃសរណគមន៍ ប៉ុន្តែមិនលះបង់ចោលភេទជាតាបសទេ តែងតែចូលទៅគាល់ព្រះវិបស្សីរឿយៗ ថ្ងៃមួយ ភិក្ខុទាំងឡាយកើតរោគឈឺព្រះសីសៈ ព្រោះត្រូវខ្យល់បក់នាំយកលំអងផ្កាឈើ ដែលមានពិសមកអំពីព្រៃហិមពាន្ត មានតែព្រះវិបស្សី និងអគ្គសាវក ទាំងពីររូបតែប៉ុណ្ណោះ ដែលមិនកើតរោគឈឺព្រះសីសៈ ព្រោះផ្កាឈើដែលមានពិសជាដើមហេតុ ។

កាលតាបសនោះ បានចូលមកគាល់ព្រះវិបស្សីហើយ បានឃើញភិក្ខុទាំងឡាយសឹងគ្របព្រះសីសៈ ទើបក្រាបទូលសួរថា ភិក្ខុទាំងឡាយមានអាពាធអ្វី ? ព្រះវិបស្សីត្រាស់តបថា ម្នាលតាបស ភិក្ខុទាំងឡាយមានអាពាធឈឺព្រះសីសៈ ព្រោះមកពីផ្កាឈើ ដែលមានពិសជាដើមហេតុ ។ តាបសនោះជ្រាបហេតុផលនៃអាពាធ របស់ភិក្ខុទាំងឡាយហើយ ក៏គិតភ្លាមថា ឱកាសនេះ ជាឱកាសដែលយើងគួរនឹងជួយព្យាបាលភិក្ខុដែលអាពាធទាំងនោះ ដើម្បីឲ្យកើតបុណ្យកុសលដល់យើង ទើបជាការល្អ ហើយក៏ប្រញាប់ទៅរកថ្នាំផ្សេងៗ ដោយអានុភាពរបស់ខ្លួនមកផ្សំជាភេសជ្ជៈប្រគេនដល់ភិក្ខុទាំងឡាយដែលអាពាធ ភិក្ខុទាំងឡាយបាន

ទទួលកេសដ្ឋៈនោះហើយ ក៏បាត់អាពាធមួយរំពេចក្នុងពេលនោះ ។

សម័យតមក តាបសនោះ ក៏អស់ជីវិតទៅកើតក្នុងព្រហ្មលោក ហើយមានការត្រាច់វន្តាត់ក្នុងមនុស្សទេវតារហូត ៩១ កប្ប ។ លុះមកដល់ពុទ្ធកាលរបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ តាបសនោះបានមកកើតនៅក្នុងក្រុងពារាណសី កាលមានអាយុដែលនឹងគ្រប់គ្រងផ្ទះតាមលោកិយប្រពៃណីបានហើយ ទើបគិតថា ផ្ទះរបស់យើងក៏ចាស់គ្រាំគ្រាទៅហើយ យើងគួរនឹងទៅរកគ្រឿងផ្ទះដើម្បីជួសជុលឲ្យល្អឡើងវិញ គិតដូច្នេះហើយ ទើបចេញទៅជាមួយនឹងពួកជាងផ្ទះ ក៏បានទៅជួបមហាវិហារចាស់គ្រាំគ្រាមួយកន្លែងក្នុងចន្លោះផ្លូវ ក៏គិតថា ការធ្វើផ្ទះរបស់យើងគួរផ្អាកទុកសិនចុះ ព្រោះថា ផ្ទះរបស់យើងមិនអាចជាប់តាមយើងទៅបាន ក្នុងពេលដែលយើងស្លាប់ទៅហើយ យើងគួរនឹងធ្វើបុណ្យកុសល ដែលជារបស់ជាប់តាមខ្លួនទៅកាន់បរលោកវិញ ទើបសមគួរ ។

លុះកុលបុត្រនោះ គិតដូច្នេះហើយ បានអង្វរឲ្យពួកជាងឈើទៅនាំយកគ្រឿងឈើផ្សេងៗ មកសាងជាព្រះវិហារ សាលាឆាន់ កុដិ រោងបាយ រហូតដល់ទីសម្រាកពេលថ្ងៃ និងពេលយប់ និងវច្ចកុដិក្នុងបរិវេណក្បែរព្រះវិហារនោះ ប្រមជាមួយនឹងការរៀបចំរកវត្ថុ ដែលជាថ្នាំសម្រាប់រក្សារោគប្រគេនដល់ភិក្ខុទាំងឡាយ ។

ទាំងកុលបុត្រនោះបានធ្វើបុណ្យកុសលដទៃទៀត រហូតអស់ជីវិត

ក៏បានទៅកើតនៅក្នុងទេវលោកខ្លះ មនុស្សលោកខ្លះ អស់មួយពុទ្ធន្តរ ទើបបានមកកើតជាបុត្រសេដ្ឋីនៅក្នុងក្រុងកោសម្ពី មុនព្រះសមណគោតមទ្រង់ឧប្បត្តិឡើងក្នុងលោក ។ តាំងតែពីកុលបុត្រនោះ មកចុះចាប់បដិសន្ធិនៅក្នុងគភ៌ភរិយាសេដ្ឋីក្រុងកោសម្ពីហើយ ត្រកូលរបស់សេដ្ឋី ក៏ចម្រុងចម្រើនដោយលាភ និងយសជាច្រើន ។

ចំណែកភរិយារបស់លោកសេដ្ឋីដែលមានគភ៌នោះ កាលមានគភ៌គ្រប់ខែហើយ ក៏បានប្រសូតបុត្រមកជាប្រុស ហើយមានការគិតថា បុត្ររបស់យើងជាមនុស្សមានបុណ្យច្រើន ដែលធ្លាប់ធ្វើទុករួចមកហើយ ប្រសិនបើគេមានអាយុនៅដរាបណា រមែងនឹងឲ្យសម្បត្តិច្រើនសន្ធឹកសន្ធាប់ដល់យើងពិតប្រាកដពុំខាន ។

មានការយល់ថា ប្រសិនបើបានយកទារកនេះទៅងូតទឹកក្នុងស្ទឹងយមុនាកើត រមែងមិនមានរោគភ័យអ្វីឡើយ មាតាបិតារបស់ទារកនោះទើបឲ្យគេនាំយកទៅដើម្បីឲ្យងូតទឹក ក្នុងស្ទឹងយមុនា ។ ចំណែកព្រះមជ្ឈិមកាណកាចារ្យទាំងឡាយ បានពោលរឿងដែលទាក់ទងការធ្វើមង្គលនៃទារកនោះ កាលបើទារកនោះកើតបាន ៥ ថ្ងៃ មាតាបិតា ព្រមទាំងពពួកញាតិឲ្យគេចាត់ចែងធ្វើមង្គល មានការកោរសក់ជាដើម ក៏បានដាក់នាមឲ្យទារកនោះ ទើបឲ្យពពួកកីលៀង ឬមេដោះនាំយកទៅងូតទឹកជម្រះខ្លួនក្នុងស្ទឹងយមុនា ។ ក្នុងខណៈនោះ មានត្រីធំហែលមកតាមក្រសែទឹក

បានក្រឡេកឃើញទារកនោះ សម្គាល់ថាជាអាហារ ទើបត្របាក់យកទារកលេបចូលទៅក្នុងពោះ ។

ធម្មតាអ្នកមានបុណ្យបារមីដូចទារកនេះ រមែងមិនមានអន្តរាយ សូម្បីនឹងចូលទៅនៅក្នុងពោះត្រីនោះក៏ដោយ ការលំបាកត្រឹមតែបន្តិចបន្តួចក៏មិនមាន ប៉ុន្តែត្រឡប់ដេកយ៉ាងសប្បាយ ដូចដេកនៅលើដំណាក់ដ៏ប្រសើរ ។ ដោយអាស្រ័យតេជៈបុណ្យបារមីរបស់ទារកនោះ ក៏បណ្តាលឲ្យត្រីនោះកើតការក្តៅក្រហល់ក្រហាយ ហាក់បីដូចថា លេបដុំរងើកភ្លើងដ៏ក្តៅចូលទៅក្នុងពោះដូច្នោះ ។ ការក្តៅក្រហល់ក្រហាយដែលកើតឡើងនៅខាងក្នុងខ្លួនរបស់ត្រីនោះ ធ្វើឲ្យត្រីហែលត្រដាបត្រដួស ហែលឆ្វេងកាត់ផ្លូវរហូតដល់ ៣០ យោជន៍ ចៃដន្យវង្វេងចូលទៅជាប់សំណាញ់របស់អ្នកនេសាទ នៅក្នុងនគរពារាណសី ។

គ្រប់គ្រា ក្នុងពេលមានត្រីធំជាប់សំណាញ់ រមែងត្រូវស្លាប់នៅក្នុងសំណាញ់នោះ ហើយទើបលើកឡើងមក ប៉ុន្តែត្រីនេះ ត្រូវអ្នកនេសាទជួយគ្នាដោះចេញអំពីសំណាញ់រួចហើយ ក៏ស្លាប់ល្មម ដោយមិនត្រូវសម្លាប់ ។ ដោយបុណ្យកុសលរបស់ទារកនោះ បានសន្សំមកហើយ ធម្មតាអ្នកនេសាទ ពេលណាបានត្រីធំ គេសម្លាប់រួចហើយ ពួកគេនឹងពន្លះ ឬកាត់ចេញជាកំណាត់តូចៗ ខ្លះ ជាកំណាត់ធំៗ ខ្លះ ប៉ុន្តែត្រីនេះមិនត្រូវពន្លះ ឬកាត់ជាកំណាត់តូចធំឡើយ យកទៅលក់ទាំងមូល ។

អ្នកនេសាទ នាំគ្នាសែងយកត្រី ទៅពពាយនាយលក់ក្នុងក្រុង ដោយតម្លៃមួយពាន់កហាបណៈ ប៉ុន្តែមិនមាននរណាទិញ ព្រោះតម្លៃថ្លៃពេក ។ ក្នុងក្រុងពារាណសី មានត្រកូលសេដ្ឋីម្នាក់ មានទ្រព្យសម្បត្តិ ៨០ កោដិ ប៉ុន្តែជាត្រកូលដែលមិនមានបុត្រធីតា ។ អ្នកនេសាទបានដើរពពាយនាយលក់ត្រីនោះ រហូតដល់ផ្ទះលោកសេដ្ឋីនោះ ។ លោកសេដ្ឋីបានឃើញអ្នកនេសាទនាំយកត្រីមកលក់ ទើបសួរថា ត្រីនេះលក់តម្លៃប៉ុន្មាន ? អ្នកនេសាទឆ្លើយថា លក់តម្លៃមួយពាន់កហាបណៈ លោកសេដ្ឋីក៏សម្រេចចិត្តថាទិញ ទើបជូនប្រាក់មួយពាន់កហាបណៈឲ្យទៅអ្នកលក់ត្រីនោះ ដោយមិនបានតថ្លៃអ្វីឡើយ ។ ថ្ងៃដទៃៗ កិរិយារបស់លោកសេដ្ឋី មិនធ្លាប់មករវល់ទាក់ទិនជាមួយនឹងរឿងការធ្វើត្រី ឬធ្វើសាច់អ្វីឡើយ ប៉ុន្តែក្នុងថ្ងៃនេះ កិរិយារបស់លោកសេដ្ឋីបានធ្វើដោយខ្លួនឯង មានការពន្វះសាច់ត្រីម្តងបន្តិចៗ ក៏បានឃើញទារកនៅក្នុងពោះត្រីនៅមានជីវិតនៅឡើយ ទារកនោះមានពណ៌សម្បុរដូចជាមាស កាលបើកិរិយារបស់លោកសេដ្ឋីបានឃើញទារកហើយ ក៏កើតសេចក្តីស្រឡាញ់ដូចជាកូនបង្កើតរបស់ខ្លួន ហើយនិយាយចេញដោយសំឡេងខ្លាំងថា យើងបានបុត្រក្នុងពោះត្រីហើយ និងនាំយកទារកនោះទៅរកលោកសេដ្ឋីជាស្វាមី ។

លោកសេដ្ឋីនៅមិនទាន់ព្រមប្រកាន់យកជាកម្មសិទ្ធិ ដើម្បីទុកដូចជាកូនរបស់ខ្លួនឡើយ ទើបឲ្យគេវាយស្គរស្រែកប្រកាសថា អ្នកណាមាន

កូនបាត់ដែរឬទេ ? ចូរមកយកទៅចុះ ។ កាលបើមិនមាននរណាមកទទួលទារកនោះ លោកសេដ្ឋីបាននាំយកទារកនោះចូលទៅគាល់ព្រះបាទពារាណសី ក្រាបបង្គំទូលឲ្យទ្រង់ជ្រាបរឿងហើយ ក៏ក្រាបទូលសួរថា ខ្ញុំព្រះអង្គនឹងធ្វើដូចម្ដេចចំពោះទារកនេះ ។

ព្រះបាទពារាណសីត្រាស់តបថា នែលោកសេដ្ឋី ទារកនេះជាអ្នកមានបុណ្យច្រើនណាស់ ទើបមិនមានអន្តរាយ កាលដែលគេនៅក្នុងពោះត្រី លោកចូរចិញ្ចឹមទុកចុះ ។ សេដ្ឋី និងភរិយាបានចិញ្ចឹមទារកនោះទុកដូចជាកូន មិនមានស្អប់ខ្ពើមឆ្អើមសូម្បីបន្តិចបន្តួចឡើយ ។ កាលតមកត្រកូលសេដ្ឋីដែលជាមាតាបិតា នៅក្នុងក្រុងកោសម្ពីក៏ដឹងរឿងរ៉ាវ ឮដំណឹងថា មានត្រកូលសេដ្ឋីនៅក្នុងក្រុងពារាណសី បានទារកនៅក្នុងពោះត្រី ក៏ប្រញាប់នាំគ្នាមកកាន់ផ្ទះលោកសេដ្ឋី នៅក្នុងក្រុងពារាណសីនោះមួយរំពេច ។

ក្នុងខណៈដែលមកដល់ផ្ទះលោកសេដ្ឋី ក្នុងក្រុងពារាណសីនោះ ពីរនាក់ស្វាមី និងភរិយា ដែលជាសេដ្ឋីក្នុងក្រុងកោសម្ពី ជាមាតាបិតាបង្កើតរបស់ទារកនោះ ក្រឡេកឃើញទារកនោះកំពុងតែលេង ក៏ចាំបានថាជាបុត្ររបស់ខ្លួន ទើបនិយាយឡើងថា ទារកនេះគួរឲ្យអាណិតណាស់ ប៉ុន្តែទារកនេះជាកូនរបស់យើង ក៏បានសម្តែងហេតុផលតាំងអំពីខាងដើមទាល់តែចប់ ឲ្យសេដ្ឋីក្នុងក្រុងពារាណសីស្តាប់ ហើយចេញវាចាសូមកូន

មកវិញ ។ ចំណែកកិរិយារបស់សេដ្ឋីក្នុងក្រុងពារាណសី មិនព្រមប្រគល់ឲ្យឡើយ ដោយអាងថា ទារកនេះបានមកអំពីពោះត្រី ដែលខ្លួនទិញតម្លៃមួយពាន់កហាបណៈ ព្រោះដូច្នោះ ទារកនេះសូម្បីមិនមែនជាកូនរបស់ខ្លួនពិតប្រាកដក៏ដោយ ក៏ហាក់បីដូចជាកូនរបស់ខ្លួន មិនព្រមឲ្យទៅជាដាច់ខាត ។ ខាងមាតាបិតាពិតប្រាកដ បាននិយាយអង្វរគ្រប់យ៉ាងថា ទារក នេះមិនមែនបុត្ររបស់លោកពិតប្រាកដទេ គារពិតជាបុត្ររបស់ខ្ញុំ ព្រោះគេនៅក្នុងពោះរបស់ខ្ញុំ ១០ ខែ ។ ចំណែកមាតាបិតាចិញ្ចឹមបាននិយាយជំទាស់តទៅទៀតថា បុត្ររបស់អ្នកអាចនឹងត្រូវត្រីដទៃលេបស៊ីបាត់ទៅហើយ គង់មិនមែនត្រីដែលខ្ញុំបានទារកនេះមកទេ ។ សេដ្ឋីដែលជាមាតាបិតាពិតប្រាកដ ឃើញអាកប្បកិរិយាថាមិនព្រមឲ្យ ទើបនាំគ្នាចូលទៅគាល់ព្រះបាទពារាណសី ដើម្បីឲ្យព្រះអង្គជួយវិនិច្ឆ័យក្នុងរឿងក្តីនេះ ។

ព្រះបាទពារាណសីទ្រង់វិនិច្ឆ័យថា នរណាៗ មិនអាចសម្រេចបានថា មាតាដើមនោះ មិនមែនមាតារបស់ទារកនេះ ព្រោះទារកនេះបានរស់នៅក្នុងផ្ទៃរបស់មាតាដើម ១០ ខែដែរ ។ អ្នកលក់ត្រីនោះ កាលបើបានលក់ទៅហើយ មិនបានទទួលត្រីនោះទុក ទើបមិនចាត់ថាជាមាតាបិតារបស់ទារកនេះ ។ ចំណែកកិរិយារបស់លោកសេដ្ឋីក្នុងក្រុងពារាណសី នរណាៗ ក៏មិនអាចសម្រេចបានថា មិនមែនមាតារបស់ទារក ព្រោះបានទារកមកពីក្នុងពោះត្រី ។ ព្រោះដូច្នោះ ទើបឲ្យទារកនេះជា

ទាយាទរបស់ត្រកូលទាំងពីរ និងឲ្យត្រកូលទាំងពីរជួយអភិបាលចិញ្ចឹមទារកនេះ ។ ចាប់ផ្តើមអំពីនោះមក ត្រកូលសេដ្ឋីទាំងពីរនោះ មានតែការចម្រើនឡើងដោយលាភយស ជាលំដាប់លំដោយមក ។ ត្រកូលសេដ្ឋីទាំងពីររួមគ្នាដាក់ឈ្មោះឲ្យកុមារនោះថា **ពាកុលៈ** ឬ **ពក្កុលៈ** ព្រោះជាអ្នកស្ថិតនៅក្នុងការគ្រប់គ្រងរបស់ត្រកូលទាំងពីរ ។ កាលបើពក្កុលៈធំពេញវ័យហើយ ត្រកូលទាំងពីរបានកសាងប្រាសាទ ៣ ខ្នង ទុកក្នុងក្រុងរបស់ខ្លួន រៀងៗ ខ្លួន ឲ្យដល់ពក្កុលៈនោះ ពក្កុលៈស្នាក់អាស្រ័យនៅក្នុងក្រុងទាំងពីរនោះ ក្រុងទីមួយៗ ៤ ខែ ចំណែកពេលដែលនៅសល់អំពី ៤ ខែទៀតនោះ ជាពេលធ្វើដំណើរក្នុងរវាងក្រុងទាំងពីរ ដោយទូក ។ កាលបើពក្កុលៈនៅក្រុងទីមួយៗ គ្រប់ ៤ ខែហើយ ទើបត្រកូលទាំងពីរឲ្យចាត់ចែងកសាងមណ្ឌបឡើងលើទូក ហើយឲ្យពក្កុលៈ ជាមួយនឹងអ្នកបម្រើឡើងទៅនៅក្នុងមណ្ឌបលើទូកនោះ ហើយបញ្ជូនទៅកាន់ក្រុងមួយទៀត ដែលចំណាយពេលប្រមាណ ៤ ខែ ។

ចំណែកអ្នកក្រុងមួយទៀត កាលឃើញពួកគេជូនមកបានពាក់កណ្តាលផ្លូវ អស់ពេលពីរខែហើយ បាននាំគ្នាចេញទៅទទួលចូលមកកាន់ក្រុងរបស់ខ្លួន ក៏ចំណាយពេលពីរខែទៀតដូចគ្នា រួមពេលធ្វើដំណើរទាំងអស់ ៤ ខែ ។ កាលបើពក្កុលៈនៅក្នុងត្រកូលនោះគ្រប់ ៤ ខែហើយ ទើបប្រញាប់ទៅក្រុងមួយទៀត ប្រើពេល ៤ ខែទៀតដូចគ្នា ជាការ

ផ្ទាស់ប្តូរវិលទៅវិលមកនោះ  រាប់ពេលដែលពក្កុលៈសោយនូវសេចក្តីសុខនេះបាន ៨០ ឆ្នាំពេញ ។

ក្នុងគ្រានោះ ព្រះសិទ្ធត្ថពោធិសត្វរបស់យើង ទ្រង់បានសម្រេចសម្ពោធិញ្ញាណ ជាព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរ ហើយស្តេចចារិកទៅដោយលំដាប់  រហូតមកដល់ក្រុងកោសម្ពី  ប៉ុន្តែមជ្ឈិមកាណកាចារ្យទាំងឡាយ បានពោលទុកថា ស្តេចយាងមកដល់ក្រុងពារាណសី  ពក្កុលៈជ្រាបដំណឹងការយាងមកដល់នៃព្រះមានព្រះ-ភាគ ទើបព្រមដោយបរិវារមានចំនួនច្រើន បានកាន់ផ្កាឈើ និងគ្រឿងក្រអូបចូលទៅគាល់ព្រះសម្ពុទ្ធ ដើម្បីនឹងបានស្តាប់ធម៌ទេសនា ហើយក៏មានសទ្ធាជ្រះថ្លា ប្រាថ្នានឹងបព្វជ្ជាឧបសម្បទានៅក្នុងធម្មវិន័យនេះ ទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទាចំពោះព្រះលោកនាថ ។

កាលបើពក្កុលៈ  បានទទួលព្រះពុទ្ធានុញ្ញាត  ការបព្វជ្ជាឧប-សម្បទាជាភិក្ខុហើយ បានស្តាប់ពុទ្ធោវាទ ដែលព្រះអង្គទ្រង់ប្រៀនប្រដៅមិនឲ្យប្រមាទ ឲ្យព្យាយាមប្រឹងប្រែងចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ក្នុងថ្ងៃទី ៨ ក៏បានសម្រេចជាព្រះអរហន្ត ព្រមដោយបដិសម្ភិទា ៤ រាប់ពីថ្ងៃដែលបព្វជ្ជាឧបសម្បទាមក ។ ចាប់ផ្តើមពីថ្ងៃសម្រេចកិច្ចនៃបព្វជ្ជាឧបសម្បទាហើយ  ព្រះពក្កុលត្ថេរឧស្សាហ៍ប្រកបកិច្ចក្នុងព្រះពុទ្ធ-សាសនា រហូតប្រាកដថា លោកប្រព្រឹត្តប្រតិបត្តិតឹងរឹងបំផុតក្នុងនេសជ្ជិក-

ធុតង្គ គឺការសមាទានអង្គុយមិនព្រមសឹង និងអារញ្ញិកធុតង្គ បានដល់ការសមាទាននៅក្នុងព្រៃជាប្រក្រតី ។

ចំណែកពួកអ្នកបម្រើរបស់លោក កាលនៅជាយរាវាស នៅក្នុងក្រុងទាំងពីរនោះ បាននាំគ្នាទៅកាន់ក្រុងវៀងៗ ខ្លួន រួចហើយបានធ្វើសំពត់ត្រៃចីវរបញ្ជូនទៅប្រគេន ព្រះពក្កុលត្ថេរមានចំនួនច្រើន ចំណែកព្រះពក្កុលត្ថេរ បានប្រើប្រាស់ត្រៃចីវរដែលបញ្ជូនពីក្រុងកោសម្ពី និងក្រុងពារាណសីនោះ មួយចំណែកៗ កន្លះខែរហូតជានិច្ច ។ វត្ថុណាជារបស់ល្អ ដែលមាននៅក្នុងត្រកូលទាំងពីរ សេដ្ឋីទាំងពីរក្រុងនោះ បានបញ្ជូនវត្ថុនោះៗ ទៅប្រគេនព្រះពក្កុលត្ថេរ មិនដែលលុះពេលឡើយ ។

ក្នុងពេលដែលព្រះពក្កុលត្ថេរ នៅជាយរាវាសរហូតអស់រយៈពេល ៨០ ឆ្នាំនោះ លោកមិនដែលមានជំងឺអ្វីឡើយ សូម្បីត្រឹមតែបន្តិចបន្តួចក៏មិនមាន ។ ចាប់ផ្តើមពីលោកបានបព្វជ្ជាឧបសម្បទាមកហើយ ក៏មិនដែលមានអាពាធសោះ ទាំងមិនខ្វះខាតនូវបច្ច័យ ៤ ទៀត ។

មូលហេតុដែលលោកមិនមានអាពាធនៅក្នុងបច្ចុប្បន្នជាតិនេះ ដោយអំណាចបុណ្យកុសលដែលធ្លាប់ប្រគេនថ្នាំ និងការតាំងសេចក្តីប្រាថ្នាទុកក្នុងអតីតជាតិ ព្រះមានព្រះភាគ ទើបទ្រង់តែងតាំងលោកទុកក្នុងតំណែងជាឯតទគ្គៈ ផ្នែកខាងអ្នកគ្មានអាពាធ ដែលបានពោលទុក ក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាត មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ព្រះពក្កុលត្ថេរ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងអ្នកគ្មានអាពាធ ។ កាលបើព្រះពក្កុលត្ថេរ បានសម្រេចជាព្រះអរហន្ត និងបានទទួលតំណែងឯតទគ្គៈហើយ លោកបានពោលគាថា ៣ គាថា ក្នុងចំណោមភិក្ខុសង្ឃ ដែលប្រាកដសេចក្ដីនៅក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា ថា ៖

បុគ្គលណា មិនធ្វើនូវអំពើដែលគួរធ្វើ ក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញ បុគ្គលនោះរមែងឃ្លាតចាកឋានៈជាសុខផង តែងក្ដៅក្រហាយរឿយៗ ក្នុងជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណា ត្រូវនិយាយតែអំពើនោះ មិនធ្វើអំពើណា មិនត្រូវនិយាយអំពើនោះឡើយ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គល កាលមិនធ្វើ បានតែនិយាយ ។ សេចក្ដីទុក្ខរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងហើយ ជាគុណជាតមិនមានសេចក្ដីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្តនាំមកនូវសេចក្ដីសុខ ដោយប្រពៃមែនពិត ។

កិច្ចការផ្សារព្រះសាសនា ដែលរាប់ថា ជាការសំខាន់របស់ព្រះពក្កុលត្ថេរ បានដល់ ការប្រាស្រ័យចរចាឆ្លើយឆ្លងគ្នា ជាមួយអចេលកស្សប ដែលជាសម្លាញ់ចាស់របស់លោកឲ្យកើតការយល់ចូលចិត្ត ឲ្យមានការជឿជ្រះថ្លាក្នុងព្រះសាសនា ដូចមានរឿងប្រាកដនៅក្នុង គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ មានន័យថា ៖

សម័យមួយ ព្រះពក្កុលៈមានអាយុ នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង អចេលឈ្មោះកស្សប ជាសម្លាញ់របស់ព្រះពក្កុលៈមានអាយុ ក្នុងកាលនៅជាគ្រហស្ថពីដើម បានចូលទៅរកព្រះពក្កុលៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់ សំណេះសំណាល ទៅរកព្រះពក្កុលៈមានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះអចេលកស្សបអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះពក្កុលៈមានអាយុដូច្នេះថា បពិត្រព្រះពក្កុលៈមានអាយុ លោកម្ចាស់បួសយូរប៉ុន្មានឆ្នាំហើយ ។ ព្រះពក្កុលៈឆ្លើយថា អាត្មាបួស ៨០ វស្សាហើយ ។ អចេលកស្សបសួរទៀតថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង ? ម្នាលអាវុសោកស្សប អ្នកកុំសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង យ៉ាងនេះឡើយ ម្នាលអាវុសោកស្សប អ្នកត្រូវសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ កាមសញ្ញារបស់លោកធ្លាប់កើតប៉ុន្មានដង យ៉ាងនេះវិញ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមសញ្ញាកើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានកាមសញ្ញាកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុក នូវហេតុនេះ ថា

ជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទសញ្ញា... មិនដែលមានវិហិង្សាសញ្ញា កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហិង្សាសញ្ញា កើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមវិតក្កកើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានកាមវិតក្កកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទវិតក្ក... មិនដែលមានវិហិង្សាវិតក្ក កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហិង្សាវិតក្ក កើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនធ្លាប់ត្រេកអរនឹងគហបតីចីវរទេ ។ ព្រះពក្កុលៈមានអាយុ មិនធ្លាប់ត្រេក-អរនឹងគហបតីចីវរអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនធ្លាប់កាត់ចីវរ

ដោយកាំបិតទេ... អាត្មាមិនធ្លាប់ដេរចីវរដោយម្ជុលទេ... មិនធ្លាប់ជ្រលក់ចីវរដោយគ្រឿងជ្រលក់ទេ... មិនធ្លាប់ដេរចីវរលើឈើស្នឹងទេ... មិនធ្លាប់ចាត់ចែងចីវរកម្ម របស់សព្រហ្មចារីបុគ្គលទាំងឡាយទេ... មិនធ្លាប់ត្រេកអរនឹងការនិមន្តទេ... មិនធ្លាប់មានគំនិតឡើងថា ធ្វើដូចម្តេចហ្ន៎ បុគ្គលណាមួយ គប្បីមកនិមន្តអញទេ ។បេ។ អាត្មាមិនដែលអង្គុយក្នុងចន្លោះផ្ទះទេ... មិនដែលឆាន់ក្នុងចន្លោះផ្ទះទេ... មិនដែលកាន់យកនិមិត្តរបស់មាតុគ្រាម ដោយអនុព្យញ្ជនៈទេ... មិនដែលសម្តែងធម៌ដល់មាតុ-គ្រាម ដោយហោចទៅសូម្បីតឹមតែគាថា ៤ បទទេ... មិនដែលចូលទៅកាន់សម្នាក់ភិក្ខុនីទេ... មិនដែលសម្តែងធម៌ដល់ភិក្ខុនីទេ... មិនដែលសម្តែងធម៌ដល់សិក្ខមានាទេ... មិនដែលសម្តែងធម៌ដល់សាមណេរីទេ... មិនដែលបំបួសទេ... មិនដែលឲ្យឧបសម្បទាទេ... មិនដែលឲ្យនិស្ស័យទេ...មិនដែលឲ្យសាមណេរបម្រើទេ មិនដែលស្រប់កាយក្នុងផ្ទះសម្រាប់កម្តៅកាយទេ... មិនដែលស្រប់កាយដោយគ្រឿងលម្អិតទេ... មិនដែលត្រេកអរនឹងការគក់ប្របាច់ខ្លួន របស់សព្រហ្មចារីបុគ្គលទេ... មិនដែលមានអាពាធកើតឡើង ដោយហោចទៅ សូម្បីតែដំណួចពិសទេ... មិនដែលផ្អែកបង្អែកទេ... មិនដែលដេកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលដេកអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំសូមចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលចូលវស្សាក្នុងទីសេនាសនៈ ក្នុងស្រុកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលចូលវស្សាក្នុងទីសេនាសនៈក្នុងស្រុកអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំសូមចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ អាត្មាប្រកបដោយកិលេស ឆាន់បិណ្ឌបាតរបស់អ្នកដែន តែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ។ ព្រះពក្កុលៈមានអាយុ ប្រកបដោយកិលេស ឆាន់បិណ្ឌបាតរបស់អ្នកដែនតែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ដោយហេតុណា យើងខ្ញុំសូមចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

បពិត្រព្រះពក្កុលៈមានអាយុ ខ្ញុំគប្បីបាននូវបព្វជ្ជា គប្បីបាននូវឧបសម្បទាក្នុងធម្មវិន័យនេះ ។ អចេលកស្សបក៏បាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងធម្មវិន័យនេះ ។ លុះព្រះកស្សបបានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយចេញចាកផ្ទះ ទៅបួសក្នុងផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម ចំពោះខ្លួនឯងក្នុងបច្ចុប្បន្ន ហើយ

សម្រាកសម្រាន្តនៅដោយឥរិយាបថទាំង ៤ រមែងដឹងថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តមួយរូបដែរ ។ លុះសម័យជាខាងក្រោយមក ព្រះពក្កុលៈមានអាយុ កាន់យកកូនសោ ចេញអំពីវិហារចូលទៅកាន់វិហារ ហើយពោលពាក្យយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃនេះ ។ ព្រះកស្សបពោលថា ព្រះពក្កុលៈមានអាយុ បានកាន់យកកូនសោ ចេញអំពីវិហារចូលទៅកាន់វិហារ ហើយពោលយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃនេះ ដោយហេតុណា ខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ឯព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្តាលភិក្ខុសង្ឃ ។ ព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្តាលភិក្ខុសង្ឃ ដោយហេតុណា ខ្ញុំក៏ចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

មានរឿងដែលទាក់ទងនឹងអាយុវែង និងការរំលត់ខន្ធបរិនិព្វាន

របស់ព្រះពក្កុលត្ថេរ ក្នុងអដ្ឋកថា បបញ្ចសូទនី ដែលអធិប្បាយសេចក្តីព្រះបាលី ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ និងគម្ពីរមជ្ឈិមនិកាយ ឧបរិ-បណ្ណាសកៈ មានសេចក្តីថា ៖

ព្រះពក្កុលត្ថេរ រាប់ថាជាអ្នកមានអាយុវែងជាងគេមួយរូប ក្នុងបណ្តាអសីតិមហាសាវកទាំងអស់ ព្រោះលោកមានអាយុបាន ១៦០ ឆ្នាំម្យ៉ាងទៀត មុននឹងលោកបរិនិព្វាន បានអធិដ្ឋានចិត្តថា កាលខ្ញុំព្រះ-ករុណាមានជីវិតរស់នៅ ក៏មិនធ្លាប់ជាភារៈរបស់ភិក្ខុរូបណាមួយឡើយ កាលបើខ្ញុំព្រះករុណាបរិនិព្វានទៅ សូមកុំឲ្យសរីរៈរបស់ខ្ញុំព្រះករុណាជាភារៈស្មុគស្មាញ ធ្ងន់ធ្ងរដល់ភិក្ខុសង្ឃឡើយ ហើយលោកទើបអង្គុយចូលតេជោធាតុ បរិនិព្វានទៅ នៅក្នុងចំណោមទីប្រជុំសង្ឃនោះ ។

កាលបើលោកបរិនិព្វានទៅហើយ បានមានអណ្តាតភ្លើងចេញពីសរីរៈរបស់លោក ឆេះសរីរៈឲ្យសល់តែអដ្ឋិធាតុ ដែលមានសណ្ឋានស្រដៀងនឹងផ្កាម្លិះក្រពុំ ។

( ជីវប្រវត្តិរបស់ព្រះពក្កុលត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះពាហិយទារុចីរិយត្ថេរ ✍

### " ដែលជាឯតទគ្គៈផ្នែកខាងត្រាស់ដឹងឆាប់រហ័ស "

*សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន មហាវិហារ ទៀបក្រុងសាវត្ថី បានត្រាស់ប្រារព្ធព្រះពាហិយទារុចីរិយត្ថេរ លោកមានអច្ឆរិយភាពផ្នែកខាងបញ្ញារហ័ស ដែលបានទទួលការលើក តម្កើងដ៏ប្រសើរអំពីព្រះសម្មាសម្ពុទ្ធ ទុកនៅក្នុងឋានៈ ខិប្បាភិញ្ញា បាន ដល់ ការត្រាស់ដឹងឆាប់រហ័ស ។*

*ព្រះពាហិយទារុចីរិយត្ថេរ ដែលបានទទួលការតែងតាំងឲ្យជាអ្នក ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងការត្រាស់ដឹងបានឆាប់រហ័សនោះ ព្រោះថា លោកបានសម្រេចជាព្រះអរហន្ត ក្នុងកាលចប់ព្រះធម៌ទេសនា ដែលព្រះលោកនាថ ទ្រង់សម្តែងដោយអត្ថ គឺសេចក្តី និងកិច្ចដែលនឹង ធ្វើក្នុងមគ្គនិងផលទាំងឡាយដទៃៗ នោះមិនធ្លាប់មានឡើយ នេះជាហេតុ មួយ ចំណែកហេតុមួយទៀត មានរឿងតំណាលទុកក្នុងអដ្ឋកថា គម្ពីរ ធម្មបទ នៃសហស្សវគ្គ ក្នុងរឿងទារុចីរិយត្ថេរ ក្នុងអដ្ឋកថា បរមត្ថទីបនី និងក្នុងអដ្ឋកថា មនោរថបូរណី មានសេចក្តីថា ៖*

*ក្នុងពុទ្ធកាលនៃព្រះបទុមុត្តរៈ ព្រះពាហិយទារុចីរិយត្ថេរ បានកើត នៅក្នុងត្រកូលមួយ នៅក្នុងនគរហង្សវតី ថ្ងៃមួយ បានទៅស្តាប់ព្រះធម៌*

ទេសនាព្រះបទុមុត្តរៈ ក្នុងពេលចប់ការសម្តែងធម៌ លោកបានឃើញភិក្ខុមួយរូប បានទទួលការតែងតាំងអំពីព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងខិប្បាភិញ្ញា គឺត្រាស់ដឹងបានឆាប់រហ័ស ក៏នឹកចង់បានតំណែងនោះ ទើបឧស្សាហ៍ធ្វើអធិការកុសលក្នុងសម្នាក់ព្រះសម្ពុទ្ធបទុមុត្តរៈ ក៏បានតាំងសេចក្តីប្រាថ្នាចំពោះតំណែងនោះ ហើយព្យាយាមបំពេញបុណ្យកុសល សេចក្តីល្អគ្រប់យ៉ាង ដរាបរហូតអស់ជីវិត ។

កាលបើលោកមានការត្រាច់រង្គាត់ទៅក្នុងមនុស្សទេវតា អស់កាលដ៏យូរអង្វែង រហូតមកដល់សាសនានៃព្រះសម្មាសម្ពុទ្ធកស្សប ប៉ុន្តែជាពេលដែលព្រះកស្សបសម្ពុទ្ធ ស្តេចរំលត់ខន្ធបរិនិព្វានទៅហើយ លោកក៏បានបព្វជ្ជាជាភិក្ខុ ក្នុងពេលដែលព្រះពុទ្ធសាសនាកំពុងធ្លាក់ចុះ ។ ក្នុងកាលនោះ មានភិក្ខុ ៧ រូប ក្នុងចំណោម ៧ រូបនោះ មានព្រះពាហិយទារុចីរិយត្ថេរមួយរូបផងដែរ កាលបើបានឃើញភិក្ខុទាំងឡាយ មិនមានសេចក្តីគោរពចំពោះព្រះធម៌ ព្រះវិន័យ ក៏កើតមានសេចក្តីសង្វេគតក់ស្លុតចិត្តឡើង ភិក្ខុទាំង ៧ រូបនោះ ទើបប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើយ៉ាងណា មានតែពួកយើងគេចទៅធ្វើសមណធម៌ ក្នុងស្ថានទីដ៏សមគួរទើបបាន កាលបើប្រឹក្សាគ្នារួចហើយ បាននាំគ្នាជួយធ្វើបង្អោនដើម្បីដាក់ឡើងទៅលើកំពូលភ្នំដ៏ខ្ពស់ ទើបបាននិយាយថា បើអ្នកណាមានការអាល័យ

ចំពោះជីវិតនេះ ចូរចុះពីភ្នំនេះទៅ មិនមានអង្គណាមួយចុះឡើយ ទើបប្រានបង្អោនទម្លាក់ទៅក្រោមវិញ ។

បន្ទាប់អំពីនោះមក ទើបនិយាយជាសំតឿនទូវគ្នានិងគ្នាថា នែអ្នកដ៏មានអាយុ លោកទាំងឡាយកុំមានសេចក្តីប្រមាទឡើយ ពោលជាសំតឿនគ្នារួចហើយមួយរូបៗ ក៏ចេញទៅរកទីកន្លែងដ៏សមគួរ ទើបចាប់ផ្តើមធ្វើសមណធម៌ ជាអ្នកមានការស្វែងរកមោក្ខធម៌ បានដល់ ធម៌ដែលនាំចេញចាកកិលេស ។ កាលកន្លងទៅបានប្រាំថ្ងៃ ព្រះមហាថេរៈមួយរូបក៏បានសម្រេចនូវព្រះអរហត្តផល លុះថ្ងៃរះឡើងមក លោកទើបហោះទៅលុបលាងមុខខ្ពុរមាត់នៅអនោតត្តស្រះ ក្នុងព្រៃហិមពាន្តហើយ ទើបទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប យកមកប្រគេនដល់ភិក្ខុទាំងឡាយ ដែលនៅលើកំពូលភ្នំនោះ ប៉ុន្តែភិក្ខុទាំងប្រាំមួយអង្គនោះ មិនព្រមទទួលឆាន់ ដោយពោលថា បើខ្ញុំព្រះករុណាមិនបានសម្រេចនូវធម៌ជាមុនទេ ខ្ញុំព្រះករុណាមិនឆាន់ចង្ហាន់នោះឡើយ ។

លុះដល់ថ្ងៃទី ៧ ព្រះថេរៈបន្ទាប់ ក៏បានសម្រេចជាព្រះអនាគាមីហើយ ក៏ហោះទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប យកមកប្រគេនភិក្ខុប្រាំរូបទៀតឆាន់ ប៉ុន្តែភិក្ខុទាំងប្រាំរូបនោះ មិនព្រមទទួលឆាន់ចង្ហាន់នោះឡើយ ដោយអាងហេតុផលដូចន័យមុនដែរ ។ កាលតមក ព្រះថេរៈដែលជាព្រះអរហន្តក៏រំលត់ខន្ធបរិនិព្វានទៅមុន ព្រះថេរៈដែលជាព្រះអនាគាមី មិន

យូរប៉ុន្មាន ព្រះថេរៈជាអនាគាមីនោះ ក៏ធ្វើមរណកាលទៅកើតក្នុងព្រហ្ម-លោកជាន់សុទ្ធាវាស ។

ចំណែកឯភិក្ខុប្រាំរូបទៀត កាលបើមិនអាចសម្រេចធម៌អ្វីបាន និង មិនព្រមឆាន់ចង្ហាន់មកច្រើនថ្ងៃ រាងកាយក៏ស្វិតស្រពោន ទើបដល់នូវ មរណកាលក្នុងថ្ងៃទីប្រាំពីរ ហើយទៅកើតក្នុងទេវលោក អស់រយៈពេល មួយពុទ្ធន្តរ ។ មកដល់កាលនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ភិក្ខុទាំង ៥ រូបនោះ បានចុតិអំពីទេវលោកមកកើតក្នុងមនុស្សលោកនេះ ចំណែក ព្រះពាហិយទារុចីរិយត្ថេរ បានមកកើតជាបុត្តរបស់កុដុម្ពិក ក្នុងដែនពា-ហិយៈ កាលបើលោកចម្រើនវ័យធំហើយ ក៏បានប្រកបអាជីពក្នុងការធ្វើ ជំនួញ ។ គ្រាមួយពាហិយៈ តាំងចិត្តនាំទំនិញទៅលក់នៅសុវណ្ណភូមិ ទើបដឹកទំនិញដាក់ក្នុងសំពៅ ហើយនាំទំនិញធ្វើដំណើរឆ្ពោះទៅកាន់ក្រុង នានា ប៉ុន្តែដល់ពាក់កណ្តាលមហាសមុទ្រ សំពៅនោះក៏ក្រឡាប់លិចចុះ ទៅ ។ ពួកជនដែលរួមដំណើរមកក្នុងសំពៅទាំងអស់ បានធ្វើជាចំណី របស់ត្រី និងអណ្តើកទាល់តែអស់ នៅសល់តែពាហិយៈម្នាក់ឯង ព្រោះ បានតោងបន្ទះក្តារមួយសន្ទឹក ហើយព្យាយាមហែលក្នុងមហាសមុទ្រអស់ ប្រាំពីរថ្ងៃ ក្នុងថ្ងៃចុងក្រោយ បានដល់កំពង់ទូកសុប្បារកៈ សំពត់ស្លៀក ដណ្តប់របស់ពាហិយៈគ្មានជាប់នឹងខ្លួនឡើយ ។

ពាហិយៈ កាលឡើងលើកំពង់ទូកសុប្បារកៈបានហើយ និងបានដឹង

ថាស្ថានទីនេះ មានប្រជាជនសង់ផ្ទះកសាងទីអាស្រ័យនៅ ទើបគិតចូលទៅរកផ្ទះរបស់ប្រជាជនទាំងនោះ ប៉ុន្តែពាហិយៈបែរមកគិតថា ការដែលយើងចូលទៅដោយមិនបានស្លៀកដណ្តប់សំពត់ដូច្នេះ ជាការមិនសមរម្យមិនគួរ ទើបទៅយកសារាយមកក្រង ហើយកាន់យកអំបែងមួយដើរទៅសូមអាហារក្នុងផ្ទះផ្សេងៗ ដើម្បីយកមកចិញ្ចឹមជីវិត ។

ជនទាំងឡាយ កាលបើបានឃើញពាហិយៈដោយមិនដឹងថា ជានរណា មកពីទីណា ទើបគិតថា ប្រាកដជាព្រះអរហន្តរបស់យើងហើយ ដែលមាននៅក្នុងលោកនេះ ព្រោះព្រះអរហន្តទាំងឡាយ ជាអ្នកមានសេចក្តីប្រាថ្នាតិច អ្នកនេះពិតប្រាកដមែន ពីព្រោះលោកមិនមានសំពត់ស្លៀកដណ្តប់ ដូច្នេះដើម្បីដឹងការពិត យើងត្រូវសាកល្បងមើល ឲ្យដឹងជាក់ច្បាស់ ទើបចាត់ចែងនាំយកសំពត់ស្លៀកដណ្តប់ មានចំនួនជាច្រើនមកឲ្យដល់ពាហិយៈ ។ ពាហិយៈ បានគិតថាប្រសិនបើយើងមិនទទួលយកទេ បុគ្គលទាំងនេះ ក៏គង់នឹងជ្រះថ្លាចំពោះយើង យើងនឹងបញ្ឆោតជនទាំងនេះ ដើម្បីរកផ្លូវចិញ្ចឹមជីវិត គិតដូច្នេះហើយ ក៏ពោលបដិសេធមិនព្រមទទួលយកសំពត់ស្លៀកដណ្តប់ ដែលបុគ្គលទាំងឡាយនោះ នាំយកមកឲ្យ ។ កាលបើដឹងថា លោកមិនព្រមទទួលហើយ ក៏មានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង និងនាំគ្នាយកអាហារមកឲ្យ និងធ្វើសក្ការបូជាដល់ពាហិយៈយ៉ាងច្រើន ។

កាលបើពាហិយៈ បរិភោគអាហារ ដែលពួកអ្នកស្រុកនាំយកមកឲ្យ រួចហើយទើបទៅរកទីកន្ទែងស្នាក់អាស្រ័យដែលតាំងនៅក្បែរនឹងតំបន់នោះ ជនជាច្រើននាំគ្នាជួយរៀបចំទីសេនាសនៈ ឲ្យដល់ពាហិយៈហើយ ។ ហេតុការណ៍ដែលកន្ទងមកធ្វើឲ្យពាហិយៈពិចារណាឃើញថាជនទាំងនេះជ្រះថ្លានឹងយើង ព្រោះតែយើងស្លៀកសារាយបិទបាំងកាតអៀនខ្មាស ទើបនាំគ្នាមកធ្វើសក្ការបូជាដល់យើង យើងគួរនឹងធ្វើឲ្យឧក្រិដ្ឋក្រៃលែងឡើងជាងនេះទៅទៀត ហើយក៏បានទៅយកសំបកឈើធ្វើជាសំពត់ស្លៀកដណ្តប់ ទើបមានឈ្មោះពាហិយទារុចិរិយៈ ប្រែថា ពាហិយៈអ្នកស្លៀកដណ្តប់សំពត់សំបកឈើ ក៏បានអាស្រ័យចិញ្ចឹមជីវិតនៅក្នុងទីនោះឯង ។

ជីវប្រវត្តិរបស់ពាហិយទារុចិរិយត្ថេរ ក្នុងវគ្គតទៅនេះ ក្រោយពីបានពោលទុកក្នុងអដ្ឋកថាគម្ពីរផ្សេងៗ រួចមកហើយ នៅមានប្រាកដក្នុងពាហិយសូត្រទៀត ក្នុងគម្ពីរខុទ្ទកនិកាយ ឧទាន ថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ សម័យនោះឯង ពាហិយទារុចិរិយបុស ( អ្នកស្លៀកសំពត់សំបកឈើឈ្មោះពាហិយៈ ) អាស្រ័យនៅទៀបឆ្នេរសមុទ្រឈ្មោះសុប្បារកៈ ជាអ្នកដែលគេធ្វើសក្ការៈ គោរព រាប់អាន បូជាកោតក្រែង បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ

គេសជួបរិក្ខារ ។ កាលពាហិយបុរស ពួនសម្ងំក្នុងទីស្ងាត់ ស្រាប់តែមានសេចក្តីត្រិះរិះកើតឡើងក្នុងចិត្តយ៉ាងនេះថា ពួកជនណាមួយក្នុងលោកជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គ បណ្តាអរហន្តទាំងនោះ ខ្លួនអញជាអរហន្តមួយដែរ ។ លំដាប់នោះ ទេវតាដែលជាសាលោហិតអំពីដើមរបស់ពាហិយបុរស ជាអ្នកអនុគ្រោះ ប្រាថ្នាប្រយោជន៍ បានដឹងច្បាស់សេចក្តីត្រិះរិះក្នុងចិត្ត ដោយចិត្តរបស់ពាហិយបុរស បានចូលទៅរកពាហិយបុរស លុះចូលទៅដល់ហើយ ក៏និយាយនឹងពាហិយបុរសយ៉ាងនេះថា នែពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ ទាំងមិនទាន់សម្រេចអរហត្តមគ្គទេ ខ្លួនអ្នកមិនមានបដិបទា ដែលនាំឲ្យបានជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គទេ ។ ពាហិយៈ សួរថា បើដូច្នោះ ក្នុងកាលឥឡូវនេះ ក្នុងលោកព្រមទាំងទេវលោក តើជនណាជាអរហន្ត ឬបានសម្រេចអរហត្តមគ្គ មានដែរឬ ? ទេវតាឆ្លើយថា ម្នាលពាហិយៈ មាន ខាងជនបទឯជើង មានក្រុងមួយឈ្មោះសាវត្ថី ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់គង់ក្នុងក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគអង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ ដើម្បីអរហត្តផង ។ លំដាប់នោះ ពាហិយបុរស ដែលទេវតានោះធ្វើឲ្យតក់ស្លុត ក៏ស្រាប់តែគេចចេញអំពីឆ្នេរសមុទ្ទ ឈ្មោះសុប្បារកៈក្នុងខណៈនោះភ្លាម ដោយការនៅតែក្នុងផ្លូវទាំងពួង អស់មួយយប់ ក៏បាន

ទៅដល់ព្រះមានព្រះភាគ ដែលកំពុងគង់ក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

សម័យនោះ គាប់ជួនភិក្ខុច្រើនរូប កំពុងដើរចង្ក្រម ក្នុងទីវាល ។ លំដាប់នោះ ពាហិយបុរស ក៏ចៀងចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ហើយ ក៏បានសួរភិក្ខុទាំងនោះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ឥឡូវនេះ ព្រះមានព្រះភាគអរហន្តជាព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅទីណា យើងមានបំណងនឹងចូលទៅ ដើម្បីជួបព្រះមានព្រះភាគ ជាអរហន្តសម្ពុទ្ធអង្គនោះ ។ ពួកភិក្ខុតបថា ម្នាលពាហិយៈ ព្រះមានព្រះភាគចូលកាន់ចន្លោះភូមិ ដើម្បីបិណ្ឌបាតទៅហើយ ។ លំដាប់នោះ ពាហិយបុរស ក៏មានដំណើរម្ហឹម្ហា ចេញពីវត្តជេតពន ចូលទៅនគរសាវត្ថី បានឃើញព្រះ-មានព្រះភាគ កំពុងនិមន្តបិណ្ឌបាត ក្នុងក្រុងសាវត្ថី ជាទីនាំមកនូវសេចក្តីជ្រះថ្លា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះទ័យស្ងប់ ទ្រង់បានដល់នូវការហាត់ពត់ និងការស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បានទូន្មាន គ្រប់គ្រងសង្រួមឥន្ទ្រិយ ជាពុទ្ធនាគ គឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ មានសិរសាឱនចុះទៀបព្រះបាទ នៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏

វែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។ កាលពាហិយៈ អារាធនាយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយៈដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដ្បិតតថាគតចូលកាន់ចន្លោះភូមិបិណ្ឌបាត។ ពាហិយៈទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយ របស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីដ៏វែង ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគ បានត្រាស់នឹងពាហិយៈ អស់វារៈពីរដងយ៉ាងនេះថា ម្នាលពាហិយៈឈប់សិន កាលនេះជាកាលមិនគួរ ដ្បិតតថាគតចូលទៅកាន់ចន្លោះភូមិបិណ្ឌបាតសិន ។ ពាហិយៈ ទូលព្រះមានព្រះភាគ អស់វារៈបីដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយ របស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់រាត្រីវែងដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា រូបារម្មណ៍ ដែលអ្នកឃើញហើយ គ្រាន់

គ្រាន់តែជារូបារម្មណ៍ដែលអ្នកឃើញហើយ សទ្ទារម្មណ៍ ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលអ្នកឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ ដែលដឹងហើយ ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។ ម្នាលពាហិយៈ រូបារម្មណ៍ ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈ រសៈ ផោដ្ឋព្វារម្មណ៍ ដែលអ្នកប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងលែងមាន ម្នាលពាហិយៈ អ្នកនឹងលែងមាន ព្រោះហេតុណា ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកនឹងមិនមានក្នុងភពនេះ និងភពមុខ នឹងមិនមានក្នុងចន្លោះនៃលោកទាំងពីរ នេះឯងជាទីបំផុតនៃទុក្ខ ។ គ្រានោះចិត្តនៃពាហិយៈ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទានក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេបរបស់ព្រះមានព្រះភាគនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ទូន្មានពាហិយទារុចីរិយបុរស ដោយឱវាទសង្ខេបនេះហើយ ពេលនោះ ពាហិយៈក៏បានក្រាបទូលសូមបព្វជ្ជាឧបសម្បទាចំពោះព្រះមានព្រះភាគ ។ ព្រះសម្ពុទ្ធត្រាស់សួរថា ម្នាល

ពាហិយៈ បាត្រ និងចីវររបស់អ្នកមានឬ ? ពាហិយទារុចិរិយៈ ក្រាបទូលថា បពិត្រព្រះមានព្រះភាគជាម្ចាស់ បាត្រ និងចីវររបស់ខ្ញុំព្រះអង្គនៅមិនទាន់មានទេ ។ ព្រះភគវា ទើបទ្រង់ត្រាស់ប្រាប់ថា បើដូច្នោះ ចូរអ្នកស្វែងរកបាត្រ និងចីវរសិនចុះ ហេតុផលដែលព្រះលោកនាថមិនប្រទានការបព្វជ្ជាជាឯហិភិក្ខុឧបសម្បទាដល់ពាហិយៈនោះ ពីព្រោះទ្រង់ជ្រាបដោយព្រះញាណថា បាត្រ និងចីវរដែលនឹងកើតឡើងដោយអំណាចបុញ្ញប្ញទ្ធិ រមែងមិនមានដល់លោក ទើបព្រះអង្គមិនប្រទានឲ្យបព្វជ្ជា ។ ទាំងនេះព្រោះតែពាហិយៈក្នុងអតីតជាតិ ដែលធ្វើសមណធម៌អស់២ ម៉ឺនឆ្នាំ មិនធ្លាប់សង្គ្រោះភិក្ខុសាមណេរ សូម្បីត្រឹមតែមួយរូប ដោយបាត្រ និងចីវរឡើយ ព្រោះលោកគិតតែប្រយោជន៍ខ្លួនឯង ចំពោះបច្ច័យ ៤ ដែលបានមកហើយ មិនអើពើដល់សព្រហ្មចារីឡើយ បរិភោគតែម្នាក់ឯង ។ ដោយហេតុផលដូចពោលមកនេះ ទើបពាហិយៈមិនអាចបួសជាឯហិភិក្ខុឧបសម្បទាបាន នេះជារឿងចាំបាច់បំផុតដែលត្រូវពាហិយៈស្វែងរកបាត្រ និងចីវរបានជាមុនសិន ទើបអាចបួសបាន ។ ប្រសិនបើថា ពាហិយៈមិនបានបួសទេ ភេទជាគ្រហស្ថរបស់លោក ដែលសម្រេចជាព្រះអរហន្តហើយ នឹងអាចនៅបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ហើយនឹងរំលត់ខន្ធបរិនិព្វាន ដោយភេទគ្រហស្ថមិនសមគួរដែលនឹងទ្រទ្រង់ ភាពជាព្រះអរហន្តបាន ព្រោះធ្វើឲ្យអ្នកដទៃកើតបាប ប្រមាថមើលងាយ

ដោយការមិនដឹង ដូច្នេះ ទើបពាហិយៈទៅស្វែងរកបាត្រ ចីវរតាមស្ថានទីផ្សេងៗ មានគំនរសម្រាមជាដើម ។

ក្នុងពេលដែលពាហិយៈកំពុងតែស្វែងរកបាត្រ និងចីវរនោះ មានអមនុស្សដែលធ្លាប់ជាសត្រូវនឹងលោកអំពីអតីតជាតិ បានចូលសណ្ឋិតនៅក្នុងមេគោកូនខ្ចី ហើយរត់មកជល់លោកឲ្យអស់ជីវិតទៅ ។ មានសេចក្តីថា ពាហិយទារុចីរិយៈបរិនិព្វានមុន ដែលនឹងបានបួសជាភិក្ខុ ។ ដែលថា អមនុស្សធ្លាប់ជាសត្រូវនឹងលោក បានចូលសណ្ឋិតនៅក្នុងមេគោ ជល់លោករហូតដល់អស់ជីវិតនោះ មានរឿងតំណាលទុកនៅក្នុងអដ្ឋកថាជាតក ថា ៖

កាលពីជាតិមុន អមនុស្សកើតជាស្រីពេស្យា ចំណែកពាហិយៈកើតជាមាណពកំលោះដ៏ស្រស់សង្ហាម្នាក់ បានបោកបញ្ឆោតស្រីពេស្យានោះឲ្យទៅរួមអភិរម្យជាមួយគ្នា រួចស្រេចហើយ មាណពកំលោះនោះបានសម្លាប់យកគ្រឿងអលង្ការរបស់ស្ត្រីពេស្យានោះៗ ទើបចងពៀរទុកថា សូមឲ្យយើងបានសម្លាប់ជីវិតអ្នកវិញ ក្នុងជាតិខាងមុខឲ្យទាល់តែបាន កាលស្រីពេស្យានោះ ត្រឡប់មកកើតជាអមនុស្ស ក៏ចូលសណ្ឋិតនៅក្នុងមេគោកូនខ្ចីដួចពោលមកនេះ ។

ប៉ុន្តែក្នុងរឿងរបស់សុប្បពុទ្ធកុដ្ឋិ ក្នុងអដ្ឋកថាធម្មបទ នៃពាលវគ្គ និងអដ្ឋកថាគម្ពីរបរមត្ថទីបនី បានពោលរឿងមេគោកូនខ្ចីនោះថា ៖

ដូចបានឮមកថា មេគោកូនខ្ចីនោះ ជាយក្ខិនី ធ្លាប់កើតជាមេគោមកមួយរយជាតិហើយ ព្រោះដោយអំណាចចិត្តដែលចងពៀរ ហើយបានសម្លាប់មនុស្ស ៤ នាក់ គឺ ព្រះបាទបុក្កុសាតិ ១ ព្រះពាហិយទារុចីរិយៈ ១ តម្ពទាឋិកចោរឃាតកៈ ១ សុប្បពុទ្ធកុដ្ឋិ ១ ។

មានរឿងក្នុងអតីតជាតិថា ជនទាំង ៤ នាក់នោះ ក្នុងអតីតកាលបានកើតជាសេដ្ឋីបុត្រទាំង ៤ នាក់ បាននាំស្រីនគរសោភិនីម្នាក់ទៅដើរលេងកំសាន្តសប្បាយរហូតមួយថ្ងៃ កាលដល់វេលាល្ងាច ក៏ប្រឹក្សាគ្នាថា កន្លែងនេះមិនមានអ្នកដទៃឡើយ មានតែពួកយើងប៉ុណ្ណោះ ពួកយើងនឹងដណ្តើមទ្រព្យមួយពាន់កហាបណៈ ដែលពួកយើងឲ្យតម្លៃឈ្នួលដល់ស្រីនេះ ព្រមទាំងគ្រឿងអាភរណៈ រួចហើយសម្លាប់ចោល នាំគ្នារត់ ។ ស្រីនគរសោភិនីបានស្តាប់ឮសម្តី របស់សេដ្ឋីបុត្រទាំង ៤ នាក់ហើយ ទើបគិតថា បុគ្គលទាំងនេះមិនមានការអៀនខ្មាស បានរួមអភិរម្យជាមួយនឹងយើងហើយ ចង់សម្លាប់យើងទៀត ។ ខណៈដែលនាងត្រូវពួកសេដ្ឋីបុត្រទាំង ៤ នាក់សម្លាប់ ក៏តាំងសេចក្តីប្រាថ្នាថា សូមឲ្យយើងកើតជាយក្ខិនី កាលបើបុគ្គលទាំងនេះសម្លាប់យើងយ៉ាងណា សូមឲ្យយើងសម្លាប់បុគ្គលទាំងនេះយ៉ាងនោះវិញ ។ ដល់មកជាតិនេះ បុគ្គលទាំងនោះទើបត្រូវមេគោកូនខ្ចីដល់សម្លាប់ដូចគ្នា ចប់ហេតុផលក្នុងរឿងសុប្បពុទ្ធ-កុដ្ឋិត្រឹមប៉ុណ្ណោះ ។

រឿងរបស់ព្រះពាហិយទារុចីរិយត្ថេរ មានពោលក្នុងព្រះបាលី ពាហិយសូត្រ គម្ពីរខុទ្ទកនិកាយ ឧទាន ដូចតទៅនេះថា ៖

លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី រួចត្រឡប់អំពីបិណ្ឌបាត វេលាខាងក្រោយភត្ត ចេញអំពីនគរជាមួយភិក្ខុច្រើនរូប បានទតឃើញពាហិយៈធ្វើមរណកាល លុះទតឃើញហើយ ទើបត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកសរីរៈពាហិយៈលើកដាក់លើគ្រែ ហើយនាំទៅដុតផង ធ្វើស្តូបដល់សរីរៈនោះផង ម្នាលភិក្ខុទាំងឡាយ ( ព្រោះថា ) សព្រហ្មចារីរបស់អ្នកទាំងឡាយធ្វើមរណៈហើយ ។ ពួកភិក្ខុទាំងនោះ ទូលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយលើកសរីរៈរបស់ពាហិយៈដាក់លើគ្រែតូច នាំទៅរំលាយ ទាំងធ្វើស្តូបដល់សរីរៈនោះ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលព្រះភគវាថា បពិត្រព្រះអង្គដ៏ចម្រើន សរីរៈពាហិយៈរំលាយហើយ ទាំងស្តូបសម្រាប់បញ្ចុះសរីរៈនោះ ក៏ធ្វើហើយ គតិរបស់គាត់តើដូចម្តេច ដំណើរក្នុងលោកខាងមុខតើដូចម្តេច ? ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយៈជាបណ្ឌិត បានប្រតិបត្តិធម៌គួរដល់ព្រះនិព្វានហើយ មិនបៀតបៀនតថាគត ព្រោះហេតុសម្តែងធម៌ទេ ម្នាលភិក្ខុទាំងឡាយ

ពាហិយៈបរិនិព្វានហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនោះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា ៖

ទឹក ដី ភ្លើង ខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានធាតុណា ពួកផ្កាយមាននាមសុក្កៈ ( មានពន្លឺ ) រមែងមិនភ្លឺ ទាំងព្រះអាទិត្យក៏មិនរុងរឿងក្នុងនិព្វានធាតុនោះ ព្រះច័ន្ទក៏មិនមានពន្លឺក្នុងនិព្វានធាតុនោះ ទាំងងងឹតក៏មិនមានក្នុងនិព្វានធាតុនោះទេ ។ ព្រាហ្មណ៍ដែលមាននាមថាមុនី ព្រោះមោនប្បដិបត្តិ ដឹងច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ក្នុងកាលណា រមែងរួចចាករូបផង អរូបផង សុខទុក្ខផង ក្នុងកាលនោះ ។

ព្រះសម្ពុទ្ធ ស្តេចចេញចាកក្រុងសាវត្ថី ព្រមដោយភិក្ខុសង្ឃជាច្រើន ទ្រង់ឃើញពាហិយទារុចីរិយៈដេកស្លាប់ ទើបត្រាស់ប្រាប់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកជួយគ្នា នាំយកសពពាហិយៈទៅបូជា រួចហើយ បានកសាងព្រះចេតិយឡើងនៅផ្លូវបែកជា ៤ និងនាំយកអដ្ឋិធាតុរបស់ពាហិយៈ បញ្ចុះទុកក្នុងចេតិយនោះ ។ ភិក្ខុទាំងឡាយបានធ្វើតាមព្រះពុទ្ធតម្រាស់រួចរៀបរយហើយ កាលជាខាងក្រោយមកភិក្ខុបានប្រជុំសន្ទនាគ្នាក្នុងរឿងរបស់ពាហិយទារុចីរិយត្ថេរថា ព្រះភគវាព្រមទាំងភិក្ខុសង្ឃទាំងឡាយ ធ្វើការបូជាព្រះសពរបស់ពាហិយៈ ហើយបានប្រមូលអដ្ឋិធាតុទៅបញ្ចុះទុកក្នុងចេតិយ ដែលកសាងឡើងនៅផ្លូវបែកជា ៤ នោះ ព្រះពាហិយទារុចីរិយៈសម្រេចមគ្គផលថ្នាក់ណាហ្ន៎ ចាត់ជាភិក្ខុ

ឬសាមណេរបានដោយប្រការណាហើយឬ ?

ព្រះលោកនាថទ្រង់យករឿងការសន្ទនា របស់ភិក្ខុទាំងឡាយមកជាដើមហេតុ ត្រាស់ទេសនាថា ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយៈជាបណ្ឌិត ប្រតិបត្តិធម៌សមគួរដល់ធម៌ ទាំងមិនធ្វើឲ្យតថាគតលំបាកទៀតផង ព្រោះហេតុនៃការសម្តែងធម៌ ពាហិយទារុចីរិយៈបរិនិព្វានទៅហើយ ។ កាលបើព្រះសម្ពុទ្ធត្រាស់ដូច្នេះហើយ ទើបទ្រង់បន្លឺឧទានក្នុងពេលនោះថា ៖

ដី ទឹក ភ្លើង និងខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានធាតុណា ពួកផ្កាយមាននាមថា សុក្កៈ មានពន្លឺ រមែងមិនពន្លឺ ទាំងព្រះអាទិត្យក៏មិនរុងរឿង ក្នុងនិព្វានធាតុនោះ ព្រះច័ន្ទក៏មិនមានពន្លឺ ក្នុងព្រះនិព្វានធាតុនោះ ទាំងងងឹតក៏មិនមាន ក្នុងនិព្វានធាតុនោះដែរ ។ ព្រាហ្មណ៍មាននាមថាមុនី ព្រោះមោនប្បដិបត្តិ ដឹងច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ក្នុងកាលណា រមែងរួចចាករូបផង អរូបផង សុខទុក្ខផង ក្នុងកាលនោះ ។

ពេលកន្លងមកមិនយូរប៉ុន្មាន ការសន្ទនាគ្នារបស់ភិក្ខុដែលមានរឿងទំនាក់ទំនងនឹងព្រះពាហិយទារុចីរិយត្ថេរ ក៏បានកើតឡើងទៀត ដែលមានរឿងតំណាលទុកក្នុងអដ្ឋកថា គម្ពីរធម្មបទ ក្នុងរឿងពាហិយៈ ថា ៖

រឿងរបស់ព្រះពាហិយៈ ភិក្ខុទាំងឡាយបានសន្ទនាគ្នាថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌មិនច្រើនឡើយឲ្យពាហិយៈ ប៉ុន្តែព្រះអង្គត្រាស់

ថា ពាហិយៈ បានសម្រេចជាព្រះអរហន្តហើយ រឿងនេះយ៉ាងណាហ្ន៎ ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយជាព្រះអរហន្ត តាំងពីពេលដែលស្តាប់ធម៌តថាគតចប់ម៉្លេះ ។ ភិក្ខុទាំងឡាយទូលសួរទៀតថា ព្រះអង្គទ្រង់សម្តែងធម៌ដល់ពាហិយៈក្នុងពេលណា ? ក្នុងពេលដែលតថាគតស្តេចបិណ្ឌបាត ។ ភិក្ខុទាំងឡាយក្រាបទូលថា ធម៌ដែលព្រះអង្គទ្រង់សម្តែងនោះ មានប្រមាណបន្តិចបន្តួច ធ្វើដូចម្តេចឲ្យពាហិយៈបានសម្រេចគុណវិសេស ដោយហេតុមានប្រមាណប៉ុណ្ណោះ ទើបព្រះអង្គទ្រង់ត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំយល់ថាធម៌របស់តថាគត តិចតួចមិនឲ្យផលឡើយ ហើយព្រះអង្គទ្រង់ត្រាស់គាថា ថា ៖

បើគាថា សូម្បី ១ ពាន់ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែ១បទក៏ឈ្មោះថាប្រសើរជាង ។

កាលជាក្រោយមក ព្រះសម្ពុទ្ធទ្រង់ប្រថាប់ឈរ ក្នុងចំណោមភិក្ខុសង្ឃ ទ្រង់ប្រកាសតែងតាំងព្រះពាហិយទារុចីរិយត្ថេរ ទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងខិប្បាភិញ្ញា គឺអ្នកត្រាស់ដឹងបានឆាប់រហ័ស និងជាអសីតិមហាសាវកផង ។

តាមដែលរឿងតំណាលមកនេះ ព្រះពាហិយទារុចីរិយត្ថេរ មិនទាន់

ធ្លាប់មានការសម្តែងរឿងណានីមួយទុកឡើយ ប៉ុន្តែក្នុងគម្ពីរខុទ្ទកនិកាយ អបទាន នៃកច្ចាយនវគ្គ ប្រាកដសេចក្តីថា ព្រះពាហិយទារុចិរិយត្ថេរ កាល បានសម្រេចជាព្រះអរហន្តហើយ បានពោលឡើងថា ៖

ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ គឺកន្លងមកបានប្រមាណ មួយសែនកប្ប លោកបានឃើញភិក្ខុមួយរូប បានទទួលតំណែងដ៏ប្រសើរ ផ្នែកខាងការត្រាស់ដឹងបានឆាប់រហ័ស ទើបរៀបចំការថ្វាយទាន ជាប់ត គ្នារហូតប្រាំពីរថ្ងៃ ហើយប្រាថ្នាតំណែងនោះ ក្នុងថ្ងៃទីប្រាំពីរ ។ ពេល ស្លាប់ពីជាតិនោះហើយ ក៏បានទៅកើតក្នុងទេវលោក កាលបើចុតិអំពី ទេវលោកមកក៏កើតជាមនុស្ស ពេលស្លាប់ពីភាពជាមនុស្ស ក៏បានទៅ កើតក្នុងទេវលោកទៀត ។

លុះមកដល់ពុទ្ធសម័យរបស់ព្រះកស្សបសម្ពុទ្ធ លោកបានចូលមក ឧបសម្បទាជាភិក្ខុ ឡើងទៅធ្វើសមណធម៌នៅលើកំពូលភ្នំ ដូចមានរឿង ដែលបានពោលរួចហើយ ខាងដើមនោះឯង ។

( ជីវប្រវត្តិរបស់ព្រះពាហិយទារុចិរិយត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ ✍

### “ ដែលជាឯតទគ្គៈផ្នែកខាងចែកសេចក្ដីក្នុងធម៌ដែលតថាគត សម្ដែងដោយសង្ខេបឱ្យពិស្ដារបាន ”

*ព្រះមហាកច្ចាយនត្ថេរ លោកមានភាពអង់អាច ខាងចែកសេចក្ដីនៃព្រះធម៌ ដែលព្រះសម្ពុទ្ធទ្រង់សម្ដែងដោយសេចក្ដីសង្ខេបឲ្យពិស្ដារបានត្រឹមត្រូវតាមពុទ្ធបំណង រហូតបានទទួលការលើកតម្កើងអំពីព្រះ-លោកនាថថា មានតែមួយមិនមានពីរ ក្នុងការអធិប្បាយធម៌ និងជាអ្នកមានរូបសម្បត្តិស្អាត ជាទីពិតពិលរមិលមើល ។ ព្រះមហាកច្ចាយនត្ថេរលោកមានជីវប្រវត្តិគួរសិក្សាដូច្នេះ ។*

*ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ មានពោលនៅក្នុងអដ្ឋកថាគម្ពីរមនោរថបូរណី ក្នុងអដ្ឋកថាបរមត្ថទីបនី និងគម្ពីរខុទ្ទកនិកាយអបទាន មានសេចក្ដីថា ៖*

*ក្នុងសម័យព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ស្ដេចទ្រង់ឧប្បត្តិឡើងក្នុងលោក ព្រះមហាកច្ចាយនត្ថេរបានកើតនៅក្នុងត្រកូលគហបតីមហាសាល ពេលចម្រើនវ័យធំឡើង ថ្ងៃមួយបានទៅស្ដាប់ព្រះធម៌ទេសនានៅឯវត្ត ។ បានឃើញព្រះបទុមុត្តរៈទ្រង់ប្រកាសតែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែង*

ដ៏ប្រសើរផ្នែកខាងបែកសេចក្តីសង្ស័យក្នុងធម៌ឲ្យពិស្តារបាន ទើបគិតថា ភិក្ខុរូបនេះជាអ្នកមានគុណធម៌ដ៏ក្រៃលែងណាស់ យើងនឹងបានដូចជាភិក្ខុរូបនេះដែរ ក្នុងព្រះសាសនាព្រះពុទ្ធអង្គណាមួយ នាកាលអនាគត ។

កាលបើលោកគិតដូច្នេះហើយ ទើបរៀបចំការថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធបទុមុត្តរៈជាប្រធាន រហូតអស់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៧ បានតាំងសេចក្តីប្រាថ្នាចំពោះព្រះភក្ត្រព្រះបទុមុត្តរៈថា បពិត្រព្រះសុគតសាស្តា ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិយ៉ាងដទៃ ដោយផលនៃការធ្វើកុសលនេះ ប៉ុន្តែសូមឲ្យខ្ញុំព្រះអង្គបាននូវតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងបែកសេចក្តីសង្ស័យក្នុងធម៌ឲ្យពិស្តារនាកាលអនាគតកុំបីខានឡើយ ។ ព្រះសម្ពុទ្ធបទុមុត្តរៈ ទ្រង់ព្រះសណ្តាប់សេចក្តីប្រាថ្នាហើយ ទើបទ្រង់ពិចារណាដល់អនាគតកាល ហើយទ្រង់ឃើញថា ការប្រាថ្នារបស់កុលបុត្រនេះនឹងបានសម្រេច ទើបត្រាស់ថា ក្នុងទីបំផុតមួយសែនកប្បខាងមុខនេះ មានព្រះពុទ្ធទ្រង់ព្រះនាមសមណគោតម ស្តេចឧប្បត្តិឡើងក្នុងលោក អ្នកនឹងបានទទួលការតែងតាំងឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងបែកសេចក្តីសង្ស័យក្នុងធម៌ឲ្យពិស្តារបាន ។

កាលបើព្រះបទុមុត្តរៈ ទ្រង់ព្យាករយ៉ាងនេះហើយ ទ្រង់បានអនុមោទនាគាថារួចជាស្រេចហើយ ព្រះអង្គក៏និមន្តត្រឡប់ទៅវិញ ។ ចំណែកកុលបុត្រនោះ បានធ្វើកុសលជារឿយៗ រហូតអស់ជីវិត បានត្រាច់រង្គាត់

ទៅក្នុងមនុស្ស និងទេវតាអស់កាលជាយូរអង្វែង ដោយអំណាចបុណ្យកុសលដែលខ្លួន ធ្វើរួចហើយនោះឯង ។ លុះមកដល់កាលនៃព្រះសម្ពុទ្ធសុមេធ កុលបុត្រនោះត្រឡប់បានមកកើតជាវិជ្ជាធរ ថ្ងៃមួយវិជ្ជាធរនោះបានហោះទៅជួបព្រះមានព្រះភាគ ដែលគង់នៅក្នុងដងព្រៃមួយកន្លែងមានសទ្ធាជ្រះថ្លា ទើបបូជាដោយផ្កាកណិការ ដោយផលនៃកុសលនោះធ្វើឲ្យកើតនៅក្នុងទេវលោកអស់កាលដ៏យូរទៀត មិនធ្លាប់ទៅកើតក្នុងទុគ្គតិឡើយ ។ លុះដល់ពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ លោកបានមកកើតនៅក្នុងត្រកូលមួយនាក្រុងពារាណសី កាលបើព្រះពុទ្ធស្តេចបរិនិព្វានទៅហើយ លោកបានកសាងព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ ដោយការលះបង់មាសមួយសែនតម្លឹងដើម្បីចាក់ពុម្ពជាឥដ្ឋ សម្រាប់ការប្រើប្រាស់ ក្នុងការកសាងព្រះចេតិយដោយតាំងសេចក្តី ប្រាថ្នាថា ៖

ខ្ញុំកើតក្នុងទីណាៗ សូមឲ្យរាងកាយមានពណ៌សម្បុរដូចមាស បានធ្វើកុសលកម្មដទៃៗ ទៀត ពេលអស់ជីវិតទៅ ក៏បានកើតជាមនុស្ស និងទេវតាអស់កាលមួយពុទ្ធន្តរ ។ ក្នុងពុទ្ធកាលនេះ លោកបានកើតជាបុត្ររបស់ព្រាហ្មណ៍ក្នុងត្រកូលកច្ចាយនគោត្រ ឪពុកជាបុរោហិតរបស់ព្រះបាទចណ្ឌប្បជ្ជោត ក្នុងនគរឧជ្ជេនី ។ ក្នុងថ្ងៃដែលដាក់ឈ្មោះឲ្យលោក មាតាបិតាប្រឹក្សាគ្នាថា បុត្ររបស់យើងមានពណ៌សម្បុរដូចមាស គួរនឹង

កាន់យកនិម្មិតដ៏ល្អនោះ ហើយដាក់ឈ្មោះឲ្យថា កាញ្ចនៈ ឬ កញ្ចនៈ ដែលប្រែថា មាស ។ កាញ្ចនមាណព កាលចម្រើនវ័យធំហើយ ក៏បាន សិក្សាវិជ្ជាត្រៃវេទរហូតដល់ចប់ ទាំងមានភាពជំនាញទៀតផង កាលបើ បិតាធ្វើកាលកិរិយាទៅ ទើបបានទទួលតំណែងជាបុរោហិតជំនួសបិតា ប៉ុន្តែឈ្មោះរបស់លោក ក្នុងកាលខាងក្រោយមក ប្តូរជាកច្ចាយនៈតាម ឈ្មោះត្រកូល ។

កាលជាខាងក្រោយមក ព្រះបាទចណ្ឌប្បជ្ជោតទ្រង់ជ្រាបដំណឹង ថា ព្រះសម្មាសម្ពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ ស្តេចតែងតែចារិក ទៅសម្តែងធម៌ ញុំាងប្រយោជន៍ឲ្យសម្រេចដល់មហាជនជាច្រើន ទ្រង់ មានព្រះរាជបំណងនឹងក្រាបទូលអារាធនាព្រះមានព្រះភាគ ឲ្យស្តេចយាង មកប្រកាសសាសនានៅនានគរឧជ្ជេនីផង ទើបទ្រង់ត្រាស់បញ្ជាឲ្យប្រជុំ ពួកអាមាត្យរាជបុរោហិត ហើយមានរាជតម្រាស់សួរថា ៖

នែ អស់លោកទាំងឡាយ អ្នកណាមានសមត្ថភាពអាចដើម្បីទៅ ក្រាបទូលអារាធនាព្រះលោកនាថ ឲ្យស្តេចយាងមកបាន សូមឲ្យអ្នក នោះចូលទៅក្រាបទូលអារាធនាព្រះសម្ពុទ្ធមក ។ ពួកអាមាត្យក្រាបបង្គំ ទូលថា អ្នកដទៃដែលនឹងមានសមត្ថភាពទៅក្រាបទូលអារាធនា ព្រះជិន ស្រីនោះ មិនឃើញមានឡើយ ក្រៅអំពីកច្ចាយនព្រាហ្មណ៍ដែលជាអា-ចារ្យតែម្នាក់ប៉ុណ្ណោះ សូមព្រះអង្គទ្រង់ព្រះករុណាឲ្យកច្ចាយនព្រាហ្មណ៍

ទៅចុះ ។ ព្រះបាទចណ្ឌបជ្ជោត ទើបត្រាស់បញ្ជាឲ្យកច្ចាយនរាជបុរោហិត ទៅក្រាបទូលអារាធនាព្រះសម្ពុទ្ធមកកាន់នគរឧជ្ជេនីនេះ ។ កច្ចាយន-ព្រាហ្មណ៍ ក្រាបបង្គំទូលទទួលដោយការស្ម័គ្រចិត្ត និងក្រាបបង្គំទូលលាបួសផងថា សូមតេជៈ កាលបើខ្ញុំព្រះអង្គទៅហើយ សូមឲ្យខ្ញុំព្រះអង្គបានបព្វជ្ជាផង ខ្ញុំព្រះអង្គនឹងក្រាបទូលអារាធនាព្រះសុគតសាស្តា ឲ្យព្រះអង្គយាងមក ។ ព្រះរាជាទ្រង់ត្រាស់អនុញ្ញាតថា លោកអាចារ្យធ្វើយ៉ាងណានីមួយក៏បាន ប៉ុន្តែចូរយាងព្រះភគវាមកឲ្យបានកុំខានឡើយ ។

កច្ចាយនព្រាហ្មណ៍ កាលបើបានទទួលព្រះបរមរាជានុញ្ញាតហើយ ទើបគិតពិចារណាមើលថា អ្នកដែលអាចចូលទៅគាល់ព្រះសម្ពុទ្ធ មិនចាំបាច់ច្រើនគ្នាឡើយ ហើយបាននាំយកព្រាហ្មណ៍ ៧ នាក់ទៅជាមួយផង រួមទាំងអស់មាន ៨ នាក់ ។ ក្នុងខណៈដែលកច្ចាយនៈ ព្រមទាំងសម្លាញ់ ៧ នាក់ទៀត បានធ្វើដំណើររហូតមកដល់ ក៏ចូលទៅគាល់ព្រះសក្យមុនី ព្រះអង្គក៏ទ្រង់សម្តែងធម៌ឲ្យដល់ជនទាំងនោះបានស្តាប់ កាលចប់ព្រះធម៌ទេសនា កច្ចាយនៈ ព្រមជាមួយនឹងព្រាហ្មណ៍ ៧ នាក់ទៀត បានសម្រេចជាព្រះអរហន្ត ព្រម ទាំងបដិសម្ភិទាទៀតផង ។

ពេលនោះក៏ទូលសូមបព្វជ្ជាឧបសម្បទា ព្រះមានព្រះភាគ ទើបត្រាស់ថា អ្នកចូរមកជាភិក្ខុចុះ នេះជាការបួសដោយវិធីជាឯហិភិក្ខុឧប-សម្បទា ជាវិធីបំបួសអ្នកដែលបានសម្រេចជាព្រះអរហន្តមុនបួស ។

រំពេចនោះឯង ព្រាហ្មណ៍ទាំង ៨ នាក់នោះ ក៏ត្រឡប់មានភេទជាភិក្ខុ ទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយបុញ្ញឫទ្ធិ ដូចព្រះថេរៈមានវស្សា ១០០ ដូច្នោះឯង ។ កិច្ចនៃការបួសដល់ទីបំផុតហើយ ព្រះមហាកច្ចា-យនត្ថេរ មិនបាននៅស្ងៀម តែងតែចាំនៅព្រះរាជតម្រាស់របស់ព្រះបាទចណ្ឌប្បជ្ជោត ទើបក្រាបទូលអារាធនាព្រះសម្ពុទ្ធ ឲ្យស្ដេចយាងទៅកាន់នគរឧជ្ជេនី ។ ព្រះអង្គទ្រង់សណ្ដាប់ហើយក៏ជ្រាបថា ធម្មតាព្រះពុទ្ធទាំងឡាយ ព្រះអង្គមិននិមន្តទៅក្នុងស្ថានទីដែលមិនសមគួរឡើយ ។ ព្រោះដូច្នោះ ទើបព្រះភគវា ត្រាស់ថាអ្នកចូរទៅនិងកាលអ្នកទៅដល់ព្រះរាជានឹងទ្រង់ជ្រះថ្លាចំពោះ ជាមួយពួកអ្នកមិនខានឡើយ ។

ព្រះមហាកច្ចាយនត្ថេរគិតថា ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយមានតែមួយដងប៉ុណ្ណោះ មិនមានលើកទីពីរឡើយ ទើបក្រាបបង្គំទូលលានាំភិក្ខុ ៧ រូបទៅជាមួយផង និមន្តទៅកាន់នគរឧជ្ជេនី ក្នុងរវាងផ្លូវបានចៀងចូលទៅបិណ្ឌបាតក្នុង នាលិនិគម ។ កន្លែងនាលិនិគមនោះ មានសេដ្ឋីធីតាម្នាក់ កាលដែលមាតាបិតាធ្វើកាលកិរិយាទៅហើយ ត្រឡប់ជាមនុស្សទ័លក្រទៅវិញ នៅជាមួយនឹងអ្នកបម្រើម្នាក់ ប៉ុន្តែជាអ្នកមានរូបរាងកាយល្អស្អាត មានសក់វែងស្អាត គួរឲ្យជាទីស្រឡាញ់ណាស់ ។

ចំណែកសេដ្ឋីធីតាត្រកូលមួយទៀត ជាស្រីដែលមានសក់តិច ធ្លាប់ប្រើអ្នកបម្រើរបស់ខ្លួន ឲ្យទៅសូមទិញសក់សេដ្ឋីធីតាធ្លាក់ខ្លួនក្រនោះ

ដោយឲ្យតម្លៃ ១០០ ឬ ១០០០ កហាបណៈ ប៉ុន្តែនាងមិនលក់ឡើយ ។ ក្នុងថ្ងៃមួយ សេដ្ឋីធីតាដែលធ្លាក់ខ្លួនក្រនោះ បានឃើញព្រះមហាកច្ចាយ-នត្ថេរ និមន្តបិណ្ឌបាតរួមជាមួយនឹងភិក្ខុ ៧ រូប ប៉ុន្តែនៅមិនទាន់បានចង្ហាន់សោះ ក្នុងបាត្ររបស់លោកក៏គ្មានចង្ហាន់ដែរ ។ នាងគិតថា រូបសម្បត្តិដែលមានពណ៌សម្បុរដូចមាសនេះ ប្រាកដជាព្រាហ្មណ៍ លោកមិនទាន់បានទទួលចង្ហាន់ពីនរណាទីមួយនៅឡើយ យើងនឹងដាក់បាត្រចំពោះលោក ប៉ុន្តែទេយ្យធម៌របស់យើងមិនមាននាង សញ្ជឹងគិតដោយការអាណិតភិក្ខុសង្ឃ ។ កាលបើនាងគិតត្រឹមតែមួយភ្លែត ក៏បាននឹកឃើញថា សេដ្ឋីធីតាឯណោះធ្លាប់ប្រើអ្នកបម្រើឲ្យមកសូមទិញសក់របស់យើង ប៉ុន្តែយើងមិនព្រមលក់ ពេលនេះយើងនឹងលក់សក់របស់យើងឲ្យដល់គេ ដើម្បីយកប្រាក់មកទិញចង្ហាន់ប្រគេនភិក្ខុសង្ឃ ។

លុះនាងបាននឹកឃើញដូច្នេះហើយ ទើបនិមន្តព្រះថេរៈទាំង ៨ រូបឡើងមកគង់លើផ្ទះ ហើយខ្លួនឯងចូលទៅបន្ទប់ កាត់សក់ឲ្យអ្នកបម្រើយកទៅលក់ឲ្យសេដ្ឋីធីតាឯណោះ ដោយតម្លៃប៉ុន្មានក៏បាន ខ្ញុំនឹងថ្វាយចង្ហាន់ដល់លោកម្ចាស់ទាំងឡាយ អ្នកបម្រើអាណិតសេដ្ឋីធីតាដែលធ្លាក់ខ្លួនក្រ ដោយឃើញការធ្វើយ៉ាងនេះហើយ នាងក៏ហូរទឹកភ្នែកដោយមិនដឹងខ្លួនចេញមក យកដៃជូតទឹកភ្នែករួចហើយ កាន់យកសក់សេដ្ឋីធីតាទៅ ទាំងមិនឲ្យព្រះថេរៈទាំងឡាយបានឃើញ ។

ធម្មតារបស់មានតម្លៃ នឹងលក់បានតម្លៃថ្លៃពេលមនុស្សត្រូវការ ប្រសិនបើមិនត្រូវការហើយ របស់មានតម្លៃក៏មិនថ្លៃដែរ ។ ព្រោះដូច្នោះ ទើបសេដ្ឋីធីតាគិតថា ក្នុងកាលមុនយើងអាចទិញសក់នេះ បានដោយ តម្លៃថ្លៃ ឥឡូវនេះ គេព្រមកាត់សក់លក់ឲ្យយើង សក់ក៏មានតម្លៃថោក រហូតដល់តម្លៃ ៨ កហាបណៈ ព្រមទាំងនិយាយថា កាលមុន ខ្ញុំមិន អាចទិញសក់នេះអំពីចៅហ្វាយស្រីរបស់នាងបាន សូម្បីឲ្យតម្លៃថ្លៃខ្ពស់ បំផុតយ៉ាងណាក៏ដោយ ក៏មិនព្រមលក់ឲ្យឡើយ ប៉ុន្តែឥឡូវនេះ សក់នេះ ឲ្យតម្លៃ ៨ កហាបណៈសមរម្យណាស់ទៅហើយ ។ អ្នកបម្រើមិន និយាយស្តីអ្វីឡើយ នាំយកប្រាក់ ៨ កហាបណៈឲ្យទៅចៅហ្វាយស្រីនោះ ទើបឲ្យអ្នកបម្រើយកប្រាក់ ៨ កហាបណៈទៅទិញចង្ហាន់ ៨ ចំណែក ក្នុងមួយចំណែកៗ ១ កហាបណៈ ហើយដាក់ចង្ហាន់ទាំងនោះទៅក្នុង បាត្រព្រះថេរៈទាំងអស់ ។

ព្រះថេរៈទាំងឡាយ មានព្រះមហាកច្ចាយនៈជាដើម បានឃើញ សេដ្ឋីធីតាដែលមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែងនោះហើយ ទើបសួរថា សេដ្ឋីធីតាទៅណា ? អ្នកបម្រើតបថា នៅក្នុងបន្ទប់ ។ ព្រះថេរៈពោល ថា ចូរទៅហៅនាងមក សេដ្ឋីធីតានោះក៏ព្រមចេញមកជួបព្រះថេរៈទាំង នោះ បានថ្វាយបង្គំព្រះថេរៈដោយសេចក្តីជ្រះថ្លាហើយ សក់របស់នាង ដែលត្រូវកាត់យ៉ាងខ្លីនោះ ត្រឡប់ដុះវែងឡើងដូចដើមវិញ ។

ទានដែលបុគ្គលបូជាចំពោះអ្នកមានសីល មានគុណធម៌ដ៏ខ្ពង់ខ្ពស់ រមែងឲ្យផលក្នុងបច្ចុប្បន្ននេះឃើញទាន់ភ្នែក ។ ព្រះថេរៈទាំងឡាយបានទទួលចង្ហាន់បិណ្ឌបាតហើយ បានហោះឡើងទៅឰដ៏អាកាស នៅចំពោះមុខសេដ្ឋីធីតានោះ ទៅចុះក្នុងកាញ្ចនឧទ្យានរបស់ព្រះបាទចណ្ឌប្បជ្ជោត ។

នាយឧទ្យានបានឃើញព្រះថេរៈទាំងនោះហើយ ទើបទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ ព្រះបុរោហិតកច្ចាយនៈបានបព្វជ្ជាហើយ ឥឡូវមកស្នាក់អាស្រ័យក្នុងព្រះរាជឧទ្យាននៅឡើយ ។ ព្រះបាទចណ្ឌបជ្ជោត ស្ដេចបានយាងទៅកាន់ព្រះរាជឧទ្យានភ្លាមៗ ប៉ុន្តែត្រូវពេលដែលព្រះថេរៈទាំងឡាយឆាន់រួចជាស្រេច ព្រះរាជាក៏ថ្វាយបង្គំហើយ ទើបត្រាស់សួរថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់នៅក្នុងទីណា ? ព្រះកច្ចាយនៈតបថា ព្រះលោកនាថ ទ្រង់មិនបាននិមន្តមកទេ ប៉ុន្តែទ្រង់អនុញ្ញាតឲ្យអាត្មាមកជំនួសវិញ ។

ព្រះរាជាទ្រង់ត្រាស់សួរទៀតថា ថ្ងៃនេះ លោកម្ចាស់ទាំងឡាយបានចង្ហាន់មកពីណាឆាន់ ? ព្រះថេរៈទាំងនោះ បានតំណាលរឿងសេចក្ដីល្អរបស់សេដ្ឋីធីតាឲ្យព្រះរាជាទ្រង់សណ្ដាប់ថា ៖

សេដ្ឋីធីតាកំសត់ម្នាក់ ដែលនៅក្នុងនាលិនិគម បានកាត់សក់របស់ខ្លួនយកទៅលក់ យកប្រាក់មកទិញចង្ហាន់ដាក់បាត្ររបស់អាត្មាភាព ។ ព្រះរាជាទ្រង់សណ្ដាប់ហើយ ទ្រង់សព្វព្រះហឫទ័យ ក៏ថ្វាយបង្គំលាព្រះ

ថេរៈទាំងឡាយ និងស្តេចត្រឡប់ទៅដល់ព្រះរាជវាំងវិញហើយ ឲ្យគេទៅនាំយកសេដ្ឋីធីតាកំសត់នោះមកធ្វើជាអគ្គមហេសីរបស់ខ្លួន ។

ចាប់ផ្តើមពីនោះមក ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ធ្វើសក្ការគោរពបូជាចំពោះព្រះថេរៈទាំងនោះជារឿយៗ ។ ព្រះមហាកច្ចាយនត្ថេរ អាចធ្វើឲ្យមហាជនកើតសេចក្តីជ្រះថ្លា ក្នុងការសម្តែងធម៌របស់ខ្លួន ជនជាច្រើននាក់បានបួសក្នុងសម្នាក់ព្រះថេរៈ ដោយសេចក្តីជ្រះថ្លា ។ ចាប់ពីព្រះកច្ចាយនត្ថេរ ព្រមទាំងព្រះថេរៈ ៧ រូបទៀត មកគង់នៅក្នុងនគរឧជ្ជេនី បានធ្វើឲ្យនគរឧជ្ជេនីទាំងអស់រុងរឿងស្រស់បស់ដោយសំពត់កាសាវពស្ត្រ ច្រើនទៅដោយអ្នកស្វែងរកបុណ្យ ។

បន្ទាប់មក អគ្គមហេសីរបស់ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់មានព្រះរាជឱរសមួយព្រះអង្គ ទ្រង់កំណត់ព្រះនាមឲ្យព្រះរាជឱរសថា គោបាលកុមារ ព្រះនាមនេះប្រោសព្រះរាជទាន ឲ្យដូចគ្នានឹងឈ្មោះរបស់ធីតាតាំងពីពេលនោះមកសេដ្ឋីធីតា ដែលជាអគ្គមហេសីរបស់ព្រះបាទចណ្ឌ-បជ្ជោតនោះ ទើបបាននាមមួយទៀតថា ព្រះនាងគោបាលមាតា ។ ព្រះនាងរឹងរឹតតែមានសេចក្តីជ្រះថ្លា ចំពោះបុណ្យកុសលណាស់ដែលខ្លួនបានធ្វើហើយ ទើបទូលសូមព្រះបាទចណ្ឌបជ្ជោត ដើម្បីកសាងវត្តថ្វាយដល់ព្រះថេរៈ ក្នុងកាញ្ចនឧទ្យាននោះឯង ។

ការនាំកងទ័ពធម៌ចារិកប្រកាសព្រះសាសនា របស់ព្រះកច្ចាយនត្ថេរ

និងព្រះថេរៈទាំង ៧ រូបទៀត ជាផលឲ្យព្រះបាទចណ្ឌប្បជ្ជោត ព្រមទាំងអ្នកនគរឧជ្ជេនីកើតសេចក្ដីជ្រះថ្លា ហើយទើបត្រឡប់មកគាល់ព្រះសម្ពុទ្ធម្ដងទៀត ។ កាលដែលព្រះមហាកច្ចាយនត្ថេរ បានទទួលការលើកតម្កើង ឲ្យជាអ្នកចែកសេចក្ដីសង្ខេបឲ្យពិស្ដារបាននោះ គ្រាមួយព្រះមានព្រះភាគ ទ្រង់សម្ដែងភទ្ទេករត្តសូត្រទុកដោយសង្ខេប ដែលប្រាកដនៅក្នុងគម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ដូចមានសេចក្ដីថា ៖

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគត ព្រោះថា បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ពិចារណាឃើញច្បាស់ នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកកម្រើកហើយ ត្រូវចម្រើនឲ្យរឿយៗ នូវផលសមាបត្តិដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតនូវកិលេស បុគ្គលគួរធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកំដៅកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់ថ្ងៃ និងយប់នោះឯង ថាជាអ្នកមានរាត្រីមួយ

ចម្រើន ។

ឧទ្ទេសនេះ បើព្រះមានបុណ្យ ទ្រង់សម្តែងដោយសេចក្តីសង្ខេប មិនបានចែកសេចក្តីដោយពិស្តារ អ្នកណាហ្ន៎ គប្បីចែកសេចក្តីដោយពិស្តារបាន ម្នាលអាវុសោកច្ចាយនៈ ពួកយើងខ្ញុំទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចាយនៈមានអាយុនេះឯង ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីជាអ្នកចេះដឹងបានលើកតម្កើងផង ព្រះមហាកច្ចាយនៈ មានអាយុ អាចចែករំលែកសេចក្តីនៃឧទ្ទេស ។

ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយសង្ខេបនេះ ឲ្យពិស្តារបានផង បើដូច្នោះ គួរតែយើងនាំគ្នាចូរទៅរកព្រះមហាកច្ចាយនៈមានអាយុ លុះចូលទៅដល់ហើយ ត្រូវសួរសេចក្តីនេះ នឹងព្រះមហាកច្ចាយនៈមានអាយុ សូមឲ្យព្រះមហាកច្ចាយនៈមានអាយុ ចែកសេចក្តីឲ្យទាន ។

ព្រះមហាកច្ចាយនៈពោលថា ម្នាលអាវុសោ បុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ស្វែងរកខ្លឹមឈើ កាលឈើមានខ្លឹមដុះនៅមុខ ក៏រម្លងគល់ រម្លងដើម ហើយសម្គាល់រកខ្លឹមឯមែកនិងសន្លឹកវិញ មានឧបមាយ៉ាងណាមិញ សេចក្តីនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ព្រះសាស្តានៅក្នុងទីចំពោះមុខ របស់លោកអ្នកមានអាយុទាំងឡាយ ពួកលោករម្លងព្រះមានព្រះភាគនោះហើយ សម្គាល់សេចក្តីដែលត្រូវសួរនោះចំពោះខ្ញុំវិញ ។

ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបនូវធម៌ ដែលគួរជ្រាបបាន ឃើញនូវធម៌ ដែលគួរឃើញបាន ទ្រង់មានបញ្ញាចក្ខុ មានញាណ ទ្រង់មានធម៌ មានគុណដ៏ប្រសើរ ទ្រង់កាន់ធម៌ប្រព្រឹត្តធម៌ ពន្យល់សេចក្តី ទ្រង់ប្រទាននូវអមតៈ ជាម្ចាស់ធម៌ ជាព្រះតថាគត ទើបសមគួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលអ្នកទាំងឡាយគួរតែសួរសេចក្តីនុ៎ះ នឹងព្រះមានព្រះភាគ បើព្រះអង្គទ្រង់ដោះស្រាយដល់អ្នកទាំងឡាយ យ៉ាងណា ចូរអ្នកទាំងឡាយ ចាំទុកសេចក្តីនោះយ៉ាងនោះចុះ ។

ម្នាលអាវុសោកច្ចាយនៈ ព្រះមានព្រះភាគ ព្រះអង្គជ្រាបនូវធម៌មានបញ្ញាចក្ខុ យើងទាំងឡាយ គប្បីចាំទុកសេចក្តីនោះ យ៉ាងនោះ ក៏ពិតមែនហើយតែថា ព្រះមហាកច្ចាយនៈមានអាយុ ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផង មួយទៀតព្រះមហាកច្ចាយនៈ លោកអាចចែកសេចក្តីនៃឧទ្ទេស ដែលព្រះភគវាសម្តែងហើយដោយសេចក្តីសង្ខេប មិនទាន់ចែករំលែកសេចក្តីដោយពិស្តារនោះ ឲ្យពិស្តារបានផង សូមព្រះមហាកច្ចាយនៈមានអាយុ កុំធ្វើឲ្យយឺតយូរឡើយ សូមចែកឲ្យទាន ។ ព្រះមហាកច្ចាយនៈតបថា ម្នាលអាវុសោ បើដូច្នោះ លោកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលពាក្យរបស់ព្រះ

មហាកច្ចាយនៈមានអាយុថា ករុណា អាវុសោ ។ ម្នាលអាវុសោ កាល ព្រះសម្ពុទ្ធ ទ្រង់សម្តែងនូវឧទ្ទេសនោះ ដោយសង្ខេប មិនទាន់បានចែក សេចក្តីឲ្យពិស្តារ ខ្ញុំយល់សេចក្តីពិស្តារដូច្នេះ ។ ម្នាលអាវុសោ បុគ្គល អាឡោះអាល័យបច្ចុប្បន្នជាអតីតតើដូចម្តេច ? វិញ្ញាណរមែងជាប់ជំពាក់ នឹងឆន្ទរាគៈក្នុងចក្ខុនិងរូបនោះថា អាត្មាអញមានចក្ខុ ក្នុងអតីតដូច្នេះ បុគ្គលតែងត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណជាប់ចំពាក់ដោយ ឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថា អាឡោះ អាល័យចក្ខុនិងរូបជាអតីត ។

អាត្មាអញ មានសោតៈ ក្នុងកាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ ... អាត្មាអញ មានឃានៈ ក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ... អាត្មាអញ មានជិវ្ហា ក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ... អាត្មា អញ មានកាយ ក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... អាត្មា អញ មានចិត្ត ក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ វិញ្ញាណ រមែងជាប់ចំពាក់នឹងឆន្ទរាគៈក្នុងចិត្តនិងធម្មារម្មណ៍នោះដូច្នេះ បុគ្គលរមែង ត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ចំពាក់នឹងឆន្ទ-រាគៈ កាលបុគ្គលត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ឈ្មោះថានៅ អាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ ម្នាលអាវុសោ បុគ្គល នៅអាឡោះអាល័យបច្ចុប្បន្នជាអតីត យ៉ាងនេះឯង ។

ម្នាលអាវុសោ បុគ្គល មិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្តេច ? វិញ្ញាណរមែងមិនជាប់ចំពាក់នឹងឆន្ទរាគៈក្នុងចក្ខុនិងរូបនោះថា អាត្មាអញ មានចក្ខុ ក្នុងកាលជាអតីតដូច្នេះ មានរូបដូច្នេះ បុគ្គលរមែងមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណមិនបានជាប់ចំពាក់នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាមិនបានអាឡោះអាល័យចក្ខុនិងរូបជាអតីត ។

អាត្មាអញ មានសោតៈ ក្នុងកាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ... អាត្មាអញ មានឃានៈ ក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ... អាត្មាអញ មានជិវ្ហា ក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ... អាត្មាអញ មានកាយ ក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... វិញ្ញាណរមែងមិនជាប់ចំពាក់ដោយឆន្ទរាគៈ ក្នុងចិត្តនឹងធម្មារម្មណ៍នោះថា អាត្មាអញ មានចិត្ត ក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ បុគ្គលមិនត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា មិនអាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ ម្នាលអាវុសោ បុគ្គល មិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ? បុគ្គលតម្កល់ចិត្តដើម្បីការបាននូវរបស់ដែលមិនទាន់បានថា ក្នុងកាលជា

អនាគត សូមឲ្យអាត្មាអញ មានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ កាលបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាប្រាថ្នានូវចក្ខុនិងរូបជាអនាគត ។

ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានសោតៈដូច្នេះ មានសំឡេងដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានឃានៈដូច្នេះ មានក្លិនដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... បុគ្គលតម្កល់ចិត្ត ដើម្បីការបាននូវចិត្តនិងធម្មារម្មណ៍ ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលនោះត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថាប្រាថ្នានូវចិត្ត និងធម្មារម្មណ៍ជាអនាគត ។ ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតយ៉ាងនេះឯង ។ ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតតើដូចម្ដេច ? បុគ្គលមិនតម្កល់ចិត្តដើម្បីការបាននូវរបស់ដែលខ្លួនមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរចំពោះចក្ខុនិងរូបនោះ កាលបុគ្គលលែងត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថា មិនប្រាថ្នានូវចក្ខុនិងរូបជាអនាគត ។ ក្នុងកាលជាអនាគត

សូមឲ្យ អាត្មាអញ មានសោតៈដូច្នេះ មានសំឡេងដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានឃានៈដូច្នេះ មានក្លិនដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានជីវ្ហាដូច្នេះ មានរសដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... បុគ្គលមិនបានតម្កល់ចិត្តទុក ដើម្បីការបាននូវចិត្តនិងធម្មារម្មណ៍ ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តទុកជាបច្ច័យនាំឲ្យបុគ្គលលែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ កាលបុគ្គលលែងត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ឈ្មោះថាមិនប្រាថ្នានូវចិត្តនិងធម្មារម្មណ៍ជាអនាគត ។ ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

ម្នាលអាវុសោ បុគ្គលសេមសោម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ? ម្នាលអាវុសោ ចក្ខុនិងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចក្ខុនិងរូបជាបច្ចុប្បន្ននោះឯង បុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាសេមសោមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ ត្រចៀកនិងសំឡេង... ច្រមុះនិងក្លិន ... អណ្តាតនិងរស.... កាយនិងផោដ្ឋព្វៈ... ចិត្តនិងធម្មារម្មណ៍ទាំង ២ នេះ

ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចិត្តនិងធម្មារម្មណ៍នោះឯង បុគ្គលរមែងត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ឈ្មោះថារសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ បុគ្គលរសេមរសាមក្នុងធម៌ជាបច្ចុប្បន្នយ៉ាងនេះឯង ។

ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ? ម្នាលអាវុសោ ចក្ខុនិងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចក្ខុនិងរូបជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ ត្រចៀកនិងសំឡេង... ច្រមុះនិងក្លិន... អណ្តាតនិងរស... កាយនិងផោដ្ឋព្វៈ... ចិត្តនិងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងមិនជាប់ជំពាក់នឹងឆន្ទរាគៈ ក្នុងចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគៈ កាលបុគ្គលមិនត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ឈ្មោះថាមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

ម្នាលអាវុសោ ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកសេចក្តីដោយពិស្តារនេះឯង ខ្ញុំយល់សេចក្តីដោយពិស្តារយ៉ាងនេះ ប្រសិនបើលោកមានអាយុប្រាថ្នា ត្រូវចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរបញ្ជាក់សេចក្តីនោះ ហើយត្រូវចងចាំសេចក្តីនោះ តាមទំនងដែលព្រះអង្គដោះស្រាយយ៉ាងនោះចុះ ។

គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះមហាកច្ចាយនៈមានអាយុ ហើយក្រោកអំពីអាសនៈចូលទៅគាល់ព្រះសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះលោកនាថហើយអង្គុយក្នុងទីដ៏សមគួរ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះសម្ពុទ្ធយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់សម្តែងនូវឧទ្ទេសណា ដោយសេចក្តីសង្ខេប មិនទាន់បានចែករំលែកសេចក្តីដោយពិស្តារនៅឡើយ ហើយក៏ក្រោកចាកអាសនៈចូលទៅកាន់វិហារទៅ ព្រះអង្គយាងទៅមិនយូរប៉ុន្មាន យើងខ្ញុំទាំងនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះអង្គទ្រង់សម្តែងនូវឧទ្ទេសនេះដោយសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈទៅ តើនរណាហ្ន៎ គប្បីចែកសេចក្តីនៃឧទ្ទេស ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្តែងដោយសង្ខេប ទ្រង់មិនទាន់ចែកសេចក្តីដោយពិស្តារនោះ ឲ្យពិស្តារបាន បពិត្រព្រះភគវា ខ្ញុំព្រះអង្គ

ទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចាយនៈមានអាយុនេះឯង ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផង ព្រះកច្ចាយនៈមានអាយុអាចចែកសេចក្តីនៃឧទ្ទេស ដែលព្រះសាស្តាទ្រង់ត្រាស់សម្តែងដោយសង្ខេប ឲ្យពិស្តារបាន បើដូច្នេះ គួរពួកយើងចូលទៅរកព្រះមហាកច្ចាយនៈមានអាយុ លុះចូលទៅដល់ហើយ ពួកយើងគប្បីសួរបញ្ហាក់សេចក្តីនោះ នឹងព្រះមហាកច្ចាយនៈមានអាយុចុះ បពិត្រព្រះសក្យមុនី កាលបើហេតុយ៉ាងនេះ ពួកខ្ញុំព្រះអង្គ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចាយនៈ លុះចូលទៅដល់ហើយ ក៏បានសួរសេចក្តីនេះនឹងព្រះមហាកច្ចាយនៈ បពិត្រព្រះភគវាព្រះកច្ចាយនៈដ៏មានអាយុ ក៏បានចែកសេចក្តីដោយអាការៈទាំងឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះ ដល់ពួកខ្ញុំព្រះអង្គទាំងនោះ ។

ម្នាលភិក្ខុទាំងឡាយ មហាកច្ចាយនៈជាបណ្ឌិត ជាអ្នកមានប្រាជ្ញាច្រើន ប្រសិនបើអ្នកទាំងឡាយ សួរបញ្ហាក់សេចក្តីនោះនឹងតថាគត តថាគតនឹងដោះស្រាយសេចក្តីនោះ តាមទំនងដែលមហាកច្ចាយនៈដោះស្រាយយ៉ាងនោះដែរ សេចក្តីនៃភាសិតនោះ ដូច្នោះមែនហើយ ចូរអ្នកទាំងឡាយចងចាំយ៉ាងនេះចុះ ។ លុះព្រះលោកនាយកត្រាស់ភាសិតនោះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់

ព្រះមានព្រះភាគ ។

បន្ទាប់មកខាងក្រោយ ព្រះសាស្ដា ទ្រង់សម្ដែងព្រះសូត្រទាំងបី គឺមធុបិណ្ឌិកសូត្រ កច្ចាយនបេយ្យាសូត្រ និងបារាយនសូត្រ ឲ្យជាមូលហេតុ គ្រាដែលព្រះអង្គទ្រង់ប្រថាប់នៅវត្តជេតពន ទើបទ្រង់តែងតាំងព្រះមហាកច្ចាយនត្ថេរក្នុងចំណោមបរិស័ទ ទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយជាសាវ័ករបស់ព្រះអង្គ អ្នកចែកសេចក្ដីសង្ខេបឲ្យពិស្ដារបាន ដូចដែលពោលទុក ក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាតថា ៖

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោ ។**

ម្នាលភិក្ខុទាំងឡាយ មហាកច្ចាយនៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងជាអ្នកចែកសេចក្ដីធម៌ដែលតថាគតសម្ដែងដោយសង្ខេបឲ្យពិស្ដារបាន ។

គុណសម្បត្តិរបស់ព្រះមហាកច្ចាយនៈ ក្រៅអំពីព្រះសាស្ដាទ្រង់លើកតម្កើងតែងតាំងហើយ សូម្បីសក្កទេវរាជ ក៏មានការគោរពលើកតម្កើងលោកដែរ ដូចមានរឿងចារឹកទុកក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃអរហន្តវគ្គ ក្នុងរឿងព្រះមហាកច្ចាយនត្ថេរ ដូចមានសេចក្ដីថា ៖

ថ្ងៃមួយ ព្រះបរមសាស្ដា ទ្រង់ប្រថាប់នៅក្នុងវត្តបុព្វារាម ត្រាស់ព្រះធម៌ទេសនា ដោយទ្រង់ប្រារព្ធដល់ព្រះមហាកច្ចាយនៈជាដើមហេតុ ។

សេចក្តីពិស្តារនៃរឿងនេះថា ក្នុងសម័យមួយ ព្រះពុទ្ធអង្គ មានសាវកជាច្រើន ទ្រង់ប្រថាប់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងថ្ងៃមហាបវារណា ។ ក្នុងគ្រានោះ ព្រះមហាកច្ចាយនត្ថេរនៅក្នុងអវន្តីជនបទ សូម្បីលោកនិមន្តមកអំពីចម្ងាយ ក៏នៅតែមានការលើកតម្កើងអំពីព្រះ-ថេរៈ ព្រោះដូច្នោះ ព្រះថេរៈទាំងឡាយកាលបើនឹងគង់ ក៏គង់វៀរអាសនៈមួយទុកដើម្បីព្រះមហាកច្ចាយនត្ថេរ ។ សក្កទេវរាជ ស្តេចយាងមកអំពីទេវលោក ព្រមដោយទេវបរិស័ទ ទ្រង់បូជាព្រះបរមសាស្តាដោយផ្កា និងគ្រឿងក្រអូបដែលជាទិព្វជាដើម ហើយនៅប្រថាប់ឈរកាលបើទតមើលទៅមិនបានឃើញព្រះមហាកច្ចាយនត្ថេរ ទើបទ្រង់រំពឹងថា ព្រោះហេតុអ្វីហ្ន៎ លោកម្ចាស់កច្ចាយនៈរបស់យើង ទើបនៅមិនទាន់មក ប្រសិនបើលោកម្ចាស់និមន្តមក រាប់ថាជាការល្អប្រពៃណាស់ ។ ព្រះមហាកច្ចាយនត្ថេរ បាននិមន្តមកដល់ក្នុងពេលនោះឯង ដោយការមកប្រាកដខ្លួន ឡើងគង់លើអាសនៈ ដែលព្រះថេរៈទាំងឡាយវៀរទុកដើម្បីខ្លួន ។ ចំណែកសក្កទេវរាជ បានទតឃើញព្រះមហាកច្ចាយនត្ថេរ ទ្រង់ចាប់កជើងទាំងពីរយ៉ាងមាំ ហើយត្រាស់ថា លោកម្ចាស់របស់យើងមកហើយ កាលបើសក្កទេវរាជពោលដូច្នេះហើយ ទើបទ្រង់យកព្រះហស្តទាំងពីរប្របាច់ព្រះបាទទាំងសងខាងរបស់ព្រះថេរៈ ទាំងទ្រង់បូជាព្រះថេរៈដោយផ្កា និងគ្រឿងក្រអូបជាដើម ទ្រង់ថ្វាយបង្គំព្រះថេរៈរួចហើយ បាន

ប្រថាប់ឈរនៅក្នុងទីដ៏សមគួរ ។

ភិក្ខុទាំងឡាយពោលទោសតិះដៀលដល់សក្កទេវរាជថា ធ្វើសក្ការៈចំពោះតែព្រះមហាកច្ចាយនៈប៉ុណ្ណោះ សូម្បីសាវកធំៗ ដ៏សេសក្រៅអំពីនោះ ទ្រង់ទតមើលមិនឃើញឡើយ ។ ព្រះសាស្តាទ្រង់សណ្តាប់ពាក្យភិក្ខុទាំងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានទ្វារ ដែលខ្លួនគ្រប់គ្រងរក្សាល្អហើយ ក្នុងឥន្ទ្រិយទាំងឡាយ ដូចមហាកច្ចាយនៈ ដែលជាបុត្ររបស់តថាគតនេះ រមែងជាទីស្រឡាញ់ពេញចិត្តរបស់សក្កទេវរាជនោះ កាលព្រះអង្គនឹងទ្រង់បន្តអនុសន្ធិសម្តែងព្រះធម៌ ទើបត្រាស់គាថាធម្មបទ ថា ៖

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថី ហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និងមនុស្សទាំងឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលមានការលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ ។

គាថានេះ មានសេចក្តីអធិប្បាយថា ពាក្យថា ឥន្ទ្រិយទាំងឡាយ សម្តៅដល់ឥន្ទ្រិយទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត របស់ភិក្ខុណាដែលដល់នូវភាពស្ងប់ គឺជាឥន្ទ្រិយដែលខ្លួនទូន្មានបានល្អហើយ បានដល់ ប្រៀបដូចគ្នានឹងសេះដែលនាយសារថី ហ្វឹកហ្វឺនរាបល្អហើយ ដូច្នោះ ។

ក្នុងពេលដែលព្រះសាស្តាទ្រង់ទេសនាចប់ ជនជាច្រើនបានសម្រេចអរិយផល ផលដ៏ប្រសើរ មានសោតាបត្តិផល ជាដើម ។ សេចក្តីល្អរបស់លោក ដែលញ៉ាំងឲ្យបានជាប្រយោជន៍រហូតមកដល់សព្វថ្ងៃនេះ គឺលោកបានក្រាបទូល សូមឲ្យព្រះភគវា ទ្រង់ដោះស្រាយចំពោះពុទ្ធប្បញ្ញត្តិ១.ខ្វះដែលខ្វះខាតក្នុងភូមិប្រទេសនាៗ ដូចមានប្រាកដក្នុងសោណសូត្រ នៃគម្ពីរខុទ្ទកនិកាយ ឧទាន និងគម្ពីរមហាវគ្គ វិន័យបិដកថា ៖

ក្នុងសម័យមួយ ព្រះមហាកច្ចាយនៈ គង់នៅលើភ្នំឈ្មោះបវត្តៈទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តីជនបទ ពេលនោះឧបាសកឈ្មោះសោណកុដិកណ្ណៈ ជាឧបដ្ឋាក របស់ព្រះមហាកច្ចាយនៈ មានបំណងនឹងបួស ក៏បានត្រឹមតែការបព្វជ្ជាជាសាមណេរប៉ុណ្ណោះ មិនអាចនឹងឧបសម្បទាជាភិក្ខុបាន ព្រោះក្នុងដែនអវន្តីជនបទ រកភិក្ខុឲ្យគ្រប់គណសង្ឃលំបាកណាស់ ត្រូវនៅរង់ចាំរហូតដល់ ៣ ឆ្នាំ ទើបអាចឧបសម្បទាជាភិក្ខុបាន ។

កាលដែលព្រះសោណកុដិកណ្ណៈ បានឧបសម្បទាជាភិក្ខុហើយ មានបំណងនឹងចូលទៅគាល់ព្រះពុទ្ធអង្គ ទើបថ្វាយបង្គំលាព្រះកច្ចាយនៈដែលជាឧបជ្ឈាយ៍ ពេលនោះព្រះថេរៈពោលថា នែសោណៈ ប្រពៃពេកណាស់ចូលទៅចុះ ហើយផ្តាំសួរសុខទុក្ខព្រះអង្គឲ្យផង កាលបើអ្នកថ្វាយបង្គំព្រះសក្យមុនីរួចហើយ ទូលសូមឲ្យព្រះសាស្តាដោះស្រាយ ចំពោះ

ពុទ្ធប្បញ្ញត្ត ដែលខ្វះខាតក្នុងដែនអវន្តីជនបទនេះ ៥ ខផង គឺ ៖

១- ក្នុងដែនអវន្តីជនបទ មានភិក្ខុតិច សូមឲ្យព្រះសុគតសាស្តា ទ្រង់អនុញ្ញាតឧបសម្បទាដោយគណសង្ឃតិចជាង ១០ រូប ។

ក្នុងខនេះ ព្រះមានព្រះភាគទ្រង់ពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំង-ឡាយ តថាគតអនុញ្ញាតឲ្យឧបសម្បទាក្នុងបច្ចន្តជនបទ ដោយមានភិក្ខុជាគណសង្ឃ ៥ រូបបាន ។

២- ក្នុងដែនអវន្តីជនបទ មានផ្ទៃដីរដិបរដុបមិនស្មើ លំបាកក្នុងការនិមន្តទៅមកណាស់ សូមទ្រង់អនុញ្ញាតស្បែកជើងផង ។

ក្នុងខនេះ ព្រះអង្គពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតស្បែកជើង ៤ ជាន់ឡើងទៅ ។

៣- ក្នុងដែនអវន្តីជនបទ ប្រជាជនជាច្រើនមានទំនៀមទម្លាប់និយមងូតទឹកជានិច្ច ប្រកបដោយសេចក្តីស្អាតព្រោះទឹក ហេតុនេះសូមឲ្យព្រះអង្គទ្រង់អនុញ្ញាតផង ។

ក្នុងខនេះ ព្រះអង្គក៏អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការងូតទឹកបានជានិច្ច ។

៤- ក្នុងដែនអវន្តីជនបទ មានកម្រាលស្បែកទាំងឡាយ មានស្បែកពពែ ស្បែកចៀម ស្បែកម្រឹគ សូមឲ្យព្រះអង្គអនុញ្ញាតផង ។

ក្នុងខនេះព្រះអង្គក៏ទ្រង់ពុទ្ធានុញ្ញាតឲ្យភិក្ខុប្រើប្រាស់កម្រាលដែល

ធ្វើដោយស្បែកនោះបាន ។

៥- ក្នុងដែនអវន្តីជនបទ ឥឡូវនេះមនុស្សទាំងឡាយគេប្រគេនចីវរ ដើម្បីពួកភិក្ខុដែលនៅក្រៅសីមា យើងនឹងប្រគេនចីវរនេះដើម្បីភិក្ខុឈ្មោះនេះ ភិក្ខុទាំងនោះមកហើយប្រាប់ថា នែអាវុសោ ពួកមនុស្សឈ្មោះនេះបានប្រគេនចីវរចំពោះលោក ភិក្ខុទាំងនោះក៏វង្វៀសមិនត្រេកអរដោយគិតថា កុំឲ្យមាននិស្សគ្គិយដល់យើងឡើយ ហេតុនេះសូមឲ្យព្រះមានព្រះភាគទ្រង់គួរប្រាប់របៀបប្រតិបត្តិក្នុងចីវរផង ។

ខនេះ ព្រះអង្គពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរបាន ចីវរមិនទាន់មកដល់ដៃដរាបណា ចីវរនោះភិក្ខុមិនទាន់ត្រូវរាប់តាមកំណត់ថ្ងៃដរាបនោះ ។

ក្នុងការមានបដិភាណឆ្លើយតបឲ្យគូសន្ទនាកើតការចាប់ចិត្ត និងយល់ក្នុងពាក្យសម្ដីដែលបានពន្យល់ហើយនោះ ព្រះមហាកច្ចាយនត្ថេររាប់ជាព្រះថេរៈមួយរូបដែលមានបដិភាណក្នុងការឆ្លើយ ដូចមានសូត្រដែលពោលថា មនុស្សចាស់ និងក្មេង ក្នុងសមចិត្តវគ្គ នៃបឋមបណ្ណាសកៈ គឺពួក ៥០ សូត្រទី ១ គម្ពីរអង្គុត្តរនិកាយ ទុកនិបាត បានសម្ដែងការ ឆ្លើយតបរវាងព្រះមហាកច្ចាយនៈ ជាមួយនឹងកណ្ឌរាយនៈព្រាហ្មណ៍ មានសេចក្ដីថា ៖

គ្រាមួយ ព្រះមហាកច្ចាយនៈសម្រាកនៅគុន្ទាវន ក្បែរក្រុងមធុរា

ក្នុងពេលនោះ កណ្ឌរាយនព្រាហ្មណ៍ចូលទៅរកព្រះថេរៈ ហើយពោលថា លោកម្ចាស់កច្ចាយនៈ ខ្ញុំព្រះករុណាបានឮមកថា លោកម្ចាស់កច្ចាយនៈ មិនសំពះ មិនក្រោកទទួលនូវព្រាហ្មណ៍ចាស់ជរា មិនឲ្យអាសនៈដល់ព្រាហ្មណ៍ចាស់ជរា កាលដែលលោកម្ចាស់កច្ចាយនៈធ្វើយ៉ាងនេះ មិនសមគួរឡើយ ។ ព្រះមហាកច្ចាយនត្ថេរតបថា នែព្រាហ្មណ៍ មនុស្សចាស់ ឬក្មេងក្នុងធម្មវិន័យនេះ ព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុកថា សូម្បីមនុស្សចាស់ជរាដល់អាយុ ៨០ ឆ្នាំ ឬ ១០០ ឆ្នាំ ក៏ដោយ ប្រសិនបើនៅបរិភោគកាម ដេកនៅក្នុងកាម ជាអ្នកក្តៅក្រហាយដោយកាម ជាអ្នកមាននូវកាមវិតក្ក ឬកំពុងខ្វល់ខ្វាយស្វែងរកកាម ក៏នៅតែរាប់ថាជាមនុស្សក្មេងដោយពិត មិនរាប់ថាជាមនុស្សចាស់ជរាឡើយ ប៉ុន្តែសូម្បីមនុស្សនោះនៅក្មេងក៏ដោយ មានសក់ខ្មៅស្រិលក៏ដោយ នៅក្នុងបឋមវ័យក៏ដោយ ប្រសិនបើមិនបរិភោគកាម មិនដេកក្នុងកាម មិនក្តៅក្រហាយដោយកាម មិនមានកាមវិតក្ក មិនខ្វល់ខ្វាយស្វែងរកកាម ក៏រាប់ថាជាមនុស្សចាស់ជរា នៅក្នុងធម្មវិន័យនេះដោយពិតប្រាកដ ។

កាលបើព្រះថេរៈតបយ៉ាងនេះហើយ កណ្ឌរាយនព្រាហ្មណ៍បានក្រោកឡើង ដណ្តប់សំពត់ឆៀងស្មាម្ខាង ក៏បានក្រាបថ្វាយបង្គំព្រះថេរៈ ហើយពោលឡើងថា លោកម្ចាស់ជាមនុស្សចាស់ ចំណែកខ្ញុំព្រះករុណាជាមនុស្សក្មេង ក្នុងធម្មវិន័យនេះ ចាប់ពីថ្ងៃនេះតទៅសូមលោកម្ចាស់

ចាំទុកខ្ញុំព្រះករុណាថាជាឧបាសក អ្នកដល់នូវព្រះរតនត្រៃស្មើដោយជីវិត ជាវៀងរហូតតទៅ ។

មួយទៀត ផលល្អនៃការសម្ដែងធម៌របស់ព្រះកច្ចាយនៈ កាលខ្លះ មានអ្នកចូលមកសួរ លោកបានអធិប្បាយឲ្យអ្នកសួរកើតការយល់ បាន យ៉ាងជាក់ច្បាស់ ដូចមានរឿងដែលពោលទុកនៅក្នុងគម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ នៃលោហិច្ចសូត្រ ដូចមានសេចក្ដីថា ៖

សម័យមួយ ព្រះមហាកច្ចាយនៈគង់នៅអរញ្ញកុដិ ដែលតាំងនៅក្បែរ កម្មក្ករកជនគរ ក្នុងអវន្តីជនបទ ។ គ្រានោះ មានពួកមាណពជាច្រើន នាក់ ដែលជាអន្តេវាសិករបស់លោហិច្ចព្រាហ្មណ៍ បានដើរទៅរកអុស និងបាននាំគ្នាចូលទៅកាន់អរញ្ញកុដិ របស់ព្រះមហាកច្ចាយនៈ ហើយនាំ គ្នាដើរទៅក្នុងបរិវេណកុដិរបស់ព្រះថេរៈ និងមានការរត់លេង ស្រែក សំឡេងអ៊ូអរស្មូរទ្រហឹង ទាំងពោលថា សមណៈត្រងោលទាំងនេះ មាន ពូជអម្បូរថ្នាក់ថោកទាប ជាពួកដែលកើតអំពីជើងរបស់ព្រហ្ម ។

ក្នុងខណៈនោះ ព្រះមហាកច្ចាយនត្ថេរ បានស្ដាប់សំឡេងពោល មើលងាយរបស់មាណពទាំងនោះ ទើបលោកចេញពីកុដិ និងបានពោល ជាមួយមាណពទាំងនោះថា នែមាណពទាំងឡាយ ពួកអ្នកកុំពោល សំឡេងឡូឡាអ្វីឡើយ ចាំអាត្មានឹងពោលធម៌ឲ្យពួកអ្នកបានស្ដាប់ ។

កាលបើព្រះមហាកច្ចាយនៈមានថេរដីកាយ៉ាងនេះ ពួកមាណពទាំង

នោះ ក៏នាំគ្នានៅស្ងៀម ហើយបានពោលជាមួយមាណពទាំងនោះ ដោយគាថាដែលជាធម៌ទាំងឡាយថា ៖

ព្រាហ្មណ៍ពួកណា រមែងរឭកនូវធម៌របស់ព្រាហ្មណ៍ពីបុរាណបាន ព្រាហ្មណ៍ទាំងនោះជាអ្នកខ្ពង់ខ្ពស់បំផុតដោយសីល ព្រាហ្មណ៍ទាំងឡាយពីបុរាណដែលសង្រួមនៅក្នុងទ្វារបាន គ្រប់គ្រងដោយល្អហើយ នឹងអាចគ្របសង្កត់នូវសេចក្តីក្រោធដែលកើតឡើងបាន ។

ព្រាហ្មណ៍ពួកណា រឭកនូវធម៌របស់ពួកព្រាហ្មណ៍ពីបុរាណបាន ព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រព្រឹត្តក្នុងធម៌ និងប្រព្រឹត្តក្នុងឈាន ។

ព្រាហ្មណ៍ពួកណា លះធម៌ទ.នេះចោលហើយ ជាអ្នកស្រវឹងដោយគោត្រថា មានអាជ្ញាក្នុងខ្លួនច្រើន ជាអ្នកប្រព្រឹត្តខុសចំពោះសត្វទាំងឡាយ ព្រាហ្មណ៍នោះជាអ្នកមានភ័យជាប់តាមខ្លួន ។

ការសមាទានវត្តទាំងពួង បានដល់ ការមិនបរិភោគ ការដេកលើបន្ទា ការចុះត្រាំទឹក និងការមិនគ្រប់គ្រងនូវទ្វារទាំងនេះ ជាការគ្មានផលប្រៀបដូចជាបុរសដែលដេកសុបិន ដូច្នោះដែរ ។ ការពោលសរសើរបរិក្ខារកណ្ឌៈទាំងនេះ គឺ ស្បែកខ្លា ព្រមទាំងក្រចក ជដា និងការសន្សំនូវរបស់មិនស្អាតជាមូល ចេ្ចញ មន្ត្ត សីលព្វតៈ ដែលថាជា តបៈ ។ ការបោកបញ្ឆោតឈើច្រត់ដែលកោង-ង និងការប្រោះព្រំទឹក ដែលពោលថាជាចំណោះដឹងរបស់ព្រាហ្មណ៍ ទាំងនេះជាការបំពេញដើម្បីអាមិសដែល

ពួកព្រាហ្មណ៍ធ្វើហើយ ។

ចំណែកពួកបុរាណណា ជាអ្នកមានចិត្តតាំងមាំល្អ មានចិត្តផូរផង់ ជាអ្នកមានចិត្តមិនឃោរឃៅចំពោះសត្វទាំងឡាយ ការធ្វើយ៉ាងនេះជា ដំណើរទៅកាន់ព្រហ្មលោក ។ ពួកមាណពទាំងនោះ បានស្តាប់ថេរវាចា របស់ព្រះមហាកច្ចាយនត្ថេរហើយ កើតការចង្អៀតចង្អល់ និងមិនពេញ ចិត្តចំពោះព្រះថេរៈឡើយ ទើបនាំគ្នាចូលទៅដល់ទីលំនៅរបស់លោហិច្ច-ព្រាហ្មណ៍ដែលជាអាចារ្យ និងបានពោលជាមួយលោហិច្ចព្រាហ្មណ៍ថា បពិត្រលោកអាចារ្យដ៏ចម្រើន សូមលោកអាចារ្យជ្រាបចុះ ព្រះកច្ចាយនៈ ពោលបញ្ចិតបញ្ចៀងបញ្ឈឺចិត្ត និងជំទាស់ចំពោះមន្ត របស់ព្រាហ្មណ៍ ទាំងឡាយ ។

កាលបើពួកមាណពពោលយ៉ាងនេះហើយ លោហិច្ចព្រាហ្មណ៍ កើតការចង្អៀតចង្អល់ចិត្ត ថែមទាំងមិនពេញចិត្តចំពោះព្រះថេរៈទៀតផង ប៉ុន្តែគេគិតឡើងថា ការដែលយើងជេរតិះដៀលព្រះថេរៈរូបនេះ ព្រោះ ជឿស្តាប់ពាក្យសម្តីរបស់ពួកមាណពទាំងនេះ ដូចមិនសមគួរដល់យើង ឡើយ ទោះបីយ៉ាងណា យើងនឹងចូលទៅរកព្រះថេរៈសួរមើលសិនមើល៍ ទើបជាការល្អ ។ កាលបើលោហិច្ចព្រាហ្មណ៍បានគិតដូច្នេះហើយ ទើប នាំមាណពទាំងនោះ ចូលទៅរកព្រះមហាកច្ចាយនត្ថេរ រហូតដល់ទីលំនៅ និងបានប្រាស្រ័យចរចាជាមួយនឹងលោក រួចហើយទើបអង្គុយនៅក្នុងទីដ៏

សមគួរ ហើយសួរព្រះថេរៈថា លោកម្ចាស់កច្ចាយនៈដ៏ចម្រើន ពួកមាណពជាច្រើន ដែលដើរមករកអុស ជាសិស្សរបស់ខ្ញុំ ធ្លាប់បានចូលមកទីនេះដែរឬទេ ? ព្រះថេរៈតបថា ធ្លាប់មក លោហិច្ចព្រាហ្មណ៍ផ្តើមសួរថា លោកម្ចាស់កច្ចាយនៈ លោកធ្លាប់បានប្រាស្រ័យចរចាជាមួយនឹងមាណពទាំងនោះដែរឬទេ ? ព្រះថេរៈតបថា ធ្លាប់បានប្រាស្រ័យចរចាដែរ ។ លោហិច្ចព្រាហ្មណ៍ផ្តើមសួរទៀតថា លោកម្ចាស់ធ្លាប់ប្រាស្រ័យចរចាជាមួយនឹងមាណពទាំងនោះ យ៉ាងណាដែរ ? ព្រះមហាកច្ចាយនៈពោលពន្យល់ថា អាត្មាបានប្រាស្រ័យចរចាជាមួយមាណពទាំងនោះយ៉ាងនេះថា ៖

ពួកព្រាហ្មណ៍ណា រមែងរឭកនូវធម៌របស់ព្រាហ្មណ៍ពីបុរាណបាន ព្រាហ្មណ៍ពួកនោះ ជាអ្នកខ្ពង់ខ្ពស់បំផុតដោយសីល ។ល។ ការធ្វើយ៉ាងនេះ ជាដំណើរទៅកាន់ព្រហ្មលោក នៃព្រាហ្មណ៍ អាត្មាបានប្រាស្រ័យចរចាជាមួយមាណពយ៉ាងនេះឯង ។ លោហិច្ចព្រាហ្មណ៍ បានស្តាប់ពាក្យពន្យល់របស់ព្រះថេរៈហើយ ក៏សួរតទៅទៀតថា លោកម្ចាស់កច្ចាយនៈដ៏ចម្រើន ដែលលោកពោលថា អ្នកដែលមិនបានគ្រប់គ្រងទ្វារ ដោយមានហេតុប្រមាណប៉ុន្មាន បុគ្គលទើបឈ្មោះថា ជាអ្នកមានទ្វារមិនបានគ្រប់គ្រង ? ព្រះមហាកច្ចាយនៈពោលអធិប្បាយថា នែព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ឃើញរូបដោយភ្នែក ឮសំឡេងដោយត្រចៀក ធុំក្លិន

ដោយច្រមុះ ដឹងរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ និង ដឹងធម្មារម្មណ៍ដោយចិត្តហើយ រមែងពេញចិត្តក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ដែលជាទីពេញចិត្ត ជាអ្នកមិនមានសតិតាំងមាំ មិនរវាំង និងមិនដឹងច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិតាមពិត ដោយ អំណាចអកុសលធម៌ដ៏លាមកទាំងនេះ កើតឡើងហើយក្នុងចិត្តនៃបុគ្គល នោះ ទាំងនេះឈ្មោះថា ជាអ្នកមិនគ្រប់គ្រងទ្វារ ។ លោហិច្ចព្រាហ្មណ៍ បានស្តាប់ដូច្នេះហើយ ក៏ពោលឡើងថា លោកម្ចាស់កច្ចាយនៈ សេចក្តី ដែលលោកបានពោលថា បុគ្គលដែលមិនបានគ្រប់គ្រងទ្វារ គួរអស្ចារ្យ ណាស់ មិនធ្លាប់មាន ទើបសួរព្រះថេរៈបន្ត ទៀតថា ចុះបុគ្គលដែលគ្រប់ គ្រងទ្វារដោយល្អនោះមានន័យយ៉ាងណា ?

ព្រះថេរៈតបថា ភិក្ខុក្នុងធម្មវិន័យនេះ បានឃើញរូបដោយភ្នែក ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ដឹងរសដោយអណ្តាត ពាល់ត្រូវផោដ្ឋព្វៈដោយកាយ និងដឹងធម្មារម្មណ៍ដោយចិត្តហើយ រមែងជាអ្នក មិនត្រេកអររីករាយចំពោះរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ដែលគួរប្រាថ្នាពេញចិត្តឡើយ ជាអ្នកមានសតិតាំងមាំ ដឹងច្បាស់នូវ ចេតោវិមុត្តិ បញ្ញាវិមុត្តិ តាមសេចក្តីពិត ដូច្នេះហើយ អកុសលធម៌ដ៏ លាមកទាំងឡាយ ក៏មិនកើតមានដល់ភិក្ខុនោះ ទាំងនេះឈ្មោះថាជាអ្នក គ្រប់គ្រងទ្វារដោយល្អ ដោយប្រការយ៉ាងនេះឯង ។

លោហិច្ចព្រាហ្មណ៍ បានពោលសរសើរព្រះថេរៈថា លោកម្ចាស់ ពោលដល់បុគ្គលដែលជាអ្នកគ្រប់គ្រងទ្វារនេះ គួរឲ្យអស្ចារ្យណាស់ មិនធ្លាប់មាន ភាសិតរបស់លោកម្ចាស់ជាក់ច្បាស់ពេកណាស់ ដោយអនេកបរិយាយ ប្រៀបដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ បើករបស់ដែលបិទ ឬដូចបុគ្គលទ្រោលប្រទីបក្នុងទីងងឹត ដូច្នោះឯង ។ បពិត្រលោកម្ចាស់កច្ចាយនៈដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះមានព្រះភាគអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះសង្ឃជាសរណៈ ជាទីពឹង ទីរឭកស្មើដោយជីវិតចាប់តាំងពីថ្ងៃនេះតទៅ ។

ម្យ៉ាងទៀត សូមលោកម្ចាស់កច្ចាយនៈដ៏ចម្រើន ចូលទៅកាន់លោហិច្ចត្រកូល ដូចដែលលោកម្ចាស់ចូលទៅកាន់ត្រកូលឧបាសកទាំងឡាយក្នុងកម្មក្ករកជនគរចុះ ពួកមាណពដែលនៅក្នុងលោហិច្ចត្រកូលទាំងនោះនឹងថ្វាយបង្គំ នឹងក្រោកឡើងទទួលលោកម្ចាស់ ដើម្បីប្រយោជន៍ និងសេចក្តីសុខអស់កាលជាយូរអង្វែងដល់ពួកគេ ។

ដូចមានរឿងសម្តែងហេតុផលថា ព្រះមហាកច្ចាយនត្ថេរ លោកមានរូបរាងកាយស្អាតណាស់ មានសម្បុរលឿងដូចមាស គួរឲ្យស្រឡាញ់ មាននៅក្នុងអដ្ឋកថា គម្ពីរធម្មបទ នៃចិត្តវគ្គ ក្នុងរឿងព្រះសោរេយ្យត្ថេរ ដូចមានសេចក្តីថា ៖

នៅក្នុងសោរេយ្យនគរ មានសេដ្ឋីបុត្រម្នាក់ ឈ្មោះថា សោរេយ្យ

បានអង្គុយលើយានជាមួយនឹងសម្លាញ់ ចេញអំពីក្រុងដើម្បីងូតទឹករួមជាមួយនឹងបរិវារជាច្រើននាក់ ។ ខណៈនោះ ព្រះមហាកច្ចាយនត្ថេរ ចូលទៅបិណ្ឌបាតក្នុងសោរេយ្យនគរ មុននឹងចូលទៅក្នុងក្រុង លោកឃ្លុំចីវរនៅក្រៅក្រុង ធ្វើឲ្យសោរេយ្យក្រឡេកមើលឃើញសម្បុរកាយពណ៌ ដូចមាស ទើបគិតឡើងថា សូមឲ្យព្រះថេរៈរូបនេះ បានជាភរិយារបស់យើង ឬសូមឲ្យភរិយារបស់យើង មានពណ៌សម្បុរកាយដូចព្រះថេរៈរូបនេះ ។ គ្រាន់តែគិតដូច្នេះ ភេទរបស់បុរសក៏បាត់ទៅ ប្រាកដជាភេទស្រីឡើង គេអៀនខ្មាសណាស់ ទើបចុះពីយាននោះរត់ទៅដោយមិនឲ្យ នរណាដឹងបាន គេបានធ្វើដំណើរទៅកាន់នគរតក្កសិលា មិនឲ្យនរណាដឹងរឿងរបស់ខ្លួន ។

ចំណែកសម្លាញ់របស់សោរេយ្យ បានស្វែងរកសព្វទិសទី ក៏នៅតែមិនបានជួបប្រទះ គ្រប់គ្នាងូតទឹករួចហើយ ក៏ត្រឡប់ទៅផ្ទះវិញ ដោយនឹកថា សោរេយ្យគេងូតទឹកហើយ គង់នឹងត្រឡប់មកផ្ទះមិនខាន ។ គ្រានោះ មាតាបិតារបស់សោរេយ្យ មិនឃើញកូនត្រឡប់មក ទើបចេញទៅតាមសួររកកូនសព្វទីកន្លែង ក៏នៅតែមិនបានជួបប្រទះ និងមិនមានការដឹងដំណឹងអ្វីសោះ ក៏បានស្រែកយំដោយយល់ថា សោរេយ្យកូនរបស់យើងស្លាប់ទៅហើយ ទើបនាំគ្នាធ្វើបុណ្យឧទ្ទិសដល់សោរេយ្យ ។

ចំណែកសោរេយ្យ ដើរតាមពីក្រោយរទេះដែលនឹងទៅកាន់នគរតក្កសិលា ប៉ុន្តែគេដើរទៅមិនបានប៉ុន្មានក៏ដើរមិនរួច ទើបគេដោះចិញ្ចៀន

មួយវង់ជាថ្ងៃឈ្នួលក្នុងការជិះរទេះ ។ ជនជាច្រើនលុះឃើញសោរយ្យេ មានរូបស្អាតរកកន្លែងរិះគន់មិនបាន ទើបប្រឹក្សាគ្នាថា បុត្រសេដ្ឋីក្នុងនគរតក្កសិលាមិនទាន់មានភរិយា ពួកយើងប្រាប់គេហើយ គង់នឹងបានរង្វាន់មិនខាន ។ ជនទាំងនោះកាលទៅដល់នគរតក្កសិលាហើយ បានប្រញាប់ទៅប្រាប់សេដ្ឋីបុត្រថា នែនាយ ពួកខ្ញុំបាននាំស្រីកែវមកឲ្យលោក សេដ្ឋីបុត្រស្តាប់ហើយចាប់ចិត្ត ទើបឲ្យនាំស្រីនោះមកមើល កាលគេឃើញរូបស្អាត ក៏បានកើតសេចក្តីស្នេហា យកនាងធ្វើជាភរិយារបស់ខ្លួន ។

បុរសដែលមិនធ្លាប់កើតជាស្រី ឬស្រីដែលមិនធ្លាប់កើតជាបុរសមិនមានឡើយ ព្រោះបុរសទាំងឡាយ ប្រព្រឹត្តខុសចំពោះបុត្រភរិយារបស់អ្នកដទៃ ស្លាប់ទៅត្រូវកើតក្នុងនរកច្រើនសែនឆ្នាំ ហើយត្រឡប់មកកើតជាមនុស្ស តែត្រូវកើតជាស្រីចំនួន ១០០ ជាតិ ។

សូម្បីព្រះអានន្ទត្ថេរ បានកសាងបុណ្យបារមីមកហើយ មួយសែនកប្ប ជាតិមួយ លោកបានកើតក្នុងត្រកូលជាងមាស បានប្រព្រឹត្តខុសចំពោះបុត្រភរិយារបស់អ្នកដទៃ ក្រោយពីស្លាប់ត្រូវទៅឆេះក្នុងនរក រួចហើយ ក៏ត្រឡប់បានកំណើតជាស្រី និងជាភរិយារបស់គេ ១៤ ជាតិ ទាំងបានជាស្រីអារ ៧ ជាតិ ប៉ុន្តែប្រសិនបើស្ត្រីប្រាថ្នាចង់កើតជាបុរសវិញ ត្រូវធ្វើបុណ្យ ឲ្យទាន រក្សាសីលជាដើម បើអស់ការពេញចិត្តជាស្រីហើយ គប្បីតាំងចិត្តទុកដូច្នេះថា ៖

បុណ្យរបស់យើងនេះ សូមឲ្យយើងបានកើតជាបុរស ពេលស្លាប់ទៅហើយ ក៏បានកើតជាបុរសមែន ។ ឬម្យ៉ាងទៀត អ្នកដែលគោរពស្វាមីដូចជាទេវតា រមែងកើតជាបុរសបាន ដោយអំណាចការបដិបត្តិចំពោះស្វាមី ។

កាលសោរេយ្យនៅរួមជាមួយនឹងសេដ្ឋីបុត្រ មានកូន ២ នាក់ទៀត កាលពីមុនដែលគេនៅក្នុងសោរេយ្យនគរ គេមានភរិយានិងមានបុត្រ ២ នាក់ទៅហើយ រួមបុត្រទាំងមុនក្រោយត្រូវជា ៤ នាក់ ។ ជាតិនេះធ្លាប់ជាស្វាមីគេផង និងធ្លាប់ជាប្រពន្ធគេផង ពេលជាខាងក្រោយមកគេបានជ្រាបដំណឹងពីសម្លាញ់ដែលនាំទំនិញមកលក់ នៅនគរតក្កសិលាថា ព្រះមហាកច្ចាយនៈ មកអាស្រ័យនៅក្នុងនគរនេះ ទើបត្រៀមរៀបចំចង្ហាន់ និងគ្រឿងសក្ការៈទុកប្រគេន ហើយនិមន្តព្រះថេរៈមកផ្ទះរបស់ខ្លួន ។ សោរេយ្យបានតំណាលរឿងក្នុងកាលមុន ឲ្យស្វាមីស្តាប់ ហើយស្វាមីក៏បាននាំចូលទៅសូមខមាទោសចំពោះព្រះថេរៈ ព្រះថេរៈក៏បានអត់ទោសឲ្យ ភេទស្រីបាត់ទៅមួយរំពេច ភេទបុរសក៏បានប្រាកដឡើងដូចដើមវិញ ព្រះមហាកច្ចាយនៈ បានស្តាប់រឿងនេះហើយ កើតការស្ញុតចិត្តនិងការពារមិនឲ្យហេតុយ៉ាងនេះកើតឡើងទៀត ព្រោះការគិតមិនល្អ ទើបលោកអធិដ្ឋានឲ្យរូបរបស់លោកមិនស្អាត មិនគួរឲ្យចង់មើលទៀតផង ។

នៅមានរឿងដែលសម្តែងដល់ព្រះមហាកច្ចាយនៈ ថាជាអ្នកមាន

រូបស្អាតឥតខ្ចោះ មានពណ៌សម្បុរល្មៀងដូចជាមាស និងមានអ្នកដទៃពោលសរសើរលោកថា មានបុគ្គលិកលក្ខណៈប្រៀបដូចព្រះសម្មុទ្ទ តាមដែលមានរឿងតំណាលទុកក្នុងគម្ពីរអសីតិមហាសាវកនិព្វាន ថា ៖

ព្រះមហាកច្ចាយនៈ ជាអ្នកមានសីល សមាធិ បញ្ញា សម្រាកសម្រួលឥរិយាបថ ប្រាសចាកភ័យនៅក្នុងកុដិ ក្នុងព្រៃស្រស់មានម្លប់ត្រឈឹងត្រឈៃ ដែលតាំងនៅជើងភ្នំបដ្ឋលិតបពិត ដោយអាស្រ័យនៅហេមនគរ ជាទីគោចរបិណ្ឌបាត លោកបានសម្តែងធម៌ធ្វើឲ្យមនុស្ស និងទេវតាកើតសេចក្តីត្រេកអរក្នុងការបរិច្ចាគទាន ក្នុងការរក្សាសីល និងមានសទ្ធាជ្រះថ្លាក្នុងព្រះសាសនា រហូតដល់មានការគោរពចំពោះព្រះរតនត្រៃជានិច្ចនិរន្តរ៍ ។ រូបកាយរបស់ព្រះមហាកច្ចាយនៈនោះ ស្អាតពេកក្រៃ រកព្រះថេរានុថេរៈទាំងឡាយប្រៀបផ្ទឹមមិនបាន វៀរលែងតែព្រះមុនីចេញប៉ុណ្ណោះ ។ ដូចមានពាក្យពណ៌នាសរសើរលោកថា ៖

កាលបើព្រះមហាកច្ចាយនត្ថេរ ចារិកបិណ្ឌបាតទៅក្នុងប្រទេសណា មនុស្ស និងទេវតាទាំងឡាយក្នុងប្រទេសនោះ ពោលសរសើរស្រែកឡើងថា **សត្ថា អាគតោ** ពួកយើង ព្រះបរមគ្រូមកប្រោសពួកយើងហើយ ទើបនាំគ្នាធ្វើសក្ការបូជាសម្តែងនូវការគោរពថ្វាយបង្គំព្រះមហាកច្ចាយនត្ថេរនោះ ដោយការពេញចិត្ត ។ កាលបើព្រះថេរៈ បានស្តាប់ពាក្យរបស់មនុស្ស និងទេវតាទាំងឡាយ ដែលនាំគ្នាពោលសរសើរ

លើកតម្កើងខ្លួនប្រៀបផ្ទឹមជាមួយគ្នានឹងព្រះមុនី ទើបលោកគិតពិចារណា នៅក្នុងចិត្តថា មនុស្ស និងទេវតាទាំងនេះ ពោលសរសើរយើងដោយ ពាក្យមិនសមគួរទាល់តែសោះ ដោយបាននាំគ្នាហៅខ្លួនយើងថា ជាព្រះ សក្យមុនីទៅវិញ ពាក្យនេះរមែងជាការមិនសមគួរទេ ។

កាលបើព្រះថេរៈ លោកគិតពិចារណាមើលហេតុផលនៃពាក្យ សម្តីរបស់មនុស្ស និងទេវតាទាំងនោះ ដែលនាំគ្នាពោលសរសើរខ្លួន មិនអាចនឹងអត់ទ្រាំស្តាប់វាចា ដែលពោលសរសើរលើកតម្កើងខ្លួនឡើង ស្មើគ្នានឹងព្រះបរមសាស្តាទៅតទៀតបាន លោកទើបគិតថា យើងចាំ បាច់ត្រូវនិម្មិតរូបកាយរបស់យើងនេះ ឲ្យផ្លាស់ប្តូរប្រែប្រួលខុសពីសភាព ដើម កាលបើលោកគិតដូច្នេះហើយ ព្រះថេរៈទើបអធិដ្ឋានចិត្ត និម្មិតរូប កាយរបស់លោកឲ្យរួញខ្ទីជាត់ អស់នូវភាពស្អាត ព្រោះដូច្នោះ រូបកាយ របស់ព្រះមហាកច្ចាយនត្ថេរ ទើបប្រាកដមានលក្ខណៈមិនស្អាតរហូតមក ដល់សព្វថ្ងៃនេះ ។

រឿងឈ្មោះរបស់ព្រះមហាកច្ចាយនត្ថេរ ជារឿងដែលគួរឲ្យចាប់ ចិត្ត ម្យ៉ាងទៀត ក្នុងគម្ពីរអសីតិមហាសាវកនិព្វាន ពោលថា អតីតៈ លោកឈ្មោះថា ព្រហ្មបុត្រ បន្ទាប់មកបានហៅឈ្មោះលោកថា ព្រះ-គវម្បតិត្ថេរ ព្រោះហេតុថា លោកមានរូបកាយស្អាតក្រៃពេក ទេសនា ក៏ពីរោះ ដូចព្រះពុទ្ធជាម្ចាស់ មហាជនទើបហៅថា គវម្បតិ ប្រែថា

ម្ចាស់នៃពាក្យនិយាយ ។

ការដែលមានចំណេះចេះដឹង អាចអធិប្បាយសេចក្តីឲ្យយល់បានងាយ នាំយកហេតុផលមកពន្យល់ឲ្យអ្នកស្តាប់យល់ចូលចិត្ត ព្រមទទួលការពិត ព្រះមហាកច្ចាយនត្ថេរ រាប់ថាជាព្រះថេរៈមួយរូប ដែលបានធ្វើសេចក្តីល្អជាច្រើន ដូចមានរឿងចារឹកទុកក្នុងគម្ពីរមជ្ឈិមនិកាយ មជ្ឈិម-បណ្ណាសកៈ នៃមធុរសូត្រ ហើយរឿងនេះនៅជាល័ក្ខដ្ឋាន បង្ហាញឲ្យបានដឹងថា លោកមានអាយុយឺនយូរ មកដល់ក្រោយព្រះពុទ្ធជាម្ចាស់ទ្រង់រំលត់ខន្ធបរិនិព្វានហើយ មានសេចក្តីថា ៖

សម័យមួយ ព្រះមហាកច្ចាយនត្ថេរ សម្រាន្តឥរិយាបថនៅក្នុងគុន្ទាវ័ន ទៀបក្រុងមធុរា ។ ព្រះបាទមធុររាជអវន្តីបុត្រ បានឮដំណឹងថា ម្នាលយើងដ៏ចម្រើន សមណៈឈ្មោះកច្ចាយនៈ ឥឡូវនេះគង់នៅក្នុងគុន្ទាវ័ន ទៀបក្រុងមធុរា កិត្តិស័ព្ទដ៏ប្រណៃយ៉ាងនេះ របស់ព្រះកច្ចាយនៈដ៏ចម្រើននោះឯង តែងផ្សាយទៅសព្វទិសថា លោកជាបណ្ឌិតឈ្លាសវៃ មានបញ្ញា ជាពហូសូត មានសម្តីដ៏វិចិត្រ មានបញ្ញាដ៏ល្អជាអ្នកចាស់ព្រឹទ្ធាផង ជាព្រះអរហន្តផង ការបានឃើញព្រះអរហន្តមានសភាពយ៉ាងនេះ ជាការញុំាំងប្រយោជន៍ឲ្យសម្រេចដោយពិត ។ គ្រានោះ ព្រះបាទមធុររាជអវន្តីបុត្ត ទ្រង់ឲ្យរៀបចំយានទាំងឡាយដែលល្អៗទ្រង់ឡើងគង់លើយានដែលល្អៗ ហើយទ្រង់ស្តេចចេញចាកក្រុងមធុរា

ដោយយានទាំងឡាយដែលល្អៗ ដើម្បីជួបនឹងព្រះមហាកច្ចាយនៈ ដោយរាជានុភាពដ៏ធំ ទ្រង់ស្ដេចទៅដោយយាន កំណត់ត្រឹមផែនដី ដែលបរយានទៅបាន ហើយទ្រង់យាងចុះពីយាន ទ្រង់ព្រះដំណើរទៅដោយព្រះបាទា ចូលទៅរកព្រះមហាកច្ចាយនៈ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះថេរៈ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ព្រះបាទមធុររាជបុត្រ លុះគង់នៅក្នុងទីដ៏សមគួរហើយ មានព្រះបន្ទូលពាក្យនេះនឹង ព្រះមហាកច្ចាយនៈមានអាយុថា បពិត្រព្រះកច្ចាយនៈដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាពោលយ៉ាងនេះថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍ មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្ររបស់ព្រហ្មជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងឲ្យកើត ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ សេចក្ដីនេះ ព្រះកច្ចាយនៈដ៏ចម្រើន នឹងពោលដូចម្ដេចទៅវិញ ។

ព្រះមហាកច្ចាយនៈថ្វាយព្រះពរថា បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាបជាដើម ។បេ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនោះ អ្នកប្រាជ្ញគប្បីដឹងដោយបរិយាយ ដូចតទៅនេះ

បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច បើក្សត្រគប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើក្សត្រ ( ដទៃ ) គប្បីជាអ្នកតើនឡើងមុន ផ្ទំក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រនោះឬទេ ? ព្រាហ្មណ៍ក្ដី... វេស្សៈក្ដី... សុទ្ទៈក្ដី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយក្ដី ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃក្សត្រនោះឬទេ ? ព្រះបាទមធុររាជត្រាស់ថា បពិត្រព្រះកច្ចានៈដ៏ចម្រើន បើក្សត្រគប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស ក្សត្រដទៃ ក៏ជាអ្នកត្រូវតើនឡើងមុន ផ្ទំក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃក្សត្រនោះឯង ។ ព្រាហ្មណ៍ក្ដី... វេស្សៈក្ដី... សុទ្ទៈក្ដី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រនោះឯង ។

ព្រះថេរៈសួរបន្តទៀតថា បពិត្រមហារាជ ប្រសិនបើសេចក្ដីត្រូវការរបស់វេស្សៈ សុទ្ទៈ... ក្សត្រ... ព្រាហ្មណ៍... នឹងត្រូវសម្រេចដោយទ្រព្យ ស្រូវ ឬមាសប្រាក់ហើយ សុទ្ទៈ... ក្សត្រ... ព្រាហ្មណ៍... ត្រូវភ្ញាក់មុន ផ្ទំក្រោយ ត្រូវរង់ចាំស្ដាប់ ទទួលបម្រើ ប្រព្រឹត្តឲ្យត្រូវចិត្ត និងត្រូវនិយាយពាក្យពីរោះចំពោះវេស្សៈយ៉ាងនោះឬ មហារាជ ? ព្រះរាជា

តបថា យ៉ាងនោះហើយ លោកម្ចាស់កច្ចាយនៈ ។ ព្រះថេរៈសួរបន្ត ទៀតថា បពិត្រមហារាជ ប្រសិនបើសេចក្ដីត្រូវការរបស់សុទ្ទៈ វេស្សៈ... ក្សត្រ... ព្រាហ្មណ៍... នឹងត្រូវសម្រេចដោយទ្រព្យ ស្រូវ ឬមាសប្រាក់ ហើយ វេស្សៈ... ក្សត្រ... ព្រាហ្មណ៍... ត្រូវភ្ញាក់មុន ផ្ទុំក្រោយ ត្រូវរង់ ចាំស្ដាប់ ទទួលបម្រើ ប្រព្រឹត្តឲ្យត្រូវចិត្ត និងត្រូវនិយាយពាក្យពីរោះ ចំពោះសុទ្ទៈយ៉ាងនេះឬ មហារាជ ? ព្រះរាជាតបថា បពិត្រលោក ម្ចាស់កច្ចាយនៈ យ៉ាងនោះហើយ ។

ព្រះថេរៈសួរបន្តទៀតថា បពិត្រមហារាជ ប្រសិនបើសេចក្ដីត្រូវ ការរបស់ព្រាហ្មណ៍ វេស្សៈ... សុទ្ទៈ... ក្សត្រ... នឹងត្រូវសម្រេចដោយ ទ្រព្យ ស្រូវ ឬមាសប្រាក់ហើយ វេស្សៈ... សុទ្ទៈ... ក្សត្រ... ត្រូវភ្ញាក់ មុន ផ្ទុំក្រោយ ត្រូវរង់ចាំស្ដាប់ ទទួលបម្រើ ប្រព្រឹត្តឲ្យត្រូវចិត្ត និងត្រូវ និយាយពាក្យពីរោះចំពោះវេស្សៈយ៉ាងនោះឬ មហារាជ ? ព្រះរាជាតប ថា យ៉ាងនោះហើយ លោកម្ចាស់កច្ចាយនៈ ។

ព្រះថេរៈទើបសួរទៀតថា បពិត្រមហារាជ កាលបើយ៉ាងនោះ បុគ្គលទាំង ៤ ពួកនេះ រមែងជាអ្នកស្មើគ្នាមិនមែនឬ តើមហារាជទ្រង់ មានព្រះទ័យយល់យ៉ាងណា ក្នុងបុគ្គលទាំង ៤ ពួកនោះ ? ព្រះរាជាតប ថា បពិត្រលោកម្ចាស់កច្ចាយនៈ កាលបើយ៉ាងនោះ បុគ្គលទាំង ៤ ពួក នេះ ជាអ្នកស្មើគ្នាទាំងអស់ ខ្ញុំព្រះករុណាមិនឃើញការប្លែកផ្សេងគ្នា

យ៉ាងណានីមួយឡើយ ។ ព្រះថេរៈសួរបន្តបន្ថែមទៀតថា បពិត្រមហារាជ សូមទ្រង់ជ្រាបនូវសេចក្ដីនេះ ដោយហេតុផលដូចតទៅនេះទៀត ប្រសិនបើក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ សម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងប្រពន្ធកូនអ្នកដទៃ និយាយកុហក និយាយញុះញង់ និយាយពាក្យរោយរាយឥតប្រយោជន៍ ចិត្តរំពៃចង់បានទ្រព្យរបស់គេ មានចិត្តគិតព្យាបាទ មានការយល់ខុស ពេលបុគ្គលទាំងនោះស្លាប់ទៅហើយ នឹងទៅកើតក្នុងអបាយភូមិ ទុគ្គតិ វិនិបាត នរក ដូច្នេះឬ មហាបពិត្រ ? ព្រះរាជាត្រាស់តបថា ខ្ញុំព្រះករុណាបានស្ដាប់ថេរវាចារបស់ព្រះអរហន្តទាំងឡាយថា បុគ្គលធ្វើអំពើអាក្រក់ទាំងនោះ ក្រោយអំពីស្លាប់ហើយ រមែងទៅកើតក្នុងអបាយភូមិដូចគ្នាទាំងអស់ ។

ព្រះថេរៈសួរទៀតថា បពិត្រមហារាជ ប្រសិនបើយ៉ាងនោះ បុគ្គលទាំង ៤ ពួកនេះ ជាអ្នកស្មើគ្នាឬទេ ឬមានសេចក្ដីប្លែកផ្សេងពីគ្នាយ៉ាងណា ? ព្រះរាជាត្រាស់តបថា បុគ្គលទាំង ៤ ពួកនេះ ជាអ្នកស្មើគ្នា ព្រមទាំងមិនឃើញការប្លែកគ្នាត្រង់កន្លែងណានីមួយឡើយ ។ ព្រះថេរៈបានដោះស្រាយបញ្ហាជាច្រើនទៀត ពន្យល់ធ្វើឲ្យព្រះរាជាយល់តាមសេចក្ដីពិតហើយ ក៏កើតសេចក្ដីត្រេកអររីករាយចំពោះភាសិតទាំងនោះដែលព្រះមហាកច្ចាយនៈបានសម្ដែងហើយ ព្រះបាទមធុររាជអវន្តីបុត្រទ្រង់ត្រាស់សរសើរព្រះថេរៈថា បពិត្រលោកម្ចាស់ ថេរវាចារបស់លោក

ម្ចាស់ជាក់ច្បាស់ពេកណាស់ លោកម្ចាស់បានសម្តែងធម៌ដល់ខ្ញុំករុណា ដោយអនេកបរិយាយ ដើម្បីឲ្យបានជាប្រយោជន៍ដល់ខ្ញុំព្រះករុណា ប្រៀបដូចបុគ្គលផ្ការបស់ដែលផ្កាប់ ប្រាប់ផ្លូវឲ្យដល់អ្នកវង្វេងផ្លូវ ដូច្នេះជាដើម ខ្ញុំព្រះករុណាសូមដល់លោកម្ចាស់កច្ចាយនៈផង ព្រះធម៌ និងព្រះសង្ឃ ជាជាសរណៈ ព្រះថេរៈត្រាស់តបថា សូមមហាបពិត្រកុំយកអាត្មាជាសរណៈឡើយ ចូរយកព្រះពុទ្ធជាសរណៈវិញចុះ ។

ព្រះបាទមធុរាជអវន្តីបុត្រ បានសួរព្រះថេរៈថា ឥឡូវនេះព្រះភគវាទ្រង់គង់ប្រថាប់នៅក្នុងទីណា ? ព្រះសាស្តាទ្រង់បរិនិព្វានទៅហើយ ។ ព្រះរាជាទ្រង់សម្តែងសេចក្តីជ្រះថ្លាក្នុងចិត្តថា ប្រសិនបើខ្ញុំករុណាបានជ្រាបដំណឹងថា ព្រះមានព្រះភាគទ្រង់គង់ប្រថាប់នៅក្នុងទីណា ចម្ងាយ ១០ យោជន៍ ២០-៣០ ឬ ១០០ យោជន៍ក៏ដោយ ខ្ញុំព្រះករុណានឹងចូលទៅគាល់ឲ្យបាន ប៉ុន្តែព្រះសម្ពុទ្ធស្តេចរំលត់ខន្ធបរិនិព្វានទៅហើយ ហេតុដូច្នេះ ខ្ញុំព្រះករុណាសូមដល់ព្រះពុទ្ធអង្គនោះផង ព្រះធម៌ និងព្រះសង្ឃជាជាសរណៈ ជាទីពឹងទីរឭក សូមលោកម្ចាស់កច្ចាយនៈ ចាំទុកខ្ញុំព្រះករុណាជាឧបាសក អ្នកដល់នូវព្រះរតនត្រៃស្មើដោយជីវិតផងចុះ ។

ដោយសរុបហេតុផលបានថា មនុស្សយើងទាំងអស់គ្នាមានភាពស្មើគ្នាគ្រប់វណ្ណៈ ដែលថាមានការប្លែកផ្សេងគ្នានោះ ក៏ដោយសារអំពើល្អ និងអាក្រក់ប៉ុណ្ណោះ ។ មានធម្មកថាដែលព្រះមហាកច្ចាយនត្ថេរ

បានឲ្យឱវាទដល់ភិក្ខុទាំងឡាយ ដែលមានប្រាកដក្នុងគម្ពីរ ខុទ្ទកនិកាយ ថេរគាថា ដោយសេចក្តីថា ៖

គ្រាមួយ ព្រះមហាកច្ចាយនត្ថេរ បានឲ្យឱវាទដល់ភិក្ខុច្រើនរូប ដោយសារភិក្ខុទាំងនោះ នាំគ្នាលះបង់ក្នុងការធ្វើសមណៈធម៌ បែរមកត្រេកអរក្នុងការងារ ជាប់ក្នុងរសអាហារ ជាអ្នកពេញចិត្តនឹងពួកគណៈ រស់នៅច្រើនទៅដោយសេចក្តីប្រាថ្នា ទើបព្រះថេរៈឲ្យឱវាទថា បព្វជិតមិនគប្បីធ្វើនូវកម្មច្រើនទេ គប្បីលះបង់ជន ( បាបមិត្ត ) មិនគប្បីខ្វល់ខ្វាយ ( ដើម្បីលាភទេ ) ព្រោះបព្វជិតអ្នកខ្វល់ខ្វាយ ជាប់ចិត្តក្នុងរសរមែងលះបង់ប្រយោជន៍ ដែលនាំមកនូវសេចក្តីសុខ ។ ការថ្វាយបង្គំ និងការបូជាក្នុងត្រកូលទាំងឡាយ ពួកព្រះអរិយៈដឹងច្បាស់ នូវការថ្វាយបង្គំ និងការបូជានោះ ថាដូចជាភក់ ទាំងដឹងថាជាសរដ៏ឆ្មារ គេកម្រដកបាន ជាគ្រឿងសក្ការៈ ដែលបុរសអាក្រក់ លះបង់បានដោយកម្រ ។ បុគ្គលមិនគប្បីសេពនូវអំពើអាក្រក់ដោយខ្លួនឯង ព្រោះបំពេញ ( ទុក្ខ ) ដល់សត្វដទៃ ( ទាំងមិនគប្បីញុំាងបុគ្គលដទៃឲ្យសេពនូវអំពើ អាក្រក់នោះ ) ព្រោះថាសត្វទាំងឡាយ មានកម្មជាផៅពង្ស ។ បុគ្គលជាចោរព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលជាអ្នកប្រាជ្ញ ព្រោះពាក្យអ្នកដទៃក៏ទេ បុគ្គលដឹងខ្លួនឯង យ៉ាងណា សូម្បីពួកទេវតាក៏ដឹងបុគ្គលនោះ ដូច្នោះដែរ ។ ពួកជនផ្សេងផ្តាស រមែងមិនដឹងច្បាស់ថា យើងទាំងឡាយនឹង

លំបាក ក្នុងលោកនេះ តែពួកជនណា ដឹងច្បាស់ក្នុងជំណើរនោះ ការជម្លោះ តែងស្ងប់រម្ងាប់ទៅ អំពីសម្នាក់ពួកជននោះ ។ បុគ្គលប្រកបដោយបញ្ញា បើទុកជាអស់សម្បត្តិរលីងធេង ក៏ឈ្មោះថារស់នៅ ឯបុគ្គលមានសម្បត្តិ ឈ្មោះថា មិនរស់នៅ ព្រោះការមិនបានទូវបញ្ញា ។ បុគ្គលរមែងស្តាប់នូវសំឡេងទាំងអស់បាន ដោយសារត្រចៀក បុគ្គលមានចក្ខុរមែងឃើញរូបគ្រប់យ៉ាង ចំណែកអ្នកប្រាជ្ញមិនគួរលះចោល ឬប្រកាន់នូវអារម្មណ៍ទាំងពួងដែលខ្លួនឃើញហើយ ឮហើយឡើយ ។ បុគ្គលអ្នកមានភ្នែក គប្បីធ្វើដូចជាខ្វាក់ បុគ្គលអ្នកមានត្រចៀក គប្បីធ្វើដូចជាថ្លង់ បុគ្គលអ្នកមានបញ្ញា គប្បីធ្វើដូចជាគ បុគ្គលអ្នកមានកម្លាំង គប្បីធ្វើដូចជាអ្នកខ្សោយកម្លាំង តែកាលបើហេតុ ( មិនគួរធ្វើ ) កើតឡើងហើយ ត្រូវដេកដូចជាស្លាប់ ។

ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ លោកមានភាពច្លាតក្នុងការចែកសេចក្តីសង្ខេបឲ្យពិស្តារបាន លោករំលត់ខន្ធបរិនិព្វាន ក្រោយពីព្រះមានព្រះភាគ ស្តេចរលត់ខន្ធបរិនិព្វានហើយ ដូចមានការសម្តែងទុកក្នុងមធុរសូត្រហើយ ប៉ុន្តែថាស្ថានទីដែលព្រះមហាកច្ចាយនត្ថេរបរិនិព្វាននោះ មិនបានឃើញមានការពោលទុកក្នុងទីកន្លែងណាទីមួយឡើយ ។

**( ជីវប្រវត្តិរបស់ព្រះមហាកច្ចាយនត្ថេរ ចប់ )**

# ជីវប្រវត្តិរបស់ព្រះមហាកប្បិនត្ថេរ

## “ ដែលជាឯតទគ្គៈផ្នែកខាងឱ្យឱវាទដល់ពួកភិក្ខុ ”

ជីវប្រវត្តិរបស់ព្រះកប្បិនត្ថេរនេះ ព្រះមានព្រះភាគទ្រង់សម្តែង កាលដែលព្រះអង្គគង់ប្រថាប់នៅវត្តជេតពន នាក្រុងសាវត្ថី ដែលមានមក នៅក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃបណ្ឌិតវគ្គ ក្នុងរឿងព្រះមហាកប្បិន មាន ក្នុងអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយសេចក្តីបាលីគម្ពីរ ខុទ្ទកនិកាយ ថេរគាថា និងមានក្នុងអដ្ឋកថាមនោរថបូរណី ដែលអធិប្បាយសេចក្តី បាលីគម្ពីរខុទ្ទកនិកាយ ឯកនិបាត មានសេចក្តីថា ៖

ការកសាងបុណ្យបារមីក្នុងអតីតជាតិ ដែលកន្លងមកប្រមាណរាប់ តាំងអំពីបច្ចុប្បន្នត្រឡប់ថយក្រោយទៅបានមួយសែនកប្ប ក្នុងពុទ្ធកាល នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ កប្បិនកុលបុត្រនោះ បានកើតនៅក្នុងនគរ-ហង្សវតី ថ្ងៃមួយ កប្បិនកុលបុត្រ បានទៅស្តាប់ព្រះធម៌ទេសនានៅឯវត្ត បានឃើញព្រះបទុមុត្តរៈទ្រង់តែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងប្រសើរ ជាងភិក្ខុសាវកទាំងឡាយ ផ្នែកខាងឲ្យឱវាទដល់ភិក្ខុ ក៏នឹកចង់បាននូវ តំណែងដូចភិក្ខុរូបនោះដែរ ទើបធ្វើអធិការកុសល គឺរៀបចំការប្រគេន ចង្ហាន់ដល់ភិក្ខុសង្ឃទាំងឡាយ មានព្រះបទុមុត្តរសម្ពុទ្ធជាប្រធានដរាប អស់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៧ ក៏បានប្រាថ្នាតំណែងនោះចំពោះព្រះភក្ត្រ

នៃព្រះបទុមុត្តរៈអគ្គនោះ ។

ចាប់ផ្ដើមតាំងពីពេលនោះមក លោកព្យាយាមបំពេញបុណ្យកុ-សលរហូតអស់ជីវិត កាលកប្បិនស្លាប់អំពីជាតិនេះទៅ ដោយអំណាចបុណ្យកុសលដែលលោកបានធ្វើហើយ ធ្វើឲ្យកប្បិនមានការត្រាច់រង្គាត់ទៅមនុស្សទេវតាអស់កាលដ៏យូរអង្វែង ប៉ុន្តែការប្រព្រឹត្តិទៅនៃជីវិតរបស់លោក សូម្បីយូរយ៉ាងហ្នឹងក៏ដោយ កប្បិនមិនធ្លាប់ទៅកើតក្នុងទុគ្គតិ គឺស្ថានទីដែលលំបាកឡើយ នេះកើតឡើងដោយផលនៃសេចក្ដីល្អ ដែលលោកធ្វើទុកនោះឯង ត្រង់នេះសមនឹងពុទ្ធតម្រាស់ថា ធ្វើល្អបានល្អ ។

ព្រះមហាកប្បិនត្ថេរ កាលដែលត្រាច់រង្គាត់ក្នុងសង្សារវដ្ត កើតស្លាប់ៗ មានជាតិមួយ លោកបានកើតជាជាងតម្បាញ ដែលស្ថិតនៅក្បែរក្រុងពារាណសី ។ ក្នុងយុគសម័យនោះ មានព្រះបច្ចេកពុទ្ធកើតឡើងក្នុងលោកប្រមាណមួយពាន់រូប អាស្រ័យនៅក្នុងព្រៃហិមពាន្តអស់ ៨ ខែ ហើយនាំគ្នានិមន្តមករកទីអាស្រ័យនៅក្បែរផ្ទះ របស់អ្នកស្រុកអស់ ៤ ខែ ក្នុងរដូវភ្លៀង ដូច្នេះឯងជានិច្ច ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធទាំងនោះ ហោះមកចុះក្បែរក្រុងពារាណសី ហើយបញ្ជូនព្រះបច្ចេកពុទ្ធប្រមាណ ៨ រូប ទៅកាន់សម្នាក់របស់ព្រះបាទពារាណសី ដើម្បីទូលសូមឲ្យព្រះរាជាទ្រង់ជួយចាត់ចែង ក្នុងការកសាងសេនាសនៈនោះ ។ ថ្ងៃដែលព្រះបច្ចេកពុទ្ធ ៨ រូប និមន្តចូលទៅរកព្រះ

បាទពារាណសីនោះ ជាថ្ងៃដែលត្រៀមក្នុងការប្រេតព្រះនង្គ័ល ដែលនឹងប្រព្រឹត្តទៅក្នុងថ្ងៃស្អែក ។ ព្រះបាទពារាណសី ទ្រង់ជ្រាបដំណឹងថា ព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ទើបស្ដេចចេញទៅទទួល និងត្រាស់សួរថា លោកម្ចាស់គ្រប់អង្គនិមន្តមកមានការអ្វី ? ព្រះបច្ចេកពុទ្ធទាំងនោះពោលថា មហាបពិត្រ អាត្មាមកនេះ ដើម្បីទូលសូមឲ្យមហាបពិត្រជួយចាត់ចែងទីសេនាសនៈសម្រាប់ស្នាក់អាស្រ័យ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយប្រមាណមួយពាន់រូប ។

ព្រះបាទពារាណសី កាលបើទ្រង់ជ្រាបនូវរឿងនោះហើយ ទើបត្រាស់ថា លោកម្ចាស់ទាំងឡាយ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនមានឱកាសនឹងទៅជួយធ្វើធុរៈឲ្យដល់លោកម្ចាស់ទាំងឡាយបានទេ ព្រោះថ្ងៃស្អែកនេះនឹងមានវប្បមង្គល គឺការប្រេតព្រះនង្គ័ល និងជាកិច្ចធុរៈដែលខ្ញុំព្រះអង្គត្រូវធ្វើបុណ្យប្រចាំឆ្នាំ ប៉ុន្តែ ៣ ថ្ងៃទៀត ទើបហើយធុរៈ កាលបើព្រះរាជាត្រាស់យ៉ាងនេះហើយ ក៏មិនបាននិមន្តព្រះបច្ចេកពុទ្ធទាំងឡាយទុក ។ ព្រះបច្ចេកពុទ្ធទាំងនោះ ទើបនាំគ្នានិមន្តចេញចាកអំពីទីនោះទៅ ដើម្បីទៅកាន់ស្រុកដទៃ ជិតគ្នានឹងក្រុងពារាណសីដែរ ។

គ្រានោះឯង កិរិយារបស់ជាងតម្បាញ ដែលត្រូវមានធុរៈទៅកាន់ក្រុងពារាណសី បានជួបនឹងព្រះបច្ចេកពុទ្ធទាំងនោះ ទើបលើកដៃសំពះ ហើយសាកសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំង

ឡាយនិមន្តមកស្រុកនេះ មានបំណងអ្វីឬ ? ព្រះបច្ចេកពុទ្ធទាំងនោះតបថា ម្នាលឧបាសិកា ពួកអាត្មានិមន្តមកទីនេះ ដើម្បីរកទីស្នាក់អាស្រ័យនៅក្បែរស្រុក ក្នុងរដូវភ្លៀងដែលមានរយៈពេល ៤ ខែ ព្រោះការនៅក្នុងព្រៃ ក្នុងរដូវនេះមានសេចក្តីលំបាកច្រើន ទើបនាំគ្នានិមន្តចេញអំពីព្រៃមកស្វែងរកទីស្នាក់អាស្រ័យ ។ ភរិយារបស់ជាងតម្បាញ ជ្រាបបំណងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយហើយ កើតសេចក្តីជ្រះថ្លា ក៏បាននិមន្តថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ ថ្ងៃស្អែកនេះ សូមលោកម្ចាស់និមន្តមកទទួលភិក្ខារបស់ខ្ញុំព្រះករុណា ។

ព្រះបច្ចេកពុទ្ធប្រាប់ថា ពួកអាត្មាមានច្រើនរូបណាស់ ភរិយាជាងតម្បាញសួរថា លោកម្ចាស់ទាំងអស់មានប៉ុន្មានរូប ? ពួកអាត្មាមានមួយពាន់រូប ។ ភរិយាជាងតម្បាញស្តាប់ហើយ ក៏សប្បាយចិត្ត ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ ចំនួនលោកម្ចាស់ទាំងឡាយស្មើនឹងចំនួនផ្ទះ ដែលនៅក្នុងស្រុកនេះគ្រប់គ្រាន់ចំនួនមួយពាន់រូបល្មម ហេតុនេះសូម លោកម្ចាស់ទាំងឡាយនិមន្តទទួលនូវភិក្ខារបស់ខ្ញុំក្នុងថ្ងៃស្អែកនេះ សូម្បីទីស្នាក់អាស្រ័យរបស់លោកម្ចាស់ទាំងឡាយ ពួកខ្ញុំនឹងរៀបចំធ្វើប្រគេនឲ្យគ្រប់រូប ។ ព្រះបច្ចេកពុទ្ធទាំងនោះព្រមទទួលការនិមន្តដោយអាការៈស្ងៀម ។ ភរិយារបស់ជាងតម្បាញ ក្រោយពីបាននិមន្តព្រះបច្ចេកពុទ្ធហើយ ទើបប្រញាប់ប្រញាល់ចូលទៅកាន់ស្រុក ដើរ

ប្រកូកប្រកាស អំពាវនាវ ឲ្យអ្នកស្រុកទាំងនោះដឹងថា យើងបានជួបព្រះបច្ចេកពុទ្ធប្រមាណមួយពាន់រូប ហើយយើងបាននិមន្តលោកទុក សូមអ្នកទាំងឡាយជួយគ្នារៀបចំអាសនៈ រៀបចំចង្ហាន់បិណ្ឌបាតជាដើម ដើម្បីប្រគេនលោកម្ចាស់ក្នុងថ្ងៃស្អែកនេះ ហើយនាងឲ្យស្វាមីជួយគ្នាសង់បារាំឡើងក្នុងទីពាក់កណ្តាលភូមិ ទាំងឲ្យគេត្រៀមអាសនៈរៀបរយ រង់ចាំទទួលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ។

ថ្ងៃស្អែកឡើង ព្រះបច្ចេកពុទ្ធទាំងអស់ និមន្តមកដល់រោងបារាំនោះ ពួកអ្នកស្រុកនិមន្តលោកឲ្យគង់លើអាសនៈដែលរៀបចំទុក ហើយនាំយកចង្ហាន់បិណ្ឌបាតមកប្រគេនលោក ។ កាលបើរួចស្រេចសព្វកិច្ចការក្នុងការឧបត្ថម្ភនោះហើយ ភរិយារបស់ជាងតម្បាញ នាំពួកស្ត្រីទាំងឡាយក្នុងស្រុកនោះ ចូលទៅរកព្រះបច្ចេកពុទ្ធ ហើយថ្វាយបង្គំអារាធនាព្រះបច្ចេកពុទ្ធទាំងនោះ ដើម្បីឲ្យចាំវស្សា នៅក្បែរស្រុករបស់ខ្លួន ។ លំដាប់តទៅ ភរិយារបស់ជាងតម្បាញ បានសូមសំណូមពរឲ្យស្វាមីគ្រប់រូបជួយចាត់ចែងទីសេនាសនៈ ប្រគេនចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ។

ពួកអ្នកស្រុក បានព្រមព្រៀងគ្នា ចាត់ចែងទីសេនាសនៈប្រគេនគ្រប់ៗ ព្រះអង្គ ថែមទាំងបានទំនុកបម្រុង និងប្រព្រឹត្តប្រតិបត្តិយ៉ាងល្អរហូតអស់ត្រៃមាស ។ លុះដល់ពេលចេញវស្សាហើយ ឧបាសិកាដែលជាភរិយារបស់ជាងតម្បាញ បានដឹកនាំឲ្យមិត្តសម្លាញ់ ថ្វាយសំពត់

សម្រាប់ធ្វើចីវរដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ មិត្តសម្លាញ់ទាំងនោះ បាន ថ្វាយសំពត់ដែលមានតម្លៃមួយផ្ទាំង មួយពាន់កហាបណៈ ប្រគេនដល់ ព្រះបច្ចេកពុទ្ធគ្រប់ៗ រូប ដោយសទ្ធាជ្រះថ្លា ។ ចំណែកព្រះបច្ចេកពុទ្ធ ទាំងឡាយ អនុមោទនាគាថាហើយ ក៏លាពួកអ្នកស្រុកទាំងនោះទៅ វិញ ។ ចំណែកអ្នកស្រុកទាំងនោះ កាលបើស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតនៅក្នុងស្ថានតាវត្តិង្ស មានឈ្មោះថា គណទេវបុត្រ សោយ ទិព្វសម្បត្តិរហូតអស់កាលយូរអង្វែង ។

មកដល់កាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ ស្តេចឧប្បត្តិឡើងក្នុង លោក គណទេវបុត្រទាំងនោះ ចុតិមកកើតនៅក្នុងត្រកូលកុដុម្ពិកនាក្រុង ពារាណសី ឯជាងតម្បាញបានមកកើតជាបុត្ររបស់កុដុម្ពិក ចំណែក ឯភរិយារបស់ជាងតម្បាញ បានមកកើតជាធីតារបស់កុដុម្ពិក ត្រកូល មួយទៀត។ កាលបើជនទាំងនោះធំពេញវ័យហើយ ត្រកូលទាំងពីរនោះ ក៏បានរៀបចំឲ្យបានគ្នាជាស្វាមីភរិយាទៅ ។ ថ្ងៃមួយ មានអ្នកមកប្រកូក ប្រកាសឲ្យទៅស្តាប់ព្រះធម៌ទេសនានៅឯវត្ត ពួកកុដុម្ពិកទាំងនោះ បានឮ ពាក្យអំពាវនាវថា ព្រះកស្សបសម្ពុទ្ធទ្រង់សម្តែងធម៌ទេសនា ទើបនាំគ្នា ទៅវត្តព្រមជាមួយនឹងភរិយា ដោយតាំងចិត្តនឹងទៅស្តាប់ធម៌ទេសនា ។

ពេលដែលពួកកុដុម្ពិកទាំងនេះ ចូរទៅដល់ពាក់កណ្តាលវត្តភ្លៀង ក៏បង្អុរចុះមកល្មម ។ ពួកអ្នកណាមកដល់វត្តមុនហើយ អ្នកដែលមាន

ភិក្ខុសាមណេរជាញាតិមិត្ត ក៏នាំគ្នាចូលទៅរកដើម្បីជ្រកភ្លៀង កុំឲ្យទទឹក នៅក្នុងសម្នាក់ភិក្ខុសាមណេរនោះឯង ។ ចំណែកពួកកុដុម្ពិកទាំងនោះ បាន ឈរនៅហាលភ្លៀង មិនដឹងចូលទៅជ្រកនៅក្នុងទីណា ព្រោះមិនស្គាល់ ភិក្ខុសាមណេរនៅក្នុងវត្តនេះឡើយ ។ ទើបនាំគ្នាគិតថា ពួកយើងនឹង កសាងទីសេនាសនៈប្រគេនចំពោះភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធកស្សប ជាប្រធាន ខ្ញុំនឹងឯងជាប្រធានបានបរិច្ចាគទ្រព្យសម្បត្តិមួយពាន់កហាបណៈ មុនគេ កុដុម្ពិកជាបន្ទាប់បានបរិច្ចាគម្នាក់ៗ ប្រាំរយកហាបណៈ ពួកភរិយា បានបរិច្ចាគម្នាក់ៗ ពីររយហាសិបកហាបណៈ ទ្រព្យសម្បត្តិទាំងអស់ ត្រូវប្រមូលមកកសាងបរិវេណទីសម្រាកធំ ដែលមានផ្ទះកំពូលមួយពាន់ ខ្នងជាបរិវារ ដើម្បីថ្វាយដល់ព្រះកស្សបសម្មាសម្ពុទ្ធជាម្ចាស់ ។

ប៉ុន្តែកាលបើធ្វើការកសាងទៅ ទ្រព្យមិនគ្រប់ចំណាយ ព្រោះ ការកសាងបរិវេណទីសម្រាកធំពេក ទើបសម្រេចគ្នាជួយបរិច្ចាគម្នាក់ៗ ពាក់កណ្តាលនៃចំនួនដែលបរិច្ចាគក្នុងគ្រាដំបូង ទ្រព្យក៏គ្រប់គ្រាន់ក្នុងការ ចំណាយការកសាងទីសេនាសនៈនោះ ។ កាលបើកសាងសម្រេចរៀប រយ ពួកកុដុម្ពិកទាំងនោះ ទើបនាំគ្នាថ្វាយមហាទានដល់ភិក្ខុសង្ឃទាំង ឡាយ មានព្រះកស្សបជាប្រធាន ក្នុងការឆ្លងនវកម្មដែលសាងសង់ថ្មីៗ នោះទៅរហូតអស់ប្រាំពីរថ្ងៃ លុះដល់ថ្ងៃទីប្រាំពីរបានរៀបចំថ្វាយចីវរដល់ ភិក្ខុសង្ឃពីរម៉ឺនរូប ។

ចំណែកកិរិយារបស់កុដុម្ពិក ជាអ្នកមានបញ្ញា បានធ្វើវត្ថុដែលពិសេសជាងគេ ដោយគិតថា យើងនឹងបូជាព្រះកស្សបៈឲ្យក្រៃលែងជាងពួកជនទាំងនោះ ទើបកាន់យកផ្កានទោងបង្អោនចូលទៅប្រគេនចំពោះព្រះសម្មាសម្ពុទ្ធកស្សបៈ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យសម្បុរកាយរបស់ខ្ញុំមានពណ៌ដូចផ្កានទោងនេះគ្រប់ៗ ជាតិ ព្រះកស្សបសម្ពុទ្ធទ្រង់ធ្វើការអនុមោទនាថា ចូរឲ្យនាងបានសម្រេចដូចសេចក្តីប្រាថ្នា ។ កាលបើជនទាំងនោះស្លាប់អំពីជាតិនេះទៅហើយ បានទៅកើតក្នុងទេវលោក ។

មកដល់ពុទ្ធសម័យនៃព្រះសមណគោតមយើងនេះ ពួកជនទាំងនោះ ក៏ចុតិអំពីទេវលោកមកកើតជាមនុស្ស ។ កុដុម្ពិកក៏បានកើតនៅក្នុងរាជត្រកូលនគរកុក្កុដវតី ពេលចម្រើនវ័យធំឡើង បានជាព្រះរាជា ទ្រង់ព្រះនាមថា មហាកប្បិន និងពួកកុដុម្ពិកជាបរិវារ បានមកកើតនៅក្នុងត្រកូលអាមាត្យទាំងឡាយ ចំណែកកិរិយារបស់កុដុម្ពិក កើតនៅក្នុងត្រកូលក្សត្រ ក្នុងសាគលនគរ ដែនមទ្ទរដ្ឋ មានពណ៌សម្បុរកាយដូចជាផ្កានទោង ទើបឈ្មោះថា ព្រះនាងអនោជា ពាក្យថា អនោជា ប្រែថា ផ្កានទោង កាលព្រះនាងចម្រើនវ័យធំឡើង បានជាអគ្គមហេសីរបស់ព្រះរាជាមហាកប្បិន ។ ចំណែកស្រីក្រៅពីនោះ ទៅកើតក្នុងត្រកូលអាមាត្យទាំងឡាយ កាលចម្រើនវ័យហើយ បានជាកិរិយារបស់បុត្រនៃអាមាត្យទាំងនោះ ពួកជនទាំងអស់នោះ សូម្បីនឹងមិនបានជាព្រះរាជា

ប៉ុន្តែជាអ្នកសម្បូណ៌ទៅដោយទ្រព្យសម្បត្តិ ប្រើប្រាស់ប្រហាក់ប្រហែលនឹងព្រះរាជា ពេលណាព្រះរាជាទ្រង់គ្រឿងអលង្ការ គឺទ្រង់គ្រឿងរបស់ព្រះរាជា ហើយស្តេចឡើងកាន់រាជរថយានចេញទៅ ពេលនោះពួកជនទាំងនោះ ក៏ជិះសេះ ជិះដំរីទៅតាមព្រះរាជា ទាំងនេះដោយអានុភាពនៃបុណ្យកុសល ដែលខ្លួនធ្វើទុកក្នុងអតីតជាតិ ។

ព្រះបាទមហាកប្បិន ទ្រង់មានព្រះទីន័ងសេះប្រាំ មានឈ្មោះដូចនេះ ១ ពល: ២ ពលវាហន: ៣ បុប្ផ: ៤ បុប្ផវាហន: ៥ សុបត្ត: ។ សេះទាំង ៥ នេះ ព្រះរាជាទ្រង់គង់ប្រថាប់តែសេះសុបត្ត: ហើយសេះ ៤ ទៀត ទ្រង់ឲ្យហ្មសេះជិះទៅស៊ើបដំណឹង ។ រៀងរាល់ពេលព្រឹក ព្រះរាជាទ្រង់អនុញ្ញាតឲ្យពួកហ្មសេះ បរិភោគអាហារតាំងពីពេលព្រឹក ហើយត្រាស់ថា ពួកអ្នកចូរនាំគ្នាទៅស៊ើបដំណឹងឲ្យបានដឹងថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃកើតឡើងហើយឬនៅ ចូរប្រញាប់នាំដំណឹងទាំងនោះ មកប្រាប់ដល់យើងផង ។

ពួកហ្មសេះទាំង ៤ នាក់ បាននាំគ្នាចេញទៅស៊ើបដំណឹងតាមទ្វារក្រុងទាំង ៤ ទិស បំបែកគ្នាម្នាក់ៗមួយទិស ដោយធ្វើដំណើរទៅរហូតអស់រយៈផ្លូវ ២-៣ យោជន៍ ប៉ុន្តែមិនបានដំណឹងអ្វីត្រឡប់មកវិញឡើយ ។ ថ្ងៃមួយ ព្រះបាទមហាកប្បិន ទ្រង់គង់លើព្រះទីន័ង សេះឈ្មោះសុបត្ត: មានពួកអាមាត្យមួយពាន់នាក់ហែហម ទៅកាន់ព្រះរាជឧទ្យាន បានជួប

ពួកឈ្មួញរទេះ ៥០០ នាក់ បាននាំគ្នាយកគ្រឿងបណ្ណាការទៅថ្វាយព្រះរាជា ក៏ទ្រង់ត្រិះរិះថា ពួកជនទាំងនេះគង់មានសេចក្តីលំបាក ដោយការធ្វើដំណើរផ្លូវឆ្ងាយ យើងអាចនឹងបានស្តាប់ដំណឹងល្អ សូម្បីរឿងអ្វីមួយពីជនទាំងនេះ ទើបមានព្រះរាជតម្រាស់ ឲ្យពួកឈ្មួញទាំងនោះចូលមកគាល់ ហើយត្រាស់សួរថា ពួកអ្នកមកពីទីណា ? ពួកឈ្មួញរទេះឆ្លើយថា មហាបពិត្រ ព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គមកពីក្រុងសាវត្ថី ដែលមានចម្ងាយផ្លូវប្រមាណ ១២០ យោជន៍ ព្រះរាជាត្រាស់សួរទៀតថា ព្រះរាជាក្នុងក្រុងរបស់ពួកលោកសុខសប្បាយជាទេ ជាអ្នកតាំងនៅក្នុងសីលឬទេ ? ពួកឈ្មួញតបថា សុខសប្បាយជាទេ ទាំងព្រះរាជាក៏ទ្រង់តាំងនៅក្នុងសីលយ៉ាងល្អ ។

ព្រះរាជាសួរថា នែអ្នកទាំងឡាយ មានដំណឹងអ្វីកើតឡើងក្នុងក្រុងរបស់ពួកលោកខ្លះឬទេ ? ពួកឈ្មួញមុននឹងក្រាបបង្គំទូលតបចំពោះសេចក្តីនោះ បានសូមការអនុញ្ញាតពីព្រះរាជាថា បើពួកខ្ញុំមិនទាន់បានខ្ពុរមាត់ជាមុនទេ មិនអាចនឹងក្រាបបង្គំទូលដំណឹងក្នុងរឿងនេះបានទេ ព្រោះថារឿងនេះសំខាន់ណាស់ ។ ព្រះបាទមហាកប្បិន ទើបព្រះរាជទានទឹកក្នុងឃ្មោកមាសរបស់ព្រះអង្គ ឲ្យពួកឈ្មួញទាំងនោះ ។ ពួកឈ្មួញទាំងនោះ បាននាំគ្នាខ្ពុរមាត់រួចជាស្រេចហើយ ទើបថ្វាយបង្គំឆ្ពោះមុខទៅកាន់ទិសដែលព្រះសម្ពុទ្ធទ្រង់គង់ប្រថាប់នៅ ហើយក្រាបបង្គំទូលថា បពិត្រ

ព្រះសម្មតិទេព **ពុទ្ធរតនំ នាម ឧប្បន្នំ** ប្រែថា ព្រះពុទ្ធរតនៈកើតឡើងហើយក្នុងលោក នៅនាក្រុងសាវត្ថី ។ កាលព្រះបាទមហាកប្បិនទ្រង់សណ្ដាប់ថា ព្រះពុទ្ធឧប្បត្តិឡើងក្នុងលោកហើយ ក៏មានសេចក្ដីជ្រះថ្លាសោមនស្សរីករាយ ប្រកបដោយបីតិ បានផ្សព្វផ្សាយ ពេញសរីរៈរហូតទាល់តែបាត់បង់ស្មារតី លុះទ្រង់ភ្ញាក់ស្មារតីវិញ ហើយត្រាស់សួរថា ពួកលោកនិយាយអ្វីអម្បាញ់មិញនេះ ពួកឈ្មួញឆ្លើយថា ព្រះពុទ្ធរតនៈកើតឡើងក្នុងលោកហើយ ។

ព្រះបាទមហាកប្បិន ទ្រង់សណ្ដាប់ហើយ ក៏បាត់ស្មារតីជាពីរលើកបីលើក ពេលដែលទ្រង់មានស្មារតីឡើងវិញ ទើបបានព្រះរាជទានទ្រព្យមួយសែនកហាបណៈឲ្យជារង្វាន់ ទ្រង់ត្រាស់សួរតទៀតថា មានដំណឹងអ្វីល្អទៀតដែរឬទេ ? ពួកឈ្មួញក្រាបបង្គំទូលថា មាន **ធម្មរតនំ នាម ឧប្បន្នំ** ព្រះធម្មរតនៈកើតឡើងក្នុងលោកហើយ ព្រះរាជាទ្រង់សណ្ដាប់ហើយ មានអាការៈដូចគ្នានឹងទ្រង់សណ្ដាប់ថា ព្រះពុទ្ធកើតឡើងក្នុងលោក ហើយក៏បានព្រះរាជទានទ្រព្យមួយសែនកហាបណៈ ជារង្វាន់ទៀត ហើយត្រាស់សួរទៀតថា អ្នកទាំងឡាយ មានដំណឹងអ្វីល្អទៀតដែរឬទេ ? ពួកឈ្មួញក្រាបបង្គំទូលថា មាន **សង្ឃរតនំ នាម ឧប្បន្នំ** ព្រះសង្ឃរតនៈកើតឡើងក្នុងលោកហើយ ។ ព្រះរាជាទ្រង់ស្ដាប់ហើយ ទ្រង់មានអាការៈដូចពេលមុន ហើយបានព្រះរាជទានទ្រព្យ ជារង្វាន់ឲ្យដល់ពួកឈ្មួញមួយ

សែនកហាបណៈទៀត ទើបទ្រង់ទតមើលពួកអាមាត្យមួយពាន់នាក់នោះ ហើយត្រាស់សួរថា នែអាមាត្យទាំងឡាយ ពួកលោកធ្វើយ៉ាងណា ទាក់ទងនឹងដំណឹងដែលបានជ្រាបនេះ ។

ចំណែកពួកអាមាត្យ មិនដឹងធ្វើយ៉ាងណាឲ្យល្អក្នុងរឿងនេះ ទើបនាំគ្នាក្រាបបង្គំទូលសួរព្រះរាជាថា បពិត្រព្រះសម្មតិទេព តើព្រះអង្គទ្រង់ធ្វើយ៉ាងណាក្នុងរឿងដំណឹងនេះ ។ ព្រះរាជាត្រាស់ថា នែពួកអាមាត្យទាំងឡាយ ខ្ញុំបានឮថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃកើតឡើងហើយក្នុងលោក ដូច្នេះ នឹងមិនត្រឡប់ទៅកាន់ព្រះរាជវាំងវិញទេ ខ្ញុំនឹងទៅគាល់ព្រះភគវា ដើម្បីបព្វជ្ជាក្នុងសម្នាក់របស់ព្រះអង្គ ។ ពួកអាមាត្យព្រមគ្នាក្រាបបង្គំទូលឡើងថា សូម្បីខ្ញុំព្រះអង្គក៏នឹងបានបព្វជ្ជាជាមួយនឹងព្រះអង្គដែរ ។ ព្រះរាជាត្រាស់ឲ្យសរសេរព្រះរាជសារ ក្នុងការព្រះរាជទានរង្វាន់ឲ្យដល់ពួកឈ្មួញ ហើយឲ្យរាជសារនោះដល់ពួកឈ្មួញដោយត្រាស់ថា ៖

នែអ្នកទាំងឡាយៗ ចូរនាំយករាជសារនេះទៅថ្វាយដល់ព្រះនាងអនោជាទេវីៗ នឹងព្រះរាជទានរង្វាន់ប្រាក់ ៣ សែនកហាបណៈដល់ពួកលោកមិនខាន ចូរពួកលោកក្រាបបង្គំទូលថា ព្រះរាជាទ្រង់លះបង់ភាពជាធំថ្វាយដល់ព្រះមេម្ចាស់ហើយ សូមព្រះមេម្ចាស់ទ្រង់សោយរាជសម្បត្តិតាមសប្បាយចុះ ប៉ុន្តែប្រសិនបើព្រះរាជទេវីមានព្រះរាជតម្រាស់ សួរថា ព្រះរាជាទ្រង់ស្តេចយាងទៅណា ចូរពួកលោកក្រាបបង្គំតបថា ព្រះរាជា

ត្រាស់ថា ទ្រង់តាំងព្រះទ័យទៅបព្វជ្ជាក្នុងសម្នាក់ព្រះសក្យមុនី ។ ចំណែក ពួកអាមាត្យក៏បានបញ្ជូនដំណឹងការចេញទៅបួសឲ្យកិរិយាវៀងៗខ្លួន បាន ដឹងដូចគ្នាដែរ ។

ពួកឈ្មួញទទួលព្រះរាជសាសន៍ហើយ ក៏នាំគ្នាចូលទៅគាល់ព្រះ នាងអនោជាទេវី ក្រោយពីបានក្រាបបង្គំទូលហើយ ទើបថ្វាយព្រះរាជ- សាសន៍ដែលចារឹករង្វាន់ ៣ សែនកហាបណៈ និងក្រាបបង្គំទូលថា សូម ព្រះមេម្ចាស់ព្រះរាជទានទ្រព្យ ៣ សែនកហាបណៈដល់ពួកខ្ញុំផង ។ ព្រះ នាងអនោជាទេវី កាលទ្រង់ទទួលព្រះរាជសាសន៍រួចហើយ ទើបមានព្រះ រាជតម្រាស់ត្រាស់សួរថា ពួកអ្នកធ្វើអ្វី បានជាព្រះមហាក្សត្រព្រះទាន ទ្រព្យដល់ពួកលោក ? ពួកឈ្មួញក្រាបបង្គំទូលថា បពិត្រព្រះមេម្ចាស់ ខ្ញុំព្រះអង្គទាំងឡាយបាននាំដំណឹង ដែលជាទីពេញចិត្តមកក្រាបទូលឲ្យ ដល់ព្រះរាជាជ្រាប ។ ព្រះនាងអនោជាទេវីត្រាស់សួរថា ពួកអ្នកនាំរឿងអ្វី អាចប្រាប់ខ្ញុំបានខ្លះដែរឬទេ ? ពួកឈ្មួញក្រាបបង្គំទូលថា បាន ព្រះមេ ម្ចាស់ ប៉ុន្តែខ្ញុំព្រះអង្គមិនអាចក្រាបបង្គំទូល ដោយមាត់មិនទាន់ខ្ពុរទេ ។ ទើបព្រះនាងអនោជាទេវី ព្រះរាជទានទឹកក្នុងឃ្លោក មាសឲ្យខ្ពុរមាត់ចេញ កាលបើពួកពាណិជបានខ្ពុរមាត់រួចហើយ ក៏ក្រាបបង្គំទូលដំណឹងព្រះ- រតនត្រៃ ថ្វាយដល់ព្រះនាងអនោជាទេវី ដូចដែលបានក្រាបបង្គំទូលដល់ ព្រះរាជាមុនដែរ ។

ព្រះនាងអនោជា ទ្រង់សណ្ដាប់ដំណឹងទាក់ទងនឹងព្រះរតនត្រៃហើយ ក៏ទ្រង់កើតសេចក្ដីត្រេកអររីករាយយ៉ាងខ្លាំង ក៏បានព្រះរាជទានទ្រព្យជារង្វាន់ ៩ សែនកហាបណៈ ។ រួមប្រាក់រង្វាន់ដែលពួកឈ្មួញបានទទួលព្រះរាជទានពីព្រះរាជា និងព្រះនាងអនោជាទាំងអស់ ១២ សែនកហាបណៈ ។ ព្រះនាងអនោជាទេវី មានព្រះរាជតម្រាស់ត្រាស់សួរពួកឈ្មួញតទៅទៀតថា ពេលនេះ ព្រះមហាក្សត្រទ្រង់គង់នៅក្នុងទីណា ? ពួកឈ្មួញក្រាបបង្គំទូលថា ព្រះមហាក្សត្រស្ដេចយាងចេញទៅបួសក្នុងសម្នាក់ព្រះសម្ពុទ្ធហើយ ។

ព្រះនាងអនោជាទេវី មានព្រះរាជសវនីយ៍អនុញ្ញាតឲ្យពួកឈ្មួញត្រឡប់ទៅវិញ កាលបើពួកឈ្មួញត្រឡប់ទៅហើយ ទើបមានព្រះរាជសវនីយ៍ត្រាស់ទៅរកស្រីទាំងឡាយ ដែលជាភរិយារបស់ពួកអាមាត្យតាមព្រះរាជាទៅ ហើយបាននិយាយជាមួយនឹងស្រីទាំងនោះថា អ្នកទាំងឡាយជ្រាបដំណឹងកន្លែង ដែលស្វាមីរបស់ពួកនាងនៅឬទេ ? ពួកភរិយារបស់ពួកអាមាត្យក្រាបបង្គំទូលថា បពិត្រព្រះមេម្ចាស់ ខ្ញុំមិនបានជ្រាបដំណឹងទេ ត្រឹមតែដឹងថា ព្រះមហាក្សត្រទៅកាន់ព្រះរាជឧទ្យានប៉ុណ្ណោះ ប៉ុន្តែស្ដេចយាងដំណើរបន្តទៅទៀតក្នុងស្ថានទីណា មិនបានដឹងទេ ។ ព្រះនាងអនោជាទេវី ត្រាស់សួរថា ខណៈនេះ ព្រះមហាក្សត្រ និងស្វាមីរបស់ពួកនាងទាំងឡាយ នាំគ្នាទៅរកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃដែល

កើតក្នុងលោកហើយ ថែមទាំងតាំងចិត្តបួសក្នុងសម្នាក់ព្រះពុទ្ធផង តើពួកនាងគិតយ៉ាងណាក្នុងរឿងនេះ ។

ពួកកិរិយាទាំងនោះ នៅមិនទាន់ក្រាបបង្គំទូលតបទេ ប៉ុន្តែក្រាបបង្គំទូលសួរថា ព្រះមេម្ចាស់ ទ្រង់សម្រេចព្រះទ័យក្នុងរឿងនេះ យ៉ាងណា ? ព្រះនាងអនោជាទេវីត្រាស់ថា នែនាងទាំងឡាយ យើងបានស្តាប់ដំណឹងព្រះរតនត្រៃហើយ បានបូជាទ្រព្យ ៩ សែនកហាបណៈ រាជសម្បត្តិនេះជាកំហាករបស់ព្រះរាជាប្រទានឲ្យយើង យើងមិនលុតជង្គង់លិទ្ធកំហាកដែលព្រះរាជាទ្រង់ស្តោះចោលទេ យើងសម្រេចចិត្តហើយថានឹងទៅបព្វជ្ជាក្នុងសម្នាក់ព្រះពុទ្ធដែរ ពួកកិរិយារបស់ពួកអាមាត្យទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមេម្ចាស់ យើងខ្ញុំទាំងអស់គ្នា ក៏នឹងចេញទៅបព្វជ្ជាជាមួយព្រះមេដែរ ។ កាលបើព្រះនាងអនោជា និងពួកកិរិយារបស់អាមាត្យទាំងនោះ បានព្រមព្រៀងគ្នាជាឯកច្ឆ័នហើយ ទើបត្រាស់ឲ្យត្រៀមរាជរថ រួចហើយក៏នាំគ្នាឡើងជិះរាជរថចេញចាក ព្រះនគរទៅរកព្រះពុទ្ធ ។ ចំណែកព្រះមហាកប្បិន ស្តេចនាំពួកអាមាត្យមួយពាន់ធ្វើដំណើរទៅរហូតដល់ច្រាំងនៃស្ទឹង អវច្ឆា ( ឬ អបរច្ឆា ) ពេលនោះទឹកកំពុងតែឡើងប្រៀបច្រាំង មិនដឹងធ្វើយ៉ាងណា អាចទៅកាន់ត្រើយនាយបាន ទើបទ្រង់ធ្វើការអធិដ្ឋានថា ៖

ប្រសិនបើព្រះសាស្តា ជាព្រះសម្មាសម្ពុទ្ធត្រាស់ដឹងក្នុងលោកពិត

ប្រាកដមែន សូមឲ្យសេះរត់លើផ្ទៃទឹក ដូចរត់លើផែនថ្ម ដោយអំណាចការអធិដ្ឋានរបស់ព្រះរាជា ដែលយកគុណព្រះពុទ្ធមកជាអារម្មណ៍ ក៏បានឆ្លងស្ទឹងផុតទៅព្រមទាំងបរិវាររបស់ខ្លួន សូម្បីជើងសេះក៏មិនទទឹកផង ។ ព្រះបាទមហាកប្បិន ស្ដេចយាងបន្តបន្ទាប់រហូតមកដល់ស្ទឹងទីពីរ ឈ្មោះថា នីលវាហនា ជាស្ទឹងដែលមានទទឹងទូលំទូលាយ និងមានជម្រៅប្រមាណកន្លះយោជន៍ ព្រះរាជាទ្រង់អធិដ្ឋានដូចមុន ក៏ស្ដេចឆ្លងស្ទឹងទៅបានតាមសប្បាយ ដោយអំណាចនឹករឭកដល់គុណព្រះធម៌ ។ ពេលស្ដេចយាងមកដល់ស្ទឹងទីបីឈ្មោះថា ចន្ទភាគា ដែលមានទទឹងទូលំ-ទូលាយ និងមានជម្រៅប្រមាណមួយយោជន៍ ព្រះរាជាក៏នាំពួកអាមាត្យឆ្លងស្ទឹងទៅបានដោយសុវត្ថិភាព ទាំងនេះដោយអំណាចការអធិដ្ឋានរបស់ព្រះរាជា ដែលនឹករឭកដល់គុណព្រះសង្ឃ ។

ក្នុងពេលជិតភ្លឺ ព្រះលោកនាថ ស្ដេចចេញចាកមហាករុណាសមាបត្តិហើយ ទ្រង់ប្រមើលមើលសត្វលោក ដែលជាពុទ្ធកិច្ចត្រូវធ្វើជាប្រចាំរៀលរាល់ថ្ងៃ ដើម្បីអនុគ្រោះដល់សត្វលោក គ្រានោះ ក៏ទ្រង់ឃើញឧបនិស្ស័យរបស់ព្រះមហាកប្បិន ជាមួយនឹងពួកអាមាត្យមួយពាន់នាក់កំពុងតែធ្វើដំណើរមកកាន់សម្នាក់របស់ព្រះអង្គ កាលបើព្រះសម្ពុទ្ធឆាន់ចង្ហាន់រួចហើយ ទើបទ្រង់ហោះទៅគង់ប្រថាប់ទៀបគល់ដើមនិគ្រោធមួយដើម ដែលតាំងនៅក្បែរច្រាំងនៃស្ទឹងចន្ទភាគានោះ ។

ព្រះភគវាទ្រង់បញ្ចេញរស្មី ៦ ពណ៌ ចេញអំពីព្រះវរកាយរបស់ព្រះអង្គ ដែលគង់ប្រថាប់នោះ ។ កាលបើព្រះមហាកប្បិន ព្រមទាំងពួកអាមាត្យ ស្តេចចូងស្ពឹងចន្ទភាគារួចហើយ បានក្រឡេកឃើញព្រះរស្មីទាំងនោះ ធ្វើឲ្យដើមនិគ្រោធដ៏ធំមានពណ៌ដូចមាស ទាំងស្លឹក ទាំងមែក ក៏កើតការឆ្ងល់ឡើងថា រស្មីនេះកើតមកពីអ្វី ? ព្រះបាទមហាកប្បិន ទ្រង់ត្រិះរិះថា ពន្លឺនេះ មិនមែនជាពន្លឺព្រះច័ន្ទ ឬព្រះអាទិត្យទេ ទាំងមិនមែនរស្មីរបស់ទេវតា ព្រហ្ម មារ នាគ គ្រុឌ ឬរបស់អ្នកណាមួយឡើយ ប៉ុន្តែដែលយើងមកនេះ ដោយការតាំងចិត្តមករកព្រះសមណគោតមប៉ុណ្ណោះ មុខជានឹងមានហេតុ ដែលព្រះសមណគោតម ទ្រង់ឃើញការប្រព្រឹត្តិទៅរបស់ពួកយើងជាពិតប្រាកដ ។

កាលបើព្រះរាជា ទ្រង់ត្រិះរិះដូច្នេះហើយ ទើបស្តេចចុះពីខ្នងសេះក្នុងពេលនោះ ទ្រង់ក៏បានឃើញរស្មីព្រះសម្ពុទ្ធ ទើបបានចូលទៅគាល់ព្រះមានព្រះភាគ ព្រមដោយពួកអាមាត្យមួយពាន់នាក់ ថ្វាយបង្គំព្រះអង្គហើយ គង់ប្រថាប់ក្នុងទីដ៏សមគួរ ។ ប៉ុន្តែព្រះបាទមហាកប្បិន ទ្រង់សម្តែងអាការៈត្រេកអររីករាយជ្រះថ្លាក្រៃលែងណាស់ ហើយស្តេចស្ទុះទៅចាប់ព្រះយុគលបាទទាំងគូនៃព្រះសម្ពុទ្ធ ទ្រង់ថ្វាយបង្គំរួចហើយ ទើបគង់ប្រថាប់ក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្តា ទ្រង់សម្តែងអនុបុព្វីកថា គឺព្រះពុទ្ធដីកា ដែលពោលទៅតាមលំដាប់ ចាប់ផ្តើមអំពីទាន សីល

ស្ថានសួគ៌ ទោសរបស់កាម និងអានិសង្សការចេញចាកកាម ទាំងអានិសង្សនៃការបព្វជ្ជា កាលបើចប់ព្រះធម៌ទេសនា ព្រះរាជា និងបរិវារទាំងអស់បានសម្រេចសោតាបត្តិផល ។

លំដាប់នោះ ជនទាំងនោះ មានព្រះមហាកប្បិនទ្រង់ជាប្រធាន នាំគ្នាក្រោកឡើង ក្រាបបង្គំទូលសូមបព្វជ្ជាចំពោះព្រះទសពល ព្រះអង្គទ្រង់ពិចារណាក្នុងការអនុញ្ញាតឲ្យបព្វជ្ជាថា កុលបុត្រទាំងនេះមានបាត្រចីវរដែលសម្រេចដោយបុញ្ញឫទ្ធិឬទេ ក៏ទ្រង់ជ្រាបថា កុលបុត្រទាំងនេះធ្លាប់បានថ្វាយចីវរមួយពាន់ផ្ទាំង ដល់ព្រះបច្ចេកពុទ្ធមួយពាន់រូបមកហើយ ថែមទាំងបានថ្វាយចីវរពីរម៉ឺនផ្ទាំងដល់ភិក្ខុសង្ឃ ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធទៀតផង ។ កាលដែលព្រះអង្គទ្រង់ពិចារណាឃើញយ៉ាងនេះហើយ ទើបត្រាស់ថា ៖

អ្នកចូរមកជាភិក្ខុចុះ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខដោយប្រពៃចុះ នេះជាវិធីនៃការបំបួសជាឯហិភិក្ខុ-ឧបសម្បទា ។ មួយរំពេចនោះ កុលបុត្រទាំងនោះ ក៏ក្លាយជាភិក្ខុទាំងអស់ ព្រមទាំងមានបរិក្ខារគ្រប់គ្រាន់ ដូចជាព្រះថេរៈដែលមានវស្សា ១០០ ហើយនាំគ្នាចូលមកថ្វាយបង្គំព្រះសាស្តា រួចហើយក៏គង់នៅក្នុងទីដ៏សមគួររៀងៗ ខ្លួន ។ ចំណែកព្រះនាងអនោជាទេវី ព្រមទាំងបរិវារមួយពាន់ ស្តេចយាងមកដល់ស្ទឹងអរវច្ឆា ( ឬ អបរច្ឆា ) ហើយ ព្រះ

នាងទ្រង់ត្រិះរិះថា ទឹកដ៏ជ្រៅ និងស្ទឹងដ៏ធំ ពាហនៈមិនអាចឆ្លងបានទេ តើព្រះមហាក្សត្រ ទ្រង់ធ្វើយ៉ាងណាទើបឆ្លងទៅបាន ប្រាកដជាទ្រង់ធ្វើសច្ចកិរិយាហើយ ទើបទ្រង់អាចឆ្លងទៅបាន ។ ការឧប្បត្តិឡើងក្នុងលោកនៃព្រះពុទ្ធ មិនមែនជាប្រយោជន៍ដល់កុលបុត្រ មួយពួកប៉ុណ្ណោះទេ ជាប្រយោជន៍ដល់ជនច្រើនក្នុងលោក កាលបើព្រះនាងទ្រង់ត្រិះរិះដូច្នេះហើយ ទើបទ្រង់ធ្វើសច្ចកិរិយាថា ៖

ប្រសិនបើ ព្រះសាស្តា ទ្រង់ជាព្រះសម្មាសម្ពុទ្ធពិតមែន សូមកុំឲ្យរថរបស់ខ្ញុំទាំងឡាយ លិចចូលទៅក្នុងស្ទឹងនេះឡើយ ។ កាលបើព្រះរាជទេវី ទ្រង់ពោលសច្ចកិរិយាដូច្នេះហើយ ទើបព្រះនាងរឭកដល់គុណព្រះរតនត្រៃជាទីពឹង ក៏បានឆ្លងផុតអំពីស្ទឹងនោះទៅ ។ ការឆ្លងស្ទឹងនីលវាហនា ស្ទឹងទីពីរ និងស្ទឹងទីបី ព្រះនាងក៏ទ្រង់ធ្វើសច្ចកិរិយា នាំបរិវារឆ្លងស្ទឹងទៅបានដោយសុវត្ថិភាព ដោយសាររឭករឭកដល់គុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

ព្រះបរមសាស្តា ទ្រង់ជ្រាបការយាងមកនៃព្រះនាងអនោជាទេវី ព្រមទាំងបរិវាររបស់ខ្លួនហើយ ទើបទ្រង់សម្តែងឫទ្ធិមិនឲ្យភិក្ខុទាំងឡាយដែលគង់ក្នុងទីនោះបានឃើញស្ត្រីទាំងនោះ ទាំងស្ត្រីទាំងនោះក៏មិនបានឲ្យឃើញភិក្ខុដែរ ។ ចំណែកព្រះនាងអនោជាទេវី កាលបើយាងទៅដោយលំដាប់ ក៏បានឃើញព្រះរស្មី ៦ ពណ៌ ផ្សាយចេញអំពីសរីរៈរបស់ព្រះ

អង្គ ព្រះនាងត្រិះរិះដូចជាព្រះមហាកប្បិនដែរ ហើយទើបនាំបរិវារចុះចាករាជរថ យាងចូលទៅគាល់ព្រះលោកនាថតាមរស្មីនោះ កាលដល់ទីគន់ប្រថាប់ ទើបក្រាបទូលសួរថា ៖

បពិត្រព្រះបរមសាស្តា ព្រះបាទមហាកប្បិន ព្រមដោយបរិវារប្រមាណមួយពាន់នាក់ ស្តេចយាងមករកព្រះអង្គ តើពេលនេះស្តេចនៅទីណា ? ព្រះភគវាត្រាស់ថា ព្រះនាងគង់ប្រថាប់សិនមក មុខជានឹងបានឃើញជនទាំងនោះមិនខានឡើយ ។ ព្រះនាងអនោជាទេវី ព្រមទាំងបរិវារក៏សប្បាយចិត្ត ទើបនាំគ្នាគង់ប្រថាប់ដោយគិតថា នឹងបានឃើញស្វាមីរបស់ខ្លួនរៀងៗខ្លួន ។ ព្រះសម្ពុទ្ធទ្រង់ទតឃើញស្ត្រីទាំងនោះ គង់ប្រថាប់រៀបរយល្អហើយ ទើបព្រះអង្គសម្តែងអនុបុព្វីកថាឲ្យបានស្តាប់ ពេលដែលចប់អនុបុព្វីកថា ព្រះនាងអនោជាទេវីព្រមទាំងបរិវារ បានសម្រេចសោតាបត្តិផលគ្រប់ៗ គ្នា ។

ចំណែកព្រះមហាកប្បិនត្ថេរ និងបរិវារ កាលបើបានស្តាប់អនុ-បុព្វីកថា ដែលព្រះអង្គទ្រង់សម្តែងឲ្យដល់ស្ត្រីទាំងនោះ បានស្តាប់ហើយក៏បានសម្រេចជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទា ។ ខណៈពេលនោះព្រះសក្យមុនី ទ្រង់រំសាយឫទ្ធិឲ្យស្ត្រីទាំងនោះបានឃើញភិក្ខុទាំងឡាយ ។ ម្យ៉ាងទៀត កាលដែលព្រះសាស្តាទ្រង់សម្តែងឫទ្ធិបិទបាំង មិនឲ្យពួកស្ត្រីទាំងនោះឃើញភិក្ខុដែលជាស្វាមីមានលក្ខណៈប្លែក ដោយការទ្រទ្រង់

សំពត់ពណ៌លឿង មានសីសៈត្រងោលដូច្នេះ ព្រោះបើពួកស្ត្រីទាំងនោះបានឃើញហើយ ចិត្តក៏មិនតាំងមាំ ឆន្ទរាគៈក៏កើតឡើង មិនអាចនឹងស្តាប់ធម៌បាន ពេលដែលបានសម្រេចធម៌ហើយ ទើបព្រះសាស្តាទ្រង់រំសាយឫទ្ធិ ឲ្យស្ត្រីទាំងនោះបានឃើញភិក្ខុដែលជាស្វាមី ក្នុងពេលដែលស្ត្រីទាំងនោះតាំងនៅក្នុងអចលសទ្ធា គឺសទ្ធាមិនញាប់ញ័រ ។ ព្រះនាងអនោជាទេវី និងបរិវារទាំងអស់បានឃើញព្រះថេរៈដែលជាស្វាមីហើយ ក៏នាំគ្នាថ្វាយបង្គំព្រះលោកនាយក ទូលសូមដើម្បីបព្វជ្ជា ។

ព្រះលោកនាថ ទ្រង់រំពឹងដល់ព្រះនាងឧប្បលវណ្ណាថេរីៗ ដឹងវារៈចិត្តនៃការត្រិះរិះរបស់ព្រះសម្ពុទ្ធថា ត្រូវឲ្យព្រះថេរីនិមន្តទៅកាន់ស្ថានទីនោះ ដោយចេតោបរិយញ្ញាណ គឺការដឹងចិត្តរបស់អ្នកដទៃ ទើបព្រះ-ថេរីហោះទៅកាន់ស្ថានទី ដែលព្រះអង្គគង់ប្រថាប់នៅនោះ ។ ព្រះភគវាទ្រង់ត្រាស់ប្រាប់ឧបាសិកាទាំងនោះថា ពួកនាងចូរទៅកាន់ក្រុងសាវត្ថី ចូរបព្វជ្ជានៅក្នុងសម្នាក់ព្រះថេរីចុះ ។ ព្រះនាងឧប្បលវណ្ណាថេរី បាននាំឧបាសិកាទាំងឡាយ មានព្រះនាងអនោជាទេវីជាដើម បានធ្វើដំណើរទៅដោយលំដាប់ ក្នុងរវាងផ្លូវពួកមហាជន បានបូជាដោយគ្រឿងសក្ការៈជាច្រើន កាលធ្វើដំណើរមកអស់រយៈផ្លូវ ១២០ យោជន៍ ក៏បានមកដល់សម្នាក់ភិក្ខុនីទាំងឡាយ ហើយក៏បានបព្វជ្ជាក្នុងសម្នាក់ព្រះថេរីទាំងនោះ មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្តីគ្រប់ៗ រូប ។

ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុមួយពាន់រូបផ្លោះទៅកាន់វត្តជេតពន មហាវិហារ តាមផ្លូវអាកាស ។ ព្រះមហាកប្បិនត្ថេរ ខណៈពេលដែលលោកគង់ក្នុងវត្តជេតពននោះ បានបន្លឺឧទានឡើងថា សុខណាស់ហ្ន៎ ! សុខណាស់ហ្ន៎ ! ជានិច្ច ទាំងថ្ងៃ ទាំងយប់ ។ កាលបើភិក្ខុទាំងឡាយបានឮព្រះមហាកប្បិនត្ថេរបន្លឺឧទានយ៉ាងនេះរឿយៗ ក៏មានសេចក្ដីសង្ស័យក្នុងពាក្យទាំងនោះ ទើបក្រាបបង្គំទូលព្រះជិនស្រីថា បពិត្រព្រះសាស្ដា ព្រះមហាកប្បិនត្ថេរតែងបន្លឺឧទានថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎ តើសម្ដៅដល់សេចក្ដីសុខក្នុងរាជសម្បត្តិរបស់លោកឬ ? ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ឲ្យភិក្ខុទៅហៅព្រះមហាកប្បិនត្ថេរចូលមកគាល់ ហើយទ្រង់ត្រាស់សួរថា ម្នាលកប្បិន បានឮថា អ្នកតែងតែបន្លឺឧទានថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎ ដូច្នេះពិតមែនឬ ? តើសម្ដៅដល់សេចក្ដីសុខក្នុងរាជសម្បត្តិរបស់អ្នកពិតមែនឬ ? ព្រះមហាកប្បិនត្ថេរក្រាបទូលថា បពិត្រព្រះលោកនាយក ព្រះអង្គតែងតែទ្រង់ជ្រាបហើយថា ដែលខ្ញុំព្រះអង្គបន្លឺឧទានសុខណាស់ហ្ន៎ សុខណាស់ហ្ន៎ នោះ មិនមែនសម្ដៅដល់សុខក្នុងកាមគុណ ឬសុខនៅក្នុងរាជសម្បត្តិ នោះទេ ។

ព្រះសក្យមុនីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនបានបន្លឺឧទាន សុខណាស់ហ្ន៎ សុខណាស់ហ្ន៎នោះ សម្ដៅដល់កាម-គុណ ឬក្នុងរាជសម្បត្តិទេ ប៉ុន្តែជាអ្នកមានបីតិក្នុងធម៌ ទើបបន្លឺឧទាន

យ៉ាងនេះ កាលបើព្រះអង្គទ្រង់ត្រាស់រ៉ាប់រងព្រះមហាកប្បិនដូច្នេះហើយ ទើបត្រាស់គាថាធម្មបទថា ៖

បុគ្គលដែលមានទូវធម្មប្បីតិ មានចិត្តថ្លាស្អាត រមែងនៅជាសុខ បណ្ឌិតរមែងត្រេកអរនៅក្នុងព្រះធម៌ ដែលព្រះអរិយៈជាម្ចាស់បានប្រ-កាសហើយសព្វៗ កាល ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរព្រះមហាកប្បិនត្ថេរថា ជាអ្នកមានភាពស្អាតហ្មត់ហ្មង មានឫទ្ធិច្រើន មានអានុភាពច្រើន និងមានសមត្ថភាព ដែលមានរឿងពោលចារឹកទុកក្នុងបាលីគម្ពីរ សំយុត្តនិកាយ និទានវគ្គ នៃភិក្ខុសំយុត្ត ក្នុងកប្បិនសូត្រ ដែលពោលដល់រឿងព្រះ-មហាកប្បិនត្ថេរថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុពីររូបជាសម្លាញ់នឹងគ្នា ជាសទ្ធិវិហារិករបស់ព្រះមហាកប្បិនមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ បានទតឃើញភិក្ខុទាំងនោះ កំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភិក្ខុទាំងពីររូបនុ៎ះ ជាសម្លាញ់នឹងគ្នាកំពុងដើរមក ជាសទ្ធិវិហារិករបស់មហាកប្បិនឬទេ ? ភិក្ខុទាំងឡាយក្រាបទូល

ថា ព្រះករុណាព្រះអង្គ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឯង មានឫទ្ធិច្រើន មានអានុភាពច្រើន សមាបត្តិណា ដែលភិក្ខុទាំងនោះមិនធ្លាប់ចូល សមាបត្តិនោះ បុគ្គលដទៃមិនបានដោយងាយឡើយ មួយទៀត ពួកកុលបុត្រ ដែលចេញចាកផ្ទះចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ភិក្ខុទាំងនោះបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌នោះ ។

ព្រះមានព្រះភាគ លុះត្រាស់ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះត ទៅទៀតថា ៖

ភិក្ខុទាំងនេះ ជាសម្លាញ់នឹងគ្នា ជាអ្នកមានលទ្ធិត្រូវគ្នា ជាយូរហើយ ទាំងព្រះសទ្ធម្មរបស់ភិក្ខុទាំងនោះ ក៏ត្រូវគ្នា ក្នុងធម៌ដែលព្រះពុទ្ធសម្ដែងហើយ ( ភិក្ខុទាំងនោះ ) កប្បិនភិក្ខុ បានទូន្មានហើយ ក្នុងធម៌ដែលព្រះអរិយៈសម្ដែងហើយ ភិក្ខុទាំងនោះ ទ្រទ្រង់នូវអត្តភាពជាទីបំផុត បានឈ្នះមារ ព្រមទាំងសេនាមារ ។

មានរឿងក្នុងការឲ្យឱវាទដល់ភិក្ខុទាំងឡាយ របស់ព្រះមហាកប្បិ-នត្ថេរ នៅក្នុងអដ្ឋកថាបរមត្ថទីបនី សេចក្ដីថា ៖

ថ្ងៃមួយ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហៅភិក្ខុមួយពាន់រូបដែលជាបរិវាររបស់ព្រះមហាកប្បិនត្ថេរ ចូលមកគាល់ព្រមគ្នា ហើយ

ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ មហាកប្បិនដែលជាអាចារ្យរបស់អ្នក ធ្លាប់សម្ដែងធម៌ឲ្យពួកអ្នកស្ដាប់ខ្លះឬទេ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ អាចារ្យរបស់ពួកខ្ញុំព្រះអង្គ មិនធ្លាប់សម្ដែងធម៌ណាមួយដល់ពួកខ្ញុំព្រះអង្គឡើយ ព្រោះលោកជាអ្នកមានការខ្វល់ខ្វាយតិច ប្រកបតែក្នុងទិដ្ឋធម្មសុខវិហារ គឺនៅជាសុខសប្បាយក្នុងធម៌ដែលលោកឃើញហើយ មិនដែលឲ្យឱវាទដល់អ្នកណាមួយឡើយព្រះអង្គ ។ ព្រះមានព្រះភាគ កាលត្រាស់ហៅព្រះមហាកប្បិនត្ថេរចូលមកគាល់ហើយ ក៏ត្រាស់សួរថា ម្នាលកប្បិន អ្នកមិនធ្លាប់បានឲ្យឱវាទ ដល់ពួកអន្តេវាសិកទាំងនោះពិតមែនឬ ? ព្រះមហាកប្បិនត្ថេរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែនព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា អ្នកជាព្រះខីណាស្រព អ្នកកុំធ្វើយ៉ាងនេះឡើយ ពីពេលនេះទៅ អ្នកចូរសម្ដែងធម៌ដល់ភិក្ខុទាំងឡាយចុះ ។ ព្រះមហាកប្បិនត្ថេរក៏ទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។

ក្នុងកាលជាខាងក្រោយមក ព្រះមានព្រះភាគជាម្ចាស់ ទ្រង់តែងតាំងព្រះមហាកប្បិនត្ថេរទុកក្នុងតំណែងឯតទគ្គៈ ដូចមានសេចក្ដីក្នុងបាលីគម្ពីរអង្គុត្តរនិកាយ ឯកនិបាត ថា ៖

ម្នាលភិក្ខុទាំងឡាយ មហាកប្បិនប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងឲ្យឱវាទដល់ពួកភិក្ខុ ។ ការឲ្យឱវាទ

ដល់ភិក្ខុទាំងឡាយ របស់ព្រះមហាកប្បិនត្ថេរ មានក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា នៃទសកនិបាត ថា ៖

នៅថ្ងៃមួយ ព្រះថេរៈបានឲ្យឱវាទដល់ពួកភិក្ខុនី ដោយពោល គាថា ១០ គាថា ដូចមានសេចក្តីថា ៖

បុគ្គលណា ពិចារណាឃើញ នូវកិច្ចជាប្រយោជន៍ និងមិនជា ប្រយោជន៍ទាំងពីរនោះ ដែលមិនទាន់មកដល់ទុកជាមុន ជនទាំងឡាយ ជាសត្រូវក្តី ជាអ្នកស្វែងរកប្រយោជន៍ក្តី កាលគយគន់មើល រមែងមិន ឃើញ នូវទោសនៃបុគ្គលនោះឡើយ ។ អានាបានស្សតិ ដែលព្រះ យោគាវចរណា បានចម្រើនល្អគ្រប់គ្រាន់ហើយ បានសន្សំហើយ តាម លំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងមក ព្រះយោគាវចរនោះ រមែងញ៉ាំង លោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះច័ន្ទផុតចាកពពក ។ ឱ ! ចិត្តរបស់អញ ស.រកប្រមាណមិនបាន អាត្មាអញ បានអប់រំល្អហើយផង បានផ្គងជា និច្ចផង ញ៉ាំងទិសទាំងពួងឲ្យភ្លឺផង ។ បុគ្គលប្រកបដោយប្រាជ្ញា បើទុក ជាអស់ទ្រព្យរលីង ក៏ឈ្មោះថា រស់នៅ ឯបុគ្គលអ្នកមានទ្រព្យ មិន ឈ្មោះថារស់នៅ ព្រោះកិរិយាមិនបាននូវប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿង វិនិច្ឆ័យនូវសុតៈ ប្រាជ្ញាជាគ្រឿងញ៉ាំងកិត្តិសព្ទ និងសេចក្តីសរសើរឲ្យ ចម្រើន នរជនប្រកបដោយប្រាជ្ញា រមែងបាននូវសេចក្តីសុខ សូម្បីក្នុង សភាវៈដែលជាទុក្ខ ។

ធម៌នេះមិនមែនជាធម៌ទើបនឹងមាន ក្នុងថ្ងៃនេះទេ ជាធម៌មិនអស្ចារ្យ មិនមែនជាធម៌ចម្លែកទេ សត្វកើតស្លាប់ ក្នុងលោកណា ហេតុតិចតួច ក៏មិនចម្លែកក្នុងលោកនោះ ។ សេចក្ដីពិតថា បន្ទាប់អំពីការកើតមក មានសេចក្ដីស្លាប់ចាកជីវិត ជាធម្មជាតទៀងទាត់ សត្វទាំងឡាយដែលកើតមកហើយៗ រមែងស្លាប់ ក្នុងលោកនេះ ព្រោះថា សត្វទាំង-ឡាយ មានសភាពយ៉ាងនេះឯង ។ សេចក្ដីសោកស្ដាយណា របស់បុរសបុគ្គល ទាំងឡាយដទៃ ដើម្បីជីវិត សេចក្ដីសោកស្ដាយទុំះ មិនមែនដើម្បីប្រយោជន៍ ដល់សត្វដែលស្លាប់ទៅហើយទេ ការយំចំពោះសត្វ ដែលស្លាប់ហើយ មិនមែនជាយស មិនមែនជាការល្អទេ សមណព្រាហ្មណ៍ទាំងឡាយ មិនសរសើរការយំឡើយ ។ ការយំ រមែងបៀតបៀននូវចក្ខុ និងសរីរៈ ( របស់បុគ្គលអ្នកយំ ) ពណ៌សម្បុរក្ដី កម្លាំងក្ដីប្រាជ្ញាក្ដី នៃអ្នកយំរមែងសាបសូន្យ ពួកសត្រូវរបស់បុគ្គលអ្នកយំនោះក៏មានសេចក្ដីត្រេកអរ ពួកបុគ្គលអ្នកស្វែងរកប្រយោជន៍ ឲ្យបុគ្គលអ្នកយំនោះ បាននូវសេចក្ដីទុក្ខ ។ ព្រោះហេតុនោះ ពួកជនធ្វើនូវកិច្ច ( របស់ខ្លួន ) ដោយកម្លាំងប្រាជ្ញា របស់អ្នកប្រាជ្ញទាំងឡាយណា ដូចពួកជន អ្នកធ្វើនូវទន្លេមានទឹកពេញដោយទូក បុគ្គលគប្បីប្រាថ្នា នូវអ្នកប្រាជ្ញ ជាពហុស្សូតនោះ ឲ្យនៅក្នុងត្រកូល ( របស់ខ្លួន ) ។

កាលបើភិក្ខុនីទាំងនោះ បានស្ដាប់ឱវាទព្រះថេរៈយ៉ាងនេះហើយ

ក៏បានបន្ទោបង់នូវសេចក្តីសោកហើយ បដិបត្តិយ៉ាងត្រឹមត្រូវល្អ មិនយូរប៉ុន្មានក៏បានញ៉ាំងប្រយោជន៍របស់ខ្លួនឲ្យសម្រេច ។

ព្រះមហាកប្បិនត្ថេរ កាលបើលោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វាន ទៅកាន់ទីបរមសុខពោលគឺព្រះនិព្វាននោះឯងហោង ។

*( ជីវប្រវត្តិរបស់ព្រះមហាកប្បិនត្ថេរ ចប់ )*

# ✍ ជីវប្រវត្តិរបស់ព្រះមហាកោដ្ឋិតត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងបានបដិសម្ភិទា "

*ព្រះថេរៈរូបនេះ ជាអរិយសាវកដ៏ធំមួយរូប ក្នុងចំណោមអសីតិ-មហាសាវក ៨០ រូប ព្រោះលោកជាឯតទគ្គៈប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងបានសម្រេចបដិសម្ភិទា កិត្តិស័ព្ទដូចពោលមកនេះ ដែលកើតពីសេចក្តីល្អ ដែលបានធ្វើទុកហើយក្នុងអតីតជាតិ ឬបច្ចុប្បន្នជាតិ ។*

*ជីវប្រវត្តិរបស់ព្រះមហាកោដ្ឋិតត្ថេរនេះ ដូចមានសេចក្តីក្នុងគម្ពីរខុទ្ទកនិកាយ អបទាន និងអដ្ឋកថាមនោរថបូរណី បានសម្តែងទុកដូចតទៅនេះថា ៖*

*ព្រះមហាកោដ្ឋិតៈ លោកកើតនៅក្នុងត្រកូលព្រាហ្មណ៍ មានធនធានច្រើនក្នុងក្រុងសាវត្ថី ។ បិតា ឈ្មោះអស្សលាយនៈ មាតាឈ្មោះចន្ទវតី ព្រះពុទ្ធទ្រង់ទូន្មានបិតារបស់ខ្ញុំ ដើម្បីសេចក្តីស្អាតគ្រប់យ៉ាង ក្នុងកាលណា ។ កាលនោះ ខ្ញុំជ្រះថ្លាចំពោះព្រះសុគត ហើយចូលទៅកាន់ផ្នួស ព្រះមហាមោគ្គល្លានជាអាចារ្យ ព្រះសារីបុត្រជាឧបជ្ឈាយ៍ ( របស់ខ្ញុំ ) ។ កាលសក់ទាំងឡាយដាច់ចុះ ទិដ្ឋិព្រមទាំងឫសក៏ដាច់ចុះដែរ ខ្ញុំកំពុងតែ ស្លៀកសំពត់កាសាវៈ ក៏បានសម្រេចអរហត្ត ។*

*ប្រាជ្ញារបស់ខ្ញុំបែកធ្លាយ ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ហេតុ*

នេះ បានជាព្រះពុទ្ធ ជាកំពូលនៃលោក ទ្រង់តែងតាំងខ្ញុំ ក្នុងតំណែងជាឯតទគ្គៈ ។ ខ្ញុំត្រូវព្រះឧបតិស្សៈ សាកសួរក្នុងបដិសម្ភិទា ក៏បានដោះស្រាយនូវធម៌ ដែលខ្លួនមិនដែលបានឃើញ ហេតុនោះហើយបានជាខ្ញុំជាអ្នកប្រសើរ ក្នុងសាសនានៃព្រះសម្ពុទ្ធ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសម្នាក់ព្រះពុទ្ធដ៏ប្រសើររបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិល្អហើយ ។ ព្រះមហាកោដ្ឋិតត្ថេរ រាប់ថាជាអ្នកបានសម្រេចមគ្គផលជាន់ខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា ជាអ្នកត្រាស់ដឹងនូវធម៌យ៉ាងរហ័ស ។ ព្រះមហាកោដ្ឋិតត្ថេរ លោកបានសម្រេចជាព្រះអរហន្តហើយ ប៉ុន្តែនៅតែពេញចិត្តក្នុងការសន្ទនាព្រះធម៌ជានិច្ច សូម្បីលោកចូលទៅគាល់ព្រះលោកនាថ ក៏ចូលចិត្តសួរបញ្ហាក្នុងបដិសម្ភិទា ៤ ជារឿយៗ ។

រឿងនេះមានហេតុផលប្រាកដនៅក្នុង មហាវេទល្លសូត្រ នៃគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះភគវាទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះកោដ្ឋិតៈមានអាយុ ចេញអំពីផលសមាបត្តិ

ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្រ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យរាក់ទាក់ សំណេះសំណាលទៅរកព្រះសារីបុត្រមានអាយុ លុះបញ្ចប់សំណេះសំណាល និងពាក្យដែលគួររឭកហើយក៏គង់ក្នុងទីដ៏សមគួរ ។

លុះព្រះមហាកោដ្ឋិតៈមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ទើបសួរព្រះសារីបុត្រមានអាយុ យ៉ាងនេះថា ម្នាលអាវុសោ គេតែងនិយាយថា បុគ្គលគ្មានប្រាជ្ញាៗ ម្នាលអាវុសោ បុគ្គលដែល ហៅថា អ្នកគ្មានប្រាជ្ញា តើដោយហេតុដូចម្ដេច ? ព្រះសារីបុត្រតបថា ម្នាលអាវុសោ បុគ្គលដែលមិនចេះមិនដឹងច្បាស់ហ្នឹងឯង ហៅថាអ្នកគ្មានប្រាជ្ញា ចុះបុគ្គលនោះមិនដឹងច្បាស់នូវអ្វី ? មិនដឹងច្បាស់ថា នេះទុក្ខ នេះហេតុឲ្យកើតទុក្ខ នេះជាគ្រឿងរំលត់ទុក្ខ នេះជាសេចក្ដីប្រតិបត្តិដែលជាដំណើរទៅកាន់ទីរំលត់ទុក្ខ ម្នាលអាវុសោ ព្រោះតែបុគ្គលនោះ មិនចេះមិនដឹងដូច្នេះឯង ទើបហៅថា អ្នកគ្មានប្រាជ្ញា ។ ចុះអ្នកមានប្រាជ្ញាវិញ តើដូចម្ដេច ? បុគ្គល ដែលចេះដឹងច្បាស់ហ្នឹងឯង ដែលហៅថា អ្នកមានប្រាជ្ញា ចុះបុគ្គលនោះដឹងច្បាស់នូវអ្វី ? ដឹងច្បាស់ថា នេះទុក្ខ នេះជាហេតុឲ្យកើតទុក្ខ នេះជាគ្រឿងរំលត់ទុក្ខ នេះជាសេចក្ដីប្រដិបត្តិដែលជាដំណើរទៅកាន់ទីរំលត់ទុក្ខ ម្នាលអាវុសោ ព្រោះតែបុគ្គលនោះដឹងច្បាស់ដូច្នេះឯងទើបហៅថា អ្នកមានប្រាជ្ញា ។

ម្នាលអាវុសោ គេតែងហៅថា វិញ្ញាណៗ ចុះធម្មជាតដែលគេហៅថា វិញ្ញាណ តើដូចម្ដេច ? ធម្មជាតដែលស្គាល់ច្បាស់ ដឹងច្បាស់ នុ៎ះឯង ដែលគេហៅថា វិញ្ញាណ ។ ចុះវិញ្ញាណនោះស្គាល់ច្បាស់អ្វីខ្លះ ? ស្គាល់ថាសុខខ្លះ ស្គាល់ថាទុក្ខខ្លះ ស្គាល់ថាមិនមែនទុក្ខមិនមែនសុខខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតិនោះស្គាល់ច្បាស់ ដឹងច្បាស់ដូច្នេះឯង ទើបហៅថា វិញ្ញាណ ។ ចុះប្រាជ្ញា និងវិញ្ញាណ ធម៌ទាំងពីរនេះតើដូចគ្នា ឬផ្សេងគ្នា មួយទៀត បុគ្គលចែករំលែកធម៌ទាំងពីរនេះបញ្ញត្តឲ្យផ្សេងៗ គ្នាបានឬទេ ? ម្នាលអាវុសោ ប្រាជ្ញា និងវិញ្ញាណ ធម៌ទាំងពីរនេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ ទាំងបុគ្គលនឹងចែករំលែកបញ្ញត្តិធម៌ទាំងពីរនេះ ឲ្យផ្សេងគ្នាមិនបានទេ ម្នាលអាវុសោ ប្រាជ្ញាដឹងច្បាស់នូវវត្ថុណា វិញ្ញាណក៏ដឹងច្បាស់នូវវត្ថុនោះដែរ វិញ្ញាណស្គាល់ច្បាស់នូវវត្ថុណា ប្រាជ្ញាក៏ដឹងច្បាស់នូវវត្ថុនោះដែរ ព្រោះហេតុនោះ បានជាធម៌ទាំងពីរនេះជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ ទាំងបុគ្គលនឹងចែករំលែកបញ្ញត្តិធម៌ទាំងពីរនេះ ឲ្យផ្សេងគ្នាមិនបានឡើយ ។

ម្នាលអាវុសោ បើប្រាជ្ញា និងវិញ្ញាណធម៌ទាំងពីរនេះដូចគ្នា មិនមែនផ្សេងគ្នាទេ ចុះសេចក្ដីប្លែកគ្នាត្រង់ណា ? ម្នាលអាវុសោ ប្រាជ្ញា និងវិញ្ញាណធម៌ទាំងពីរនេះជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ តែប្រាជ្ញាបុគ្គលគួរចម្រើន វិញ្ញាណបុគ្គលគួរកំណត់ដឹង នេះជាសេចក្ដីប្លែកគ្នានៃ

ធម៌ទាំងពីរនេះឯង ។ ម្នាលអាវុសោ គេតែងហៅថាវេទនាៗ តើវេទនាដោយហេតុដូចម្ដេច ? ម្នាលអាវុសោ ធម្មជាតដែលទទួលដឹងច្បាស់នូវអារម្មណ៍ហ្នឹងឯង ដែលគេហៅថាវេទនា វេទនានោះដឹងអ្វីខ្លះ ? ដឹងសុខខ្លះ ដឹងទុក្ខខ្លះ ដឹងមិនមែនទុក្ខមិនមែនសុខខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះទទួលដឹងអារម្មណ៍ដូច្នេះឯង ទើបហៅថាវេទនា ។ ម្នាលអាវុសោ គេតែងហៅថាសញ្ញាៗ តើសញ្ញាដោយហេតុដូចម្ដេច ? ម្នាលអាវុសោ ព្រោះតែធម្មជាតនោះកត់សម្គាល់ ចំណាំ ទើបហៅថា សញ្ញា សញ្ញានោះតែងសម្គាល់អ្វីខ្លះ ? សញ្ញានោះតែងសម្គាល់ពណ៌ខៀវខ្លះ សម្គាល់ពណ៌លឿងខ្លះ សម្គាល់ពណ៌ក្រហមខ្លះ សម្គាល់ពណ៌សខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះកត់សម្គាល់ហ្នឹងឯង ទើបហៅថា សញ្ញា ។ ម្នាលអាវុសោ វេទនា សញ្ញា និងវិញ្ញាណ ធម៌ទាំងនេះជាធម៌ច្រឡំគ្នា ឬមិនច្រឡំគ្នាទេ មួយទៀត បុគ្គលនឹងចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តិកុំឲ្យច្រឡំគ្នាបានឬទេ ? ម្នាលអាវុសោ វេទនា សញ្ញា និងវិញ្ញាណ ធម៌ទាំងនេះច្រឡំគ្នា មិនមែនផ្សេងគ្នាទេ ហើយបុគ្គលចែករំលែកធម៌ទាំងនេះ បញ្ញត្តិឲ្យផ្សេងគ្នាមិនបានទេ ម្នាលអាវុសោ វេទនាទទួលដឹងអារម្មណ៍ណា សញ្ញាក៏សម្គាល់អារម្មណ៍នោះដែរ សញ្ញាសម្គាល់នូវអារម្មណ៍ណា វិញ្ញាណក៏ដឹងច្បាស់នូវអារម្មណ៍នោះដែរ ព្រោះហេតុនោះ ធម៌ទាំងនេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ បុគ្គលនឹងចែក

វិលែកធម៌ទាំងនោះ ហើយបញ្ញត្តិឲ្យផ្សេងគ្នាមិនបានទេ ។

ម្នាលអាវុសោ ធម្មជាតអ្វីដែលគេគប្បីដឹងដោយមនោវិញ្ញាណដ៏បរិសុទ្ធ ប្រាសចាកឥន្ទ្រិយ៍ទាំង ៥ ប្រការ ? ម្នាលអាវុសោ អាកាសានញ្ចាយតនជ្ឈានដែលបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ គប្បីដឹងដោយមនោវិញ្ញាណដ៏បរិសុទ្ធ ប្រាសចាកឥន្ទ្រិយ៍ទាំង ៥ ប្រការ វិញ្ញាណញ្ចាយតនជ្ឈាន ដែលបរិកម្មថា វិញ្ញាណមិនមានទីបំផុត និង អាកិញ្ចញ្ញាយតនជ្ឈាន ដែលបរិកម្មថា អ្វីតិចតួចមិនមានដូច្នេះ គប្បីដឹងបាន ដោយមនោវិញ្ញាណដ៏បរិសុទ្ធប្រាសចាកឥន្ទ្រិយ៍ទាំង ៥ ប្រការ ។ ម្នាលអាវុសោ ធម៌ដែលគេគប្បីដឹង តើគេតែងដឹងបានដោយអ្វី ? ម្នាលអាវុសោ ធម៌ដែលគេគប្បីដឹងនោះឯង គេតែងដឹងដោយបញ្ញាចក្ខុ ម្នាលអាវុសោ ប្រាជ្ញាមានសេចក្តីថាដូចម្តេចខ្លះ ? ម្នាលអាវុសោ ប្រាជ្ញាមានសេចក្តីថា ដឹងប្រាកដ ដឹងសព្វ និងលះបង់ ។ ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើងមានប៉ុន្មាន ? ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មាន ២ គឺការស្តាប់អំពីសម្នាក់ជនដទៃ ១ ការយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញាខ្លួនឯង ១ ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើងមានពីរយ៉ាងនេះឯង ។ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផលគឺចេតោវិមុត្តិជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គ

ប៉ុន្មានទំនុកបម្រុង ? ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គ ៥ ជួយទំនុកបម្រុង ម្នាលអាវុសោ សម្មាទិដ្ឋិក្នុងទីនេះ មានសីលជួយទំនុកបម្រុង ១ មានសុតៈជួយទំនុកបម្រុង ១ មានសាកច្ឆាជួយទំនុកបម្រុង ១ មានសមថៈជួយទំនុកបម្រុង ១ មានវិបស្សនាជួយទំនុកបម្រុង ១ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផលគឺចេតោវិមុត្តិជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គ ៥ នេះឯងជួយទំនុកបម្រុង ។

ម្នាលអាវុសោ ភពតើមានប៉ុន្មាន ? ម្នាលអាវុសោ ភពនេះមាន ៣ គឺ កាមភព ១ រូបភព ១ អរូបភព ១ ។ ម្នាលអាវុសោ ការកើតក្នុងភពថ្មីតទៅទៀត ព្រោះហេតុដូចម្តេច ? ម្នាលអាវុសោ ព្រោះសេចក្តីត្រេកអរក្នុងភពនោះៗ របស់ពួកសត្វ ដែលមានអវិជ្ជាជានីវរណៈ មានតណ្ហាជាសំយោជនៈ ការកើតក្នុងភពថ្មីតទៅទៀតយ៉ាងនេះឯង ។ ម្នាលអាវុសោ ការមិនកើតក្នុងភពថ្មីតទៅទៀត ព្រោះហេតុដូចម្តេច ? ម្នាលអាវុសោ ព្រោះប្រាសចាកអវិជ្ជា ព្រោះវិជ្ជាកើតឡើង ព្រោះការរលត់នៃតណ្ហា ការមិនកើតក្នុងភពថ្មីតទៅទៀតយ៉ាងនេះឯង ។

ម្នាលអាវុសោ បឋមជ្ឈានដូចម្តេច ? ម្នាលអាវុសោ ភិក្ខុក្នុង

សាសនានេះ ជាអ្នកស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កប្រកបដោយវិចារៈ មានបីតិ និងសុខៈដែលកើតអំពីវិវេក ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលអាវុសោ នេះហៅថា បឋមជ្ឈាន ។ ម្នាលអាវុសោ បឋមជ្ឈានមានអង្គប៉ុន្មាន ? បឋមជ្ឈានមានអង្គ ៥ ម្នាលអាវុសោ កាលភិក្ខុក្នុងសាសនានេះ ចូលកាន់បឋមជ្ឈាន មានអង្គ ៥ គឺវិតក្ក វិចារៈ បីតិ សុខៈ និងចិត្តេកគ្គតា រមែងប្រព្រឹត្តទៅ ម្នាលអាវុសោ បឋមជ្ឈានអង្គ ៥ យ៉ាងនេះឯង ។ ម្នាលអាវុសោ បឋមជ្ឈានលះអង្គប៉ុន្មាន ប្រកបដោយអង្គប៉ុន្មាន ? ម្នាលអាវុសោ បឋមជ្ឈានលះអង្គ ៥ ប្រកបដោយអង្គ ៥ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ កាលចូលកាន់បឋមជ្ឈាន ជាអ្នកលះបង់កាមឆន្ទៈ លះបង់ព្យាបាទ លះបង់ថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ចំណែកខាងវិតក្ក វិចារៈ បីតិ សុខៈ និងចិត្តេកគ្គតា ក៏ប្រព្រឹត្តទៅ ម្នាលអាវុសោ បឋមជ្ឈានលះអង្គ ៥ ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ ប្រការនេះ មានវិស័យផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា ទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាមិនបានទេ ឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ ? គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះ មាន

វិស័យផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ ចុះមានអ្វីជាទីពឹង មួយទៀត សភាពអ្វីទទួលវិស័យដែលកើតជាអារម្មណ៍របស់ឥន្ទ្រិយទាំង ៥ ប្រការនោះ ? ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ ប្រការនោះមានវិស័យផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលវិស័យ ដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ ឥន្ទ្រិយទាំង ៥ ប្រការ គឺ អ្វីខ្លះ ? គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះឯង មានវិស័យផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ មានចិត្តជាទីពឹង មានចិត្តទទួលវិស័យ ដែលកើតជាអារម្មណ៍របស់ឥន្ទ្រិយទាំង ៥ នោះ ។

ម្នាលអាវុសោ ឥន្ទ្រិយ ៥ ប្រការនេះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ នេះឯងអាស្រ័យនឹងអ្វី ទើបតាំងនៅបាន ? ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ នេះឯង អាស្រ័យនឹងអាយុ ទើបតាំងនៅបាន ។ ម្នាលអាវុសោ ចុះអាយុលុះតែអាស្រ័យនឹងអ្វីទើបតាំងនៅបាន ? អាយុលុះតែអាស្រ័យចំហាយភ្លើងធាតុ ទើបតាំងនៅបាន ។ ម្នាលអាវុសោ ចំហាយភ្លើងធាតុអាស្រ័យនឹងអ្វីទើបតាំងនៅបាន ? ចំហាយភ្លើងធាតុ លុះតែអាស្រ័យ

នឹងអាយុទើបតាំងនៅបាន ។ អម្បាញ់មិញនេះ ខ្ញុំដឹងច្បាស់ភាសិតរបស់ព្រះសារីបុត្រមានអាយុយ៉ាងនេះថា អាយុលុះតែអាស្រ័យចំហាយភ្លើងធាតុទើបតាំងនៅបាន ឥឡូវនេះ ខ្ញុំដឹងច្បាស់ភាសិតរបស់ព្រះសារីបុត្រមានអាយុយ៉ាងនេះថា ភ្លើងធាតុលុះតែអាស្រ័យនឹងអាយុ ទើបតាំងនៅបានដូច្នេះវិញ ។ ម្នាលអាវុសោ បើដូច្នេះ ខ្ញុំត្រូវយល់សេចក្ដីនៃភាសិតនោះដូចម្ដេច ? ម្នាលអាវុសោ បើដូច្នោះ ខ្ញុំនឹងធ្វើសេចក្ដីឧបមា ដ្បិតជនជាអ្នកចេះដឹងពួកខ្លះក្នុងលោកនេះ គង់យល់សេចក្ដីនៃភាសិត ដោយពាក្យឧបមាបានដែរ ម្នាលអាវុសោ ដូចប្រទីបប្រេងកាលឆេះមានពន្លឺប្រាកដឡើង ព្រោះអាស្រ័យអណ្ដាត អណ្ដាតប្រាកដឡើង ព្រោះអាស្រ័យពន្លឺ សេចក្ដីនេះយ៉ាងណាមិញ អាយុតាំងនៅបាន ក៏ព្រោះអាស្រ័យចំហាយភ្លើងធាតុ ចំហាយភ្លើងធាតុតាំងនៅបាន ព្រោះអាស្រ័យអាយុក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាយុសង្ខារទាំងនេះ ជាវេទនីយធម៌នោះ ឬថាអាយុសង្ខារផ្សេង វេទនីយធម៌ផ្សេង ? ម្នាលអាវុសោ មិនមែនអាយុសង្ខារទាំងនោះ ជាវេទនីយធម៌នោះទេ ម្នាលអាវុសោ ប្រសិនបើអាយុសង្ខារទាំងនោះជាវេទនីយធម៌នោះហើយ ភិក្ខុដែលចូលទៅកាន់សញ្ញាវេទយិតនិរោធនេះ ចេញចាកសមាបត្តិមកវិញមិនកើតទេ គឺអាយុសង្ខារផ្សេង វេទនីយធម៌ផ្សេង ហេតុនោះ បានជាភិក្ខុចូលកាន់សញ្ញាវេទយិតនិរោធ ចេញចាកសមាបត្តិមកវិញបាន ។ ម្នាលអាវុសោ ធម៌ប៉ុន្មាន

ដែលលះបង់កាយនេះ ក្នុងកាលណាហើយ កាយនេះត្រូវគេចោលរាត់រាយ ដេកស្តូកស្តឹងដូចជាកំណាត់ឈើដែលគ្មានចេតនា ? ម្នាលអាវុសោ ធម៌ ៣ ប្រការ គឺអាយុ ១ ចំហាយភ្លើងធាតុ ១ វិញ្ញាណ ១ លះបង់កាយនេះក្នុងកាលឯណាហើយ កាយនេះគេចោលរាត់រាយ ដេកស្តូកស្តឹងដូចកំណាត់ឈើដែលគ្មានចេតនា ។ ម្នាលអាវុសោ បុគ្គលដែលធ្វើកាលកិរិយា ១ ភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ១ បុគ្គលទាំង ២ ពួកនេះ មានសេចក្តីប្លែកគ្នាដូចម្តេច ? ម្នាលអាវុសោ បុគ្គលដែលធ្វើកាលកិរិយា បុគ្គលនោះ កាយសង្ខារគឺខ្យល់ដង្ហើមចេញចូល រលត់ស្ងប់ស្ងៀម វចីសង្ខារ គឺវិតក្កនិងវិចារៈ រលត់ស្ងប់ស្ងៀម ចិត្តសង្ខារ គឺសញ្ញានិងវេទនា រលត់ស្ងប់ស្ងៀម អាយុក៏អស់ ចំហាយភ្លើងធាតុក៏រលត់ស្ងប់ស្ងៀម ឥន្ទ្រិយក៏បែកធ្លាយ ឯភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ភិក្ខុនោះមានកាយសង្ខារ វចីសង្ខារ ចិត្តសង្ខារក៏រលត់ស្ងប់ស្ងៀមដែរ តែអាយុមិនអស់ ចំហាយភ្លើងធាតុមិនរលត់ស្ងប់ទេ ឥន្ទ្រិយនៅថ្លាល្អ ម្នាលអាវុសោ បុគ្គលដែលធ្វើមរណកាល និងភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ បុគ្គលទាំង ២ ពួកនេះ មានសេចក្តីផ្សេងគ្នាយ៉ាងនេះឯង ។

ម្នាលវុសោ អទុក្ខមសុខាចេតោវិមុត្តិសមាបត្តិ មានបច្ច័យប៉ុន្មាន ? មានបច្ច័យ ៤ គឺ ភិក្ខុក្នុងសាសនានេះព្រោះលះបង់នូវសេចក្តី

សុខ ១ ព្រោះលះបង់សេចក្តីទុក្ខ ១ ព្រោះរំលត់នូវសោមនស្ស និង ទោមនស្សក្នុងកាលមុន ១ ចូលកាន់ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខ មាន សតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ទាំងបួន ១ ម្នាលអាវុសោ អទុក្ខមសុខាចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ នេះឯង ។ ម្នាលអាវុសោ អនិមិត្តាចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ប៉ុន្មាន ? អនិមិត្តាចេតោវិមុត្តិសមាបត្តិមានបច្ច័យ ២ គឺការមិនយកចិត្ត ទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុ ដែលប្រាសចាកអារម្មណ៍ ១ ម្នាលអាវុសោ អនិមិត្តាចេតោវិមុត្តិសមា-បត្តិ មានបច្ច័យ ២ នេះឯង ។ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តា ចេតោវិមុត្តិតាំងនៅបានយូរ តើមានប៉ុន្មាន ? បច្ច័យដែលឲ្យអនិមិត្តា ចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ គឺការមិនយកចិត្តទុកដាក់ ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុ ដែល ប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងទុកពីខាងដើម ១ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តាចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការនេះ ឯង ។ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តាចេតោវិមុត្តិ មាន ប៉ុន្មាន ? មាន ២ ប្រការ គឺការយកចិត្តទុកដាក់ចំពោះអារម្មណ៍ ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលមិនមានអារម្មណ៍ ១ ម្នាល អាវុសោ បច្ច័យនៃការចេញចាកអនិមិត្តាចេតោវិមុត្តិ មាន ២ ប្រការនេះ

ឯង ។ ម្នាលអាវុសោ អប្បមាណាចេតោវិមុត្តិ អាកិញ្ចញ្ញាចេតោវិមុត្តិ សុញ្ញតាចេតោវិមុត្តិ និងអនិមិត្តាចេតោវិមុត្តិ ធម៌ទាំងនេះមានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ឬមានសេចក្តីដូចគ្នា គ្រាន់តែព្យញ្ជនៈផ្សេងគ្នាប៉ុណ្ណោះទេឬ ? ម្នាលអាវុសោ មានបរិយាយដែលធម៌ទាំងនេះ អាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង មួយទៀត មានបរិយាយដែលធម៌ទាំងនេះអាស្រ័យហើយ ក៏បែរជាមានសេចក្តីដូចគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ម្នាលអាវុសោ ចុះបរិយាយដូចម្តេច ដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ? ភិក្ខុក្នុងសាសនានេះ មានចិត្តដែលប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសកណ្តាល ព្រោះយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ មានចិត្តប្រកបដោយករុណា... ប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាង

លើ ទិសខាងក្រោម ទិសទទឹង ព្រោះបង្អោនខ្លួនទៅប្រៀបធៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ម្នាលអាវុសោ នេះហៅថា អប្បមាណាចេតោវិមុត្តិ ។ ម្នាលអាវុសោ អាកិញ្ចញ្ញាចេតោវិមុត្តិ តើដូចម្តេច ? ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ដោយសព្វអន្លើ ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ម្នាលអាវុសោ នេះហៅថា អាកិញ្ចញ្ញាយតនចេតោវិមុត្តិ ។ ម្នាលអាវុសោ សុញ្ញតាចេតោវិមុត្តិ តើដូចម្តេច ? ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងសុញ្ញាគារដ្ឋានក្តី រមែងពិចារណាយ៉ាងនេះថា របស់នេះតែងសាបសូន្យចាកអត្តភាព ឬចាកវត្ថុសម្រាប់ទំនុកបម្រុងខ្លួន មានចីវរជាដើម ម្នាលអាវុសោ នេះលោកហៅថា សុញ្ញតាចេតោវិមុត្តិ ។ ម្នាលអាវុសោ អនិមិត្តាចេតោវិមុត្តិ តើដូចម្តេច ? ភិក្ខុក្នុងសាសនានេះ ចូលកាន់ចេតោសមាធិដែលមិនមាននិមិត្ត ព្រោះមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង នេះហៅ អនិមិត្តាចេតោវិមុត្តិ ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលធម៌ទាំងនោះអាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ម្នាលអាវុសោ ចុះបរិយាយដូចម្តេច ដែលពួកធម៌ទាំងនេះអាស្រ័យហើយ បែរជាមានសេចក្តីដូចគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ម្នាលអាវុសោ រាគៈជាកិលេសធ្វើនូវប្រមាណ ទោសៈជាកិលេសធ្វើនូវប្រមាណ មោហៈ

ជាកិលេសធ្វើនូវប្រមាណ កិលេសទាំងនេះ ភិក្ខុដែលជាខីណាស្រពបាន លះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យកើតតទៅទៀត ដូចដើមត្នោតដែលគេក្របែលមិនឲ្យដុះតទៅទៀត ធ្វើមិនឲ្យមានបែបភាពតទៅទៀត ជាធម៌មិនកើតតទៅទៀត ។ ម្នាលអាវុសោ បណ្តាអប្បមាណាចេតោវិមុត្តិទាំងប៉ុន្មាន មានអកុប្បាចេតោវិមុត្តិ ប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យរាគៈ ទោសៈ មោហៈ ។ ម្នាលអាវុសោ រាគៈ ទោសៈ មោហៈជាគ្រឿងកង្វល់ កិលេសទាំងនេះ ភិក្ខុជាខីណាស្រពបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចដើមត្នោត ដែលគេកាប់ក្របែល ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ ។ ម្នាលអាវុសោ អាកិញ្ចញ្ញាចេតោវិមុត្តិទាំងប៉ុន្មាន មានអកុប្បាចេតោវិមុត្តិប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យរាគៈ ទោសៈ មោហៈ ។ ម្នាលអាវុសោ រាគៈ ទោសៈ មោហៈជាកិលេសធ្វើនិមិត្ត ពួកកិលេសធ្វើនិមិត្តទាំងនេះ ភិក្ខុជាព្រះខីណាស្រព បានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចដើមត្នោតដែលគេក្របែលចោលហើយ ធ្វើឲ្យលែងមានបែបភាពតទៅទៀត ជាធម៌លែងមានកំណើតតទៅទៀតហើយ ។ ម្នាលអាវុសោ អនិមិត្តាចេតោវិមុត្តិទាំងប៉ុន្មានមាន

អកុប្បាចេតោវិមុត្តិប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យរាគៈ ទោសៈ មោហៈ ម្នាលអាវុសោ នេះឯងជាបរិយាយដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្តីដូចគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ។ លុះព្រះសារីបុត្តមានអាយុ បានពោលពាក្យនេះហើយ ព្រះមហាកោដ្ឋិតៈមានអាយុ ក៏មានចិត្តរីករាយត្រេកអរហើយ ចំពោះភាសិតរបស់សារីបុត្តមានអាយុ ។

កាលដែលព្រះមហាកោដ្ឋិតត្ថេរ បានទទួលការលើកតម្កើងឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដូចមានប្រាកដក្នុងបាលី គម្ពីរអង្គុត្តរ-និកាយ ឯកនិបាត មានសេចក្តីថា ៖

ព្រះសុគតសាស្តា ទ្រង់លើកមហាវេទល្លសូត្រ ជាហេតុសំអាងទ្រង់តែងតាំងព្រះមហាកោដ្ឋិតត្ថេរ នៅក្នុងកណ្តាលសង្ឃសន្និបាតថា ជាឯតទគ្គៈ គឺប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងសម្រេចបដិសម្ភិទា ។ បដិសម្ភិទា សំដៅដល់ភាពជំនាញ ឬបញ្ញាដ៏ជំនាញ ៤ ប្រការ គឺអត្ថ ១ ធម៌ ១ និរុត្តិ ១ និងបដិភាណ ១ ។ ការទទួលតំណែងឯតទគ្គៈនេះ ក្រៅអំពីមានមហាវេទល្លសូត្រជាមូលដ្ឋាន នៅមានរឿងអតីតជាតិ ជាមូលហេតុមួយទៀត ។

ជីវប្រវត្តិរបស់ព្រះមហាកោដ្ឋិតត្ថេរ ដែលមានពោលទុកក្នុងអដ្ឋ-កថាមនោរថបូរណី និងអដ្ឋកថាបរមត្ថទីបនី អធិប្បាយសេចក្តីបាលី

គម្ពីរខុទ្ទកនិកាយ ថេរគាថា ថា ៖

ព្រះមហាកោដ្ឋិតត្ថេរ កើតនៅក្នុងត្រកូលមានវណ្ណៈល្អ នៅនគរហង្សវតី ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ។ លុះមាតា បិតាធ្វើកាលកិរិយាទៅ លោកបានទទួលនាទីជាអ្នកគ្រប់គ្រងថែរក្សា ទ្រព្យសម្បត្តិក្នុងត្រកូលជាបន្តមក ។ ថ្ងៃមួយ កុលបុត្រកោដ្ឋិតៈ ក្រឡេកឃើញពួកជនជាច្រើន ដែលនៅក្នុងនគរហង្សវតី មានការកាន់គ្រឿងសក្ការៈចូលទៅដើម្បីស្តាប់ព្រះធម៌ទេសនា ទើបគេរួមដំណើរទៅជាមួយមនុស្សទាំងនោះ ។ ក្នុងថ្ងៃនោះ រាប់ថាជាជោគសំណាងល្អរបស់កុលបុត្រកោដ្ឋិតៈ បានឃើញព្រះបទុមុត្តរៈ ទ្រង់តែងតាំងភិក្ខុមួយរូប ទុកក្នុងតំណែងដ៏ប្រសើរ ផ្នែកខាងសម្រេចបដិសម្ភិទា ៤ ក្នុងព្រះពុទ្ធសាសនានេះ ទើបគិតថា យើងគួរបាននូវតំណែងដ៏ប្រសើរនេះ ក្នុងសម្នាក់ព្រះពុទ្ធអង្គណាមួយ នាកាលអនាគត ។ កាលចប់ព្រះធម៌ទេសនា មហាជននាំគ្នាត្រឡប់ទៅវិញហើយ ទើបកុលបុត្រនោះចូលទៅគាល់ ក្រាបទូលអារាធនាព្រះសុគតសាស្តា ព្រមទាំងភិក្ខុសង្ឃទាំងឡាយ ឲ្យទទួលភិក្ខារបស់ខ្ញុំក្នុងថ្ងៃស្អែក ។ ព្រះបទុមុត្តរសម្ពុទ្ធ ទ្រង់ទទួលការអារាធនារបស់កុលបុត្រនោះដោយតុណ្ហីភាព ។ កាលកុលបុត្រនោះជ្រាបថា ព្រះអង្គទ្រង់ទទួលហើយ ទើបក្រាបថ្វាយបង្គំលាត្រឡប់ទៅផ្ទះវិញ ។

កាលបើគេទៅដល់ផ្ទះហើយ ប្រញាប់ប្រញាល់ចាត់ចែងអាសនៈ

សម្រាប់ព្រះពុទ្ធ និងភិក្ខុសង្ឃទាំងឡាយ ដោយប្រើកម្រាលផ្កា និង សំពត់ជាដើម ប្រដាប់ប្រដាយ៉ាងល្អស្អាត ដោយនៅធ្វើរហូតទាល់តែ យប់ ។ ចំណែករឿងចង្ហាន់ ប្រាប់មនុស្សដទៃៗ ឲ្យជួយរៀបចំចម្អិន ជាចង្ហាន់ដ៏ប្រសើរទុករង់ចាំប្រគេនព្រះបទុមុត្តរៈ និងភិក្ខុសង្ឃយ៉ាងល្អ ។ ថ្ងៃស្អែកឡើង ភិក្ខុសង្ឃប្រមាណមួយសែនរូប មានព្រះបទុមុត្តរៈទ្រង់ ជាប្រធាន ព្រះអង្គនិមន្តមកដល់ផ្ទះកុលបុត្រនោះរៀបរយហើយ ពពួក ញាតិមិត្ត និងសម្លាញ់ទាំងឡាយ ជួយគ្នាប្រគេនចង្ហាន់ព្រះបទុមុត្តរៈ និង ភិក្ខុសង្ឃ ។ ពេលឆាន់រួចជាស្រេចហើយ កុលបុត្រនោះគិតឡើងថា ៖

យើងប្រាថ្នានូវតំណែងនោះ ប៉ុន្តែការដែលយើងធ្វើទានត្រឹមតែ មួយថ្ងៃប៉ុណ្ណេះ មិនសមគួរនឹងតំណែងនោះសោះ យើងនឹងត្រូវថ្វាយទាន ៧ ថ្ងៃ ទើបសមគួរដល់តំណែងដ៏ខ្ពង់ខ្ពស់នោះ ។ កាលបើកុលបុត្រនោះ គិតដូច្នេះហើយ ក៏បានថ្វាយមហាទានដល់ភិក្ខុប្រមាណមួយសែនរូប មាន ព្រះពុទ្ធជាព្រះប្រធាន គ្រប់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ដែលជាថ្ងៃចុងក្រោយ ទើបបញ្ជាឲ្យបើកឃ្លាំងសំពត់ចេញ ជ្រើសរើសយកតែសំពត់សាច់ រលោងៗ ដែលល្អមធ្វើជាត្រៃចីវរបាន មកប្រគេនចំពោះ ព្រះបទុមុត្តរៈ និងភិក្ខុសង្ឃគ្រប់ៗ រូប រួចជាស្រេចហើយ ទើបកុលបុត្រនោះតាំង បណិធាន គឺសេចក្តីប្រាថ្នាថា បពិត្រព្រះសុគតសាស្តា ភិក្ខុរូបណា ដែល បានទទួលតំណែងដ៏ប្រសើរ រាប់ពីថ្ងៃនោះមកដល់ថ្ងៃ នេះបាន ៧ ថ្ងៃ

សូមឲ្យខ្ញុំព្រះអង្គបានបួសក្នុងព្រះពុទ្ធសាសនា ក្នុងកាលជាអនាគត ឲ្យបានតំណែងដ៏ប្រសើរ ផ្នែកខាងសម្រេចបដិសម្ភិទា ៤ ដូចភិក្ខុរូបនោះដែរ ។ ព្រះបទុមុត្តរៈ ទ្រង់ពិចារណាឃើញសេចក្ដីប្រាថ្នារបស់កុលបុត្រនោះ នឹងត្រូវបានសម្រេច ទើបទ្រង់ព្យាករថា ក្នុងទីបំផុតមួយសែនកប្បរាប់តអំពីកប្បនេះទៅ សេចក្ដីប្រាថ្នារបស់អ្នក នឹងបានសម្រេចក្នុងសាសនារបស់ព្រះសមណគោតម ដែល ទ្រង់កើតឡើងក្នុងលោក ។ ចំណែកប្រវត្តិ របស់ព្រះមហាកោដ្ឋិតត្ថេរ មានប្រាកដក្នុងបាលីគម្ពីរខុទ្ទកនិកាយ អបទាន ដោយលោកជាអ្នកតំណាល ដល់ជីវប្រវត្តិរបស់ខ្លួនឯងទុកថា ៖

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាអ្នកប្រាជ្ញ ទ្រង់ជាក់ច្បាស់នូវលោកទាំងអស់ មានចក្ខុកើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ប្រទានឱវាទ ញុំាំងសត្វឲ្យជីងចម្លងសព្វសត្វ ញុំាំងពពួកជនច្រើនឲ្យឆ្លង ទ្រង់អនុគ្រោះ មានសេចក្ដីករុណា ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង បានញុំាំងពពួកតិរ្ថិយទាំងអស់ ដែលមកប្រជុំគ្នា ឲ្យតាំងនៅស៊ប់ក្នុងសីល ៥ ។ សាសនានេះឯង មិនរឹកររ សូន្យចាកពួកតិរ្ថិយ វិចិត្រដោយព្រះអរហន្តទាំងឡាយជាបុគ្គលស្ទាត់ជំនាញ ប្រកបដោយតាទិគុណ ។ ព្រះមហាមុនីនោះ មានកំពស់ ៥៨ ហត្ថ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មាន

លក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ មានព្រះជន្មាយុមួយសែនឆ្នាំ កាល ព្រះអង្គគង់ព្រះជន្មនៅ បានញ៉ាំងពពួកជនច្រើនឲ្យឆ្លងចាកលោក ។ កាលនោះ ខ្ញុំកើតជាព្រាហ្មណ៍ ក្នុងនគរហង្សវតី ជាអ្នកដល់នូវត្រើយនៃវេទ បានចូលទៅជិតព្រះពុទ្ធជាកំពូល នៃសត្វលោកទាំងពួង ហើយស្តាប់ធម្មទេសនា ។ គ្រានោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់តាំងសាវកមួយអង្គ ដែលបែកធ្លាយបដិសម្ភិទា ជាអ្នកឈ្លាសវៃក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ក្នុងតំណែងជាឯតទគ្គៈ កាលនោះ ខ្ញុំបានឮនូវតំណែងនោះហើយ ក៏មានចិត្តរីករាយ បានញ៉ាំងព្រះជិនស្រីដ៏ប្រសើរ ព្រមទាំងសាវកឲ្យឆាន់អស់ ៧ ថ្ងៃ ។ ខ្ញុំញ៉ាំងព្រះពុទ្ធដូចជាសាគរ ព្រមទាំងសិស្សឲ្យស្លៀកសំពត់រួចខ្ញុំក្រាបទៀបព្រះបាទមូល ប្រាថ្នាតំណែងនោះ ។

លំដាប់នោះ ព្រះពុទ្ធជាកំពូលក្នុងលោក ទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរមើលព្រាហ្មណ៍ដ៏ខ្ពស់ទ្រុំ ក្រាបទៀបបាទមូល មានរស្មីពួដ៏ពោះ ដូចផ្កាឈូក ព្រាហ្មណ៍នេះ បរិបូណ៌ដោយសទ្ធា ចាគៈ និងសទ្ធម្មស្សវនៈនោះ ប្រាថ្នានូវតំណែងនៃភិក្ខុ របស់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រាហ្មណ៍នេះជាអ្នកដល់នូវសេចក្តីសុខ ក្នុងទីទាំងពួង អន្ទោលទៅក្នុងភពតូចភពធំ រមែងបានតំណែងនោះ ដូចបំណង ក្នុងកាលជាអនាគត ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានមហាបុរសសម្ភព ក្នុងត្រកូលស្តេចឱក្កាកៈ នឹងបានជាព្រះសាស្តាក្នុងលោក ព្រះនាមគោតម ។ ព្រាហ្មណ៍

នេះ នឹងបានជាធម្មទាយាទ ជាឱរស ជាធម្មនិមិត្ត របស់ព្រះគោតមនោះ នឹងបានជាសាវ័ក នៃព្រះសាស្ដា មាននាមថា កោដ្ឋិតៈ ។ កាលនោះ ខ្ញុំឮព្រះពុទ្ធព្យាករនោះហើយ ក៏មានចិត្តរីករាយ ប្រកបដោយមេត្តា មានប្រាជ្ញាខ្ជាប់ខ្ជួន បានបម្រើព្រះជិនស្រី ដរាបដល់អស់ជីវិត ។ ដោយផលនៃកុសលកម្មនោះផង ដោយការតម្កល់ទុក នូវសេចក្ដីប្រាថ្នានោះផង ខ្ញុំលុះលះបង់រាងកាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងស្ថានតាវត្តិង្ស ។ ខ្ញុំបានសោយរាជ្យ ជាស្ដេចទេវតាអស់ ៣០០ ដង បានជាស្ដេចចក្រពត្តិអស់ ៥០០ ដង បានជាព្រះរាជាចំពោះ ប្រទេសមួយៗ រាប់ជាតិមិនបាន មានសេចក្ដីសុខគ្រប់ជាតិ អស់មួយសែនកប្ប និងក្នុងមួយសែនកប្បនោះ បានកើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ គឺក្សត្រ និងព្រាហ្មណ៍ប៉ុណ្ណោះ ។

ក្នុងជាតិចុងក្រោយនេះ ខ្ញុំបានមកកើតក្នុងវណ្ណៈព្រាហ្មណ៍ ដែលមានធនធានច្រើន ទាំងចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសម្រេចជាព្រះអរហន្ត ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយផ្នែកខាងបដិសម្ភិទា ៤ បានដុតកិលេស ដកចោលភពទាំងពួង និងកាត់គ្រឿងចងចោលអស់ហើយ ។ ព្រះមហាកោដ្ឋិតត្ថេរ បានពោលគាថាទុក ក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា មានសេចក្ដីថា ៖

បុគ្គលអ្នកស្ងប់រម្ងាប់ វៀរចាកបាប ពោលពាក្យដោយឧបាយ

ប្រាជ្ញា ជាអ្នកមិនរវើរវាយ តែងកម្ចាត់បង់ នូវបាបធម៌ចាកខន្ធសន្តាន ដូចខ្យល់បក់ផ្ដាច់ស្លឹកឈើ ។

ការទ្រទ្រង់ជន្មាយុសង្ខារ របស់ព្រះមហាកោដ្ឋិតត្ថេរ មកដល់កាលដ៏សមគួរហើយ លោកក៏រំលត់ខន្ធបរិនិព្វានទៅ ។

***( ជីវប្រវត្តិរបស់ព្រះមហាកោដ្ឋិតត្ថេរ ចប់ )***

# ✍ ជីវប្រវត្តិរបស់ព្រះមហាបន្ថកត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងឈ្លាសក្នុងការបើកប្រាជ្ញា "

ភាពប្រសើរបំផុត របស់ព្រះអរិយសាវក ដែលគួរដល់ការគោរព និងលើកតម្កើងរបស់សព្រហ្មចារីទាំងឡាយ ឬថាជាអ្នកឈ្លាសវៃក្នុងបញ្ញាវិវដ្ដៈ ទាំងជាកត្តុទ្ទេសក៍ និងជាអសីតិមហាសាវកមួយរូបក្នុងព្រះពុទ្ធសាសនានេះ បានដល់ព្រះមហាបន្ថកត្ថេរ ។

ជីវប្រវត្តិរបស់ព្រះមហាបន្ថកត្ថេរ មាននៅក្នុងអដ្ឋកថាមនោរថ-បូរណី និងអដ្ឋកថាធម្មបទ នៃអប្បមាទវគ្គ ដូចមានតំណាល ក្នុងរឿងព្រះចូឡបន្ថកៈថា ៖

ព្រះសុគតសាស្ដា ទ្រង់ត្រាស់ប្រារព្ធដល់ព្រះមហាបន្ថកៈ កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុង វត្តវេឡុវ័នមហាវិហារ គឺព្រៃឬស្សីដែលព្រះបាទពិម្ពិសារកសាងថ្វាយក្នុងក្រុងរាជគ្រឹះ ។ កាលនោះមានសេដ្ឋីធីតាម្នាក់នៃត្រកូលរបស់ធនសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ។ មាតាបិតាតែងតែមានការប្រុងប្រយ័ត្ន ដើម្បីការពារភាពអន់ថយ កិត្តិយស កេរ្តិ៍ឈ្មោះ ដែលនឹងកើតមានដល់ត្រកូល ព្រោះការប្រព្រឹត្តិមិនល្អរបស់កូនស្រី ពេលដែលសេដ្ឋីធីតានោះធំពេញវ័យហើយ មាតាបិតាក៏បានឲ្យទៅនៅលើប្រាសាទជាន់ទី ៧ មិនឲ្យចុះមកក្រោម ឬចេញទៅក្រៅផ្ទះឡើយ។

មនុស្សយើងប្រសិនបើ ពេញចិត្តធ្វើអំពើអាក្រក់ហើយ ក៏មិនអាចនឹងហាមឃាត់បាន សេដ្ឋីធីតានោះ មាតាបិតាចិញ្ចឹមបានតែចំពោះរូបកាយប៉ុណ្ណោះ ចំណែកចិត្តមិនអាចថែរក្សា ឬគ្រប់គ្រង បានឡើយ ។

សេដ្ឋីធីតានោះ ជាអ្នកមានចិត្តគិតរើរវាយចំពោះបុរស ដោយភាពស្រើនក្នុងវ័យក្រមុំ ទើបកើតចិត្តប្រតិព័ទ្ធដល់បុរសជានិច្ច ៗ ក្នុងកាលជាទីបំផុត នាងក៏ស្រឡាញ់គ្នាជាមួយនឹងទាសៈក្នុងផ្ទះរបស់ខ្លួន ហើយនាងកើតការខ្លាចថា នឹងមានអ្នកដទៃដឹងរឿងរបស់ខ្លួន ថែមទាំងខ្លាចមាតាបិតាដាក់ទោសចំពោះខ្លួន ទើបនិយាយប្រាប់ដល់ទាសៈ ដែលជាស្វាមីរបស់ខ្លួនថា យើងមិនអាចនៅក្នុងផ្ទះនេះតទៅទៀតបានទេ ប្រសិនបើមាតាបិតារបស់យើងដឹងដល់ទោសកំហុសនេះ យើងទាំងពីរនាក់ប្រាកដជានឹងស្លាប់ទាំងអស់គ្នា ដូច្នេះយើងនឹងទៅនៅទីកន្លែងដទៃចុះ ។ កាលបើអ្នកទាំងពីរនាក់សម្រេចចិត្តយ៉ាងនេះហើយ បានជួយគ្នាជ្រើសរើសយកទ្រព្យដែលតម្លៃនៅក្នុងផ្ទះរបស់នាង វត្ថុណាដែលប្រើជាប្រយោជន៍បានក៏នាំយកវត្ថុនោះទៅ ហើយនាំគ្នាចេញទៅតាមទ្វារទិសឧត្តរ ដោយគិតថា យើងនឹងទៅនៅទីកន្លែងណាដែលគេមិនស្គាល់យើង ហើយនាំគ្នាធ្វើដំណើរទៅរហូតបានទីស្នាក់សមរម្យ ហើយរស់នៅជាស្វាមីភរិយាតទៅ ។ កាលបើអ្នកទាំងពីរនោះ ស្នាក់អាស្រ័យរួមប្រពៃណីជាមួយគ្នា សេដ្ឋីធីតានោះក៏មានគភ៌ ។ កាលបើគភ៌របស់នាងជិតគ្រប់ខែហើយ នាងក៏បាន

និយាយជាមួយនឹងស្វាមីថា គភ៌របស់ខ្ញុំជិតគ្រប់ខែហើយ ប៉ុន្តែការប្រសូតិបុត្រក្នុងស្ថានទីដែលមិនមានញាតិសន្តាន រមែងជាការលំបាកណាស់ យើងទាំងពីរនាក់គួរត្រឡប់ទៅផ្ទះវិញ ទៅរកមាតាបិតារបស់យើង ។

បុរសដែលជាស្វាមី ពិចារណាឃើញការប្រព្រឹត្តិទៅដែលនឹងត្រូវកើតឡើង ទើបរករឿងមកនិយាយប្រកែក ដើម្បីពន្យាពេលទុកថា :

ចាំថ្ងៃនេះ ចាំថ្ងៃស្អែក ដូច្នេះជាដើម គេតែងនិយាយពន្យាពេលមួយថ្ងៃៗ ទាំងនេះ ដោយខ្លាចថា ប្រសិនបើយើងត្រឡប់ទៅវិញ នឹងត្រូវមាតាបិតាក្មេកសម្លាប់ ។ សេដ្ឋីធីតាមានការគិតថា ស្វាមីរបស់យើងនេះល្ងង់ណាស់ មិនហ៊ានត្រឡប់ទៅផ្ទះវិញ ព្រោះខ្លួនជាមនុស្សមានទោសកំហុសច្រើន ធម្មតាមាតាបិតា មានបំណងអនុគ្រោះដល់កូនប្រុសស្រីជានិច្ច ណ្ហើយ គេមិនទៅស្រេចតែគេចុះ តែយើងនឹងទៅ ។ កាលបើបុរសដែលជាស្វាមីមិននៅផ្ទះ ចេញទៅធ្វើការយ៉ាងណានីមួយ សេដ្ឋីធីតាចាត់ចែងទុកដាក់អង្គរបស់របរខាងក្នុងផ្ទះ រួចជាស្រេចហើយ បានផ្តាំមនុស្សជិតខាងឲ្យដឹងថា ខ្លួននឹងត្រឡប់ទៅរកឪពុកម្តាយនៅឯស្រុកកំណើតរបស់ខ្លួន ហើយបានធ្វើដំណើរទៅ ។

ចំណែកបុរសដែលជាស្វាមី ត្រឡប់មកដល់ផ្ទះវិញ មិនឃើញភរិយា ទើបសួរញាតិជិតខាង ក៏បានដឹងថា ភរិយារបស់ខ្លួនត្រឡប់ទៅរកឪពុកម្តាយនៅឯស្រុកកំណើតហើយ ទើបប្រញាប់ប្រញាល់ធ្វើដំណើរ

ទៅតាម បានទៅទាន់គ្នាក្នុងពាក់កណ្តាលផ្លូវ ។ ហេតុដែលបុរសជាស្វាមីតាមទៅទាន់ភរិយា ព្រោះតែភរិយាបានប្រសូតបុត្រនៅក្នុងពាក់កណ្តាលផ្លូវនោះ ដែលនៅមិនទាន់ទៅដល់ផ្ទះមាតាបិតារបស់ខ្លួនផង ។

កាលបុរសជាស្វាមីទៅទាន់ហើយ ក៏ឃើញភរិយាប្រសូតបុត្ររួចជាស្រេច ក៏សប្បាយចិត្តដែលបានកូន ទើបសួរភរិយាថា កូនរបស់យើងប្រុស ឬស្រី ភរិយាតបថា ចាស កូនរបស់យើង ប្រុស ស្វាមីសួរតទៅទៀតថា យើងធ្វើយ៉ាងណាល្អក្នុងពេលនេះ ។ ភរិយាពោលថាយើងគួរនឹងត្រឡប់ទៅផ្ទះរបស់យើងវិញ ល្អជាង មិនបាច់ទៅផ្ទះឪពុកម្តាយយើងទេ ។ ការដែលនឹងត្រឡប់ទៅផ្ទះរបស់ឪពុកម្តាយ ដើម្បីប្រយោជន៍ក្នុងការប្រសូតិបុត្រប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះ យើងបានប្រសូតបុត្ររួចហើយក្នុងពាក់កណ្តាលផ្លូវ ដូច្នោះ ពួកយើងនាំគ្នាត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនល្អជាង ថាហើយ នាំគ្នាត្រឡប់ទៅផ្ទះវិញ និងបានដាក់ឈ្មោះឲ្យកូនប្រុសថា បន្ថកៈ ។ ការដាក់ឈ្មោះឲ្យទារក ដែលកើតថ្មីៗ នោះថា បន្ថកៈ ព្រោះថា ជាអ្នកកើតក្នុងពាក់កណ្តាលផ្លូវ ឈ្មោះនេះចាត់ជានេមិត្តកនាម ធ្វើឲ្យបុគ្គលទាំងឡាយត្រូវព្រមទទួលក្នុងហេតុផល នៃការដាក់ឈ្មោះឲ្យដល់បុត្រនោះ ។ កាលបើអ្នកទាំងពីរនោះ រស់នៅជាមួយគ្នា ចេះស្គាល់តួនាទីរបស់ខ្លួន តមកមិនយូរប៉ុន្មានភរិយាក៏មានគភ៌ជាលើកទីពីរទៀត ។ កាលបើគភ៌ជិតគ្រប់ខែហើយ ទើបនិយាយប្រាប់

ដល់បុរសដែលជាស្វាមីថា នឹងមានបំណងទៅប្រសូតបុត្រនៅឯផ្ទះរបស់ឪពុកម្តាយ ដូចពេលមុនដែរ ប៉ុន្តែស្វាមីមិនព្រមជូនទៅ ដោយខ្លាចឪពុកម្តាយក្មេកដាក់ទោស ទើបហាមភរិយាមិនឲ្យទៅ ចំណែកភរិយាមិនព្រមតាមពាក្យហាមរបស់ស្វាមីទេ ក្រោយមកស្វាមីទៅប្រកបការងារក្រៅផ្ទះ ភរិយាទើបរត់ទៅទៀត មកដល់ពាក់កណ្តាលផ្លូវ ក៏បានប្រសូតបុត្រជាលើកទីពីរ ក្នុងវវាងផ្លូវដូចកាលមុនទៀត ។ កាលស្វាមីតាមមកទាន់ក្នុងវវាងផ្លូវ បានមកជួបភរិយាប្រសូតកូនរួចជាស្រេចហើយ ទើបសួរភរិយាថា កូនរបស់យើង ប្រុស ឬស្រី ភរិយាតបថា ចាស ជាកូនប្រុស ។

បុរសដែលជាស្វាមី ទើបនាំភរិយា និងកូនត្រឡប់មកផ្ទះរបស់ខ្លួនវិញ ក៏បានតាំងនាមថា បន្ថកៈ ដូចកូនបង ព្រោះកើតនៅក្នុងវវាងផ្លូវដូចគ្នា ។ ពីរនាក់ស្វាមី និងភរិយាមានសេចក្តីប្រាថ្នាចង់ឲ្យឈ្មោះកូនទាំងពីរនោះប្លែកផ្សេងគ្នា ដើម្បីស្រួលហៅប្រើ ទើបដាក់ឈ្មោះឲ្យកូនបងថា មហាបន្ថកៈ ចំណែកកូនប្អូនដាក់ឈ្មោះឲ្យថា ចូឡបន្ថកៈ ។ ជនទាំងពីរនាក់នោះចិញ្ចឹមកូនរបស់ខ្លួន រហូតមានវ័យចម្រើនជាលំដាប់តមក ។ កូនដែលឈ្មោះថា មហាបន្ថកៈ កាលបើបានឮក្មេងដទៃៗ ស្រែកហៅអ្នកនោះអ្នកនេះថា អ៊ំ តា យាយជាដើម ប៉ុន្តែខ្លួនឯងមិនដែលធ្លាប់បានហៅនរណាៗ ដូច្នេះឡើយ ។ ថ្ងៃមួយ ទើបសួរមាតាថា អ្នកម៉ែៗ ក្មេងដទៃៗ គេតែងហៅអ្នកនេះអ្នកនោះថា តា យាយ តើញាតិរបស់យើង

មិនមាននៅកន្លែងនេះខ្លះទេឬ ? មាតាប្រាប់កូនថា កូនអើយ ក្នុងទីកន្លែងនេះ ញាតិរបស់យើងមិនមានទេ ប៉ុន្តែមាននៅក្នុងក្រុងរាជគ្រឹះឯណោះ លោកតារបស់កូន ឈ្មោះធនសេដ្ឋី ជាអ្នកដែលមានប្រជាជនស្គាល់គាត់ច្រើន មាតាប្រាប់ ពន្យល់ទៅតាមសេចក្តីពិត ។

កូនសួរថា ម៉ែៗ ព្រោះហេតុអ្វី ទើបពួកយើងមិនទៅនៅក្រុងរាជគ្រឹះ កាលមាតាបានស្តាប់ពាក្យសួររបស់មហាបន្ថកៈ ក្នុងសេចក្តីនេះរួចហើយ ទើបទៅជាស្រឡាំងកាំង ប្រែទឹកមុខសម្តែងអាការៈផ្លាស់ប្តូរទៅ មិនអាចនឹងឆ្លើយសំណួររបស់កូនបាន ដោយអាការៈដែលប្រាកដចេញមកនោះ ទើបពោលនឹងស្វាមីថា ប្រសិនបើមហាបន្ថកៈធំពេញវ័យបន្តិចទៀត គង់តែនឹងយល់បានថា ម៉ែរបស់យើង ដូចម្តេចត្រូវធ្វើទឹកមុខយ៉ាងនេះ ប៉ុន្តែដោយថានៅក្មេងពេក មិនទាន់ដឹងក្តី ទើបមិនយល់អាការៈនោះបាន ។ ប៉ុន្តែមហាបន្ថកៈ រំអុកចាំសួរជានិច្ច ទាំងដែលម៉ែព្យាយាមនិយាយគេចកែសេចក្តីទៅណាក៏ដោយ មហាបន្ថកៈរង់ចាំរំអុកត្អូញត្អែរដោយទឹកភ្នែក នៅចាំសួររឿយៗ ទាល់តែនាងអត់ទ្រាំមិនបាន ទើបប្រាប់ដល់ស្វាមីថា កូនប្រុសរបស់យើងចាំសួរធ្វើការរំខានចិត្តរបស់ខ្ញុំហួសប្រមាណ ខ្ញុំគិតស្មានយល់ថា ឪពុកម្តាយរបស់យើងបានឃើញពួកគេហើយ នឹងត្រូវសម្លាប់ពួកយើងទាំងពីរនាក់ក៏ដោយចុះ នឹងនាំយកកូនទាំងពីរនាក់របស់យើងទៅកាន់ត្រកូល នៃជីតារបស់ពួកគេ ។

បុរសដែលជាស្វាមី មានការព្រួយបារម្ភណាស់ មិនហ៊ានទឹងចូល ទៅជួបមុខឪពុកក្មេកម្ដាយក្មេកឡើយ ចំណែកកិរិយាក៏ដូចគ្នាដែរ មិនហ៊ានទៅជួបម៉ែឪ ប៉ុន្តែយើងនឹងនាំកូនទាំងពីរទៅ រកឧបាយយ៉ាងណានីមួយ ឲ្យកូនទាំងពីរបានជួបជីតា កិរិយាក៏យល់ព្រមគំនិតនេះដូចគ្នាដែរ ទើបសម្រេចចិត្តនាំកូនប្រុសទាំងពីរនាក់ ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ ប៉ុន្តែមិនហ៊ានចូលទៅកាន់ផ្ទះរបស់ធនសេដ្ឋីដែលជាបិតា ត្រឹមតែចូលទៅស្នាក់អាស្រ័យនៅក្នុងសាលាមួយខ្នង ដែលនៅក្បែរទ្វារក្រុង ។ មាតារបស់ក្មេងទាំងពីរ ឲ្យមនុស្សទៅជម្រាបដំណឹង ដល់មាតាបិតាបង្កើតរបស់ខ្លួនឲ្យជ្រាបថា ខ្លួនបាននាំកូនប្រុសទាំងពីរមកសួរសុខទុក្ខ ស្នាក់អាស្រ័យនៅសាលាក្បែរទ្វារក្រុង ទាំងនេះគង់នឹងជាការសាកល្បងមើលថា មាតាបិតានឹងថាយ៉ាងណា ។

មាតាបិតា ជ្រាបដំណឹងនោះហើយ មានការទឹងក្រោធយ៉ាងខ្លាំង ដែលកូនរបស់ខ្លួន ធ្វើឲ្យមានការអាប់កិត្តិយស ទើបនិយាយជាមួយអ្នកនាំដំណឹងមកថា ៖

បុគ្គលទាំងពីរនាក់នោះ បានធ្វើខុសចំពោះយើង គេមិនហ៊ាននឹងមកប្រឈមមុខជាមួយយើងបានទេ យ៉ាងហ្នឹងក៏ដោយចុះ ឲ្យពួកគេទាំងពីរនាក់ នាំយកទ្រព្យមួយចំនួនទៅចិញ្ចឹមជីវិត នៅជាមួយគ្នាតាមសប្បាយចុះ មិនត្រូវឲ្យចូលមកក្នុងផ្ទះរបស់យើងទេ ប៉ុន្តែត្រូវបញ្ជូនក្មេងទាំងពីរ

នាក់ ដែលមិនមានកំហុសមកឲ្យយើង ដើម្បីឲ្យទារកទាំងពីរនោះរស់នៅបានសុខ ។ ស្វាមីភរិយា សូម្បីមានសេចក្ដីស្រឡាញ់ចំពោះកូនទាំងពីរនាក់ មិនចង់ឲ្យកូនព្រាត់ប្រាសចេញអំពីខ្លួនក៏ដោយ ប៉ុន្តែដើម្បីអនាគតរបស់កូនទាំងពីរ ទើបសម្រេចចិត្តឲ្យកូនទាំងពីរ ទៅរស់នៅជាមួយជីតា ខ្លួនឯងព្រមទទួលយកទ្រព្យ ដែលមាតាបិតាបញ្ជូនមកឲ្យ ហើយប្រគល់ក្មេងទាំងពីរនាក់នោះ ឲ្យអ្នកបម្រើនាំយកទៅរស់នៅជាមួយជីតា ។

មហាបន្ថកៈ និងចូឡបន្ថកៈ បានចម្រើនធំពេញវ័យក្នុងត្រកូលរបស់ជីតាដែលជាសេដ្ឋី ប៉ុន្តែត្រូវធ្លាក់នៅក្នុងឋានៈជាក្មេងកំព្រាឪពុកម្ដាយ ខ្វះភាពកក់ក្ដៅ មានតែភាពស្រងេះស្រងោច មិនដូចជាក្មេងដទៃៗដែលនៅជាមួយមាតាបិតា ។ ចូឡបន្ថកៈ នៅជាក្មេងតូចនៅឡើយ មិនអាចនឹងទៅតាមជីតាបានដូចមហាបន្ថកៈទេ មហាបន្ថកៈជាទីស្រឡាញ់ពេញចិត្តរបស់ធនសេដ្ឋី ទៅណា មកណា តែងតែទៅតាម ទើបជាហេតុធ្វើឲ្យមហាបន្ថកៈទៅស្ដាប់ធម្មកថា របស់ព្រះសុគតសាស្ដាជាមួយនឹងជីតា នៅក្នុងវត្តវេឡុវ័នមហាវិហារជានិច្ច កាលបើមហាបន្ថកៈចូលទៅកាន់សម្នាក់ព្រះសម្ពុទ្ធជារឿយៗ ចិត្តទើបបង្អោនទៅដើម្បីបព្វជ្ជា ។ កាលបើមហាបន្ថកៈមានចិត្តគិតនឹងបព្វជ្ជា ទើបប្រាប់ដល់ជីតាថា លោកតាៗ ប្រសិនបើលោកតាអនុញ្ញាតឲ្យខ្ញុំបួស ខ្ញុំនឹងបួសនៅក្នុងសម្នាក់ព្រះមានព្រះភាគ ។

ធនសេដ្ឋី និយាយជាមួយនឹងចៅប្រុសដោយភាពសប្បាយចិត្តថា : មហាបន្ថកៈ ចៅនិយាយអ្វីយ៉ាងនេះ ការបព្វជ្ជារបស់ចៅ តាអរណាស់ ប្រសិនបើចៅអាចបួសបាន ចូរបួសចុះ កាលបើជីតាពោលដូច្នេះហើយ ទើបនាំមហាបន្ថកៈទៅកាន់សម្នាក់ព្រះលោកនាថ ព្រះភគវាទ្រង់ត្រាស់សួរថា គហបតី លោកនាំចៅមកពីណា ធនសេដ្ឋីក្រាបទូលថា បពិត្រព្រះសក្យមុនី ចៅរបស់ខ្ញុំមានសទ្ធាជ្រះថ្លា ចង់បួសក្នុងសម្នាក់ព្រះអង្គ ។ ព្រះមានព្រះភាគ កាលបើទ្រង់ជ្រាបបំណងរបស់ធនសេដ្ឋីនិងចៅដូច្នេះហើយ ទើបត្រាស់បញ្ជាឲ្យភិក្ខុមួយរូប ដែលមានប្រក្រតីបិណ្ឌបាតជាវត្តថា ម្នាលភិក្ខុ អ្នកចូរឲ្យក្មេងនេះបព្វជ្ជាចុះ ។ ភិក្ខុរូបនោះទទួលស្ដាប់ព្រះពុទ្ធដីកាហើយ ទើបឲ្យមហាបន្ថកៈបព្វជ្ជាភ្លាមៗ ។ ព្រះថេរៈបានប្រាប់ព្រះកម្មដ្ឋាន ដែលហៅថា តចបញ្ចកកម្មដ្ឋាន គឺការពិចារណាឃើញរាងកាយ ដែលមានសក់ រោម ក្រចក ធ្មេញ ស្បែកដល់មហាបន្ថកៈ ហើយទើបឲ្យបព្វជ្ជាជាសាមណេរ ។

សាមណេរមហាបន្ថកៈនោះ ជាអ្នកមានសេចក្ដីព្យាយាមរៀនសូធ្យនូវព្រះពុទ្ធវចនៈ កាលនឹងមានអាយុគ្រប់ម្ភៃឆ្នាំហើយ ក៏បានឧបសម្បទាជាភិក្ខុ ។ ការព្យាយាមនៅទីណា ការសម្រេចនៅទីនោះ ជាសេចក្ដីពិតដែលគ្រប់គ្នាត្រូវព្រមទទួល ព្រះមហាបន្ថកត្ថេរ លោកតាំងចិត្តចម្រើនសមណធម៌ ដោយសេចក្ដីព្យាយាមប្រឹងប្រែង មិនយូរប៉ុន្មាន

ក៏បានសម្រេចជាព្រះអរហន្ត កិច្ចរបស់សមណៈដែលទាក់ទងនឹងការប្រព្រឹត្តិព្រហ្មចរិយធម៌របស់លោក ក្នុងព្រះពុទ្ធសាសនា ដើម្បីធ្វើឲ្យដល់ទីបំផុតទុក្ខ បានធ្វើរួចហើយ ដោយអំណាចការព្យាយាមនោះឯង ។ ព្រះមហាបន្ថកត្ថេរ លោកជាអ្នកឈ្លាសវៃក្នុងបញ្ញាវិវដ្ដៈ គឺបញ្ញាដែលធ្វើឲ្យចូលដល់ព្រះនិព្វាន ដែលមានវដ្ដៈទៅប្រាសហើយ ។

ហេតុដូចដែលពោលមកនេះ ព្រោះលោកបានសម្រេចអរូបាវចរឈាន កាលបើចេញចាកអរូបឈានហើយ បានសម្រេចអរហន្តផល ជាព្រះអរិយបុគ្គលថ្នាក់ខ្ពង់ខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា តាមដែលលោកបែងចែកអរិយបុគ្គលជា ៤ ពួក គឺ ១ សោតាបត្តិផល ( ផលនៃការចូលដល់ក្រសែធម៌ ឬព្រះនិព្វាន ) ២ សកទាគាមិផល ( ផលរបស់អ្នកមកកើតម្ដងទៀត ) ៣ អនាគាមិផល ( ផលរបស់អ្នកមិនមកកើតទៀត ) ៤ អរហត្តផល ( ផល គឺភាពជាអ្នកមិនមានកិលេស ) ។

សេចក្ដីល្អជាផលការងាររបស់ចំណែករួម ដែលលោកមានចេតនាល្អ ដោយគិតថា យើងសមគួរនឹងទទួលភារៈមួយរបស់ភិក្ខុសង្ឃ គិតដូច្នេះហើយ ព្រះមហាបន្ថកៈ បានចូលទៅគាល់ព្រះភគវាក្រាបទូល ទទួលធ្វើជាភត្តុទ្ទេសក៍ ។ ក្រោយពីព្រះមហាបន្ថកៈ បានទទួលធ្វើជាភត្តុទ្ទេសក៍ហើយ បានចាត់ចែងភិក្ខុសង្ឃបានយ៉ាងល្អ មិនលុះក្នុងអគតិ មានឆន្ទាគតិជាដើម នេះជាតួយ៉ាងរបស់អ្នកបុណ្យដើម្បីបានបុណ្យ ។

មានសម្តែងនៅក្នុងគម្ពីរ អង្គុត្តរនិកាយ ឯកនិបាត ដែលពោល ទាក់ទងក្នុងតំណែងជាឯតទគ្គៈរបស់ព្រះមហាបន្ថកត្ថេរទុកថា ៖

ព្រះមហាបន្ថកត្ថេរ បានទទួលការលើកតម្កើងពីព្រះមានព្រះភាគ នៅក្នុងកណ្តាលបរិស័ទ ឲ្យជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាង ឈ្លាសវៃក្នុងបញ្ញាវិវដ្តៈ សម្តៅដល់ការផ្លាស់ប្តូរខាងផ្លូវនៃបញ្ញា បានដល់ ការឈ្លាសវៃក្នុងវិបស្សនា ។ តំណែងឯតទគ្គៈនេះ ជាកិត្តិយសដែល ប្រព្រឹត្តទៅ ដែលរកបានដោយលំបាក ព្រោះជាកិត្តិគុណដែលនឹងបាន មក ត្រូវជាអ្នកបរិបូណ៌ដោយបុណ្យបារមី ដែលត្រូវធ្វើឲ្យព្រមទាំងក្នុង បច្ចុប្បន្នជាតិ និងអតីតជាតិ ដែលរាប់ដោយវេលាយូរប្រមាណមួយ សែនកប្ប ។ ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិ ដូចបានពោលរួចមកហើយ រីឯ អតីតជាតិរបស់ព្រះមហាបន្ថកត្ថេរ លោកធ្លាប់បានកសាងសន្សំបុណ្យ កុសល រួមជាមួយនឹងព្រះចូឡបន្ថកត្ថេរដែលជាប្អូនប្រុស មានសម្តែង ក្នុងគម្ពីរខុទ្ទកនិកាយ អបទាន ក្នុងអដ្ឋកថាបរមត្ថទីបនី ដែលអធិប្បាយ សេចក្តីបាលីក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា និងអដ្ឋកថា មនោរថបូរណី មានសេចក្តីថា ៖

ក្នុងសម័យព្រះបទុមុត្តរសម្មាសម្ពុទ្ធ ព្រះថេរៈទាំងពីររូបនេះធ្លាប់ កើតជាកុដុម្ពិកជាបងប្អូនគ្នានៅក្នុងនគរហង្សវតី និងជាអ្នកមានសទ្ធាជ្រះ ថ្លាចំពោះព្រះមានព្រះភាគបទុមុត្តរៈ បានធ្លាប់ទៅស្តាប់ធម៌ទេសនា ព្រះ

បទុមុត្តរៈជារឿយៗ ។ នៅថ្ងៃមួយ កុដុម្ពិកពីរនាក់បងប្អូន បានឃើញព្រះបទុមុត្តរៈ ទ្រង់តែងតាំងភិក្ខុមួយរូបទុកក្នុងតំណែងដ៏ប្រសើរ ជាងភិក្ខុទាំងឡាយ ផ្នែកខាងឈ្លាសវៃក្នុងបញ្ញាវិវដ្ដៈ ។ កុដុម្ពិកទាំងពីរនាក់នោះនឹកចង់បានតំណែងដូច្នេះ ទើបមានការថ្វាយមហាទានដល់ភិក្ខុសង្ឃទាំងឡាយ មានព្រះបទុមុត្តរៈជាប្រធាន រហូត ៧ ថ្ងៃ ។

ក្នុងថ្ងៃទី ៧ កាលបើមានការថ្វាយមហាទានរួចជាស្រេចហើយ កុដុម្ពិកទើបថ្វាយបង្គំ ហើយតាំងនូវសេចក្ដីប្រាថ្នាចំពោះព្រះភក្ត្ររបស់ព្រះបទុមុត្តរៈថា បពិត្រព្រះសុគតជាសាស្ដា ព្រះអង្គទ្រង់តែងតាំងភិក្ខុមួយរូបណា ឲ្យជាអ្នកឈ្លាសវៃបំផុតក្នុងបញ្ញាវិវដ្ដៈ ៧ ថ្ងៃមុននោះ សូមឲ្យខ្ញុំករុណាបានតំណែងដូចភិក្ខុរូបនោះដែរ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងកាលជាអនាគត ។ ព្រះបទុមុត្តរៈ ទ្រង់ពិចារណាឃើញសេចក្ដីប្រាថ្នានៃកុដុម្ពិកនោះថា នឹងត្រូវបានសម្រេចតាមសេចក្ដីប្រាថ្នា ទើបទ្រង់ព្យាករថា ការប្រាថ្នារបស់អ្នក នឹងបានសម្រេចក្នុងសាសនារបស់ព្រះសមណគោតម ដែលទ្រង់បានឧប្បត្តិឡើងក្នុងលោកក្នុងរយៈពេល មួយសែនកប្បខាងមុខទៀតនេះ ។ កុដុម្ពិកពីរនាក់បងប្អូនសប្បាយចិត្តណាស់ ដូចនឹងបានសម្រេចក្នុងថ្ងៃស្អែក ឬខានស្អែកនេះ ។ តមក កុដុម្ពិកពីរនាក់បងប្អូន មិនបានលះបោលក្នុងការធ្វើសេចក្ដីល្អឡើយ ក្នុងពេលដែលព្រះបទុមុត្តរៈទ្រង់មានព្រះជន្មនៅ បានធ្វើកុសល-

កម្មជារឿយៗ សូម្បីព្រះបទុមុត្តរៈស្តេចរំលត់ខន្ធបរិនិព្វានទៅហើយ ក៏នៅតែធ្វើការបូជាព្រះចេតិយ ដែលបញ្ចុះព្រះបរមសារីរិកធាតុដោយផ្កាមាស ។ ផលនៃការកសាងបុណ្យកុសលផ្សេងៗ ទុកមក កុដុម្ពិកទាំងពីរនាក់ កាលអស់ជីវិតទៅហើយ បានត្រាច់រង្គាត់ទៅក្នុងមនុស្សទេវតារហូតមួយសែនកប្ប ។

លុះមកដល់ពុទ្ធកាល នៃព្រះសមណគោតមបរមគ្រូរបស់យើងនេះ លោកត្រឡប់មកជាចៅរបស់ធនសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ ។ ក្នុងទីបំផុតលោកបានចូលមកកាន់ផ្នួស បួសក្នុងព្រះពុទ្ធសាសនា បានទទួលនូវតំណែងដ៏ខ្ពង់ខ្ពស់ថា ជាអ្នកឈ្លាសវៃក្នុងបញ្ញាវិវដ្ដៈ បានដល់ឈ្លាសវៃក្នុងវិបស្សនា សំដៅដល់ជាអ្នកឈ្លាសវៃ ក្នុងការប្រឈមចុះកាន់វិបស្សនាភាវនា ជាអ្នកឈ្លាសវៃក្នុងការសង្ខេបអារម្មណ៍ និងជាអ្នកឈ្លាសវៃក្នុងការកំណត់អារម្មណ៍ រួមសេចក្ដីថា ជាអ្នកឈ្លាសវៃក្នុងការផ្លាស់ប្ដូរខាងបញ្ញា ។ ថ្ងៃមួយ ព្រះមហាបន្ថកៈ នឹកដល់សេចក្ដីបដិបត្តិរបស់លោក បានពោលគាថា ដែលមានប្រាកដនៅក្នុងបាលីគម្ពីរខុទ្ទកនិកាយ ថេរគាថា ថា ៖

កាលណាខ្ញុំឃើញព្រះសាស្ដា ព្រះអង្គគ្មានភ័យអំពីទីណាជាដំបូងក្នុងកាលនោះ សេចក្ដីសង្វេគក៏មានដល់ខ្ញុំ ព្រោះឃើញព្រះសាស្ដា ជាឧត្តមបុរស ។ អ្នកណា ប្រាទសិរីដែលមករកខ្លួនដោយដៃ ឬជើង អ្នក

នោះឈ្មោះថា ញ៉ាំងព្រះសាស្តាបែបនេះឲ្យត្រេកអរ ហើយប្រាសចាក សេចក្តីត្រេកអរវិញ ។ ក្នុងកាលនោះ ខ្ញុំលះបោលកូន និងប្រពន្ធផង ទ្រព្យ និងស្រូវផង គោរសេក់ និងពុកចង្កា ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបរិបូណ៌ដោយសិក្ខា និងសាជីវៈ សង្រួមក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នក មិនចាលចាញ់កិលេស តែងនមស្ការព្រះសម្ពុទ្ធ សម្រាន្តនៅ ។ ខណៈ នោះសេចក្តីតាំងចិត្ត ខ្ញុំបានតម្កល់ហើយថា កាលបើខ្ញុំមិនទាន់ដកសរ គឺ តណ្ហាបានទេ ខ្ញុំមិនអង្គុយសូម្បីមួយរំពេច ។ អ្នកចូរមើលសេចក្តីព្យា-យាម និងការប្រឹងប្រែងរបស់ខ្ញុំនោះ យ៉ាងនេះ វិជ្ជា ៣ ខ្ញុំបានសម្រេច ហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ ខ្ញុំដឹងនូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំក៏ បានជម្រះហើយ ខ្ញុំជាព្រះអរហន្ត គួរទទួលនូវទក្ខិណាទាន មានចិត្តរួច ស្រឡះហើយ មិនមានឧបធិ ។ លំដាប់នោះ ក្នុងកាលរាត្រីអស់ទៅ ព្រះអាទិត្យក៏រះឡើង ខ្ញុំបានធ្វើតណ្ហាទាំងអស់ឲ្យរីងស្ងួត ហើយអង្គុយ ដោយភ្នែន ។

កាលព្រះមហាបន្ថកត្ថេរ លោកបានបំពេញបុណ្យកុសល ទាំង ជាប្រយោជន៍ខ្លួននិងជាប្រយោជន៍សាធារណៈមកជាច្រើនហើយ មកដល់ កាលដ៏សមគួរ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅ ។៚

( ជីវប្រវត្តិរបស់ព្រះមហាបន្ថកត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះរាធត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងជាអ្នកឈ្លាសវៃក្នុងបដិភាណ "

*ព្រះរាធត្ថេរ ជាព្រះអរហន្តសាវ័ក លោកចាត់ចូលនៅក្នុងអសីតិមហាសាវ័ក ៨០ រូប ថែមទាំងជាអ្នកមាននិស្ស័យពោលអប់រំបានងាយ នេះជាលក្ខណៈប្រចាំខ្លួនរបស់លោក ទាំងបានទទួលការតម្កើងពីព្រះបរមសាស្ដាថា ៖*

*ម្នាលភិក្ខុទាំងឡាយ រាធៈជាឯតទគ្គៈ គឺជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ជាអ្នកឈ្លាសវៃក្នុងបដិភាណ ។*

*ជីវប្រវត្តិរបស់ព្រះរាធត្ថេរ មានសេចក្ដីពិស្ដារ នៅក្នុងអដ្ឋកថាមនោរថបូរណី ដែលអធិប្បាយសេចក្ដីបាលីក្នុងគម្ពីរខុទ្ទកនិកាយ ឯកនិបាត បានពណ៌នាដល់ការកសាងសន្សំបុណ្យកុសលរបស់លោក ដូចមានរឿងតំណាលពោលទុកថា ៖*

*ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ព្រះរាធត្ថេរបានកើតនៅក្នុងត្រកូលមួយ នៅក្នុងនគរហង្សវតី ។ ថ្ងៃមួយ លោកបានទៅស្ដាប់ធម៌ទេសនារបស់ព្រះបទុមុត្តរៈ ក៏កើតសទ្ធាជ្រះថ្លាយ៉ាងក្រៃលែង ក៏បានឃើញព្រះបទុមុត្តរៈ ទ្រង់ប្រកាសតែងតាំងភិក្ខុមួយរូបជាឯតទគ្គៈ ផ្នែកខាងឈ្លាសវៃក្នុងបដិភាណ ។ ក៏កើតមានការពេញចិត្តក្នុងតំណែងនោះ*

លោកទើបរៀបចំថ្វាយមហាទានដល់ភិក្ខុសង្ឃ និងបូជាព្រះបទុមុត្តរៈ ដោយគ្រឿងសក្ការៈដ៏មានតម្លៃជាច្រើន ដើម្បីប្រាថ្នានូវតំណែងនោះ ។

កាលបើលោកបានធ្វើអធិការកុសលយ៉ាងនេះហើយ តាំងសេចក្តីប្រាថ្នាថា សូមឲ្យខ្ញុំព្រះករុណាបានជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងឈ្លាសវៃក្នុងបដិភាណ ក្នុងព្រះសាសនានៃព្រះពុទ្ធអង្គណាទីមួយនាអនាគតកាល ហើយតាំងចិត្តប្រតិបត្តិចំពោះព្រះបទុមុត្តរៈទាល់តែអស់ជីវិត ។ ពេលដែលលោកស្លាប់ពីជាតិនេះ បានទៅកើតក្នុងទេវលោក លុះមកដល់ពុទ្ធកាលរបស់ព្រះវិបស្សី លោកបានមកកើតជាមនុស្ស និងបានថ្វាយផ្លែស្វាយដល់ព្រះវិបស្សី ហើយទៅកើតក្នុងទេវលោក និងមនុស្សលោក តទៅទៀតរហូតអស់កាលដ៏យូរ ។ ចំណែកក្នុងគម្ពីរខុទ្ទកនិកាយ អបទាន បានពោលដល់អតីតជាតិរបស់ព្រះរាធត្ថេរទុកថា បន្ទាប់អំពីបានធ្វើសេចក្តីល្អរួចហើយ ដោយអំណាចផលបុណ្យនោះ បានកើតជាព្រះឥន្ទ្រ ៣០០ ជាតិ កើតជាស្តេចចក្រពត្តិ ៥០០ ជាតិ និងកើតជាព្រះរាជារាប់ជាតិមិនអស់ ។ កាលមកដល់សម័យនៃព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ស្តេចឧប្បត្តិឡើងក្នុងលោកហើយ កុលបុត្រនោះត្រឡប់មកកើតជាបុត្ររបស់ព្រាហ្មណ៍ ជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ នៅក្នុងក្រុងរាជគ្រឹះ មានឈ្មោះថា រាធៈ ។

កាលបើរាធមាណពធំពេញវ័យហើយ មានដំណើរជីវិតដូចគ្នានឹង

មនុស្សស្រោមញ្ញទាំងឡាយ គឺមានភរិយា និងបុត្រ ទាំងគ្រប់គ្រងផ្ទះដែលរស់នៅយ៉ាងមានសេចក្ដីសុខមួយរយៈនៃជីវិត ក្នុងវ័យដែលមានកម្លាំងមាំមួន ប្រកបអាជីពចិញ្ចឹមបុត្រភរិយាបានយ៉ាងសប្បាយ ។ ប៉ុន្តែកាលរាធព្រាហ្មណ៍មានអាយុឈានចូលកាន់វ័យជរា រាងកាយក៏ចាប់ផ្ដើមថមថយ អន់កម្លាំង កិច្ចការដែលធ្លាប់ធ្វើ ក៏ធ្វើមិនកើត ទីបំផុតត្រូវភរិយានិងបុត្របណ្ដេញចេញពីផ្ទះ ដោយយល់ថា រាធព្រាហ្មណ៍ធ្វើការរកស៊ីមិនកើត ។ រឿងរបស់ព្រះរាធត្ថេរ ក្រៅពីបានពោលទុកក្នុងអដ្ឋកថាមនោរថបូរណី នៅមានពោលទុកក្នុងគម្ពីរធម្មបទ នៃបណ្ឌិតវគ្គ មានសេចក្ដីថា ៖

រាធព្រាហ្មណ៍ កាលគេបណ្ដេញចេញពីផ្ទះ សភាពប្រែក្លាយមកជាអ្នកកំសត់គ្មានទីពឹង ទើបគិតឃើញក្នុងការប្រព្រឹត្តិទៅ ក្នុងជីវិតថា យើងគួរទៅនៅអាស្រ័យចិញ្ចឹមជីវិត នៅជាមួយភិក្ខុសង្ឃ ឯវត្តវេឡុវ័ន ប្រសិនបើមានឱកាសល្អ ដែលអាចនឹងបួសបាន យើងនឹងបួសក្នុងព្រះពុទ្ធសាសនានេះ ។ កាលបើលោកគិតដូច្នេះហើយ ទើបដើរទៅកាន់វត្តវេឡុវ័ន ដើម្បីសូមបដិបត្តិបម្រើភិក្ខុសង្ឃទាំងឡាយ ដោយធ្វើនាទីប្រគេនទឹកលុបមុខ ទឹកឆាន់ ជម្រះស្មៅ បោសសំអាតកុដិ និងបរិវេណផ្សេងៗ ។ ចំណែកភិក្ខុទាំងឡាយ ក៏សង្គ្រោះដល់ព្រាហ្មណ៍ដោយបាយនិងទឹកជាដើម ។ តមករាធព្រាហ្មណ៍ មានបំណងនឹងបព្វជ្ជា តែមិនមាន

ភិក្ខុរូបណាមួយនឹងឲ្យបព្វជ្ជាទេ ព្រោះយល់ថា រាធព្រាហ្មណ៍មានវ័យជរាហើយ ។ កាលបើរាធព្រាហ្មណ៍មិនបានបព្វជ្ជា ក៏កើតមានការអាក់អន់ចិត្ត រហូតដល់មានរាងកាយស្គម ពណ៌សម្បុរសៅហ្មង មិនផូរផង់ ។

ថ្ងៃមួយ ព្រះសក្យមុនី ទ្រង់ប្រមើលមើលឧបនិស្ស័យរបស់សត្វលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញឧបនិស្ស័យរាធព្រាហ្មណ៍នោះ បានសម្រេចជាព្រះអរហន្ត ក្នុងពេលល្ងាច ព្រះសម្ពុទ្ធស្តេចនិមន្តចង្ក្រមក្បែរវិហារ ហើយទ្រង់ចូលទៅរករាធព្រាហ្មណ៍នោះ បានត្រាស់សួរថា ម្នាលរាធៈ អ្នកកំពុងធ្វើអ្វី ? រាធព្រាហ្មណ៍ក្រាបបង្គំទូលថា ខ្ញុំព្រះករុណាកំពុងតែបដិបត្តិបម្រើភិក្ខុសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់សួរទៀតថា អ្នកបានទទួលការសង្គ្រោះពីភិក្ខុសង្ឃខ្លះដែរឬទេ ? តបថា បពិត្រព្រះសុគត បានទទួលការសង្គ្រោះពីភិក្ខុសង្ឃត្រឹមតែអាហារប៉ុណ្ណោះ តែភិក្ខុសង្ឃមិនព្រមឲ្យខ្ញុំព្រះអង្គបានបព្វជ្ជាឡើយ ។ ព្រះបរមសាស្ដា ទ្រង់សណ្ដាប់នូវពាក្យក្រាបទូលរបស់រាធព្រាហ្មណ៍ហើយ ទើបទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ដោយអាស្រ័យរាធព្រាហ្មណ៍ជាដើមហេតុ ។ គ្រានោះ ភិក្ខុសង្ឃទាំងឡាយមកប្រជុំព្រមគ្នាហើយ ព្រះពុទ្ធជាម្ចាស់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយមាននរណានឹករឭក ឃើញគុណរបស់រាធព្រាហ្មណ៍ខ្លះដែរឬទេ ? ព្រះសារីបុត្តត្ថេរទើបក្រាបបង្គំទូលថា ខ្ញុំព្រះអង្គនឹករឭកឃើញ កាលដែលខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតនៅក្នុងក្រុងរាជគ្រឹះ រាធព្រាហ្មណ៍នេះ បានដាក់

ចង្ហាន់បិណ្ឌបាតដល់ខ្ញុំមួយវែកដែរ រាធព្រាហ្មណ៍នេះ ជាអ្នកមានឧប-ការគុណដល់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់សណ្តាប់ពាក្យក្រាបទូលរបស់ព្រះសារីបុត្រហើយ ត្រាស់ថា ល្អហើយសារីបុត្រ អ្នកជាសប្បុរស ជាអ្នកមាននូវកតញ្ញូកតវេទី ប្រសិនបើយ៉ាងនោះ អ្នកចូរឲ្យរាធៈបព្វជ្ជាចុះ ព្រះសារីបុត្រក៏បានរៀបចំឲ្យរាធៈឧបសម្បទា ដោយញត្តិចតុត្ថកម្មវាចាឧបសម្បទា បានដល់ ការឧបសម្បទា ដោយការសូត្រប្រកាសឲ្យសង្ឃដឹង ៤ ដង ។ ព្រះលោកនាថទ្រង់ត្រាស់សរសើរការឧបសម្បទា ដោយការឲ្យត្រៃសរណគមន៍ ដែលទ្រង់អនុញ្ញាតរួចមកហើយ ប៉ុន្តែចំពោះរាធព្រាហ្មណ៍ ទ្រង់អនុញ្ញាតដោយញត្តិចតុត្ថកម្មវាចាជាលើកដំបូង ដូច្នេះ នេះជាការប្រគល់អំណាចឲ្យសង្ឃជាធំ ហើយប្រើរហូតមកដល់សព្វថ្ងៃនេះ ។ កាលបើរាធព្រាហ្មណ៍បួសរួចហើយ ក្នុងឋានៈដែលលោកទើបតែបួសថ្មី សូម្បីអាយុច្រើន តែព្រះពុទ្ធសាសនាប្រកាន់យកអាយុនៃការបួសមុនជាប្រធាន លោកមានអាយុច្រើនយ៉ាងហ្នឹងក៏ដោយ តែជាជាអ្នកបួសក្រោយ ត្រូវអង្គុយខាងចុងអាសនៈក្នុងសាលាឆាន់ ហើយព្រះរាធៈលំបាកដោយចង្ហាន់ មានបបរ និងបាយជាដើម ។ ព្រះសារីបុត្តត្ថេរ ត្រិះរិះដល់ការលំបាករបស់ព្រះរាធៈថា សូម្បីព្រះសម្ពុទ្ធទ្រង់ឃើញការលំបាករបស់រាធៈទើបឲ្យបព្វជ្ជា ចំណែកយើងគួរតែជួយសង្គ្រោះប្រយោជន៍ដល់រាធៈ កាលបើគិតដូច្នេះហើយ សារីបុត្រ

ទើបនាំព្រះរាធៈទៅកាន់ គាមកាវាសវិហារ ដែលនៅជិតស្រុកមួយ ថែមទាំងឲ្យអាហារបិណ្ឌបាតដ៏ប្រណីតៗ ដល់ព្រះរាធត្ថេរ ចំណែកព្រះរាធៈ កាលបើបានអាហារបិណ្ឌបាត និងសេនាសនៈដែលជាទីសប្បាយហើយ ទើបតាំងចិត្តរៀនសូធ្យបដិបត្តិតាមឱវាទព្រះសារីបុត្រ មិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទា ។

ម្យ៉ាងទៀត មុនដែលព្រះរាធត្ថេរ នឹងបានសម្រេចជាព្រះអរហន្ត ជាមគ្គផលដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះពុទ្ធសាសនានេះ មានសម្ដែងក្នុងព្រះបាលីនៃរាធសំយុត្ត គម្ពីរសំយុត្តនិកាយ ខន្ធវារវគ្គ និងក្នុងគម្ពីរអសីតិ-មហាសាវកនិព្វាន ពោលទុកថា ៖

កាលបើរាធៈឧបសម្បទារួចហើយ ថ្ងៃមួយ ចូលទៅគាល់ព្រះ-បរមសាស្ដាទ្រង់គង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី បានក្រាបបង្គំទូលថា សូមព្រះសុគតទ្រង់សម្ដែងធម៌ដល់ខ្ញុំព្រះអង្គ ដោយសេចក្ដីសង្ខេបតាមដែលខ្ញុំព្រះអង្គអាចស្ដាប់យល់ ហើយនឹងគេចទៅនៅតែម្នាក់ឯង ជាអ្នកមិនមានសេចក្ដីប្រមាទ មានការព្យាយាម និងជាអ្នកមានចិត្តបញ្ជូនទៅកាន់ការនា ។ ព្រះលោកនាថទ្រង់ត្រាស់ថា ម្នាលរាធៈ វត្ថុណាជាមារ ចូរអ្នកលះបង់នូវការត្រេកអរពេញចិត្តក្នុងវត្ថុនោះចេញ អ្វីដែលឈ្មោះថាមារ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ( រួមហៅថា បញ្ចក្ខន្ធ ) ដែលមានលក្ខណៈមិនទៀង ជាទុក្ខ មិនមែនខ្លួន មានការអស់ទៅសូន្យទៅ និង

មានការកើតរលត់ជាធម្មតា នេះឈ្មោះថាជាមារ ចូរអ្នកលះបង់នូវការត្រេកអរពេញចិត្តក្នុងបញ្ចក្ខន្ធទាំងនេះចេញ ។ ព្រះរាធៈទទួលស្តាប់ឱវាទដូច្នេះហើយ ទើបនិមន្តទៅជាមួយនឹងព្រះសារីបុត្រ កាលតមកមិនយូរប៉ុន្មាន ព្រះរាធៈក៏បានសម្រេចជាព្រះអរហន្ត ដូចដែលបានពោលមកហើយនុ៎ះឯង ។ តមកមកព្រះសារីបុត្រ បាននាំព្រះរាធត្ថេរ ដែលបានសម្រេចជាព្រះអរហន្តហើយ ចូលទៅគាល់ព្រះសក្យមុនី កាលបើចូលទៅដល់ហើយ ក្រាបថ្វាយបង្គំ រួចហើយក៏អង្គុយក្នុងទីដ៏សមគួរ ។

ព្រះសម្ពុទ្ធ ទ្រង់ជ្រាបនូវការប្រព្រឹត្តិទៅរវាងព្រះសារីបុត្រ ជាមួយនឹងព្រះរាធត្ថេរដោយសព្វគ្រប់ តែទ្រង់ក្លែងធ្វើការត្រាស់សួរថា ម្នាលសារីបុត្រ សទ្ធិវិហារិកដែលតថាគតប្រគល់ឲ្យដល់អ្នក តើងាយប្រដៅទូន្មាន ជាអ្នកមានចិត្តត្រេកអររីករាយ ក្នុងការប្រព្រឹត្តិបដិបត្តិ នៅក្នុងសាសនព្រហ្មចរិយធម៌នេះដែរឬទេ ? ព្រះសារីបុត្រ ក្រាបទូលថា រាធៈដែលជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ ជាអ្នកប្រដៅបានងាយ កាលដែលខ្ញុំព្រះអង្គបានប្រដៅទូន្មានថា វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ ចូរធ្វើយ៉ាងនេះ កុំធ្វើយ៉ាងនោះ ឬសូម្បីត្រូវបន្ទោសថាយ៉ាងណានីមួយ ក៏មិនមានការខឹងក្រោធកើតឡើង ទាំងជាអ្នកមានចិត្តត្រេកអររីករាយ ក្នុងការបដិបត្តិក្នុងសាសនព្រហ្មចរិយធម៌នេះទៀតផង ។ ព្រះភគវា ទ្រង់ត្រាស់សួរទៀតថា ម្នាលសារីបុត្រ ប្រសិនបើអ្នកបានសទ្ធិវិហារិកដូចរាធៈនេះ

តើអ្នកត្រូវការទទួលប៉ុន្មានរូបទៀត ? ព្រះសារីបុត្រក្រាបទូលតបថា បពិត្រព្រះអង្គទ្រង់មានជោគ ប្រសិនបើមានសទ្ធិវិហារិកដូចគ្នានឹងព្រះរាធៈនេះ សូម្បីមានច្រើនប៉ុន្មានក៏បាន ។ នៅថ្ងៃមួយ ភិក្ខុទាំងឡាយបានសន្ទនាគ្នាក្នុងសាលាធម្មសភា ពីរឿងព្រះសារីបុត្រជាអ្នកមានចិត្តកតញ្ញូកតវេទី ចំពោះឧបការគុណរបស់រាធព្រាហ្មណ៍ ដែលបានដាក់បាយមួយវែកប៉ុណ្ណោះ ចំណែករាធត្ថេរជាអ្នក ប្រដៅបានដោយងាយ ។

ព្រះមានព្រះភាគ ទ្រង់ស្តាប់ការសន្ទនាសរសើរពីរឿងព្រះសារីបុត្រនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រ ជាអ្នកមានចិត្តប្រកបដោយកតញ្ញូកតវេទីក្នុងកាលឥឡូវនេះ មិនអស្ចារ្យប៉ុន្មានទេ តែក្នុងអតីតជាតិកន្លងមកហើយ សារីបុត្រ កើតក្នុងកំណើតអហេតុកបដិសន្ធិ បានដល់ការកើតជាសត្វតិរច្ឆាន តែជាអ្នកមានចិត្តប្រកបដោយកតញ្ញូកតវេទិតាធម៌គួរឲ្យអស្ចារ្យណាស់ ភិក្ខុទាំងឡាយបានស្តាប់រឿងនោះហើយ ក៏បានក្រាបទូលអារាធនាព្រះបរមសាស្តា ឲ្យទ្រង់សម្តែងអតីតនិទាននោះ ដែលមានប្រាកដក្នុងអលីនចិត្តជាតក ដែលមានរឿងតំណាលទុកក្នុងអដ្ឋកថា គម្ពីរខុទ្ទកនិកាយ ជាតក នៃទុកនិបាត ថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាលកន្លងមកហើយ មានពួកបុរសជាជាងឈើប្រមាណ ៥០០ នាក់ ដែលស្នាក់អាស្រ័យនៅជើងភ្នំ បាននាំគ្នាចូលទៅក្នុងព្រៃធំ ដើម្បីកាប់ឈើយកមកធ្វើទព្វសម្ភារៈផ្សេងៗ

កាលកាប់រួចហើយ ទើបយកឈើទាំងនោះមករួមគ្នាចងជាក្បូនធំ ហើយបណ្ដែតទៅតាមក្រសែទឹកទន្លេគង្គាចុះមក ។ គ្រានោះ មានដំរីមួយយកប្រមោយការមែកឈើចុះឡើងៗ បានជន់ជើងនឹងជន្លត់ឈើ ក៏ដល់នូវទុក្ខវេទនា ដើរទ្រេតទ្រោតៗ រហូតមិនអាចនឹងទប់កាយដើរទៅបាន ក៏ដេកនៅក្នុងទីនោះឯង ។ លុះកន្លងមកបានពីរបីថ្ងៃ ដំរីនោះបានឃើញពួកជាងឈើធ្វើដំណើរចូលមកជិត ទើបត្រិះរិះថា យើងនឹងមានជីវិតរស់នៅបានក៏ព្រោះអាស្រ័យបុរសទាំងនេះ គិតដូច្នេះហើយ ទើបប្រឹងក្រោកឡើងដើរប៉ាក់ពៀចៗ សំដៅទៅរកពួកជាងឈើទាំងនោះ ។ ពួកជាងឈើបានឃើញដំរីដើរមកតាមក្រោយ ម្នាក់ៗ ភ័យខ្លាច ទើបនាំគ្នារត់ ។ ដំរីឃើញមនុស្សទាំងនោះរត់ ទើបឈប់នៅស្ងៀម កាលពួកជាងឈើឈប់ ដំរីក៏ដើរប៉ាក់ពៀចតម្រង់ទៅទៀត ធ្វើឲ្យពួកគេមានការឆ្ងល់ ។ មេជាងឈើទើបពិចារណាថា ហេតុដូចម្ដេចហ្ន៎ ដំរីនេះ កាលពួកយើងឈប់ក៏ដើរតាមពួកយើងមក កាលពួកយើងរត់ ដំរីនេះឈប់នៅស្ងៀម ហាក់បីដូចមានហេតុអ្វី កើតមានដល់ដំរីនេះជាពិតប្រាកដ កាលគិតដូច្នេះហើយ ទើបស្រែកប្រាប់បរិវារទាំងអស់ ឲ្យឡើងទៅលើដើមឈើ ចំណែកខ្លួនឯងរង់ចាំមើលអាកប្បកិរិយាដំរីនោះ តើមិនដឹងថា មានផលល្អ ឬអាក្រក់ឡើយ ។ ដំរីនោះដើរចូលទៅជិតជាងឈើ ដោយអាការជាមិត្ត និងលើកជើងដែលឈឺចុកចាប់ បង្ហាញឲ្យជាងឈើមើល ទើបផ្ដួលខ្លួនដេកនៀល

ទៅមកៗ ហើយដេកនៅស្ងៀមត្រង់ទីនោះឯង ។ មេជាងឈើពិចារណា ឃើញហើយ ក៏យល់អាការរបស់ដំរី ទើបប្រាប់ពួកជាងឈើជាបរិវារថា ពួកអ្នកទាំងឡាយមក ដំរីនេះមកដោយអាការឈឺចាប់ មិនមែនមកដោយហេតុដទៃ ពោលរួចហើយក៏ដើរចូលទៅរកដំរីនោះ បានឃើញដំបៅដែលត្រូវដង្គត់ឈើមុតត្រង់ជើង ទើបសន្និដ្ឋានក្នុងចិត្តថា ដំរីនេះមកដើម្បីសូមឲ្យយើងជួយសង្គ្រោះក្នុងហេតុនេះ ។ កាលបើពួកជាងឈើ កំណត់ដឹងហេតុបានដូច្នេះហើយ ក៏នាំគ្នាយកកាំបិតព្រាវះចំមុខដំបៅ ដើម្បីដកយកនូវដង្គត់ឈើស្រួច ដែលជាប់នៅក្នុងជើងដំរីនោះចេញមក រួចក៏ប្របាច់ខ្ទុះឲ្យហូរចេញមកឲ្យអស់ បិទថ្នាំឲ្យដំរីនោះ មិនយូរប៉ុន្មានដំរីនោះក៏បានជាសះស្បើយទៅ ។ ចំណែកសត្វដំរី ត្រិះរិះថា ពួកជាងឈើទាំងនេះមានឧបការគុណជួយជីវិតយើង គួរណាស់តែយើងដឹងគុណពួកគេ គិតដូច្នេះហើយ ក៏ដើរទៅកាន់លំនៅ របស់ពួកជាងឈើ បាននាំកូនដំរីសដែលជាដំរីអាជានេយ្យ មកឲ្យដល់ពួកជាងឈើ ។ កាលបើពួកជាងឈើ បានឃើញកូនដំរីសនោះ ក៏មានសេចក្តីត្រេកអរក្រៃពេក ដោយគិតដល់ដំរីនេះថា ទៅរកកូនដំរីមកឲ្យពួកយើង ។ ចំណែកដំរីនោះ សញ្ជឹងគិតនៅក្នុងចិត្តថា កាលបើយើងនៅឈរ ជនទាំងឡាយនឹងដឹងនូវហេតុដែលយើងមកឬ គិតហើយ ទើបដើរចេញពីកន្លែងនេះទៅ ។ ចំណែកកូនដំរីស បានដើរទៅតាមក្រោយឪពុក ។ ដំរីដែលជាឪពុក កាលដឹងថា

កូនរបស់ខ្លួនដើរមកតាមក្រោយ ទើបបញ្ចេញសំឡេងជាសញ្ញា ដើម្បីឲ្យកូនដំរីសនោះត្រឡប់ទៅរកពួកជាងឈើវិញ ។

កូនដំរី កាលបានឮសំឡេងរបស់ឪពុកដូច្នោះហើយ ក៏បានត្រឡប់ទៅរកពួកជាងឈើវិញ ជាងឈើទាំងនោះ ដឹងច្បាស់នូវហេតុនេះថា ដំរីនេះ ប្រហែលជានាំកូនមកឲ្យពួកយើងយ៉ាងពិតប្រាកដ ទើបពោលនឹងកូនដំរីនោះដូច្នេះថា កន្លែងរបស់ពួកយើងមិនមានកិច្ចការអ្វីឲ្យអ្នកជួយធ្វើទេ ចូរត្រឡប់ទៅរកឪពុករបស់អ្នកវិញទៅ កូនដំរីកាលបើពួកជាងឈើពោលយ៉ាងនេះ ក៏ត្រឡប់ទៅរកឪពុក ហើយដំរីដែលជាឪពុកបានប្រាប់ឲ្យត្រឡប់ទៅរកពួកជាងឈើទៀត ពួកជាងឈើប្រាប់ឲ្យកូនដំរីត្រឡប់ទៅរកឪពុកទៀតដូចគ្នា ។ រហូតទៅមកៗ ដល់ ៣ ដង ចាប់ផ្ដើមពីនោះមក ពួកជាងឈើទើបទទួលយកកូនដំរីនោះ ទុកក្នុងសម្នាក់របស់ខ្លួន ថែមទាំងចិញ្ចឹមថែរក្សាទុកយ៉ាងល្អ ។ វិធីដែលពួកជាងឈើចិញ្ចឹមថែរក្សាកូនដំរីនោះមានដូច្នេះគឺ ក្នុងពេលបរិភោគអាហារ ពួកជាងឈើបានបែងចែកអាហារឲ្យដល់កូនដំរីម្នាក់ៗ មួយពំនូតៗ បានចំនួន ៥០០ ពំនូត ក៏ល្មមជួយឲ្យកូនដំរីនោះរស់នៅយ៉ាងសប្បាយ ។ ចំណែកកូនដំរីជួយអូសទព្វសម្ភារៈ គ្រឿងឈើដែលពួកជាងចងទុក ដើម្បីឲ្យខ្លួនជួយអូសទាញ ប្រមូលមកទុកដាក់ក្នុងស្ថានទី របស់ពួកជាងឈើទាំងនោះ និងជួយធ្វើកិច្ចការផ្សេងៗដទៃទៀត ។

កាលព្រះសម្ពុទ្ធ ទ្រង់នាំអតីតនិទានមកសម្ដែងចប់ហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រជាអ្នកមានចិត្តប្រកបដោយកតញ្ញូកតវេទី មិនមែនត្រឹមតែពេលនេះប៉ុណ្ណោះទេ ក្នុងកាលមុនសារីបុត្រកើតជាសត្វដំរី ក៏ធ្លាប់មានការដឹងគុណចំពោះអ្នកដទៃដែរ ដូចរឿងដែលពោលរួចមកហើយ ។ ចំណែករាធៈ ជាអ្នកមានសេចក្ដីប្រឹងប្រែងព្យាយាម ទាំងជាអ្នកប្រដៅបានដោយងាយ ជាទីស្រឡាញ់ពេញចិត្តរបស់អាចារ្យ ធ្លាប់កើតជាកូនដំរីស ដែលប្រដៅបានដោយងាយ និងយកចិត្តទុកដាក់បំពេញបុណ្យកុសលជារឿយៗ ។

ក្នុងទីបំផុត ព្រះលោកនាថ បានទ្រង់ត្រាស់ព្រះគាថា ដែលមានប្រាកដក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃបណ្ឌិតវគ្គ ថា ៖

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិនចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នេះ គួរគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា ) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះ ហើយរមែងមានសេចក្ដីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

មានពាក្យអធិប្បាយសេចក្ដីក្នុងគាថានេះ តាមន័យដែលអដ្ឋកថាបានសម្ដែងទុកថា ៖

ពាក្យថា រណ្ដៅកំណប់ទ្រព្យ បានដល់ ក្រឡ ឬក្អម ដែលពេញដោយប្រាក់ និងមាស ដែលបុគ្គលកប់ទុកក្នុងទីនោះៗ ។ ពាក្យថា អ្នក

ប្រាប់ បានដល់ អ្នកនិយាយប្រាប់ប្រកបដោយមេត្តាចិត្តដល់អ្នកខ្វះខាត ចិញ្ចឹមជីវិតបានដោយលំបាកថា ចូរមកនេះ ខ្ញុំនឹងបង្ហាញឧបាយការទ្រ ទ្រង់ជីវិតយ៉ាងសុខសប្បាយឲ្យដល់អ្នក ពោលរួចហើយ ទើបនាំទៅកាន់ ទីកំណប់ទ្រព្យ ចង្អុលប្រាប់ថា ចូរអ្នកកាន់យកទ្រព្យមួយចំនួននេះ ទៅ ចិញ្ចឹមជីវិតឲ្យបានសុខសប្បាយចុះ ។ ពាក្យថា អ្នកចង្អុលប្រាប់ទោស បានដល់ អ្នកប្រាប់ទោសមាន ២ យ៉ាង គឺអ្នកនិយាយប្រាប់នូវទោស កំហុសដោយបំណងមិនល្អ ១ អ្នកនិយាយប្រាប់នូវទោសកំហុសដើម្បីឲ្យ បានសម្រេចនូវប្រយោជន៍ ១ ។ ពាក្យថា ពោលសង្កត់សង្កិន គឺបុគ្គល ខ្វះបានឃើញទោសដូច្នេះហើយ ក៏គំរាមកំហែង ផ្ដន្ទាទោស ដាក់ទណ្ឌកម្ម បណ្ដេញចេញចាកវិហារជាដើម អ្នកនេះឈ្មោះថា ពោលសង្កត់សង្កិន ។ ពាក្យថា អ្នកប្រាជ្ញ គឺអ្នកប្រកបដោយធម្មជាតបញ្ញា បានដល់ បញ្ញា ដែលផ្សព្វផ្សាយទៅក្នុងធម៌ ។ ពាក្យថា គួរគប់រកអ្នកប្រាជ្ញ បានដល់ បុគ្គលដែលណែនាំនូវប្រយោជន៍ឲ្យចម្រើន ។

កាលព្រះបរមសាស្ដា ត្រាស់សម្ដែងព្រះធម៌ទេសនេះចប់ហើយ បុគ្គលជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ។ ព្រះរាធត្ថេរ ក្រោយពីបានសម្រេចជាព្រះអរហន្តហើយ បាន ចូលទៅគាល់ព្រះលោកនាយក ថែមទាំងបានស្ដាប់ព្រះធម៌ទេសនានៃ ភគវាជារឿយៗ ទៀតផង រហូតជាអ្នកយល់ចូលចិត្តនៅក្នុងធម៌ ដែលជា

ពាក្យប្រៀនប្រដៅយ៉ាងជាក់ច្បាស់ ។

ការទទួលតំណែងជាឯតទគ្គៈរបស់ព្រះរាធត្ថេរ មានសម្ដែងក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាត មានសេចក្ដីថា ៖

ព្រះមានជោគ ទ្រង់តែងតាំងព្រះថេរៈទាំងឡាយ ឲ្យស្ថិតនៅក្នុងតំណែងផ្សេងៗ តាមសមត្ថភាពរៀងៗ ខ្លួន ទៅតាមបារមីដែលធ្លាប់សន្សំមក ព្រះអង្គបានតែងតាំងព្រះរាធៈទុកក្នុងតំណែង ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងជាអ្នកឈ្លាសវៃក្នុងបដិភាណ ។ ព្រះរាធត្ថេរ ក្រោយពីបានសម្រេចអរិយធម៌ថ្នាក់ខ្ពង់ខ្ពស់បំផុតជាព្រះអរហន្តហើយ ថ្ងៃមួយ លោកបានពោលគាថាទុក ដែលមានប្រាកដក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា ថា ៖

**យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ**
**ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។**
**យថា អគារំ សុឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ**
**ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។**

ភ្លៀង រមែងលេចធ្លុះនូវផ្ទះដែលប្រក់មិនល្អ យ៉ាងណាមិញ រាគៈរមែងចាក់ធ្លុះចិត្តដែលមិនបានអប់រំល្អ ក៏យ៉ាងនោះដែរ ។ ភ្លៀង រមែងមិនលេចធ្លុះ នូវផ្ទះដែលប្រក់ល្អ យ៉ាងណាមិញ រាគៈរមែងមិនចាក់ធ្លុះចិត្តដែលបានអប់រំល្អ ក៏យ៉ាងនោះដែរ ។

គាថានេះជាគោលអះអាងថា ព្រះរាធត្ថេរ ជាអ្នកមានបដិភាណក្នុងធម៌ គឺអាចសម្តែងធម៌បានដោយការចេះដឹង ការគិតឃើញរបស់ខ្លួនឯង ដោយមិនត្រូវពឹងសព្រហ្មចារីដទៃឡើយ ។ ចំណែកក្នុងផ្នែក ឧបនិស្ស័យ គឺការប្រព្រឹត្តិមករបស់ព្រះរាធត្ថេរ តាមជីវប្រវត្តិរបស់លោក សម្តែងឲ្យឃើញថា ជាអ្នកប្រដៅបានងាយ ធ្វើឲ្យអ្នកដទៃជួយក្នុងរឿងដែលជាប្រយោជន៍ រហូតបានសម្រេចបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ។

លុះកាលជាខាងក្រោយមក ព្រះរាធត្ថេរ ក៏រំលត់ខន្ធបរិនិព្វានទៅហោង ។៚

( ជីវប្រវត្តិរបស់ព្រះរាធត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះរេវតខទិរវនិយត្ថេរ ✍

## " ដែលជាឯតទគ្គៈផ្នែកខាងនៅក្នុងព្រៃ "

ព្រះរេវតខទិរវនិយត្ថេរ លោកជាអ្នកចៀវឈ្លាស មានភាពជំនាញអង់អាច និងមានភាពក្លាហាន នៅវ័យក្មេង ទាំងបានទទួលតំណែងជាឯតទគ្គៈ ដែលព្រះជិនស្រីទ្រង់លើកតម្កើង ដូចមានសម្តែងក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាត មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ព្រះរេវតខទិរវនិយៈ ជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ផ្នែកខាងនៅក្នុងព្រៃ ។

ជីវប្រវត្តិអតីតជាតិ របស់ព្រះរេវតខទិរវនិយត្ថេរ មានប្រាកដក្នុងអដ្ឋកថាមនោរថបូរណី ដែលអធិប្បាយសេចក្តីក្នុងគម្ពីរអង្គុត្តរនិកាយ ឯកនិបាត ថា ៖

ក្នុងសម័យនៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ព្រះរេវតខទិរវនិយៈ បានកើតនៅក្នុងនគរហង្សវតី ជាអ្នកមានអាជីពធ្វើជំនួញទៅតាមសំពៅ ដោយមានកំពង់ចំណតសំពៅ ឈ្មោះថា បយាគបតិដ្ឋាន ដែលតាំងនៅក្បែរប្រាំងនៃស្ទឹងមហាគង្គា ។ ព្រះរេវតខទិរវនិយៈ មានឋានៈជានាយសំពៅ និងមានអំណាចក្នុងការពោលដោះស្រាយ កិច្ចការងារទំនិញគ្រប់យ៉ាង ។ ក្នុងពេលនោះ ព្រះបទុមុត្តរៈ ព្រមដោយភិក្ខុសង្ឃមួយសែនរូប ស្តេច

យាងមកកាន់កំពង់ចំណតបយាគបតិដ្ឋាននោះ ។ នាយសំពៅនោះ បាន ឃើញព្រះបទុមុត្តរៈ ក៏គិតថា មិនងាយនឹងមានឱកាសបានឃើញព្រះពុទ្ធ ជារឿយៗ ទេ ពេលនេះ ជាឱកាសល្អសម្រាប់យើងបំពេញបុណ្យកុសល គិតដូច្នេះហើយ ទើបឲ្យមនុស្សទាំងឡាយ ជួយចងទូកតម្រៀបបន្តគ្នា ហើយរៀបចំចងពិតានខាងលើ ថែមទាំងចងកម្រងផ្កាឈើឲ្យសំយុងចុះ មកយ៉ាងស្អាត ក្រាលកម្រាលដោយរបស់មានតម្លៃ រួចហើយ ទើប និមន្តព្រះបទុមុត្តរៈ ព្រមទាំងភិក្ខុសង្ឃមួយសែនរូប ឲ្យនិមន្តចូលទៅគង់ ប្រថាប់ក្នុងទូក ដែលរៀបចំរៀបរយបានល្អហើយ ដើម្បីចម្លងទៅត្រើយ ម្ខាង ។ ពេលនោះ ព្រះបទុមុត្តរៈតែងតាំងភិក្ខុមួយរូប ជាអ្នកប្រសើរ ជាងភិក្ខុទាំងឡាយ ផ្នែកខាងនៅក្នុងព្រៃ ។ នាយសំពៅបានឃើញភិក្ខុ នោះ មានការទទួលតែងតាំងក្នុងកណ្តាលជំនុំសង្ឃ នឹកពេញចិត្ត ក៏គិត ថា យើងគួរនឹងបានតំណែងនេះ ក្នុងសាសនានៃព្រះពុទ្ធអង្គណាមួយ នា កាលជាអនាគត ដែលទ្រង់ត្រាស់ដឹងក្នុងលោក ហើយបានរៀបចំថ្វាយ មហាទានចំពោះព្រះបទុមុត្តរៈ ព្រមជាមួយភិក្ខុសង្ឃមួយសែនរូប រហូត អស់ ៧ ថ្ងៃ ។ កាលបើថ្វាយមហាទានជាប់តគ្នាគ្រប់ ៧ ថ្ងៃ ហើយបាន ក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះបទុមុត្តរៈ តាំងសេចក្តីប្រាថ្នាថា ភិក្ខុរូបណាដែលព្រះអង្គប្រកាសតែងតាំង ឲ្យប្រសើរជាងភិក្ខុទាំងឡាយ ផ្នែកខាងនៅព្រៃនោះ សូមឲ្យខ្ញុំព្រះអង្គបានទទួលតំណែងនោះ ក្នុងព្រះ-

សាសនារបស់ព្រះពុទ្ធអង្គណាមួយ នាកាលជាអនាគត ។ ព្រះបទុមុត្តរៈទ្រង់ព្យាករថា នឹងបានសម្រេចក្នុងសាសនារបស់ព្រះសមណគោតម ក្នុងរយៈពេលមួយសែនកប្បខាងមុខទៀត ។ ក្រោយពីព្រះអង្គទ្រង់ព្យាករហើយ នាយសំពៅសប្បាយចិត្តណាស់ ដូចបានសម្រេចថ្ងៃស្អែកនេះ ។ ប៉ុន្តែយ៉ាងណាក៏ដោយ សេចក្តីពេញចិត្តក្នុងតំណែងនោះ ជារឿងធ្វើឲ្យនាយសំពៅ មានការព្យាយាមបំពេញកុសលជារឿយៗ រហូតអស់ជីវិតបានកើតជាមនុស្សទេវតាអស់កាលដ៏យូរ ។

ចំណែកជីវប្រវត្តិក្នុងអតីតជាតិរបស់លោក មានសម្តែងក្នុងគម្ពីរខុទ្ទកនិកាយ អបទាន ដែលជាការពោលផ្ទាល់ដោយខ្លួនឯង ក្រោយពីលោកបានជាព្រះអរហន្តហើយ មានសេចក្តីថា ៖

មានស្ទឹងមួយ ឈ្មោះភាគីរសី ហូរចេញអំពីព្រៃហិមពាន្ត កាលនោះខ្ញុំកើតជានាយទូកក្នុងកំពង់មិនល្អ ជាកំពង់សម្រាប់ឆ្លងមកកាន់ត្រើយអាយ ។ ព្រះបទុមុត្តរៈ ព្រះអង្គប្រសើរជាងសត្វជើងពីរ បម្រុងនឹងឆ្លងខ្សែទឹកក្នុងស្ទឹង ជាមួយនឹងភិក្ខុសង្ឃមួយសែនអង្គ ។ ខ្ញុំបានប្រមូលទូកជាច្រើនមក ហើយធ្វើជំបូលទូក ដែលពួកជាងឈើ តាក់តែងល្អហើយទៅទទួលព្រះនរាសភៈ ។ ព្រះសម្ពុទ្ធ ទ្រង់ស្តេចមកឡើងគង់លើទូក ព្រះ-សាស្តាទ្រង់ឋិតត្រង់កណ្តាលទឹកស្ទឹង ហើយត្រាស់គាថាទាំងនេះថា ៖

បុគ្គលណា បានចម្លងព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃជាអ្នកមិន

មានអាសវៈ បុគ្គលនោះនឹងត្រេកអរក្នុងទេវលោក ដោយចិត្តជ្រះថ្លានោះឯង ។ វិមានមានសណ្ឋានដូចទូក ដែលបុញ្ញកម្មធ្វើល្អហើយ នឹងកើតដល់អ្នក វិមាននោះ នឹងទ្រទ្រង់នូវដំបូល ជាវិការៈនៃផ្កាឰដ៏អាកាស មានសព្វៗ កាល ។ ក្នុងកប្បទី ៥៨ បុគ្គលនោះ នឹងបានជាស្តេចចក្រពត្តិព្រះនាមតារណៈ ( ជាឥស្សរៈលើផែនដី ) មានសមុទ្រទាំង ៤ ជាទីបំផុតទ្រង់ឈ្នះសង្គ្រាម ។ ក្នុងកប្បទី ៥៧ នឹងបានជាស្តេចព្រះនាមចម្តកៈមានកម្លាំងច្រើន រុងរឿងដូចព្រះអាទិត្យកំពុងរះ ។ ក្នុងកប្បទីមួយសែនព្រះសាស្តា ព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ស្តេចចម្តកៈនោះ ចុតិចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹងកើតជាព្រាហ្មណ៍ ឈ្មោះរេវតៈ ។ រេវតកុមារនោះ ត្រូវកុសលមូលជាស់តឿន នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា នៃព្រះមុនីព្រះនាមគោតម ។ រេវតភិក្ខុនោះ លុះបួសរួចហើយ ក្នុងកាលជាខាងក្រោយ ប្រកបដោយសេចក្តីព្យាយាម ខំចម្រើនវិបស្សនា កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ សេចក្តីព្យាយាមរបស់ខ្ញុំ គួរដើម្បីនាំមកនូវធុរៈ ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគៈ ខ្ញុំទ្រទ្រង់រាងកាយ មានក្នុងទីបំផុត គឺបច្ឆិមជាតិ ក្នុងសាសនានៃព្រះសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រព្រឹត្តហើយ ។

ជីវប្រវត្តិរបស់ព្រះរេវតៈក្នុងជាតិជាបច្ចុប្បន្ននេះ មានសម្ដែងទុកនៅក្នុងអដ្ឋកថា មនោរថបូរណី មានសេចក្ដីថា ៖

ព្រះថេរៈរូបនេះ បានមកចុះចាប់បដិសន្ធិក្នុងគភ៌ របស់នាងសារី-ព្រាហ្មណី បិតាឈ្មោះ វង្គន្តព្រាហ្មណ៍ នៅស្រុកនាលកៈ ឬនាលន្ទា ក្នុងដែនមគធៈ បានកើតជាកូនពៅគេឈ្មោះថា រេវតៈ មានបងប្អូនទាំងអស់ ៧ នាក់ គឺបងប្រុសរបស់រេវតៈមាន ៣ នាក់ ឈ្មោះថា ឧបតិស្សៈ ( សារីបុត្រ ) ១ ចុន្ទៈ ១ ឧបសេនៈ ១ មានបងស្រី ៣ នាក់ដែរ គឺ ចាលា ១ ឧបចាលា ១ សីសុបចាលា ១ ។

រួមបងប្រុស និងបងស្រីទាំងអស់មាន ៦ នាក់ មានព្រះសារីបុត្រជាដើម បានចេញបួសនៅក្នុងព្រះពុទ្ធសាសនាទាំងអស់គ្នា នៅសល់តែរេវតៈប្អូនពៅម្នាក់ឯង នៅជាមួយនឹងឪពុកម្ដាយ ។ កាលរេវតៈមានអាយុតាំងនៅក្នុងបឋមវ័យ មានប្រមាណអាយុបាន ៧ ខួប មាតាបិតាមានភាពកង្វល់ខ្លាចកូនប្រុសនឹងរត់ចេញទៅបួសទៀត ព្រោះមានហេតុធ្លាប់កើតឡើងហើយ ក៏គិតសញ្ជឹងជារឿយៗ ថា កាលបើរេវតៈធំដឹងក្ដីហើយ ខ្លាចព្រះសមណសក្យបុត្រទាំងឡាយនាំទៅបព្វជ្ជា យើងនឹងចងរេវតៈទុកដោយគ្រឿងចង គឺផ្ទះ បានដល់ ឲ្យមានគ្រួសារនៅពីក្មេង គិតដូច្នេះហើយ ទើបទៅសុំកុមារិកាពីត្រកូលដែលមានឋានៈស្មើគ្នា និងកំណត់ថ្ងៃឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយរេវតៈ ។ លុះដល់ថ្ងៃរៀបការ

ពពួកញាតិបានរៀបចំខ្លួនឲ្យរេវតៈ ព្រមដោយបរិវារជាច្រើននាក់ទៀតផង នាំគ្នាទៅកាន់ផ្ទះនៃពពួកញាតិកុមារិកានោះ ។

កាលពពួកញាតិទាំងពីរចំណែក បានមកជួបជុំគ្នាអស់ហើយ ទើបចាប់ផ្តើមធ្វើមង្គលការឡើង ។ ពួកញាតិដែលប្រាថ្នានូវសេចក្តីចម្រើន បានជូនពរឲ្យដល់កុមារិកាថា សូមឲ្យមានអាយុវែងដូចលោកយាយ ។ រេវតៈបានស្តាប់ហើយ គិតថា កុមារិកានេះ ទីបំផុតនឹងមានរូបចាស់ជរាទ្រុឌទ្រោមដូចជាលោកយាយអញដែរ ព្រោះថាលោកយាយរបស់អញមានអាយុ ១២០ ឆ្នាំហើយ មានធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ មានខ្លួនពាសពេញដោយអាចម៍រុយ មានគ្រោងឆ្អឹងដូចបង្គន់ផ្ទះទៅហើយ ពួកគេសូមឲ្យកុមារិកានេះ មានអាយុ យឺនយូរដូចលោកយាយដែរ ។ រេវតៈត្រូវការដឹងសេចក្តីពិត ទើបសួរថា អ្នកទាំងឡាយ ក្នុងអនាគតរូបរាងរបស់កុមារិកានេះ ដូចជាលោកយាយខ្ញុំដែរឬទេ ? ពួកជនទាំងនោះតបថា នែរេវតៈ តើហេតុអ្វី ទើបអ្នកសួរយ៉ាងនេះ ធម្មតាមនុស្សយើងមិនអាចមានអ្នកណាគេចផុតបានឡើយ ត្រូវតែមានសភាពយ៉ាងនេះឯង ។ ទើបរេវតៈគិតថា រាងកាយនេះ នឹងដល់នូវអាការៈដ៏ប្លែក មានស្បែកជ្រីវជ្រួញ សក់ស្កូវ ធ្មេញបាក់ ដូចជាលោកយាយរបស់យើងដែរ តើមានប្រយោជន៍អ្វីចំពោះរូបនេះ ឧបតិស្សៈបងប្រុសរបស់យើងប្រហែលជាពិចារណា ឃើញការពិតក្នុងរឿងនេះហើយ បានជាទៅបួស

ថ្ងៃនេះ យើងនឹងរត់ទៅបួសឲ្យបាន ។ វិធីរត់ចេញទៅបួសរបស់រេវតៈ មានពីរយ៉ាងគឺ វិធីទី ១ ដែលមានរឿងសម្តែងប្រាកដនៅក្នុងអដ្ឋកថា គម្ពីរមនោរថបូរណី ពោលដល់វិធីរត់ចេញទៅបួសរបស់រេវតៈថា យើងនឹងទៅរត់លេងជាមួយគ្នា ហើយបានរត់ចេញទៅជាមួយគ្នានឹងពួកក្មេងៗ ។ ប៉ុន្តែរេវតៈធ្វើជានៅលេងជាមួយនឹងពួកក្មេងៗ ដែលមានអាយុស្រករគ្នា កាលដល់វារៈរបស់ខ្លួន បានរត់ទៅបន្តិចហើយ ក៏ត្រឡប់មកវិញ កាលដែលរត់ចេញទៅលើកទីពីរ ក៏រត់ទៅឆ្ងាយបន្តិចជាងមុន ហើយក៏ត្រឡប់មកវិញម្តងទៀត លុះដល់លើកទីបី បានសម្រេចចិត្តថា លើកនេះជាឱកាសរបស់អញហើយ ក៏រត់រហូតទៅដល់ក្នុងព្រៃ បានជួបលំនៅរបស់ភិក្ខុទាំងឡាយ អ្នកកាន់បង្សុកូលជាវត្ត ។

មានរឿងរបស់ព្រះរេវតត្ថេរមួយទៀត នៅក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃអរហន្តវគ្គ តំណាលទុកថា ៖

គ្រានោះ ពួកញាតិនៃរេវតកុមារឡើងជិះលើយានហើយ ជាមួយនឹងកុមារិកា ហើយនាំយកទៅ ។ កុសលោបាយ ( ឧបាយដ៏ឈ្លាសវៃ ) ដែលរេវតៈនាំយកមកប្រើ គឺកាលបររថទៅបានបន្តិច ក៏អាងលេសថា ខ្ញុំសូមចុះទៅធ្វើសរីរកិច្ចបន្តិច ចូរឈប់យានរង់ចាំបន្តិចសិន ប្រាប់រួចហើយ ក៏ចុះចាកយាន រត់ទៅកាន់គុម្ពោតព្រៃមួយកន្លែង ធ្វើឲ្យយូរបន្តិច ហើយក៏ត្រឡប់មកវិញ ។ កាលបរយានទៅមិនបានឆ្ងាយប៉ុន្មាន រេវតៈ

ក៏សូមចុះទៅម្ដងទៀត ហើយបានត្រឡប់មកវិញដូចលើកទីមួយ ។ ពួកញាតិសង្កេតឃើញទង្វើរបស់រេវតៈហើយ ម្នាក់ៗ ជឿថា រេវតៈនឹងត្រឡប់មកវិញជាពិតប្រាកដ ដូច្នេះ ទើបមិនបានប្រយ័ត្នប្រយែងការពារ ។

លុះដល់លើកទីបី កាលបរយានទៅបានត្រឹមតែបន្តិច រេវតៈក៏សុំចុះចាកយានដូចលើកមុនទៀត តែលើកនេះបានប្រាប់ពួកញាតិថា អ្នកទាំងឡាយចូរបរយានទៅខាងមុខចុះ ខ្ញុំទៅតែមួយភ្លែតទេ នឹងទៅតាមក្រោយ ហើយក៏ចូលទៅរកគុម្ពោតព្រៃ ធ្វើដូចជាចូលទៅបន្ទោបង់ឧច្ចារៈ ។ ចំណែកពួកញាតិទុកចិត្ត ដោយគិតថា រេវតៈនឹងដើរមកតាមក្រោយ ។ រេវតៈឃើញឱកាសល្អ ក៏រត់ចេញពីទីនោះ បានទៅដល់សម្នាក់របស់ភិក្ខុ ៣០ រូប ដែលមានអធ្យាស្រ័យនៅក្នុងព្រៃមួយកន្លែង ។ កាលបើរេវតៈ មកដល់សម្នាក់ភិក្ខុទាំងឡាយហើយ បានពោលថា សូមលោកម្ចាស់ទាំងឡាយ បំបួសខ្ញុំព្រះករុណាផង ។

ព្រះថេរៈទាំងឡាយពោលថា នែកុមារ ឯងតាក់តែងកាយដោយគ្រឿងអលង្ការដូច្នេះ ពួកយើងមិនស្គាល់អ្នកឯងថាជាបុត្ររបស់ព្រះរាជា ឬជាបុត្ររបស់អាមាត្យ អីចឹង ឲ្យពួកអាត្មាបំបួសម្ដេចនឹងបាន ។ រេវតៈស្ដាប់ហើយស្រែកឡើងថា ចោរប្លន់ខ្ញុំព្រះករុណាៗ ។ ភិក្ខុទាំងឡាយបានឮសំឡេងស្រែករបស់រេវតៈ ក៏សួរថា ហេតុអ្វីបានជាអ្នកស្រែកយ៉ាងនេះ ? រេវតៈឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះលោក

ម្ចាស់ទាំងឡាយ លួចសម្បត្តិផ្ទះរបស់ខ្ញុំព្រះករុណា រេវតៈក៏ពោលទៅទៀតថា សូមលោកម្ចាស់ទាំងឡាយជួយប្រាប់ដល់បងប្រុស របស់ខ្ញុំព្រះ-ករុណាផង ព្រះថេរៈទាំងឡាយពោលថា តើបងប្រុសរបស់អ្នកឈ្មោះអ្វី? រេវតៈប្រាប់ថា បងប្រុសរបស់ខ្ញុំ នៅជាគ្រហស្ថឈ្មោះថា ឧបតិស្សៈ ។ ព្រះថេរៈសួរថា ឧបតិស្សៈនោះគឺជានរណា ? រេវតៈប្រាប់ថា លោកម្ចាស់ទាំងឡាយតែងតែហៅបងប្រុស របស់ខ្ញុំព្រះករុណាថាសារីបុត្រនោះអី ព្រោះដូច្នោះ កាលបើខ្ញុំព្រះករុណាហៅបងប្រុសថាឧបតិស្សៈ លោកម្ចាស់ទាំងឡាយទើបមិនស្គាល់ ។ ព្រះថេរៈសួរថា អ្នកជាប្អូនប្រុសរបស់ព្រះសារីបុត្រទីប៉ុន្មាន ? រេវតៈឆ្លើយថា ខ្ញុំជាប្អូនពៅគេ ។ ព្រះថេរៈពោលថា ប្រសិនបើយ៉ាងនោះ អ្នកក៏ជាប្អូនប្រុសរបស់ពួកយើងដែរ ព្រោះថា ព្រះធម្មសេនាបតីសារីបុត្រ រាប់ថាជាបងប្រុសច្បងរបស់ពួកយើង លោកធ្លាប់ប្រាប់ដល់ពួកយើងជាមុនហើយថា បើមានពួកញាតិឯណាទីមួយរបស់លោកមកសុំបព្វជ្ជា គប្បីអនុញ្ញាតឲ្យបួសផង ។ ព្រះថេរៈពោលថា រេវតៈនេះជាប្អូនព្រះសារីបុត្រ ព្រោះដូច្នោះ អ្នកទាំងឡាយ ចូរឲ្យគេបព្វជ្ជាផងចុះ ។ ភិក្ខុទាំងឡាយពោលជាមួយនឹងរេវតៈថា ប្រសិនបើយ៉ាងនោះ ចូរអ្នកបព្វជ្ជាចុះ បងប្រុសរបស់អ្នកបានអនុញ្ញាតទុករួចហើយ ។ មុននឹងឲ្យរេវតៈបព្វជ្ជា ព្រះថេរៈទាំងឡាយ ឲ្យរេវតៈដោះគ្រឿងអលង្ការចេញឲ្យអស់ ហើយទើបប្រាប់នូវកម្មដ្ឋាន មានស្បែកជាទី ៥ ហៅថា

តចបញ្ចកកម្មដ្ឋានឲ្យដល់រេវតៈ ហើយទើបឲ្យបព្វជ្ជា ជាសាមណេរ ក្រោយពីនោះ ទើបបញ្ជូនដំណឹងទៅឲ្យដល់ព្រះសារីបុត្រ ។ កាលតមក សាមណេររេវតៈ មានអាយុគ្រប់បរិបូណ៌ដែលនឹងឧបសម្បទាបាន ព្រះ ថេរៈទាំងឡាយ ក៏ឲ្យឧបសម្បទាជាភិក្ខុ ថែមទាំងប្រាប់នូវកម្មដ្ឋាន ដែល ជាកិច្ចប្រតិបត្តិប្រចាំថ្ងៃ ។ ព្រះរេវតៈរៀនកម្មដ្ឋានរួចហើយ បានទៅ ចម្រើនសមណធម៌នៅក្នុងព្រៃខទិរៈ គឺព្រៃដើមគគីរ ដែលតាំងនៅឆ្ងាយ ពីសម្នាក់ឧបជ្ឈាយ៍ និងអាចារ្យទៅប្រមាណ ៣០ យោជន៍ ។ ហេតុ ដែលលោកមកចម្រើនសមណធម៌នៅក្នុងព្រៃដើមគគីរនោះ ដោយខ្លាច ពួកញាតិតាមមករក នឹងហៅខ្លួនឲ្យត្រឡប់ទៅផ្ទះវិញ ទើបលោកមាន ឈ្មោះ មួយទៀតថា ព្រះរេវតខទិរវនិយៈ ប្រែថា ព្រះរេវតៈអ្នករស់នៅ ក្នុងព្រៃគគីរ ពាក្យថា **វនិយ** ប្រែថា នៅព្រៃ ។ ការគិតដែលប្រព្រឹត្ត ទៅជាមួយនឹងសេចក្តីព្យាយាម របស់ព្រះរេវតខទិរវនិយត្ថេរថា ប្រសិន បើយើងមិនទាន់សម្រេចជាព្រះអរហន្តដរាបណា នឹងមិនចូលទៅគាល់ ព្រះវិជិតមារ ថែមទាំងមិនទៅរកព្រះសារីបុត្រជាបងដរាបនោះដែរ ។

កាលលោកប្រឹងប្រែងព្យាយាម កន្លងទៅបាន ៣ ខែ ចិត្តរបស់ លោក ធ្លាប់ជាអ្នកមានសេចក្តីសុខតាំងពីកំណើត ពេលបានបរិភោគ អាហារដែលមិនជាទីសប្បាយ ចិត្តក៏មិនបង្អោនចុះទៅក្នុងកម្មដ្ឋាន ។ លុះ ដល់ពេលបវារណាចេញព្រះវស្សាហើយ លោកក៏នៅតែមិនលះបង់

សេចក្ដីព្យាយាម បានធ្វើសមណធម៌នៅក្នុងទីនោះហើយ ចិត្តក៏មានអារម្មណ៍តែមួយ បញ្ញាក៏ចាស់ក្លាឡើង ដរាបប្រហារបង់កិលេស ទើបបានសម្រេចជាព្រះអរហន្ត ព្រមដោយបដិសម្ភិទា ៤ ( សមពិតដូចមានពាក្យពោលថា មានសេចក្ដីព្យាយាមនៅទីណា សេចក្ដីសម្រេចក៏នៅទីនោះដែរ ) ។ ចំណែកព្រះសារីបុត្រ បានជ្រាបដំណឹងថា រេវតៈប្អូនប្រុសបួសហើយ មានបំណងនឹងទៅសួរសុខទុក្ខ ទើបក្រាបបង្គំទូលដល់ព្រះភគវាថា បពិត្រព្រះសយម្ភូ មានអ្នកបញ្ជូនដំណឹងមកថា ភិក្ខុទាំងឡាយនៅក្នុងព្រៃ ឲ្យរេវតៈប្អូនប្រុសរបស់ខ្ញុំព្រះអង្គបួសហើយ ខ្ញុំព្រះអង្គនឹងមានបំណងទៅមើលរេវតៈ ថាជាអ្នកត្រេកអរចំពោះការបួសដែរឬទេ រួចហើយនឹងត្រឡប់មកវិញ ។ ព្រះលោកនាថមិនបានអនុញ្ញាត តែត្រាស់ជាមួយនឹងព្រះសារីបុត្រថា ម្នាលសារីបុត្រ ចូរអ្នករង់ចាំបន្តិចសិន ។ ពីរបីថ្ងៃក្រោយមកទៀត ព្រះសារីបុត្របានចូលទៅក្រាបទូលលាទៅម្ដងទៀត តែព្រះមុនីក៏ទ្រង់មិនអនុញ្ញាត បានត្រាស់ថា ម្នាលសារីបុត្រ អ្នកចូររង់ចាំបន្តិចសិន សូម្បីតថាគតក៏នឹងទៅដែរ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហាមឃាត់ព្រះសារីបុត្រ ព្រោះទ្រង់ជ្រាបថា រេវតៈកំពុងចម្រើនវិបស្សនាជាលំដាប់ ជិតនឹងបានសម្រេចមគ្គផលថ្នាក់ខ្ពង់ខ្ពស់បំផុតហើយ ខ្លាចនឹងកើតមានអន្តរាយដល់ការបដិបត្តិធម៌របស់រេវតៈ ទើបទ្រង់ត្រាស់ហាមឃាត់ព្រះសារីបុត្រមួយដងជាពីរដង ។

ដល់លើកទី ៣ ព្រះសក្យមុនីទ្រង់ជ្រាបថា រេវតៈបានសម្រេចជាព្រះអរហន្តហើយ ទើបទ្រង់អនុញ្ញាត និងត្រាស់ថា សូម្បីតថាគតក៏នឹងទៅដែរ ចូរអ្នកប្រាប់ដល់ភិក្ខុទាំងឡាយឲ្យជ្រាបផង ។ ព្រះសារីបុត្រឲ្យប្រជុំភិក្ខុទាំងឡាយ ហើយប្រាប់ថា ព្រះសុគតស្ដេចនឹងចារិកទៅកាន់ព្រៃគីរ នរណាប្រាថ្នានឹងទៅតាមព្រះអង្គ ចូរទៅចុះ ។ តាមធម្មតាពេលដែលព្រះសម្ពុទ្ធ ទ្រង់ចារិកទៅកាន់ទីណាៗ រមែងមានភិក្ខុនៅសល់តិច អ្នកដែលទៅតាមព្រះអង្គមានច្រើន ទាំងនេះដោយគិតថា យើងនឹងបានឃើញព្រះវរកាយ ដែលមានពណ៌សម្បុរដូចមាស របស់ព្រះភគវាខ្លះក៏គិតថា យើងនឹងបានស្ដាប់ធម្មកថាដ៏ពីរោះ ដោយហេតុនេះ ព្រះ-លោកនាថ ទើបមានភិក្ខុសង្ឃហែហមជាច្រើន ។ ព្រះមានព្រះភាគ ព្រមដោយភិក្ខុសង្ឃប្រមាណ ៥០០ រូប ស្ដេចពុទ្ធដំណើរទៅរហូតដល់ផ្លូវបំបែកជាពីរ ។ ព្រះអានន្ទត្ថេរ បានឈប់ឈរនៅត្រង់ផ្លូវបំបែកជាពីរនោះ ក្រាបទូលសួរព្រះភគវន្តមុនីឡើងថា បពិត្រព្រះសយម្ភូ តើផ្លូវដែលទៅកាន់សម្នាក់ព្រះរេវតៈ ផ្លូវទាំងពីរនេះណាមួយ ? ព្រះលោកនាយកសួរថា អានន្ទ ផ្លូវណាជាផ្លូវត្រង់ ? ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គ ផ្លូវត្រង់មានចម្ងាយ ៣០ យោជន៍ ជាផ្លូវដែលមានពួកអមនុស្សហួងហែង ចំណែកផ្លូវវាងមានចម្ងាយ ៦០ យោជន៍ ជាផ្លូវផុតភ័យ រកអាហារបានងាយ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់សួររកព្រះសីវលី

ថា អានន្ទ សីវលីមកជាមួយពួកយើងដែរឬទេ ? ព្រះអានន្ទក្រាបទូល ថា សីវលីមកដែរ ប្រសិនបើយ៉ាងនោះ ចូរនាំគ្នាទៅតាមផ្លូវត្រង់ចុះ តថាគតនឹងល្បងមើលបុណ្យសីវលី ហើយទ្រង់នាំភិក្ខុទាំងឡាយស្តេច ទៅតាមផ្លូវត្រង់នោះឯង ។

មានសេចក្តីពោលថា ព្រះបរមសាស្តា មិនត្រាស់អួតអាងថា តថាគតនឹងធ្វើឲ្យកើតយាគូ ចង្ហាន់ដល់ពួកអ្នក ចូរពួកអ្នកទៅតាមផ្លូវ ត្រង់ ដោយទ្រង់ជ្រាបរួចហើយថា បុណ្យរមែងឲ្យផលដល់អ្នកឲ្យទាន ទើបត្រាស់ថា ប្រសិនបើសីវលីនិមន្តមក ចូរនាំគ្នាទៅតាមផ្លូវត្រង់ ដោយ ថា កាលបើព្រះសម្ពុទ្ធស្តេចយាងទៅតាមផ្លូវត្រង់ ទេវតាទាំងឡាយនឹង គិតថា ពួកយើងនឹងធ្វើសក្ការៈដល់ព្រះសីវលិត្ថេរ ដែលជាលោកម្ចាស់ របស់ពួកយើង ។ ព្រះពុទ្ធដំណើរ នៃព្រះមានជោគ ទ្រង់បែរព្រះភក្ត្រ តម្រង់ទៅតាមផ្លូវត្រង់ ពួកទេវតានិម្មិតស្រុក ក្រុង និងវិហារ ដើម្បីជាទី សម្រាករបស់ភិក្ខុសង្ឃ មានព្រះពុទ្ធជាព្រះប្រធាន មួយយោជន៍មួយ កន្លែងៗ ។ ពួកទេវតាក្លែងភេទដូចជាអ្នកបម្រើរបស់ព្រះរាជា បានកាន់ យកយាគូ និងចង្ហាន់ជាដើម ដើរសួររកថា ព្រះសីវលិត្ថេរគង់នៅទីណា ? ព្រះសីវលិត្ថេរ បានឲ្យពួកទេវតានាំគ្រឿងសក្ការៈ ទៅបូជាថ្វាយចំពោះ ព្រះសុគត និងភិក្ខុសង្ឃទាំងឡាយ ។

ព្រះជិនស្រី ព្រមទាំងភិក្ខុសង្ឃទាំងឡាយ ទ្រង់ទទួលយកគ្រឿង

សក្ការបូជាតាមទំនងនេះ រយៈផ្លូវមួយយោជន៍រៀងរាល់ថ្ងៃ ដរាបអស់រយៈផ្លូវ ៣០ យោជន៍ ទើបឆ្ពងផុតពីព្រៃកន្តារ ហើយស្ដេចយាងចូលទៅកាន់លំនៅរបស់ព្រះរេវតខទិរវនិយត្ថេរ ។ ចំណែកព្រះរេវតៈ បានជ្រាបដំណឹងថា ព្រះបរមសាស្ដា ស្ដេចយាងមក ទើបនិម្មិតព្រះគន្ធកុដិថ្វាយ និងទាំងនិម្មិតផ្ទះកំពូល ឲ្យជាទីស្នាក់អាស្រ័យនៅដល់ភិក្ខុសង្ឃប្រមាណ ៥០០ ខ្នង និងទីចង្ក្រម ៥០០ កន្លែង រហូតដល់ទីសម្រាកពេលយប់ ពេលថ្ងៃ ៥០០ កន្លែងទៀត រួចជាស្រេចហើយ ទើបចេញទៅទទួលព្រះសម្ពុទ្ធ និមន្តព្រះអង្គឲ្យចូលទៅកាន់ព្រះគន្ធកុដិ ។ កាលព្រះសក្យមុនី ស្ដេចយាងចូលទៅកាន់ព្រះគន្ធកុដិហើយ ភិក្ខុទាំងឡាយបានចូលទៅកាន់សេនាសនៈ ដែលសមគួរដល់ខ្លួន តាមលំដាប់វស្សា ។ ទេវតាទាំងឡាយប្រាប់ដល់គ្នានិងគ្នាថា ពេលនេះមិនមែនជាពេលថ្វាយចង្ហាន់ទេ ហើយនាំគ្នាកាន់យកទឹកអដ្ឋបាន បានដល់ ទឹកដែលភិក្ខុសង្ឃឆាន់បានក្នុងពេលវិកាល មាន ៨ យ៉ាងគឺ ទឹកផ្លែស្វាយ ១ ផ្លែព្រីង ១ ផ្លែចេក ១ ផ្លែចេកអត់គ្រាប់ ១ ផ្លែមាក់ប្រាង ១ ផ្លែច័ន ១ ផ្លែស្រគំ ១ មកថ្វាយដល់ព្រះសយម្ភូ ព្រមទាំងភិក្ខុសង្ឃ ។ ព្រះពុទ្ធទ្រង់គង់សម្រាកនៅក្នុងព្រះគន្ធកុដិ ដែលព្រះរេវតៈនិម្មិតថ្វាយរយៈពេល ១ ខែប៉ុណ្ណោះ ( កន្លែងខ្លះថា កន្លះខែ ) កាលទ្រង់គង់សម្រាកនៅស្ថានទីនោះ ក៏បានសោយបុណ្យរបស់ព្រះសីវលិត្ថេរគ្រប់កាល ។

ក្នុងពេលដែលចូលទៅកាន់ព្រៃគគីរនោះ មានភិក្ខុចាស់ពីររូប ភិក្ខុទាំងពីររូបនេះគិតថា ព្រះរេវតៈនេះធ្វើតែការកសាងប៉ុណ្ណោះ តើនឹងមានពេលណាមកធ្វើសមណធម៌បាន ដែលព្រះអង្គស្តេចយាងមកសួរសុខទុក្ខនេះដោយទ្រង់យល់មុខថា ព្រះរេវតៈជាប្អូនប្រុសរបស់ព្រះសារីបុត្រលោកជាអគ្គសាវក ទើបស្តេចទ្រង់មកសួរសុខទុក្ខដូច្នេះ សូម្បីវត្តជេតពន ឬវត្តវេឡុវ័នជាដើម ក៏មិនអាចនឹងប្រៀបធៀបកន្លែងនេះបានឡើយ ។ ព្រះសម្ពុទ្ធ ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វលោកក្នុងពេលជិតភ្លឺទ្រង់ឃើញភិក្ខុចាស់ពីររូបនោះ ទាំងទ្រង់ជ្រាបដល់វារៈចិត្តរបស់ភិក្ខុចាស់ពីររូបនោះ ហើយទ្រង់ត្រិះរិះថា កាលបើតថាគតនៅក្នុងទីនេះយូរតទៅទៀត ស្ថានទីនេះនឹងកើតភាពកុះករអ៊ូអរ ធម្មតាភិក្ខុអ្នករស់នៅក្នុងព្រៃ រមែងត្រូវការភាពស្ងៀមស្ងាត់ ការមិនសប្បាយនឹងមានដល់រេវតៈ ។ ព្រោះហេតុនេះ កាលព្រះទសពល ទ្រង់សម្រាកនៅក្នុងស្ថានទីនេះបានត្រឹមតែកន្លះខែ ទើបស្តេចយាងចេញទៅ តែមុននឹងស្តេចយាងចេញទៅនោះ ទ្រង់អធិដ្ឋានឲ្យភិក្ខុចាស់ពីររូបនោះ ភ្លេចឈើប្រត់ ឆត្រ និងស្បែកជើង ហើយតាមព្រះពុទ្ធចេញទៅ លុះដល់ខាងក្រៅឧបចារៈវិហារ ក៏ទ្រង់រំសាយឫទ្ធិនៃការអធិដ្ឋាននោះ ។ ពេលនោះ ភិក្ខុទាំងពីររូបនោះនឹកឡើងថា អាត្មាអញភ្លេចរបស់នេះរបស់នោះ បាននាំគ្នាត្រឡប់ទៅវិញ តែកាលត្រឡប់ទៅតាមផ្លូវដែលមក មិនអាចចាំស្ថានទីបាន ព្រោះ

គ្រប់យ៉ាងត្រឡប់ក្លាយទៅជាព្រៃដូចដើមវិញទាំងអស់ ។ ទើបនាំគ្នាដើរទៅជាន់ជន្ទត់ឈើ និងជាន់បន្ទា ដើរៗ ទៅរហូតដល់កន្លែងដែលខ្លួនធ្លាប់ស្នាក់នៅ បានជួបប្រទះឃើញរបស់ដែលខ្លួនដាក់នៅលើជន្ទត់ឈើគគីរខ្លះ ព្យួរនៅលើដើមគគីរខ្លះ ហើយក៏កាន់យកត្រឡប់មកវិញ ។

ព្រះថេរៈទាំងពីររូបនោះ ទើបដឹងថា ព្រះរេវតៈជាអ្នកមានឫទ្ធិសូម្បីវិហារ និងគ្រឿងសក្ការៈ ដែលលោកនិម្មិតនោះ ដើម្បីព្រះភគវា និងភិក្ខុសង្ឃតែប៉ុណ្ណោះ ។ ព្រះមានព្រះភាគ ទ្រង់នាំភិក្ខុសង្ឃទាំងឡាយត្រឡប់មកតាមផ្លូវដើម បានអាស្រ័យបុណ្យរបស់ព្រះសីវលិត្ថេរ រហូតមួយខែទៀត ហើយស្តេចយាងចូលទៅកាន់បុព្វារាម វត្តដែលកសាងដោយឧបាសិកាវិសាខា នៅក្នុងក្រុងសាវត្ថី ។ តាំងពីព្រះថេរៈទាំងពីររូប បានដឹងសេចក្តីពិតហើយ បាននាំគ្នានិមន្តទៅឆាន់យាគូផ្ទះរបស់មហាឧបាសិកាវិសាខា ឆាន់រួចស្រេចហើយ បានគង់សម្រាកក្នុងទីដ៏សមគួរ ។ គ្រានោះ មហាឧបាសិកាវិសាខា បានសួរចំពោះព្រះថេរៈទាំងពីររូបថា បពិត្រលោកម្ចាស់ តើលោកម្ចាស់បាននិមន្តទៅលំនៅព្រះរេវតត្ថេរ ជាមួយនឹងព្រះលោកនាថដែរឬទេ ? អាត្មាបាននិមន្តទៅដែរ ។ តើទីលំនៅរបស់ព្រះរេវតៈ គួរឲ្យត្រេកអរ ចង់រស់នៅដែរឬទេ ? កុំសួរយ៉ាងហ្នឹងឡើយ តើគួរឲ្យត្រេកអរចង់រស់នៅបានយ៉ាងណា ជាកន្លែងដែលរដិបរដុបដោយដុំថ្ម ដុំក្រួស ជាព្រៃមានតែជន្ទត់ឈើគគីរ ស្រដៀងគ្នានឹងទី

លំនៅរបស់ប្រេតដូច្នោះឯង ។ លុះបន្ទាប់មកទៀត មានភិក្ខុកំលោះពីររូប បាននិមន្តមកកាន់ផ្ទះរបស់មហាឧបាសិកាវិសាខា ។ មហាឧបាសិកាវិសាខា ក៏បាននាំយាគូមកប្រគេនភិក្ខុកំលោះទាំងពីររូបនោះ ហើយសួរដល់ទីលំនៅរបស់ព្រះរេវតៈថា ស្ថានទីលំនៅរបស់ព្រះរេវតៈនោះ គួរឲ្យត្រេកអរពេញចិត្ត ចង់រស់នៅដែរឬទេ ? ភិក្ខុកំលោះទាំងពីររូបនោះឆ្លើយថា ពួកអាត្មាមិនអាចនឹងពណ៌នាឲ្យអស់បាន ព្រោះទីលំនៅរបស់ព្រះរេវតៈ ស្រដៀងគ្នានឹងសុធម្មាទេវសភា ក្នុងឋានតាវត្តិង្ស ហាក់បីដូចតាក់តែងឡើងដោយឫទ្ធិ ដែលគួរឲ្យត្រេកអរពេញចិត្ត ចង់រស់នៅ ។

មហាឧបាសិកាវិសាខា ស្តាប់ចម្លើយរបស់ភិក្ខុទាំងពីរពួកនេះហើយ ក៏កើតការឆ្ងល់ថា ព្រះថេរៈមកមុន និយាយពាក្យម្យ៉ាង ចំណែកភិក្ខុកំលោះដែលមកក្រោយ ក៏និយាយពាក្យម្យ៉ាងទៀត ។ តើសំដីលោកម្ចាស់ទាំងពីរពួកនេះ មួយណាជាការពិត ដូច្នេះ ដែលអាចដឹងការពិតបាន មានតែព្រះភគវាទេ ។ តពីពេលនោះមកមួយស្របក់ ព្រះភគវាព្រមដោយភិក្ខុសង្ឃ បាននិមន្តមកកាន់ផ្ទះរបស់ មហាឧបាសិកាវិសាខា ទ្រង់គង់ប្រថាប់លើអាសនៈ ដែលគេតាក់តែងទុកជាពុទ្ធាសនៈ ចំណែកភិក្ខុសង្ឃទាំងឡាយ ក៏និមន្តគង់លើអាសនៈតាមសមគួរ ។ ឧបាសិកាវិសាខា រៀបចំការថ្វាយភិក្ខាដល់ភិក្ខុសង្ឃទាំងឡាយ មានព្រះមហាមុនីជាព្រះប្រធានដោយសេចក្តីគោរព ក្នុងពេលភិក្ខុសង្ឃឆាន់រួចស្រេច ហើយ

ទើបក្រាបទូលសួរចំពោះព្រះជិនស្រីថា បពិត្រព្រះសយម្ភូ មានពួកភិក្ខុដែលតាមព្រះអង្គ ទៅកាន់លំនៅរបស់ព្រះរេវតៈ ពួកខ្លះពោលថា ស្ថានទីនោះ ជាព្រៃគគីរ រជិបរជុប មិនគួរឲ្យត្រេកអរចង់រស់នៅទេ ពួកភិក្ខុខ្លះទៀតពោលថា ស្ថានទីនោះ ជាទីត្រេកអរ ចង់ឲ្យរស់នៅណាស់ តើសេចក្ដីទាំងពីរនេះ មួយណាជាការពិត ? ព្រះបរមសាស្ដា ទ្រង់សណ្ដាប់ពាក្យក្រាបទូលសួរនោះហើយ ទើបត្រាស់ថា ម្នាលឧបាសិកាវិសាខា ស្រុក ឬព្រៃក៏ដោយ ព្រះអរហន្តទាំងឡាយរស់នៅក្នុងទីណា ទីនោះឯងគួរឲ្យត្រេកអររីករាយទាំងអស់ កាលទ្រង់សម្ដែងធម៌បន្តសេចក្ដី ទើបត្រាស់ព្រះគាថា ដែលមានសេចក្ដីថា ៖

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា មិនថានៅក្នុងស្រុក ឬនៅក្នុងព្រៃ ក្នុងស្ថានទីទំនាប ឬទីទួលក៏ដោយ កន្លែងនោះ រមែងជាទីគួរឲ្យត្រេកអរ ។

កាលជាខាងក្រោយមក ព្រះសម្ពុទ្ធទ្រង់គង់ប្រថាប់ក្នុងកណ្ដាលជំនុំព្រះអរិយសង្ឃ នៅវត្តជេតពន ទ្រង់ប្រកាសតែងតាំងព្រះរេវតៈទុកក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ អ្នកនៅក្នុងព្រៃ ។ ការនៅក្នុងព្រៃរបស់ព្រះរេវតខទិរវនិយត្ថេរ មិនធ្លាប់ឲ្យខូចវត្តបដិបត្តិក្នុងផ្នែកដទៃៗដូចការចូលទៅគាល់ព្រះមានជោគ ការទៅសួរសុខទុក្ខព្រះថេរានុថេរៈទាំងឡាយ មានព្រះធម្មសេនាបតីសារីបុត្រដែលជាបងប្រុស លោកតែង

តែទៅមកជារឿយៗ ដូចជាលោកទៅក្នុងពុទ្ធសម្នាក់ ឬសម្នាក់របស់ឧបជ្ឈាយ៍ អាចារ្យ ប្រមាណពីរបីថ្ងៃ ហើយត្រឡប់ចូលទៅកាន់ព្រៃខទិរៈវិញ រស់នៅយ៉ាងសុខសប្បាយក្នុងផលសមាបត្តិ និងព្រហ្មវិហារធម៌ ។ កាលជីវិតរបស់លោក ស្ថិតនៅក្នុងវ័យចាស់ជរាហើយ មានរឿងតំណាលទុកក្នុងអដ្ឋកថា បរមត្ថទីបនី ដែលអធិប្បាយសេចក្ដីបាលីគម្ពីរខុទ្ទកនិកាយ ថេរគាថា នៃចុទ្ទសកនិបាតថា ៖

ថ្ងៃមួយ ព្រះរេវតៈ បាននិមន្តចូលទៅគាល់ព្រះវិជិតមារ ហើយបានគង់សម្រាកពីការហត់នឿយ ក្នុងចន្លោះផ្លូវមួយកន្លែង ជិតក្រុងសាវត្ថី ។ ពេលនោះ ពួកចោរលួចទ្រព្យរបស់អ្នកស្រុក ហើយត្រូវគេដេញតាមចាប់យ៉ាងប៉ផាប់ពពីង កាលពួកចោរឃើញព្រះថេរៈ ដោយខ្លាចត្រូវគេចាប់បាន ទើបបោះទ្រព្យចោល ទុកក្នុងស្ថានទីជិតព្រះថេរៈដែលគង់នោះ ហើយក៏រត់យកតែរូបខ្លួនទៅ ។ ចំណែកពួកមនុស្សដែលដេញតាមមក បានឃើញរបស់ធ្លាក់នៅក្បែរព្រះថេរៈអង្គុយ យល់ថាព្រះថេរៈជាពួកចោរ ចាប់ព្រះថេរៈចង និងនាំទៅថ្វាយព្រះរាជា ព្រមទាំងក្រាបទូលថា លោកម្ចាស់អង្គនេះជាចោរ ។ ព្រះរាជាទ្រង់តាំងនៅក្នុងទសពិធរាជធម៌ ទ្រង់មិនទាន់ជឿបុគ្គលទាំងនោះភ្លាមៗ ទេ ទើបទ្រង់ត្រាស់ឲ្យស្រាយចំណងព្រះថេរៈចេញ និងត្រាស់សួររកសេចក្ដីពិតថាលោកម្ចាស់បានធ្វើជាចោរមែនឬទេ ? ព្រះរេវតខទិរវនិយត្ថេរ ឆ្លើយថា

អាត្មាភាពមិនមែនជាចោរទេ ។

តពីនោះមក ព្រះថេរៈបានសម្តែងធម៌ថ្វាយដល់ព្រះរាជា ដែលមានសេចក្តីប្រាកដនៅក្នុងគម្ពីរខុទ្ទកនិកាយ ថេរគាថា ថា ៖

ខ្ញុំចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងកាលណា កាលណោះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះមិនប្រសើរ ដែលប្រកបដោយទោសទេ ។ ក្នុងចន្លោះកាលដ៏វែងនេះ ខ្ញុំមិនដែលនឹកនូវសេចក្តីត្រិះរិះថា ពួកសត្វទាំងនេះចូរលំបាកចុះ ចូរស្លាប់ចុះ ចូរដល់នូវសេចក្តីទុក្ខចុះ ដូច្នេះទេ ។ ប៉ុន្តែខ្ញុំធ្លាប់នឹកនូវមេត្តារកប្រមាណមិនបាន ដែលបានចម្រើនល្អហើយ បានសន្សំហើយ តាមលំដាប់ ដូចព្រះពុទ្ធទ្រង់សម្តែងហើយ ។ ខ្ញុំមានសត្វទាំងពួងជាមិត្ត មានសត្វទាំងពួងជាសម្លាញ់ ជាអ្នកអនុគ្រោះដល់សត្វទាំងពួង បានចម្រើននូវមេត្តាចិត្ត ត្រេកអរក្នុងការមិនបៀតបៀនសត្វកាល ។ ខ្ញុំត្រេកអរចំពោះចិត្តដែលមិនឆាករេ មិនកម្រើក ខ្ញុំចម្រើនព្រហ្មវិហារធម៌ ដែលព្រះអរិយៈជាបុរសមិនថោកទាបគប់រកហើយ ។ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ដល់នូវឈានមិនមានវិតក្ក រមែងជាអ្នកប្រកបដោយតុណ្ហីភាពដ៏ប្រសើរ ក្នុងខណៈនោះ ។ ភ្នំថ្មមិនកម្រើកតាំងនៅស៊ប់ យ៉ាងណាមិញ ភិក្ខុរមែងមិនញាប់ញ័រដូចជាភ្នំ ព្រោះអស់ទៅនៃមោហៈ ក៏យ៉ាងនោះដែរ ។ សប្បុរសមិនមានទីទួល គឺកិលេសអ្នកស្វែងរកនូវសេចក្តីស្អាតជានិច្ច ទុកជាមានបាបបន្តិចបន្តួច ប៉ុនចុង

រោមកន្ទុយសត្វ ក៏ប្រាកដដូចជាប៉ុនមេឃ ។ នគរជាទីបំផុតនៃដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុងខាងក្រៅ យ៉ាងណាមិញ អ្នកទាំងឡាយ ចូរគ្រប់គ្រងខ្លួនយ៉ាងនោះ ខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅទេ ខ្ញុំរង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ដូចអ្នកស៊ីឈ្នួល ទន្ទឹងតែអស់ថ្ងៃ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ ខ្ញុំមិនត្រេកអរនឹងការរស់នៅ ខ្ញុំជាអ្នកដឹងខ្លួន មានស្មារតីតាំងមាំ រង់ចាំតែកាល ( បរិនិព្វាន ) ប៉ុណ្ណោះ ។ ព្រះសាស្ដាខ្ញុំបានបម្រើហើយ ព្រះពុទ្ធសាសនាខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលមកកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍គឺការអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានដល់ហើយ ។ អ្នកទាំងឡាយ ចូរឲ្យដល់ព្រម ដោយសេចក្ដីមិនប្រមាទចុះ នេះជាពាក្យប្រៀនប្រដៅរបស់ខ្ញុំ ណ្ហើយចុះ ខ្ញុំនឹងបរិនិព្វាន ខ្ញុំជាអ្នកមានចិត្តរួចស្រឡះហើយចាកកិលេសទាំងពួង ។

ព្រះរេវតខទិរវនិយត្ថេរពោលដូច្នេះហើយ ក៏បានហោះឡើងទៅអន្តរីយព្ធដ៏អាកាស ចូលតេជោធាតុសមាបត្តិ ហើយមានភ្លើងឆេះសន្ធោសន្ធៅពេញរាងកាយរបស់លោក លោកក៏បានរំលត់ខន្ធបរិនិព្វានទៅ ដោយមិនមានកិលេស និងបញ្ចក្ខន្ធនៅសេសសល់ប្រាកដ ក្នុង

លោកនេះតទៅទៀត ។

ការបរិនិព្វានរបស់ព្រះរេវតៈនៅលើអាកាសនេះ មានសេចក្តីប្រាកដក្នុងអដ្ឋកថា បរមត្ថទីបនី ដែលអធិប្បាយសេចក្តីបាលីគម្ពីរខុទ្ទកនិកាយ ថេរគាថា ។ ចំណែកក្នុងគម្ពីរអសីតិមហាសាវកនិព្វាន មានប្រាកដត្រឹមតែថា កាលទ្រទ្រង់អាយុសង្ខារមកដល់កាលកំណត់ ក៏រំលត់ខន្ធចូលកាន់អមតសិវមោក្ខនគរនិព្វាន លុះអវសានជីវិត ដល់ឯកន្តបរមសុខ មិនបានពោលដល់ស្ថានទីណាមួយឡើយ ។៚

*( ជីវប្រវត្តិរបស់ព្រះរេវតខទិរវនិយត្ថេរ ចប់ )*

បាត់ដំបង ធ្វើនៅថ្ងៃ ១ កើត ខែភទ្របទ ពុទ្ធសករាជ ២៥៥០
ត្រូវនឹងថ្ងៃទី ២៤ សីហា គ្រឹះសករាជ ២០០៦

ដោយខ្ញុំព្រះករុណា **យង់ សុផាត**